ព្រះរាជាណាចក្រ កម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
មហាវិទ្យាល័យ ឱសថសាស្ត្រ

# កម្រងរុក្ខជាតិឱសថ

*ចុះស្រាវជ្រាវនៅខេត្តរតនគិរី*



និស្សិតឱសថសាស្ត្រជំនាន់ ៣២
ឆ្នាំសិក្សា ២០០៧-២០១២

# អារម្ភកថា

រុក្ខជាតិដែលមានសព្វថ្ងៃនៅលើផែនដី ពិតជាមានសារប្រយោជន៍ជាច្រើន ដូចជាខ្លះធ្វើជាបន្លែខ្លះអោយផ្លែ អោយមើម អោយស្លឹកជាអាហារ អោយផ្កាសំរាប់តាំងលំអរ ខ្លះទៀតអោយដើមសំរាប់ធ្វើសំភារៈសំណង់ផ្សេងៗ និង លើសពីនេះទៅទៀត រុក្ខជាតិមួយចំនួនប្រើប្រាស់ជាថ្នាំសង្កូវសំរាប់ព្យាបាលជំងឺដ៏មានប្រសិទ្ធភាពទៀតផង។

តាំងពីបុរាណកាល មនុស្សបានចេះប្រើប្រាស់ផ្នែកផ្សេងៗនៃរុក្ខជាតិតាមរបៀបផ្សេងៗដូចជាស្ងោររំងាស់ ឆុង កិនជាម្សៅជាដើមដើម្បីយកទៅព្យាបាលជំងឺនានា ដែលទង្វើនេះមកដល់បច្ចុប្បន្នត្រូវបានគេអោយឈ្មោះថា **"វេជ្ជសាស្ត្របុរាណ"**។ ការប្រើប្រាស់រុក្ខជាតិឱសថទាំងនេះពេលខ្លះមានគុណសម្បត្តិក្នុងការព្យាបាលមិនចាញ់ឱសថទំនើបដែលផលិតតាមបច្ចេកវិជ្ជាសម័យថ្មីនោះទេ មិនតែប៉ុណ្ណោះបើកាន់តែស្រាវជ្រាវ និង ពិសោធន៏កាន់តែច្រើនប៉ុនណាគឺកាន់តែរកឃើញថា **"រុក្ខជាតិឱសថ"** ដែលមានតាំងពីបរមបុរាណនៅលើផែនដីនេះគឺជាថ្នាំពហុប្រយោជន៍ ប្រើសម្រាប់ព្យាបាលរោគ ជំនួយសុខភាពថែមទាំងអាចប្រើដើម្បីបង្កើនសម្រស់ផងដែរ ។

មកដល់យុគសម័យបច្ចេកវិទ្យានាសតវត្សទី២១ក៏ដោយ ក៏រុក្ខជាតិក៏នៅតែជាប្រភពដ៏សំខាន់ក្នុងការផ្តល់នូវម៉ូលេគុលថ្មីៗសំរាប់ប្រើប្រាស់ជាឱសថ។ គួបផ្សំនឹងការរីកចំរើនរបស់វិទ្យាសាស្រ្ត មនុស្សអាចចំរាញ់យកធាតុសកម្មទាំងនោះ កាន់តែងាយស្រួលនិងប្រកបដោយទិន្នផលខ្ពស់សំរាប់បំរើអោយវិស័យសុខាភិបាល។

នៅប្រទេសកម្ពុជាក្បួនវេជ្ជសាស្រ្តបុរាណមួយចំនួនធំត្រូវបានគេស្គាល់ច្បាស់ថាមានវត្តមានតាំងពីសម័យអង្គរមកម្លេះ តែដោយសារភ្លើងសង្គ្រាមផ្ទៃក្នុង និង របបប្រល័យពូជសាសន៏ដ៏សាហាវឃោរឃៅឯកសារភាគច្រើនក៏ដូចជាអ្នកដែលមានចំណេះដឹងខាងការប្រើប្រាស់ឱសថបុរាណ ត្រូវបានបាត់បង់ធ្វើអោយវិស័យនេះមិនទាន់សូវរីកចំរើនដូចនៅបណ្តាប្រទេសជិតខាងមួយចំនួន ។ ចំណែកឯរុក្ខជាតិឱសថទៀតសោតមានជាច្រើនប្រភេទ ដែលក្នុងនោះមានមួយចំនួន មានសក្តានុពលភាពអាចអោយយើងចំរាញ់យកសារធាតុសកម្មសំរាប់ព្យាបាលជម្ងឺសំខាន់ៗដូចជាជម្ងឺមហារីកជាដើម តែដោយប្រទេសកម្ពុជាយើងជាប្រទេសកំពុងអភិវឌ្ឍដូចនេះទាំងធនធានមនុស្សនិងមធ្យោបាយក្នុងការសិក្សាស្រាវជ្រាវ នៅមានកំណត់។

ដូច្នេះហើយ ក្នុងគោលបំណងរួមចំណែកថែរក្សាវេជ្ជសាស្រ្តបុរាណខ្មែរកុំអោយសាបសូន្យនិងដោយមើលឃើញ ពីសក្តានុពលភាពរបស់រុក្ខជាតិឱសថកម្ពុជា ព្រមទាំងដោយហេតុថាសព្វថ្ងៃនេះឱសថបុរាណនៅតែមានប្រជាប្រិយក្នុងចំណោមប្រជាជនខ្មែរ មហាវិទ្យាល័យឱសថសាស្រ្តបានបញ្ចូលមុខវិជ្ជាមួយចំនួនដែលទាក់ទងនឹងឱសថបុរាណក្នុងកម្មវិធីសិក្សា ជាក់ស្តែងដូចជាការរៀនសំគាល់រុក្ខជាតិឱសថស្រស់ និង រុក្ខជាតិឱសថស្ងួត (la reconnaissance des plantes fraîches et des plantes sèches) និង ការសិក្សាពីការប្រើប្រាស់រុក្ខជាតិទាំងនោះក្នុងពេលម៉ោងអនុវត្តជាដើម។ លើសពីនេះទៅទៀត ជារៀងរាល់ឆ្នាំ

មហាវិទ្យាល័យឱសថសាស្ត្របានរៀបចំដឹកនាំនិស្សិតឱសថសាស្ត្រ ឆ្នាំទី៥ ចុះធ្វើទស្សនកិច្ចសិក្សានៅក្នុង ព្រៃនៅតាមបណ្តាខេត្តមួយចំនួនក្នុងព្រះរាជាណាចក្រកម្ពុជា។

សំរាប់ឆ្នាំសិក្សា **២០១១-២០១២** នេះ និស្សិតឱសថសាស្ត្រជំនាន់**៣២** បានចុះធ្វើទស្សនកិច្ចសិក្សានៅទិសឦសាននៃព្រះរាជាណាចក្រកម្ពុជា ក្នុងខេត្ត**រតនគិរី** ក្រោមការដឹកនាំពីសំណាក់លោក-លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូនៃមហាវិទ្យាល័យឱសថសាស្ត្រ ក៏ដូចជាលោកគ្រូឱសថបុរាណ។ ដំណើរទស្សនកិច្ចសិក្សានេះ មានរយះពេល ៤ ថ្ងៃគឺចាប់ពីថ្ងៃទី ០១ ដល់ថ្ងៃទី ០៤ ខែមិនា ឆ្នាំ ២០១២។ ការចុះអង្កេតរុក្ខជាតិបានប្រព្រឹត្តទៅភូមិសាស្ត្រមួយចំនួនក្នុងខេត្ត**រតនគិរី** ដូចជានៅតំបន់វាលថ្មរុំប្លង់តំបន់បឹងយក្សឡោម ទឹកជ្រោះកាទៀង ព្រៃតាមបណ្តោយផ្លូវទៅស្រែពក។

ដំណើរចុះ **"អង្កេតរុក្ខជាតិឱសថ"** នេះ ពិតជាមានអត្ថន័យ និង អត្ថប្រយោជន៍ក្រៃលែងចំពោះយើងខ្ញុំ។វាធ្វើអោយយើងខ្ញុំស្គាល់រុក្ខជាតិឱសថជាច្រើនដែលមានដុះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទទួលបានចំណេះដឹងពីការប្រើប្រាស់រុក្ខជាតិឱសថពីសំណាក់លោកគ្រូឱសថបុរាណ យល់ដឹងពីរបៀបរៀបចំសំណាករុក្ខជាតិ (Herbier) និង មិនតែប៉ុណ្ណោះ វាបានបំផុសស្មារតីធ្វើការងារជាក្រុមប្រកបដោយសាមគ្គីភាព និងភាពអត់ធ្មត់ សមដូចពាក្យស្លោកថា **"នៅផ្ទះម្តាយទីទៃ ចូលព្រៃម្តាយតែមួយ"** ។ បន្ថែមពីនោះការចុះស្រាវជ្រាវនេះក៏បានផ្តល់អោយយើងខ្ញុំនូវអនុស្សាវរីយ៍ដ៏រីករាយមិនអាចបំភ្លេចបាននៅក្នុងឆ្នាំចុងក្រោយនៃការសិក្សាផ្នែកឱសថសាស្ត្រនេះ។

ក្នុងកម្មសិក្សានេះយើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការជួយជ្រោមជ្រែងពីសំណាក់ឯកឧត្តមសាស្ត្រាចារ្យ **យក់ សុផាន់ណា** អតីតសាកលវិទ្យាធិការនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល។ សូមថ្លែងអំណរគុណចំពោះលោកជំទាវសាស្ត្រាចារ្យ **ទេព វង្សី** ព្រឹទ្ធបុរសមហាវិទ្យាល័យឱសថសាស្ត្រ ចំពោះការដឹកនាំកិច្ចការ ក្នុងមហាវិទ្យាល័យប្រកបដោយទស្សនវិស័យ។ សូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យ ចេង ស៊ុងកាំង លោកបណ្ឌិត គឹម សុធា លោកគ្រូឱសថបុរាណ និង សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មក្នុងការដឹកនាំដំណើរការកម្មសិក្សានេះ ប្រកបទៅដោយជោគជ័យ។

ក្នុងនោះផងដែរ យើងខ្ញុំក៏សូមអរគុណជាអនេកកប្បការជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការដឹកនាំនាវាកម្ពុជាពុះពាររាល់ឧបសគ្គ គ្រប់បែបយ៉ាងក្នុងការពន្លត់ភ្នក់ភ្លើងសង្គ្រាម ដើម្បីធ្វើការបង្រួបបង្រួមជាតិ ស្វែងរកសុខសន្តិភាពជូនប្រជាពលរដ្ឋ ព្រមទាំងបានខិតខំកសាងស្តារអភិវឌ្ឍន៍ប្រទេសជាតិឡើងវិញឲ្យមានការរីកចំរើនលើគ្រប់វិស័យទាំងនៅទីក្រុងក៏ដូចជា នៅតាមទីជនបទ សំដៅលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឲ្យកាន់តែមានភាពប្រសើរឡើងជាលំដាប់។

ជាចុងបញ្ចប់ យើងខ្ញុំក៏សង្ឃឹមថាសៀវភៅ **“កំរងវុត្តជាតិឱសថ”** នេះនឹងប្រើជាឯកសារសំរាប់ការស្រាវជ្រាវបន្តបន្ទាប់ទៀត។ យើងខ្ញុំសូមប្ដេជ្ញាចិត្តប្រើប្រាស់ចំណេះដឹងដែលទទួលបានក្នុងកម្មសិក្សានេះ ក៏ដូចជាចំណេះដឹងចំណេះធ្វើ ដែលទទួលបានបន្ទាប់ពីការសិក្សានៅមហាវិទ្យាល័យឱសថសាស្ត្រប្រកបដោយសុចរិតភាពសមដូច ប្រសាសន៍ដ៏ថ្លៃថ្លារបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានលើកឡើងថា៖ **“គ្រូពេទ្យគឺជាអ្នកជួយអាយុជីវិតអ្នកជម្ងឺ”**។

**និស្សិតឱសថសាស្ត្រជំនាន់៣២**

លោកអ្នកអាចទាញយកឯកសារសៀវភៅនេះ

តាមរយៈគេហទំព័រសមាគមនិស្សិតឱសថសាស្ត្រ៖ WWW.AEPCAMBODGE.COM

# មាតិកា


| ល.រ | ឈ្មោះជាភាសាខ្មែរ | Nom scientifique | នាមនិស្សិត | ទំព័រ |
|---|---|---|---|---|
| 1 | កណ្តៀវខ្ទត | *Smilax glabra* wall.ex.Roxb | ស៊ុន ច័ន្ទមករា | 1 |
| 2 | ក្រពើរោទ៍ | *Peikiosopermum suaveoleus* Merr | ម៉ាយ ស៊ីនឡេង | 3 |
| 3 | ក្តាំងបាយស | *Leea Indica* Merr | ហេង ភារ៉ា | 5 |
| 4 | កកោះ | *Sindora siamensis* Teijsm ex.Miq, var siamensis. | លឹម ហ៊ារម៉ី | 7 |
| 5 | កន្ទួតព្រៃ | *Phyllanthus emblica* L. | ហ៊ាម លីដា | 9 |
| 6 | កន្ទាំងហែរ | *Polygonum tomentosum* Willd. | ផាត សុផល្លាប | 11 |
| 7 | កន្ទុយរេ វល្លិ | *Neoliltsea zeylanica* Meer | ឌុល ស្រីណែត | 13 |
| 8 | កន្រ្ទាកដំរី | *Clausena excavata* Burm f | ហេង សុវណ្ណ | 15 |
| 9 | កន្រ្ទាកឆ្កែ | *Clausena excavata* Burm.f.var.villosa Hook | លី ដារ៉ា | 17 |
| 10 | កណ្តោលធំ | *Careya arborea* Roxb | ទី រិទ្ធិកា | 19 |
| 11 | រាជដាស | *Melastoma Malabathricum* | គឹម ដានី | 21 |
| 12 | ក្តួច (វល្លិ) | *Dioscorea Hispida* Dennst | សុខ ផល្លី | 23 |
| 13 | ក្រពុលបាយ-កំពុលបាយ | *Litsea glutinosa* | សួន សំអែល | 25 |
| 14 | ក្រាយ | *XYLOPIA* | សេង លីដា | 27 |

| | | | | |
|---|---|---|---|---|
| 15 | ក្រឡាញ់ | *Dialium cochinchinense* Pierre | ពុធ សុខហេង | 29 |
| 16 | ក្រវ៉ក់ | *Triumfetta bartramia* L. | លី មុនីនាថ | 31 |
| 17 | ក្រវ៉ាន់ចត-ពុកមាត់ឆ្មា | *Acalypha indica* L. | ស្រ៊ុន សុភា | 33 |
| 18 | ក្រូចព្រៃ | *Atalantia monophylla* DC | នួន សូឡី | 35 |
| 19 | កាំរន្ទះព្រៃ | *Ixora Chinensis* LAM | ឈឹម ស្រីមរកត | 37 |
| 20 | កាំរន្ទះធំ-ឈាមអន្ទង់ | *Saraca declinata* (Jack)Miq. | សៀម វណ្ណសក្តិ | 39 |
| 21 | ខាន់ម៉ា-ឃុនម៉ា-ធនម៉ា | *Ancistrocladus tectorius* (Lour) Merr. | និល ច័ន្ទធារត្ន | 41 |
| 22 | ខ្យូស (វល្លិ) | *Calycopteris floribunda* Lamk | សុខ សោភា | 43 |
| 23 | ខ្យូសរមៀត (វល្លិ) | *Combretum latifolium* Blume | សាម សុផានី | 45 |
| 24 | ខ្នុរព្រៃ | *Artocorpus Rigidus* Blume | ដួង មាលា | 47 |
| 25 | ខ្លុង | *Dipterocarpus tuberculatus* | ឌី ធារី | 49 |
| 26 | ខ្វាវធំ (វល្លិ) | *Haldina cordifolia* Roxd. Ridsdale | តាំង សៀលិញ | 51 |
| 27 | ខ្លែងពណ៌ (វល្លិ) | *Bauhinia bassacensis* Pierre ex Gagnep | បូ តាំងគីម | 53 |
| 28 | ខ្លែងគង់-ស្លែងគង់ | *Wrightia Tomentosa* Roem-schult | វ៉ាន់ សុគន្ធា | 55 |
| 29 | គោមួយ-សសៃ១០០ | *Euonymus cochinchinensis* Pierre | អាង រដ្ឋា | 57 |
| 30 | គ្រុង-គ្រង់ | *Aporosa Filicifolia* Baill | ថា ប៊ុនណា | 59 |

| | | | | |
|---|---|---|---|---|
| 31 | គ្រៀលធំ | *Uvaria rufa* Blume | ផាន់ សុខហ្គេច | 61 |
| 32 | គ្រាំពុក-អំពុក | *Catunaregam uliginosa* Poir | ហារ គីមឡេង | 63 |
| 33 | ឃ្លាយ-ផ្លាយ-វល្លិ | *Enkleia siamensis* nervling | ឆាយ ចក្ករ៉ា | 65 |
| 34 | ចង្កៀងបាត-ស្រោមដាវ | *Psycotria pseudoixora* | តឹក គីម | 67 |
| 35 | ចង្គុរត្នោត | *Stereospermum cylindricum* Pierre ex Dop | នួន សុធារី | 69 |
| 36 | ចង្កេងសេក | *Erythroxylum cambodianum* Pierre | សួន ស៊ាកលី | 71 |
| 37 | ចង្កេះអង្រ្កង | *Desmmodium triquetrum,* | ថន សុធារី | 73 |
| 38 | ចាក់ក្រឡេក-ចាក់ក្រលឹក | *Dioecercis erythroclada* (kurz) tirveng | ជី ណាលីន | 75 |
| 39 | ចំប៉ីភ្នំ | *Alstonia scholaris* R-BrEchites Scholaris L | ហេង ហ្វង | 77 |
| 40 | ច្រត់តស្សី-កំប៉ុញ | *Aglaonema siamense* | លាច សេងហៀង | 79 |
| 41 | ចំរៀក | *Albizia lebbckoides* ( DC )Benth | មាស អ៊ីសានីរ៉ា | 81 |
| 42 | ចំបក់ប្រាំង | *Elaeocarpus hygrophilus* Kurz | លី វ៉ាន់ឌី | 83 |
| 43 | ចំបក់ | *Irvingia malayana* div-ex | ស៊ុយ ស្រីនិច | 85 |
| 44 | ចំបក់ប្រាំង | *Elaeocarpus hygrophilus* Kurz | ហារ រ័ត្នពិសី | 87 |
| 45 | ឆ្កែស្រែង-កែស្រែង | *Cananga Latifolia* Finet et Gagnep | សុវណ្ណ រតនា | 89 |
| 46 | ឆ្កែស្រែងខ្មៅ-កែស្រែងខ្មៅ | *Miliusa velutina*(Dun) Hook.f et Thoms | ឆេង សុភក្រ | 91 |

| | | | | |
|---|---|---|---|---|
| 47 | ជន្ទល់ពងមាន់ | *Gardenia obtusifolia* Roxb | ឆេង សុភា | 93 |
| 48 | ជម្ពូក្រហម | *Bixa Orellana* Linn. | ពេន សណ្ដាប់ | 95 |
| 49 | ជន្លាត់ដៃ | *Euphorbia lacteal* | ហេង បុរី | 97 |
| 50 | ជោគ (វល្លិ) | *Embelia sp,* | ប៊ុន មយូរី | 99 |
| 51 | ជន្លួស (ដើមតូច) | *Lepisanthes rubiginose* (Roxb) Leenh | គី ដារ៉ា | 101 |
| 52 | ជ្រោយ | *Casearia grewiaefolia* Vent | ហេង សុថាដា | 103 |
| 53 | ឈើទាល-ដើមយាង | *Dipterocarpus dyeri* | ឈា សុភារម្យ | 105 |
| 54 | ញក្នុំ-ញរព្រៃ | *Morinda tomentosa* Heyne ex Roth. | ជា សុគាំង | 107 |
| 55 | ដង្កៀបក្ដាម | *Antidesma ghaesembilla* Gaertn | ឆេង ណាឡែន | 109 |
| 56 | ដង្កិតធំ | *Cassia alata Linn* | អៀ សុមុន្នី | 111 |
| 57 | ដូនកាយ-ដើមធំ | *Lepisanthes rubiginosa (Roxb). Leenh* | នន់ ដាលី | 113 |
| 58 | ស្មៅប្រម៉ាត់មនុស្ស | *Andrographis paniculata* Nees, | ឈុន វាសនា | 115 |
| 59 | ដើមជើងគោ | *Bauhinia hirsute* weinm | តាន់ វាសនា | 117 |
| 60 | ដូងទន្សាយ | *Phoenic humilis* Royle | ឈៀង ថាសុមិនា | 119 |
| 61 | ដកដាវ (វល្លិ) | *Spatholobus* | ឃុន ណារីន | 121 |
| 62 | ដក់ទក់ | *Olax scandens* Roxb. | ទង ដាលី | 123 |
| 63 | ដក់ពរ | *Markhamia stipulacea* | ប៊ិច ចំណានប្រណិត | 125 |

| | | | | |
|---|---|---|---|---|
| 64 | ដៃខ្លា (ដើម) | *Gandenia angkorensis* | ផេង សុភ័ក្រ | 127 |
| 65 | ដោះគន់-ដោះកុន (វល្លិ) | *Tetracera scandens* (Linn) | ហេង ជុងហ័រ | 129 |
| 66 | ត្បាល់ដែក | *Peliosanthes teta* Andrews | ជិន សុជាតិ | 131 |
| 67 | ត្រគៀតជូរ-ឆាយនីក្រៀម | *Homalomena aromatica* | ខាន់ សុម៉ានីតា | 133 |
| 68 | ត្រថុក | *Costus speciosus* | ឡាយ សុខរក្សា | 135 |
| 69 | ត្រឡាក់-តាឡាត់ | *Canariume albume* | គុន បុប្ផា | 137 |
| 70 | ត្រសេក | *Peltophorum dasyrrhachis* (Miaq) *Hurz* | ម៉ន ចន្ទម៉ាលីកា | 139 |
| 71 | ត្រសៀត | *Vitex Negundo* L | ទុយ មួយខេង | 141 |
| 72 | ថ្កុវភ្នំ | *Anthocephalus chinensis* | ប៉េង រូចងី | 143 |
| 73 | ថ្នឹង (វល្លិ) | *Aganomerion polymorphum* | វ័ន្ត វិច្ឆិកា | 145 |
| 74 | ទន្ទ្រានខេត្ត | *Eupatorium odoratum* L. | ហាន សុលីតា | 147 |
| 75 | ទ្រមូង-ត្រមូង | *Garcinia oliveri* Perre | ប៊ូរ សុម៉ាល័យ | 149 |
| 76 | ទ្រមូងសេក | *Suregada muliflora* Baill | ភួន លក្ខិណា | 151 |
| 77 | ទំពូងភ្លើង | *Croton oblongifolius* Roxb | សៀ រុក្ខា | 153 |
| 78 | ទំពូង | *Croton jusfra* | រ៉ែន សំភ័ស្ត | 155 |
| 79 | ទឹកដោះខ្លាតូច | *Halorrhena pubeseu* | ហាក់ ផល្លីណែត | 157 |
| 80 | ទឹកដោះខ្លាធំ | *Holarrhena antidysenterica* (L.) Well | សាម ម៉ូនីកា | 159 |

| | | | | |
|---|---|---|---|---|
| 81 | ទ្រៀលស្វា | *Uvaria rufa Blume, Uvaria solanifolia* Presl. | អ៊ឹម សំខាន់ | 161 |
| 82 | ទន្សែ-អន្សែ | *Caryota urens* Linn, | ហ៊ុន ឪឡុង | 163 |
| 83 | ទ្វារព្រះ-ត្រាង | *Lasia spinosa* (L) Thwaites | លាង សុខឃឹម | 165 |
| 84 | ធ្នា | *Acacia hamandiana*(Pirre) Gagnep | គង់ សុដានី | 167 |
| 85 | ធ្លក | *Parinari annamensis* Hance. | គ្រុយ តឹមសួរ | 169 |
| 86 | នគររាន-បន្លាទន្រ្ទានគរ | *Ageratum conyzoides* L. | ប្រាជ្ញ កែវពិសី | 171 |
| 87 | នាងនួន | *Dalbergia bariensis* pierre | សេង វណ្ណី | 173 |
| 88 | នាងខ្មៅ | *Dichroa febrifuga* Lour | ឆៃ សៀកម៉េង | 175 |
| 89 | បូព្រឹក្ស | *Cassia Javanica* Linn, | ស៊ុយ សុវណ្ណរិទ្ធ | 177 |
| 90 | បំពង់រឿង | *Gomphia Serrata* | ត្រាយ ឆេងស៊ុម | 179 |
| 91 | ប៉ប្រឹក | *Drynaria quercifolia* (L.) J Sm | សេង វណ្ណា | 181 |
| 92 | ព្រះកំចាត់ | *Zanthoxylum rhetsa* DC. | ញឹប សុភារី | 183 |
| 93 | ប៉ះខ្លប-ព្រះខ្លប-សំពះ | *Mimosa pudica* L. | ហុង ម៉ាណែត | 185 |
| 94 | ប៉េងប៉ោះស្រោម | *Physalis angulata* L. | ឡេង ច័ន្ទឌីកា | 187 |
| 95 | ប្អាក់ដោក | *Siphonodon celastrineus* Griff | រឿន វិច្ឆ័យ | 189 |
| 96 | ប្អាក់ដង | *Gardenia Sootepensis* Hutch. | ល្បី សុធាវេន | 191 |
| 97 | ប្អាតផ្ទិល | *Polyalthia evecta* (Pierre) | ណារ៉ា គន្ធី | 193 |
| 98 | ប្អាយម៉ាត | *Conyza balsamiferal.* | ហាក់ គឹមហួង | 195 |

| | | | | |
|---|---|---|---|---|
| 99 | ប្រាយម៉ាតឆ្កែ | *Blumea Lacera* | ថន ស្រីម៉េង | 197 |
| 100 | បេង | *Afzelia xylocarpa* (Kurz) Craib | ស្រែង ស្រីខ្សែន | 199 |
| 101 | ប្រក្រាបដំរី | *Elephantopus Seaber* L. | ង៉ាន់ ច័ន្ទមករា | 201 |
| 102 | ប្រក្រាបដំរីធំ | *Elephantopus scaber* L. | សេង ស៊ីវនី | 203 |
| 103 | ប្រឡៅពពែ-ក្រឡាំពែ (វល្លិ) | *Aganosma marginata* (Roxb.)G.Don | ឡុង ស៊ីថា | 205 |
| 104 | ប្រាំដំឡឹង | *Terminalia corticosa* | ទឹង ស្រីមុំ | 207 |
| 105 | ផ្ទឹក | *Shorea obtusa* wall | មឿង ធារី | 209 |
| 106 | ផ្ដៅដំបង | *Calamus rudentum* Lour. | ធឿន ចន្ទី | 211 |
| 107 | ផ្ទាញ | *Stenochlaenapalustris* (Burm.f.)Bedd. | វ៉ែន ពៅ | 213 |
| 108 | ពភ្លា | *Microcos tomentosa* Sm | ស៊ុត ដានី | 215 |
| 109 | ពពកត្រឡប់ | *Phyllodium pulchellum*(L)Desv. | យឹម សុប៉ាមី | 217 |
| 110 | ពពាលខែស្លឹកធំ | *Terminalia calamansanail* ( Blanco ) Rolfe | ពិសិដ្ឋ សោភ័ណ | 219 |
| 111 | ពពេល | *Shorea roxburghi* G Don<br>*Shorea cochinchinensis* pierre | អ៊ុក រ័ត្នមុន្នី | 221 |
| 112 | ពពូលថ្ម | *Vitex Pubescens* Vahl | ថា ផានី | 223 |
| 113 | ពពូកសំឡី | *Vitex quinata* (Lour.)F.N.Williams | ពៅ លក្ខណា | 225 |
| 114 | ពុទ្រាព្រៃ | *Harrrisonia perforata* ( Blanco ) Merr | ហ៊ុយ បារាំង | 227 |
| 115 | ពង្រ | *Schleicheria oleosa* (Lour) Oken | វ៉ា រតនា | 229 |
| 116 | ព័ន្ធតាឡី | *Terminalia corticosa* Pierre ex lanessan | ទាវ សុភារី | 231 |

| | | | | |
|---|---|---|---|---|
| 117 | ព្រាលខ្មែរ-ព្រាលចន្លុះ | *Colona auriculata* ( Desv. ) Craib. | ផៃ ប៊ុណ្ណា | 233 |
| 118 | ព្រះភ្លៅ | *Termainalia nigrovenulosa* Pierre exlanesse | វណ្ណ ស៊ុណា | 235 |
| 119 | ព្រះកំចាត់ | *Zanthoxylum rhetsa* DC. | នី ច័ន្ទរស្មី | 237 |
| 120 | ព្រីង | *Syzygium cumini* (L) Skeels | អ៊ុម សីលវត្តី | 239 |
| 121 | ភ្នំភ្លើង | *Hymenocardia punetata* Wall ex lindl, | ធូន សុខលីនដា | 241 |
| 122 | ភ្លូធំ | *Dilleniaovata* wall.exhook.f.et.thomson | ឡាយ សុវណ្ណារី | 243 |
| 123 | ភ្លាំង | *Glycosmispentaphylla* (Retz) Correa | សៅ លីហ៊ុយ | 245 |
| 124 | មហាមេឃ (វល្លិ) | *Merremia vitifolia* (Burm. f.) Hallier f. *Ipomoea vitifolia* Sw. | ទិត រដ្ឋលីណា | 247 |
| 125 | មីងមាំង | *Diospyros ehretioides* Wallich ex. G. Don | កាង មួយហ្វង | 249 |
| 126 | មេជីវ | *Strophanthus Caudatus* (L.) Kurz | អ៊ឹង លីដា | 251 |
| 127 | ម្រាមដៃនាងសេដា | *Schefflera elliptica* (Blume)Harm | អ៊ឹម ស្រីម៉ៅ | 253 |
| 128 | ម្លូរចេងគ្រេង | *Hibiscus surattensis* L. | ៉ា ចាន់ដានិត | 255 |
| 129 | រកា | *Bombax ceiba* Linn. *Bombax malabaricum* Linn. | អែម ច័ន្ទរស្មី | 257 |
| 130 | របុកដាស | *Helicteres angustifolia* DC | ចាន់ ដានី | 259 |
| 131 | រលួយបាយភ្នំ | *Eryhrina Veriegata* L. | ឆាយ រ៉ាវីន | 261 |
| 132 | រលាយឈាមតូច | *Cnetis palala* (Lour) Merr | តាន់ គិមស៊ី | 263 |
| 133 | រាជព្រឹក្ស-លឿងរាជ | *Cassia fistula.* Linn | ឈ្យូក ម៉ារីណា | 265 |

| | | | | |
|---|---|---|---|---|
| 134 | រំដួល | *Melodorum fruticosum* Lour. | សេត វ៉ែហ្វាត | 267 |
| 135 | រំដេងព្រៃ | *Alpinia conchigera* Grulf | អៀម សុខគីម | 269 |
| 136 | រលាយស្មង | *Micromelum falcatum* (lour).tanak, | សុវណ្ណ<br>រ៉ូចណាង | 271 |
| 137 | រលាយធំ | *Neonauclea sessilifolia* (Roxb.)Merr.. | ឡាយ<br>លាងស៊ីម | 273 |
| 138 | ផ្ចឹករាំង | *Shorea siamensis* Miq | ភួង<br>សុផាលីនដា | 275 |
| 139 | លាំងជ័យស្លឹកតូច | *Buchanania siamensis* Mig | ធី រចនា | 277 |
| 140 | ល្ហុងខ្វងក្រហម | *Jatropha gossypifolia* Linn | ខាត់ សុធា | 279 |
| 141 | លាចផ្ទុះដើម | *Flueggea microcarpa* Bl | ម៉ុក សារ៉ាត | 281 |
| 142 | វិលេនពៃន (វល្លិ) | *Tetrastigma Planicaule* (Hook f.) Gagnep | ហាក់ បញ្ញា | 283 |
| 143 | ល្បៀងកូនង៉ែត | *Cratoxylum formosum.* Jack Dyer subsp. PrunifIorumKurs | លី កល្យាណ | 285 |
| 144 | ដើមល្មុតស្រងាំ | *Sideroxylon Cambodianum* Pierre | ស្រី ពេជ្រ | 287 |
| 145 | ល្វាដី | *Ficus hispida* Linn.f. | ហេង ស៊ុឆន | 289 |
| 146 | ល្វាធំ | *Ficus racemosa* L. Syn-Ficus glomerata Roxb. | ស៊ុម ណារុំ | 291 |
| 147 | វល្លិ គុយ | *Willughbeiae cochinchinensis* | កៀន ពុទ្ធិតា | 293 |
| 148 | វល្លិ ឯម | *Streblus ilicifolius* | ចឺ នាងល័ក្ខ | 295 |
| 149 | វល្លិ ចារក្រហម | *ButeaSuperbaRoxb* | នង សុគន្ធារ័ត្ន | 297 |
| 150 | វល្លិ ជុយ | *Streptocaulon juventas,* | លុន ភូរីណា | 299 |

| | | | | |
|---|---|---|---|---|
| 151 | វល្លិដឺស | *Dioscorea bulbifera* L | ឈើ តុលា | 301 |
| 152 | វល្លិ ត្នោត | *Thunbergia grandiflora* Roxb. | ឡាយ សិកា | 303 |
| 153 | វល្លិ ត្រចៀកដំរីស្លឹកទាលឆក | *Ohya obovata* Decne | ម៉ុម សាររីយ៍ | 305 |
| 154 | វល្លិ ត្រចៀកដំរីស្លឹកស្រួច | *Hoya parasitica* | គឹម ពន្លក | 307 |
| 155 | វល្លិ ទន្លីងដំរីស | *Ventilago gristata* pierre. | ដា សុវណ្ណារ័ត្ន | 309 |
| 156 | វល្លិ ទឹក | *Cissus rosea* Royle | យួន កញ្ញា | 311 |
| 157 | វល្លិ បង្គងក្អែក | *Dischidia rafflesiana* wall | កែវ ដារី | 313 |
| 158 | វល្លិ ផោមស្លឹកធំ | *Paederia foetida* L. | ផារ សុផារដ្ឋ | 315 |
| 159 | វល្លិ ព្រះក្រុងស្លឹករលីង | *Cyclea Barbat* Mier | ឈួន ឆាមសុវណ្ណរ៉ា | 317 |
| 160 | វល្លិ ព្រះក្រុងរោម | *Aporusa villosa* | ហាក់ សុខធីតា | 319 |
| 161 | វល្លិ យាវ | *Tiliacora triandra* Diels<br>*Cocculus thumbergii* DC.<br>*Limacia triandra* Miers | រឹម សារី | 321 |
| 162 | វល្លិឪឡ | *Lygodium flexuosum* (L.)S | យូ ស៊ង | 323 |
| 163 | វល្លិ ឪជុំតូច | *Scindapsus officinails* schott | រី សុវត្ថា | 325 |
| 164 | វល្លិ ទាស់ | *Dalbergia hancei* Benth. | ម៉ៅ ស៊ីវលីញ | 327 |
| 165 | វល្លិ វាយ | *Salacis chinensis* Linn. | ត្រាយ សុថានិត | 329 |
| 166 | វល្លិ សាវម៉ាវព្រៃ | *Aporusa villosa* | អឿ ស្រីលិះ | 331 |

| | | | | |
|---|---|---|---|---|
| 167 | វល្លិ៍អាណោ, វល្លិ៍ឪណោ | *Adenia parviflora* (Blanco) Cusset | មៅ រីណា | 333 |
| 168 | ដើមសម៉ ឬ ស្រម៉ | *Terminalia chebula* Rezt | ហួរ ណារី | 335 |
| 169 | ដើមសង្កុងតូច ឬ ជូរព្រឹក | *Embelia ribes* Burm. f. | ទុយ រដ្ឋា | 337 |
| 170 | សង្ខ្យារ៍ | *Zizyphus oenoplia* Mill | សៅ សូយានីត | 339 |
| 171 | ដើមសម្កុងតូច | *Embelia ribes* (Burm.f) | សៀង ចាន់ណា | 341 |
| 172 | ស្តៅ | *Azadirachta indica* A. Juss | សោ ដាលីន | 343 |
| 173 | ដើមស្នាយ | *Streblus asper* Lour, | នាង ស្រីណែត | 345 |
| 174 | ដើមស្នាយដែល | *Polyalthia cerasoides* (Roxb.) *Benth.* | អោក មួយឡេង | 347 |
| 175 | ស្នាយបាយរមាស, ស្នាយបន្លាក្រូច | *Streblus ilicifolius*(Vidol) Corner | យក់ សម្ភាសន៍ | 349 |
| 176 | ស្នាយញាតិ | *Streblus ilicifolius* | រ៉ាន់ សុលីណា | 351 |
| 177 | ដើមស្នាក្របី | *Knema Globularia* Warb, | យៀង គីមហុង | 353 |
| 178 | ស្វាយព្រៃ | *Mangifera du perreana* Pierre | សេង ដារីកា | 355 |
| 179 | ដើមស្វាយចន្ទី | *Anacardium occidental* Linn, | តុល សុគន្ធង | 357 |
| 180 | ស្លែងប្រវៀក | *Strychnosnux-blanda* A.W.Hill. | កាន់ ច័ន្ទណា | 359 |
| 181 | ដើមសិរសាច់ | *Glochidion obscurum* (Roxb.ex Willd.)Blume | ជី សុជីវិន | 361 |
| 182 | ដើមសូក្រំ | *Xylia xylocarpa*(Roxp).Tanb.Var.Kerrii | សៀក ផាន់ណាត | 363 |

| | | | | |
|---|---|---|---|---|
| 183 | ដើមស្វូភី | *Mammea siamensis* Kosterm | គឹម ចរិយា | 365 |
| 184 | ចន្ទ័រាប, | *Homalomena aromatica* | ខាន់ សុម៉ានីតា | 367 |
| 185 | ស្មៅស្លែព្រៃ | *Erechites Hieracisolia* | ឈុន សុម៉ាលីន | 369 |
| 186 | សម្បូរកក់ | *Acacia concinna* (Willd) DC. | មៀង សុធារ៉ា | 371 |
| 187 | ព័ន្ធតាឡី ឬ ប្រាំដំឡឹង | *Terminalia corticosa* Pierre ex lanessan | ទាវ សុភារី | 373 |
| 188 | ស្មៅក្បាលពស់វែក | *Barleria siamensis* Craib, | ធៀក ធីណា | 375 |
| 189 | ស្មៅកន្ទុយឆ្កែ | *Pennisetum alopecuroides* (L) Spreng, | ផល គឹមហ៊ាង | 377 |
| 190 | ស្មៅជើងតុកកែ | *Coldenia procumbens* L. | យ៉ន់ សុផល្គុណ | 379 |
| 191 | ដើមអង្កត់ខ្មៅធំ | *Diospyros venosa* | ណុប វិជ្ជនី | 381 |
| 192 | អំព្រំប្រែក្រោយ | *Phyllodium pulchellum*(L)Desv | មុយ វណ្ណថេន | 383 |
| 193 | ដើមអង្គ្រឹង | *Zizyphus cambodiana* Pierre | ឈិន ស៊ីណាន | 385 |
| 194 | អង្រែដែក | *Dracaena angustifolia* Jack | ឆេង ជ័រ | 387 |
| 195 | ដើមអង្គាសីល | *Ochna integerrima* (Lour) Merr. | ជា ដារី | 389 |
| 196 | ដើមអំបែងចាន | *Mallotus philippinensis,* | ឃូ សុខជា | 391 |
| 197 | ដើមអញ្ចាញ | *Gmelina asiatica* L. | ឡៅ គឹមឆេង | 393 |
| 198 | កញ្ចាន់អាចម៍ជ្រូក ជញ្ចាន់អាចម៍ជ្រូក | *Urena lobata* L, | ស៊ូ បូទុម | 395 |







# ឝណ្ដៀរខ្មែរ,ប្រហៀរខ្មែរ(វល្លិ៍)

Nom Scientifique : ***Smilax glabra wall.ex.roxb***

Famille : **SMILACEAE**

# កណ្តៀរខ្មៅ,ប្រហៀរខ្មៅ(វល្លិ៍)

Nom Scientifique : ***Smilax glabra wall.ex.Roxb***

Famille : **SMILACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាវល្លិ៍ព្រៃតោងឡើងដើមឈើមានប្រវែង៥.១០ម៉ែត្រ។

- **ស្លឹក** ៖ ស្លឹកទោលដុះឆ្លាស់ទង រាងជាពងក្រពើ ឬ រាងមូល ស្រួចចុង។

- **ផ្កាផ្លែ** ៖ -ចង្កោមផ្កាមានពណ៌លឿងបៃតង មានផ្កាតូចចំនួន១០ ហើយផ្កាចែកជាពីរភេទគឺ ផ្កាញីនិងផ្កាឈ្មោលតែមួយភេទប៉ុណ្ណោះ ដែលត្រូវបានរកឃើញនៅលើដើមតែ១
-ផ្លែមានពណ៌ក្រហម និង មានរាងដូចផ្លែឈើរី មានវិជ្ជមាត្រ៥មីលីម៉ែត្រ។

+ **កន្លែងដាំដុះ** ៖ គេប្រទះឃើញនៅតំបន់ព្រៃជើងភ្នំ ឬ ជ្រលងភ្នំ ឬ តំបន់ដៃសមុទ្រ។

+ **សមាសធាតុគីមី** ៖ β-Sitosterol, -Dancostérol, 1-0 hexadeconoyl-3-0-β-D-galactopyranosyl-glyce Astillbin, Isostilbin, Quercetin, Taxifolin, Flavonoide, Engelitin.

+ **ផ្នែកប្រើប្រាស់** ៖ ផ្លែ ស្លឹក និង ឬសជាទូទៅប្រើ ឬស ឬ ដើម។

+ **ការប្រើប្រាស់** ៖ -Anti-proliferative et Pro-apoptotic effet, Anti-tumor et anti atherosclerosis activity, Antiscrophulatic.

+ **វិធីប្រើប្រាស់** ៖ - ស្លឹកយកធ្វើតែ
-ផ្លែមិនទាន់ទុំត្រូវបានគេញ៉ាំដើម្បីបំបាត់ការស្រេកទឹក
-ឬស ឬ មើម ប្រើជាថ្នាំជំនួយសុខភាពព្យាបាលឈាមតាមអញ្ចាញធ្មេញ ធ្វើឲ្យខ្យល់ដើរជួយបណ្តេញជាតិពុល និងកាកសំនល់ពីក្នុងខ្លួន ធ្វើឲ្យបែកញើស និងប្រើជាថ្នាំបញ្ចុះទឹកនោម ព្យាបាលជំងឺសើស្បែក(ជាពិសេសជំងឺPoriasis)បំបាត់ឈឺសន្លាក់ប្យាលបាលរលាកពោះវៀន រាគមូលដោយបាក់តេរី ស្វាយប្រមេះ។

+ **ឯកសារយោង** ៖ -http://www.rain-tree.com/saraparilla-htm
-កំរងរុក្ខជាតិឱសថស្តីពីការចុះស្រាវជ្រាវក្នុងខេត្តកោះកុង(ឆ្នាំ២០១០)

**រៀបរៀងដោយនិស្សិត ៖ ស៊ុន ច័ន្ទមករា**





# គ្រពើរោទ៍

Nom Scientifique : ***Peikiosopermum suaveoleus Merr***

*Famille :* ***URTICEAE***

# គ្រពើរេទ៍

Nom Scientifique *Peikiosopermum suaveoleus Merr*

Famille ***URTICEAE***

**+ លក្ខណៈរុក្ខជាតិ** ៖ ជាវល្លិ៍ឈើ មែកខ្ចីមានពកកន្ទួល ។

**- ស្លឹក** ៖ ស្លឹកទោលដុះឆ្លាស់ទង រាងពងក្រពើទ្រវែង ស្រួចចុង ទទឹង 10-14ស.ម បណ្តោយ 12-26 ស.ម ផ្ទៃស្លឹករលោង ទ្រនុងស្លឹកលេចច្បាស់ ទងស្លឹកពណ៌ក្រហម ដុះផ្តុំនៅចុងមែក ។

**- ផ្កាផ្លែ** ៖ កញ្ចុំផ្កាចេញតាម ប្រគាបស្លឹក ឬស្នាមស្លឹកជ្រុះផ្កាញែកភេទពីគ្នា ផ្កាឈ្មោលចេញរួមគ្នាជាដុំ ពណ៌ស៊ីជម្ពូលាយក្រហម ទំហំ1-1,5 ស.ម ផ្កាញីរួមគ្នា ជាក្បាលដូចផ្កាឈ្មោល ផ្កាជាប់គ្នា គល់ផ្កាវាងជាបំពង់តូច ចុងផ្កាបែកជា4 ចែកកេសរឈ្មោលមាន 2-4។ ផ្លែមានរាងមូល ពណ៌ក្រហម ឬក្រហមត្នោត ទំហំ2-4 ស.ម ។

**+ កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯងតាមមាត់អូរ មាត់ជ្រោះ ដែលមានថ្មនៃតំបន់ភ្នំ និងតាមឆ្នេរសមុទ្រ ដែលមានថ្មធំៗ បន្តពូជដោយគ្រាប់ ។

**+ សមាសធាតុគីមី** ៖ មិនទាន់ស្រាវជ្រាវនៅឡើយ ។

**+ ផ្នែកប្រើប្រាស់** ៖ ដើម ស្លឹក ឬស ។

**+ ការប្រើប្រាស់** ៖ ដើមប្រើផ្សំជាថ្នាំ ជំនួយបេះដូង ជម្ងឺសរសៃប្រសាទ រក្សាគភ៌ ។ ដើមបុករួច យកទៅកក់សក់ធ្វើឲ្យងាប់ចៃ។ ទឹកដែលបានកាប់ពីដើម យក ទៅបន្តក់ភ្នែកព្យាបាលជំងឺឈឺភ្នែក ។ស្លឹកដាំទឹកផឹកសំរាប់ព្យាបាលគ្រុនក្តៅ គ្រុនចាញ់ ខ្សោយតំរងនោម និងផ្សះបូស។

**+ កំរិតប្រើប្រាស់** ៖ ស្ងួតប្រើ 20-30 ក្រាម ដាំទឹកហូប ។

**+ ឯកសារយោង** ៖
- http://www.ku.ac.th/AgrInfo/plant/plant2/p155.
- រុក្ខជាតិឱសថកម្ពុជាភាគ៤/ បោះពុម្ពដោយថវិការជាតិឆ្នាំ២០១០។

**រៀបរៀងដោយនិស្សិត ៖ ម៉ាយ ស៊ីនឡេង**








# ភ្លាំងបាយស

Nom Scientifique : ***Leea Indica Merr,***

Famille : **LEEA CEAE**

# ក្តាំខបាយស

Nom Scientifique : ***Leea Indica Merr***

Famille : **LEEA CEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ចុលព្រឹក្ស មានកំពស់ ២-៤ម៉ែត្រ

- **ស្លឹក** ៖ ស្និតសេសដុះឆ្លាស់ទងកួនទ្រវែងស្រួចចុងទទឹង ៤-៦ ស.ម, បណ្តោយ ១២-១៨ ស.ម, ទងស្លឹកស្ទបអោបដើម ។

- **ផ្កា ផ្លែ** ៖ កញ្ចុំផ្កាចេញពីប្រគាបស្លឹកនិងចុងមែកលក្ខណៈជាខ្នែងរួមទងមានពណ៌បៃតងខ្ចី ។ ផ្កាតូចៗតំរៀបគ្នាញឹកក្តាំង(ដូចបាយក្តាំង)។ តូចមូលញឹកក្តាំងប្រែទៅជាពណ៌ក្រហមក្រមៅ ឬ ខៀវពេលទុំ ។

+ **កន្លែងដាំដុះ** ៖ ដុះនៅតំបន់ខ្ពង់រាប ។ បន្តពូជដោយគ្រាប់ និងបែកខ្នែងពីឫស ។

+ **សមាសធាតុគីមី** ៖ មិនទាន់មានឯកសារស្រាវជ្រាវបញ្ជាក់នៅឡើយ ។

+ **ផ្នែកប្រើប្រាស់** ៖ មើម, ស្លឹក, ឫស

+ **ការព្យាបាល** ៖ - មើម: បញ្ចុះកំដៅចេញញើស, ធ្លាក់ស, មហារីកពោះវៀន
-ស្លឹក: បុកព្យាបាលរោគសើរស្បែកដូចជាស្រែង, រមាស់, ឈឺខ្លួន
-ឫស: ព្យាបាលជំងឺ ឈឺសន្លាក់ឆ្អឹង (ប្រើជាមួយឫសអណ្តាតគោ) ឈឺពោះ ចុកពោះ, ស្ត្រីរដូវមិនទៀង, ស្ត្រីមានផ្ទៃពោះសុខភាពពុំសូវល្អ, ស្ពឹកដៃជើង ។

+ **កំរិតប្រើប្រាស់** ៖ ពី១៥-៣០ ក្រាមដាំផឹកក្នុងមួយថ្ងៃ ។

+ **ឯកសារយោង** ៖ ដកស្រង់ចេញពីសៀវភៅ រុក្ខជាតិឱសថកម្ពុជា (ភាគ១)បោះពុម្ពដោយថវិកាជាតិ ឆ្នាំ ១៩៩៧ et ២០០៦
www.leeaceae/imag.com

**រៀបរៀងដោយនិស្សិត ៖ ហេង តារ៉ា**






## អង្កោះ

Nom Scientifique : ***Microcos tomentosa Sm***

*Famille :* ***FABACEAE***

# គគោះ

Nom Scientifique : ***Sindora siamensis Teijsm ex.Miq, var siamensis.***

Famille : **FABACEAE**

**+ លក្ខណៈរុក្ខជាតិ** ៖ ឈើមធ្យមមានកំពស់ពី១៥-២៥ម ។

**- ស្លឹក** ៖ រួមស្លាបគូ ,រាងពងក្រពើ , ដុះទល់ទងគ្នា,មានពី២-៤គូ ,ស្លឹកវាស្វិត, ខាងលើស្លឹកមានរោមតិចៗ, ខាងក្រោមស្លឹកមានសរសៃនិងរោមច្រើន , ស្លឹកប្រវែងពី៥-១០សម, ទទឹងពី២,៥-៥,៥សម។

**- ផ្កាផ្លែ** ៖ - ផ្កា: ដុះជាចង្កោមធំមានពណ៌លឿង, ចេញនៅចុងមែកនិងប្រគាបស្លឹក។

- ផ្លែ: រាងមូលសំប៉ែតមានបន្លាពណ៌បៃតង, ផ្លែ១មានគ្រាប់១, នៅលើទងគ្រាប់មានក្បាលរាងដូចផ្សិត។

**+ កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯងនៅតំបន់ភ្នំនិងខ្ពង់រាបឬគេដាំ។ដុះជាមួយសន្តានខ្លង ឬត្បែង។

**+ ផ្នែកប្រើប្រាស់** ៖ សំបកដើម, ពកដើមនិងគ្រាប់។

**+ ការប្រើប្រាស់** ៖ -សំបកដើម: ដាំផឹកព្យាបាលអុតក្តាម, ក្មេងដែលខ្សោយកំលាំងហើយដែលមិនឃ្លានអាហារព្រមទាំងមានជ្រាំងអណ្តាតនិងរលាកក្រអូមមាត់/បំពង់ក។

-ពកដើម: ដាំផឹកព្យាបាលព្រូន, រោគស្បែក, ដាំឆ្អង់អោយឫសដូងរួញបាត់។

-គ្រាប់: ដុសបិតឫស, រោគសើស្បែក។

**+ កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី១០g -១៥g ដាំផឹកក្នុង១ថ្ងៃ។

**+ ឯកសារយោង** ៖ - សៀវភៅរុក្ខជាតិឱសថកម្ពុជាពីអក្សរកដល់ឋ បោះពុម្ព ឆ្នាំ២០០៨, ភាគ១.

- Dictionnaire des plantesutilisés au Cambodge,DY PHON PAULINE.

- Medicinal plants in Thailand, volume II.

**រៀបរៀងដោយនិស្សិត ៖ លឹម ហ៊ារម៉ី**







# ដើមកន្ទួតព្រៃ

Nom Scientifique : ***Phyllanthus emblica* L.**

Famille : **EUPHORTBIACEAE**

# ដើមកន្ទួតព្រៃ

Nom Scientifique *: Phyllanthus emblica* **L.**

Famille : **EUPHORTBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិដើមតូចមានកំពស់ពី ២-៨ម។ សំបក ដើម ស្លឹក និងផ្កា ផ្តល់ជាល័ក្ខលឿង ។
  - **ស្លឹក** ៖ ជាប្រភេទស្លឹកតូចៗទទឹង0,២៥-0,៥0 ស.ម បណ្តោយ0,៨-១,២ស.ម។ តែមស្លឹករលោង ដុះឆ្លាស់ទងគ្នាជាពីរជួរ សងខាងបែកមែកតូច ៗ ។
  - **ផ្លែ** ៖ រាងមូលរសជាតិជូរ គេអាចបរិភោគស្រស់ក៏បាន ជាគ្រឿងសម្លរក៏បាន។
+ **កន្លែងដាំដុះ** ៖ ដុះនៅតាមព្រៃរបោះនៃប្រទេសកម្ពុជា។ គេប្រទះឃើញមានជាច្រើននៅខេត្តកំពង់ស្ពឺ និង ខេត្តភាគអាគ្នេយ៍នៃប្រទេសកម្ពុជានៅលើភ្នំតូចៗ ។
+ **សមាសធាតុគីមី** ៖ Polyphenol មានដូចជា gallic acid, organic acids, cytokinins, chebulagic acids, phyllenblin emblicol,emblican A និង B, quercetin, fatty acids និង arachicic acids។
+ **ផ្នែកប្រើប្រាស់** ៖ ផ្លែក្រៀម សាច់គ្រាប់ គ្រាប់ ស្លឹក ឬស សំបកដើម និង ផ្កា។ ផ្លែទុំជាទូទៅគេប្រើស្រស់ ស្ងួតក៏ប្រើបានដែរ។
+ **ការប្រើប្រាស់** ៖ កន្ទួតព្រៃស្រស់ប្រើក្នុងករណី ហើមរលាកលើថ្លាស(ប្លោកនោម) សួត និង ភ្នែក។ ម្សៅផ្លែកន្ទួតព្រៃលាយទឹកផុកៗ ប៉ាតលើថ្លាស(ប្លោកនោម)ព្យាបាលនោមក្រហាយ ក្នុងករណីនោមទាស់ និង ប៉ាតលើថ្លាស(ក្បាល) ក្នុងករណីប្រកាំង (ឈឺ១ចំហៀងក្បាល) ផ្លែមានសកម្មភាពកាត់ស្លេស៍ បង្កើនទឹកនោម បំបាត់រាគ បន្ថយកំដៅ និង ប្រឆាំងការខ្វះជីវជាតិវីតាមីនសេ។
+ **ឯកសារយោង** ៖ -សៀវភៅរុក្ខជាតិកម្ពុជា-ក្រសួងសុខាភិបាល-មជ្ឈមណ្ឌលជាតិស្រាវជ្រាវ ម មុ វេជ្ជសាស្ត្របូរាណបោះពុម្ពផ្សាយឆ្នាំ ២០០៦។
  -http://en.wikipedia.org/wiki/Phyllanthus_emblica

**រៀបរៀងដោយនិស្សិត ៖ ហ៊ាម លីដា**










# កន្ទាំងខហែរ

Nom Scientifique : ***Polygonum tomentosum Willd.***

*Famille :* **POLYGONACEAE**

# កន្ទាំងហែរ

Nom Scientifique : *Polygonum tomentosum Willd.*
Famille : **POLYGONACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ តិណជាតិរស់បានយូរឆ្នាំ មានរោមគ្រប់ដណ្តប់ ដើមដុះក្នុងទឹក ដីសើម។ ដើមមូលមានថ្នាំង មានទំហំ ១,៥សម។
  - **ស្លឹក** ៖ ស្លឹកទោលមានរាងផ្លែលំពែង មានទងស្លឹកខ្លី បន្ទះស្លឹកមានរោមពណ៌ស។
  - **ផ្កា** ៖ ដុះជាគួរនៅខាងចុង មានផ្កាពណ៌ស។
  - **ផ្លែ** ៖ ផ្លែជាគួរលើង ក្នុងមួយគួរមានផ្លែច្រើន។
  - **គ្រាប់** ៖ ពណ៌ត្នោត ក្រមៅ ក្នុងមួយផ្លែមាន១គ្រាប់។
+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯង តាមមាត់បឹង ទន្លេ ត្រពាំង ដីលិចទឹក។ បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ មានជាតិ Tanin & Flavonoid glycosides
+ **ការប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល។
+ **ការព្យាបាល** ៖ បញ្ចុះកំដៅ ក្អក បុកយកទឹកខ្ពុលមាត់ រាក់ស៊ីធ្មេញ ធ្លាក់ស ឡើងឈាមគ្រាំ។
+ **កំរិតប្រើប្រាស់** ៖ ឫសស្ងួតពី ១៥ទៅ៣០ក្រាម ដាំផឹកក្នុង១ថ្ងៃ។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ១ ពីអក្សរ ក ដល់ ផ រៀបរៀងដោយមជ្ឈមណ្ឌលស្រាវជ្រាវវេជ្ជសាស្ត្របូរាណ ឆ្នាំ២០០៨។

**រៀបរៀងដោយនិស្សិតៈ ផាត សុផល្លាប**



# ដើមកន្ទុយទេ

Nom Scientifique : ***Neoliltsea zeylanica Meer***

Famille : **LAURACEAE**

# ដើមកន្លយទេ

Nom Scientifique : ***Neoliltsea zeylanica Meer***

Famille : **LAURACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាដើមឈើមធ្យមមានកំពស់ ២០ម ។
- **ស្លឹក** ៖ ដុះឆ្លាស់គ្នា ស្ថិតរលោងនៅខាងលើមានពណ៌បៃតង ខាងក្រោមមានពណ៌ស មានរាងពងក្រពើស្រួចគល់ ស្រួចចុងមានប្រវែងពី ៨-១៦ ស.ម ទទឹងមានប្រវែងពី ១៨-៣០ ម.ម មានទ្រនុងស្របចំនួន៣ ទងស្លឹករលោងមានប្រវែង១.៥-១.៧ សម
- **ផ្កា ផ្លែ** ៖ មាន៥ស្រទាប់ ។
+ **កន្លែងដាំដុះ** ៖ ដាំនៅព្រៃស្រោង តំបន់ភ្នំ ។
+ **សមាសធាតុគីមី** ៖ ក្នុងស្លឹកមាន ជាតិប្រេង Ocimen ៣៥ភាគរយ និងមានជាតិក្រអូប ។
+ **ផ្នែកប្រើប្រាស់** ៖ ឫស
+ **ការប្រើប្រាស់** ៖ -យកឫសបុក បិទកន្លែងកើតបូស
  -សំបករបស់ដើម ជំនួយឈាម គ្រេចថ្លស់ ជំនួយក្រពះ ឈឺស្បូនក្រោយពេលសំរាលកូន
  -ស្លឹកយកមកឆ្អុង
  -បុកឫស និង សំបកយកម្សៅទៅធ្វើធូប ។
+ **កំរិតប្រើប្រាស់** ៖ ស្ងួត ប្រើប្រាស់ពី ១០-១៥ក្រាម ក្នុង១ថ្ងៃ
+ **ឯកសារយោង** ៖ http://www.cactuspedia.info/schede/EUPHORBIA/Euphorbia_lactea/Euphorbia_lactea/Euphorbia_lactea.htm
  http://www.aujardin.org/euphorbia-lactea-t48415.html
  http://www.mi-aime-a-ou.com/euphorbia_lactea_cristata.php

**រៀបរៀងដោយនិស្សិត ៖ ឌុល ស្រីណែត**







# ដើម កន្ទ្រោកដំរី

Nom Scientifique : *Clausena excavata Burm f*

Famille : **RUTACEAE**

# ដើម កន្ទ្រោកដំរី

Nom Scientifique : ***Clausena excavata Burm f***

Famille : **RUTACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើតូច មានកំពស់ពី ១-៥ m ដើមមានរោមតិចៗ។
  - **ស្លឹក** ៖ មានលក្ខណៈរោមបក្សី ជាងស្លឹកដុះឆ្លាស់គ្នា។ ស្លឹកខាងលើរលោង ខាងក្រោមមានរោមច្រើន។
  - **ផ្កា** ៖ ផ្កា ពណ៌ផ្កាឈូកដុះជាកញ្ចុំនៅចុងមែក, ផ្កាមានប្រវែង២៤ mm ផ្កាមាន៤ស្រទាប់, នៅស្រទាប់នីមួយៗមាន៤សន្លឹក។
  - **ផ្លែ** ៖ ផ្លែរាងពងក្រពើពណ៌ទឹកក្រូច-ពណ៌ក្រហមផ្លែជាចង្កោម ១ផ្លែមានពី១-២គ្រាប់។
+ **កន្លែងដាំដុះ** ៖ ដុះតាមភ្នំ, ចំការ, ឬ គេដាំ។
+ **សមាសធាតុគីមី** ៖ ក្នុងស្លឹក និង ដើមមានជាតិប្រេង១ប្រភេទពិសេសដែលកំពុងស្រាវជ្រាវ។ ឬសមានជាតិ acetone, carbazole akaloids, clausenatine-A, glycozolidal, heptaphilline, 3-methylcarbazole, methylcarbazole-3-carboxylate
+ **ផ្នែកប្រើប្រាស់** ៖ ស្លឹក, សំបកដើម, និង គ្រាប់។
+ **ការប្រើប្រាស់** ៖ - ស្លឹក: បិតកន្លែងហើមរលាកសន្លាក់, ដួលហើម, ដាំទឹកមុជព្យាបាលកើតអាត់, កើតរមាស់ និង បន្សាបពិសពស់។
  - សំបក: ព្យាបាលឈឺពោះបណ្ដាលមកពីគ្រឿងរំលាយអាហារខ្សោយ។
  - ដើម: ធុងជីកព្យាបាលឈឺពោះ។
+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី ៨-១៦ក្រាម សំបកស្រស់ ដាំទឹកផឹកក្នុង១ថ្ងៃ។
+ **ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជា មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ ភាគ១ បោះពុម្ពឆ្នាំ២០០៨។
  http://www.newcrops.uq.edu.au/listing/commonnameslistingindexw.html

រៀបរៀងដោយនិស្សិត ៖ **ហេង សុវណ្ណា**







# ដើមកន្ទ្រោកឆ្អេះ, កន្ទ្រោកខ្មោច

Nom Scientifique : *Clausena excavata Burm.f.var.villosa Hook*

Famille : **RUTACEAE**

# ដើមកន្ទ្រោកឆ្កែ, កន្ទ្រោកខ្មោច

Nom Scientifique : ***Clausena excavata Burm.f.var.villosa Hook***

Famille : **RUTACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាចុល្លព្រឹក្សមានកំពស់០.៥ទៅ១.៥ម៉ែត្រ សំបកមានពណ៌ត្នោតក្រមៅ មែកខ្ចីមានរោម។
  - **ស្លឹក** ៖ រួមស្លាបសេសដុះឆ្លាស់ទងខ្វែង កូនស្លឹករាងស៊ុតត្រមាចមានកូនស្លឹកពី១៥ ទេ មានបណ្តោយប្រវែងពី១ ទៅ ៤សម ទទឹង១ទៅ២.៥សម ហើយ មាន រោមទន់គ្របដណ្តប់។
  - **ផ្កា** ៖ ផ្កាតូចៗ កញ្ចុំ ចេញនៅចុងមែកពណ៌សលាយបៃតង។
  - **ផ្លែ** ៖ ផ្លែសាច់រាងជាស៊ុតពណ៌បៃតងខ្ចី ពេលទុំពណ៌ទឹកក្រូចលាយជំពូមានជាតិទឹក ច្រើន។
+ **កន្លែងដាំដុះ** ៖ ដាំតាមព្រៃល្បោះដីទំនេរ តាមមាត់ផ្លូវជាតិ បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ ។
+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល ។
+ **ការប្រើប្រាស់** ៖ ឬស សំរាប់ព្យាបាលគ្រុនផ្តាសាយ ចុកពោះពេលមានរដូវ ទប់ឈាម ផ្សេះស្បូន។
+ **គំរិតប្រើប្រាស់** ៖ ស្ងួត៦ទៅ១២ក្រាម ដាំផឹក។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជា ភាគ៣

**រៀបរៀងដោយនិស្សិត ៖ លី ដារ៉ា**



## ដើមកណ្ដោលធំ

Nom Scientifique : ***Careya arborea Roxb***

Famille : **LECYTHIDACEAE**

# ដើមកណ្ដោលធំ

Nom Scientifique : *Careya arborea Roxb*

Famille : **LECYTHIDACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើមធ្យម មានកំពស់ ១០-២០ ម
  - **ស្លឹក** ៖ ដុះឆ្លាស់ទង រាងពងក្រពើ គល់ក្រាស់ ស្និត ប្រវែងពី ១២-២០ ស.ម និង ទទឹងពី ៦-១២ ស.ម
  - **ផ្កា** ៖ ផ្កាអត់មានទង ត្របកផ្កាមានពណ៌បៃតង លាយពណ៌ផ្កាឈូកតិចៗ កេសរវែងៗ ច្រើនសរសៃមានពណ៌ស និង គល់កេសរពណ៌ក្រហម។
  - **ផ្លែ** ៖ ផ្លែមូលមានរោមតិចៗ
+ **កន្លែងដាំដុះ** ៖ ជួបប្រទៈឃើញនៅតាមតំបន់ខ្ពង់រាប ។
+ **សមាសធាតុគីមី** ៖ នៅក្នុងសំបកឈើមានក្រុម piperin ដូចជា 1-[5-(1,3-benzodioxol-5-yl)-1-oxo-2,4-pentadienyl] piperidine,
+ **ផ្នែកប្រើប្រាស់** ៖ សំបកដើម ផ្កា គ្រាប់ ផ្លែ និង ស្លឹក
+ **ការប្រើប្រាស់** ៖ ស្លឹក: ផ្សះដំបៅ ផ្សះរបួស,
  សំបកដើម: ព្យាបាលពស់ចឹក ផ្សះដំបៅ ប្លោះគ្រច រសេះរសោះ ធ្លាក់ស ផ្សះទូទៅ
  សំបកឈើ: antioxidant, activite dela hepato protection, antitumoraux
  ផ្កា: ជាថ្នាំសំរាប់ស្ត្រីឆ្លងទន្លេហើយ ផ្កាសាយ ក្អក, គ្រាប់: ព្យាបាលពិស,
  ផ្លែ: ជួយរំលាយអាហារ
+ **កំរិតប្រើប្រាស់** ៖ ៩-១២ ក្រាម ក្នុងមួយថ្ងៃ ដាំផឹក
+ **ឯកសារយោង** ៖ http://www.worldagroforestry.org/Sea/Products/AFDbases/AF/asp/SpeciesInfo.asp?SpID=18147
  http://www.ijrap.net/admin/php/uploads/297_pdf.pdf
  កំរងរុក្ខជាតិឱសថស្តីពីការចុះអង្កេតស្រាវជ្រាវក្នុងខេត្តមណ្ឌលគីរី ជំនាន់ទី៣១

**រៀបរៀងដោយនិស្សិត ៖ ធី ទិទ្ធិកា**







# ដើមរាជដាស

Nom Scientifique : *Melastoma Malabathricum*

Famille : **MELASTOMACEAE**

# ដើមរាជដាស

Nom Scientifique : ***Melastoma Malabathricum***

Famille : **MELASTOMACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាចល្លព្រឹក្សតូច ដែលមានកំពស់ជាមធ្យមពី 1 ទៅ 1.5 ម៉ែត្រ ទងរបស់វាមានពណ៌ក្រហមស្រគាំ ហើយស្លឹកមានរោមច្រើន ដើមមានរាងជាពងក្រពើទ្រវែង ដុះឆ្លាស់គ្នា
  - **ស្លឹក** ៖ ស្លឹកវាមានរាងវែងរាវឡើង មានទ្រនុង 3 ផ្សេងគ្នា និងមានរោមជាច្រើននៅតាមបណ្តោយនៃទ្រនុងដែលនៅបាតស្លឹក
  - **ផ្កាផ្លែ** ៖ ផ្កាមានអង្កត់ផ្ចិតជាមធ្យម 7 cm និងដុះជាលក្ខណៈផ្តុំគ្នា ផ្កានីមួយៗមាន 5 ស្រទាប់មានពណ៌ផ្កាត្របែកព្រៃចាស់ ផ្លែវាជាប្រភេទ berries មានរសជាតិផ្អែម
+ **កន្លែងដាំដុះ** ៖ មានពាសពេញពិភពលោក ដែលដុះភាគច្រើនបំផុតនៅតាមតំបន់ត្រូពិច នឹងតំបន់ដែលមានសំណើមខ្លាំង
+ **សមាសធាតុគីមី** ៖ Flavonoids, Flavan-3-ols, Triterpenes, Tannins, Anthocyanins, Saponisns, Alkaloids, Steroids
+ **ផ្នែកប្រើប្រាស់** ៖ យើងអាចយកមកប្រើបាននៅផ្នែក ស្លឹក ឬស នឹង ផ្កា
+ **ការប្រើប្រាស់** ៖ ព្យាបាលតាមបែបបុរាណ៖ ព្យាបាលជំងឺរាគ រាគមួល ឬសដូងបាត សំរាប់បិទលើរបួសនៅលើស្បែក រីដំបៅ បំបាត់ការឈឺធ្មេញ នឹងឈឺពោះជាដើម។ ព្យាបាលតាមបែបវិទ្យាសាស្ត្រ៖ ប្រើប្រាស់ចំពោះការព្យាបាលដូចជា៖
  + Anti-nociceptive, Anti-inflammation, Wound healing, Anti-Oxydant achtivité
+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់សំរាប់ Activités Antibactériennes (3 – 6 mg/ml), Antiviral (1000 µg/ml)
+ **ឯកសារយោង** ៖ http://www.proseanet.org/
http://dspace.fsktm.um.edu.my/handle/1812/600

**រៀបរៀងដោយនិស្សិត ៖ គីម ដានី**







# វល្លិ៍ក្តួចពុល

Nom Scientifique : ***Dioscorea Hispida Dennst***

Famille : **DIOSCOREACEAE**

# វល្លិ៍ក្តួចពុល

Nom Scientifique *:* ***Dioscorea Hispida Dennst***

Famille : **DIOSCOREACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទវល្លិ៍តោងឡើង ដើមមានបន្លា មានមើមធំៗ និងស្លឹកមានទងដុះឆ្លាសគ្នា ក្នុងទងស្លឹកនីមួយៗ មានស្លឹកដុះដាច់ពីគ្នាចំនួនបី ដែលមានរាងពងក្រពើ ទ្រវែង ទំហំ 6 – 15 cm ប្រវែង 8 – 25 cm ។
  - **ស្លឹក** ៖ រួមមាន ៣ កូនស្លែក ដុះដាច់ពីគ្នាដែលមានរាងពងក្រពើ
  - **ផ្កា** ៖ ជាចង្កោម គួរវែង ប្រវែងរហូតដល់ 40 cm ផ្កាតូចៗ មានពណ៌លឿង
  - **ផ្លែ** ៖ ស្ងួតមានស្លាប 3 គ្រាប់មានប្រវែង 10 cm ទទឹង 6 mm
+ **កន្លែងដាំដុះ** ៖ គេឃើញមានដុះក្នុងព្រៃ
+ **សមាសធាតុគីមី** ៖ Tanin, alcaloides
+ **ផ្នែកប្រើប្រាស់** ៖ មើម, ស្លឹក, វល្លិ៍
+ **ការប្រើប្រាស់** ៖ - ការឈឺពោះ និងចុកក្នុងពោះ- បញ្ចុះកំដៅ
  - បំពោកលើដំបៅរបូស, បូស, ដើម្បីបឺតខ្ទុះចេញ
  - បំពោកលើកន្លែងសត្វល្អិតទិច រឺខាំដើម្បីបឺតបិសចេញ
+ **គំរិតប្រើប្រាស់** ៖ ប្រើដោយប្រុងប្រយត្ន័បមផុត ជាធម្មតា 100 mg ស្ងួន្យជាគ្រាប់ប្រហែលប៉ុន សណ្តែកបាយ
+ **ឯកសារយោង** ៖ - សៀវភៅរុក្ខជាតិឱសថកម្ពុជា ភាគ 3 ទំពរ័ 8
  - កំរងរុក្ខជាតិឱសថស ស្តីពីការចុះអង្កេតស្រាវជ្រាវ ក្នុងខេត្តមណ្ឌលគីរី និង ក្នុងខេត្តព្រះសីហនុ ។

**រៀបរៀងដោយនិស្សិត ៖ សុខ ផល្លី**







# ក្រពុលបាយ,កំពុលបាយ

Nom Scientifique : ***Litsea glutinosa***

Famille : **LAURACEAE**

# ក្រពុលបាយ,កំពុលបាយ

Nom Scientifique : *Litsea glutinosa*

Famille : **LAURACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើមធ្យមមានកំពស់ពី ៦ ដល់ ១៥ ម៉ែត្រ សំបកដើមមានជាតិរំអិល។
  - **ស្លឹក** ៖ ស្លឹកទោល ដុះឆ្លាស់ទង រាងជាស៊ុត មានប្រវែងពី ១០–២០សម ទទឹង ៥–៩សម
  - **ផ្កាផ្លែ** ៖ -កញ្ចុំផ្កាចេញតាមប្រគាបស្លឹក ជាដង្កោមផត្រ ផ្កាតូចៗពណ៌លឿងភាវ។
  -ជាផ្លែសាច់ រាងមូល ពេលខ្ចីពណ៌បៃតងចាស់ ពេលទុំពណ៌ចខ្មៅ។
+ **កន្លែងដាំដុះ** ៖ ដុះនៅព្រៃរបោះ វាលទំនាប ពាសពេញកម្ពុជា។
+ **សមាសធាតុគីមី** ៖ មាន Alcaloide ដែលគេមិនស្គាល់។ មានប្រេងក្រអូបម្យ៉ាង និង Arabinoxylon
+ **ផ្នែកប្រើប្រាស់** ៖ ស្លឹក សំបក។
+ **ការប្រើប្រាស់** ៖ - សំបកដើមបុកព្យាបាល បូស (បុកបិទលើបូស) ជួយឃាត់ឈាម។
  - ស្លឹកអាចប្រើទាំងនៅស្រស់ៗ។
  -ដើមក្រពុលបាយបាននាំមកនូវជាតិសកម្មប្រឆាំងមេរោគ ។
  -ឬស ព្យាបាលរាគ និង រលាកពោះវៀន។
  -សំបក ព្យាបាលបូស រលាកដោះ រើម (ប្រើខាងក្រៅ) ព្យាបាលមូល រមាស់ ឈឺចាប់ក្នុងស្បូន ចុកសាច់ដុំ ស្ពឹក–ខ្វិនឈឺក្នុងឆ្អឹង(ដាំផឹក)។
+ **កំរិតប្រើប្រាស់** ៖ ស្ងួត ១៥-២០ក្រាម ដាំផឹក។
+ **ឯកសារយោង** ៖ http://www.cactuspedia.info/schede/EUPHORBIA/Euphorbia_lactea/Euphorbia_lactea/Euphorbia_lactea.htm
http://www.aujardin.org/euphorbia-lactea-t48415.html

**រៀបរៀងដោយនិស្សិត ៖ សួន សំអែល**







# ដើមត្រាយ

Nom Scientifique : ***XYLOPIA***

Famille : **ANNONACEAE**

# ដើមក្រាយ

Nom Scientifique : ***XYLOPIA***

Famille : **ANNONACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាដើមឈើមានកំពស់ ១០-២០ម៉ែត មានសម្បកពណ៌ត្នោតស្រគាំ។

- **ស្លឹក** ៖ ទោលរាងពងក្រពើ ដុះសងខាងមែក មានទទឹង ៣-៥ ស.ម បណ្ដោយ ៩-១០ ស.ម ផ្ទៃស្លឹកមានរោមទន់ខ្លីៗទាំងសងខាង និងមានទ្រនុងស្លឹកពី ៧-១២ គូ ចុងស្លឹករាងស្រួចគល់ ស្លឹកមូល រឺឆកតិចៗ ទងស្លឹកប្រវែង ០.៥-១ ស.ម។

- **ផ្កាផ្លែ** ៖ ផ្កាទោលរឺចេញចង្កោម២-៣ផ្កាស្ថិតនៅតាមប្រកៀបស្លឹកជិតចុងមែក មានត្របកផ្កាពណ៌លឿងខ្ចី២ជាន់ដោយ១ជាន់មាន៣ត្របក។ត្របកនីមួយៗមានរាងរាវ ទទឹង០.៥-០.៨ ស.ម ប្រវែង២ស.ម ហើយនៅផ្ទៃខាងក្រៅត្របកមានរោមពណ៌ លឿងត្របដណ្ដប់ក្រាស់។ ផ្លែចេញជាក្រុម មានរាងជាបំពង់ ទទឹងប្រហែល ១ស.ម ប្រវែង ៣-៤ស.ម។ ផ្លែទុំមាពណ៌លឿងទឹកក្រូចនិងមាន គ្រាប់ ២-៣ ដែលគ្រាប់ មានសាច់រុំពណ៌ក្រហមហើយផ្លែទុំនោះវាប្រះ បែក តាមខ្សែថ្នេរមួយ។

+ **កន្លែងដាំដុះ** ៖ ដាំនៅដុះតាមព្រៃស្រោងក្រាស់នៅប្រទេសកម្ពុជា ថៃ និងវៀតណាម។

+ **សមាសធាតុគីមី** ៖ Xylopyranose, Xylopyranoyl, Xylose, Xylose, Xylosides, Xylosyl-taxol, Xylopyranosylaucubin

+ **ផ្នែកប្រើប្រាស់** ៖ ដើម សំបក និងឫស។

+ **ការប្រើប្រាស់** ៖ គ្រុនចាញ់ឫសដូងបាតក្រោយសម្រាលកូនទាស់ និង ស្រុតស្បូន។

+ **កំរិតប្រើប្រាស់** ៖ ដើមដាំទឹកហូប ២០-៣០ក្រាមក្នុងមួយថ្ងៃ សំបក និងឫសដាំទឹកផឹក២០ក្រាមក្នុងមួយថ្ងៃ។

+ **ឯកសារយោង** ៖ http://es.wikipedia.org/wiki/Xylopia
សៀវភៅកម្រងរុក្ខជាតិឱសថ ២០១០-២០១១

**រៀបរៀងដោយនិស្សិត ៖ សេខ លីដា**









# ក្រឡាញ់

Nom Scientifique: ***Dialium cochinchinense*** **Pierre**

Famille : **FABACEAE**

# ក្រខ្សាញ់

Nom Scientifique : ***Dialium cochinchinense Pierre***

Famille : **FABACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទដើមឈើធំមានកំពស់ពី15-25ម ដើមដុះត្រង់ មាំ មែកតូចៗធ្លាក់សំយ៉ាបចុះក្រោម សំបកដើមពណ៌សប្រផេះ
    - **ស្លឹក** ៖ ដូចរោមស្លាបបក្សីមានពី 5-9 សន្លឹក ពណ៌បៃតងចាស់រាងពងក្រពើស្រួចចុង
    - **ផ្កា** ៖ នៅចុងមែកដុះជាចង្កោម ស ប្រវែង30សម រីវែងជាង ហើយផ្កាមានពណ៌សតូចៗច្រើន។
    - **ផ្លែ** ៖ ផ្លែវាមូលប្រវែង 15សម ទទឹង 8-9មម មានរោមទន់ដូចកាំញី ពណ៌ខ្មៅនៅពេលទុំ គ្រាប់វាសំប៉ែតពណ៌កាហ្វេ សាច់ផ្លែមានរសជាតិផ្អែមលាយចត់
+ **កន្លែងដាំដុះ** ៖ ដុះនៅកន្លែងដីសើម ជំរាលភ្នំ ជើងភ្នំ
+ **សមាសធាតុគីមី** ៖ មិនទាន់ស្រាវជ្រាវ
+ **ផ្នែកប្រើប្រាស់** ៖ សំបក
+ **ការប្រើប្រាស់** ៖ ព្យាបាលជំងឺ រាគ និងឬសដូងរិល
+ **កំរិតប្រើប្រាស់** ៖ សំបកស្ងួតប្រើពី10-15ក្រាម ក្នុងមួយថ្ងៃ ដាំផឹក
+ **ឯកសារយោង** ៖ កំរងរុក្ខជាតិឱសថក្នុងការចុះអង្កេតស្រាវជ្រាវនៅខេត្តព្រះសីហនុ

**រៀបរៀងដោយនិស្សិត ៖ ពុធ សុខហេង**







# ដើមក្រទក់

Nom Scientifique : ***Triumfetta bartramia L.***

Famille : **TILIACEAE**

# ដើមក្រចក់

Nom Scientifique : *Triumfetta bartramia L.*

Famille : **TILIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាស្មៅដើមរឹង រឺ ចុល្លព្រឹក្សតូចមានកម្ពស់១ m ហើយជារុក្ខជាតិដុះ១ឆ្នាំ ( annuelles)។

- **ស្លឹក** ៖ មានរោមគគ្រាត តែមស្លឹកមានធ្មេញរណា ហើយចែកជា៣ក្លែប ។

- **ផ្កាផ្លែ** ៖ - ផ្កាតូចៗពណ៌លឿងចេញតាមប្រគាបស្លឹក ហើយមានផ្កា២ ទៅ ៣ផ្កាក្នុង ប្រគាបមួយ ផ្កាមាន ៥ត្របក ត្របកផ្ការាងដូចស្លាបកង្ហា ។ ចេញផ្កានៅខែកញ្ញា និង ខែតុលា ។
- ផ្លែជាចង្កោមតូចៗមានរោមបន្លាៗ ហើយផ្លែនៅខែវិច្ឆិកា និងខែធ្នូ ។

+ **កន្លែងដាំដុះ** ៖ នៅកន្លែងដីទំនេរ ដីដុះស្មៅ និងព្រៃរបោះដែលមានពន្លឺគ្រប់គ្រាន់ ។

+**សមាសធាតុគីមី** ៖ - β-caryophyllène (22,4%)
- Kessane(14%) et Oxyde de Caryophyllène (13%)

+ **ផ្នែកប្រើប្រាស់** ៖ ប្រើឬស រុក្ខជាតិទាំងមូល

+ **ការប្រើប្រាស់** ៖ ដកឬសយកមកលាងទឹករួចហើយហាន់ជាចំណិតស្តើងៗហាលថ្ងៃឲ្យ ស្ងួតទុកប្រើ។គេប្រើប្រាស់ ជាធាតុត្រជាក់ បញ្ចុះទឹកនោម រំលាយគ្រួស បញ្ចុះកម្តៅរាគមូល ប្រមេះទឹកបាយ និងបំបាត់ផ្កាសាយ។ មិនតែប៉ុណ្ណោះជាតិអន្ទិលរបស់ផ្លែជួយឲ្យសម្រាលកូនស្រួល ហើយកបនិងជំងឺគ្រួសតាមផ្លូវនោម ផ្កាសាយ និងគ្រុនក្តៅ ។

+**កម្រិតប្រើប្រាស់** ៖ ប្រើប្រាស់ពី ៣០ ទៅ ៦០ក្រាម យកទៅដាំទឹកហូប

+ **ឯកសារយោង** ៖
- CHINESE MEDICINAL HERBS OF HONG KOHG
- COMPENDIUM OF MEDICINAL PLANTS USED IN MALAYSIA

**រៀបរៀងដោយនិស្សិត ៖ លី មុនីនាថ**







# គ្រវ៉ាន់ចត,ពុកមាត់ឆ្មា

Nom Scientifique : ***Acalypha indica L.***

Famille : **EUPHORBIACEAE**

# ក្រវ៉ាន់ចត,ពុកមាត់ឆ្មា

Nom Scientifique : *Acalypha indica L.*

Famille : **EUPHORBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ រុក្ខជាតិមានកំពស់ពី ៥០-១០០ Cm ដើមត្រង់បែកមែកច្រើន។

- **ស្លឹក** ៖ ស្លឹកទោលទន់រាងស្ទើរមូល ស្រួចចុងបន្តិច គែមស្លឹកមានធ្មេញរណារតូចៗ ទងស្លឹកវែង ដុះចេញពីដើមទំហំស្លឹកបណ្តោយ ៣,៥-៥ Cm ទទឹង២,៥-៤ Cm។

- **ផ្កាផ្លែ** ៖ ដុះចេញពីដើម និងចេញពីគ្រប់ប្រគាបទងស្លឹក មានទងវែង និងសន្លឹកតូចមួយនៅប្រគាបទង ផ្កាបន្តបន្ទាប់រាងជាស្លឹកតូចៗ តាមបណ្តោយទងផ្កា។

+ **កន្លែងដាំដុះ** ៖ ដាំតាមភូមិ, ដីចំការ, ដីសើម ដីវាលទំនេរ។

+ **សមាសធាតុគីមី** ៖ ដើមមាន Acalyphine,glucosid,cyanogenetic,triacetonamine,HCN, ព្រមទាំងមានជាតិគីមីពុលខ្លាំងម្យ៉ាងដែលគេមិនទាន់រកឃើញ។

+ **ផ្នែកប្រើប្រាស់** ៖ គេប្រើរុក្ខជាតិទាំងមូល។

+ **ការប្រើប្រាស់** ៖ ជាថ្នាំរំលាយស្លេស្ម៍, បំបាត់ក្អក, ហាត់, ផ្សះ, បន្ទន់លាមក, រលាកទងសួត , រលាកសួត។

+ **កំរិតប្រើប្រាស់** ៖ ប្រើក្នុងកំរិត ១៥-៣០ក្រាម ដាំផឹក។ ប្រើខាងក្រៅ សំរាប់ព្យាលរមាស់ និងពស់ចឹក ដោយយកស្លឹកស្រស់បុកបិតពីលើមុខពស់ចឹក។

+ **ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជា ឆ្នាំ ២០០៦

**រៀបរៀងដោយនិស្សិត ៖ ស្រ៊ុន សុភា**







# ក្រូចព្រៃ

Nom Scientifique : *Atalantia monophylla DC*

Famille : **RUTACEAE**

# គ្រួចព្រៃ

Nom Scientifique : ***Atalantia monophylla DC***

Famille : **RATACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិឈើមធ្យម អាចមានកំពស់ដល់ទៅ ១២ម ។
  - **ស្លឹក** ៖ មានរាងពងក្រពើ ទ្រវែង, ក្រាស់, ស្វិត, រលោង, (មានក្លិនដដូចក្រូច) មានប្រវែងពី ៤ - ៩ ស.ម ទទឹងពី ៤ - ៩ ស.ម បន្លាចេញពីប្រគាបស្លឹក ។
  - **ផ្កា** ៖ ពណ៌សជាចង្កោម ដុះចេញពីប្រគាបស្លឹក ។
  - **ផ្លែ** ៖ មានរាងមូល តូចជាងក្រូចឆ្មា ទំហំ ១៥ ម.ម ។
+ **កន្លែងដាំដុះ** ៖ ដុះខ្លួនឯង តាមខ្ពង់រាប និងតាមជ្រលងភ្នំ ព្រៃរបោះ ។
+ **សមាសធាតុគីមី** ៖ ស្លឹកស្រស់ មានជាតិប្រេងពី ០,៤ - ០,៦%, សំបកផ្លែមានជាតិប្រេងដែរ ។
+ **ផ្នែកប្រើប្រាស់** ៖ ស្លឹក, ឬស, និង ជាតិប្រេង ៕
+ **ការប្រើប្រាស់** ៖ គេប្រើជាតិប្រេងរបស់សំបកផ្លែ ជាថ្នាំរឹតឈើឆ្អឹង
  ស្លឹកព្យាបាលពស់ចឹក
  រឹសមានជាតិផ្សះ, គ្រុនញាក់ ៣០ ក្រាម ដាំទឹកផឹក មុនញាក់ ៤ ម៉ោង
  ដើមដុតយកធ្យូងធ្វើថ្នាំក្រពះ
+ **កំរិតប្រើប្រាស់** ៖ ១០ - ៣០ ក្រាម ដាំទឹកផឹកក្នុងមួយថ្ងៃ
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជា ភាគ១

**រៀបរៀងដោយនិស្សិត ៖ នួន សូឡី**







# ដើមកាំរន្ទះ រឺ ឈាមអន្ទង់

Nom Scientifique : ***Ixora Chinensis LAM***

Famille : **RUBIACEAE**

# ដើមកាំរន្ធះ រឺ ឈាមអន្ទង់

Nom Scientifique : ***Ixora Chinensis LAM***

Famille : **RUBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ចុល្លព្រឹក កំពស់ ០,៥០ ទៅ ២ម៉ែត្រ ។
  - **ស្លឹក** ៖ ទោលដុះទល់ទង គែមស្លឹកពេញ រាងជាផ្លែលំពែង ស្រួចចុង រៀវគល់ ក្រាស់រលោងផ្ទៃខាង ក្រោមពណ៌បៃតងស្លេក ផ្ទៃខាងលើពណ៌បៃតង បណ្ដោយមានទំហំ៨,១២ សង់ទីម៉ែត្រ និងទទឹងមានទំហំ ៣,៥ សង់ទីម៉ែត្រ ទងស្លឹកខ្លី។
  - **ផ្កា** ៖ ផ្ការាងជាកញ្ចុំ មានផ្កានៅខាងចុងមែក ជាកញ្ចុំរួមទង មានការផ្កាពណ៌លឿងៗ ខ្លះលាយជាមួយ ។
  - **ផ្លែ** ៖ ផ្លែ ជាប្រភេទផ្លែសាច់ ជាចង្កោមនៅខាងចុងមែក ទងផ្លែខ្លី រាងមូល រាងព្រែក ។ ពេលទុំក្រហមក្រមៅ ទំហំពី ៧-៨ មម ។
+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯងលើដីល្បាយខ្សាច់ តំបន់ខ្ពង់រាប និងតំបន់ភ្នំ និងគេយកមកដាំលំអ ។ បន្តពូជដោយគ្រាប់ ។
+ **សមាសធាតុគីមី** ៖ ឫសមានជាតិ IXOSIDE ,(1.8 Dehydroxforsythide) និង Acide Organice ផ្សេងទៀត ។
+ **ផ្នែកប្រើប្រាស់** ៖ ផ្កា ស្លឹក មែក ដើម និងឫស ។
+ **ការប្រើប្រាស់** ៖ ផ្កាឃាត់ឈាម ព្យាបាលរបេង ក្អកធ្លាក់ឈាម រាំងរដូវ ឡើងឈាម ។ ឫស ព្យាបាលរបេង ក្អកមានឈាម។ មែក និងស្លឹក ព្យាបាលឆ្អឹងខ្នង ស្ត្រីឆ្លងទន្លេហើយ។
+ **កំរិតប្រើប្រាស់** ៖ ផ្កាដាំទឹកផឹក ក្នុង ១ថ្ងៃ ពី១០-១៥ ក្រាម។ ឫស ដាំទឹកផឹក ក្នុង ១ថ្ងៃ ពី៣០-៥០ ក្រាម ។ មែក និងស្លឹក ក្នុង ១ថ្ងៃ ពី៣០-៥០ ក្រាម ។

+ **ឯកសារយោង** ៖ <u>សៀវភៅ</u>រុក្ខជាតិឱសថកម្ពុជា <u>មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ។</u>

**រៀបរៀងដោយនិស្សិត ៖ ឈឹម ស្រីមរកត**







## កាំរន្ទះធំ - ឈាមអន្ទង់ - អៈសោក - ជាយស្បៃ

Nom Scientifique : ***Saraca declinata(Jack)Miq.***

*Famille :* ***FABACEAE***

# អាំរន្ធះធំ - ឈាមអន្ធច់ - អះសោក - ជាយស្បៃ

Nom Scientifique : ***Saraca declinata(Jack)Miq.***

*Famille :* ***FABACEAE***

+ **លក្ខណៈរុក្ខជាតិ** ៖ ដើមឈើតូចមានកំពស់ពី៥ទៅ១០ម៉ែត្រ
  - **ស្លឹក** ៖ ស្លឹករួមស្លាបគូ មានពី៣ទៅ៧គូកូនស្លឹកមានរាងស៊ុតឬលំពែង មានទទឹងប្រវែង២ទៅ៨ស.មបណ្ដោយ១២ទៅ២៥ស.ម ស្លឹកខ្ចីពណ៌លឿងភាវស្លឹកចាស់ពណ៌បៃតង
  - **ផ្កាផ្លែ** ៖ ផ្កាះ ផ្កាតូចៗមានពណ៌លឿងទឹកក្រូច។ត្របកផ្កាមានរាងស៊ុត មាន៥ត្របក។ គល់ផ្ការាងជាបំពងចេញជាចង្កោមតូចៗ មានកេសរជាសរសៃលឿងក្លិនក្រអូប។ ផ្លែះ ជាកូរសំប៉ែតវែង។
+ **កន្លែងដាំដុះ** ៖ ដុះតាមជាយព្រៃ តាមបណ្ដោយមាត់ទឹក។ បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ។
+ **ផ្នែកប្រើប្រាស់** ៖ ផ្កា ស្លឹក សំបក។
+ **ការប្រើប្រាស់** ៖ -ស្លឹកះត្រូយហូបជាបន្លែ ឬ ជាថ្នាំបញ្ចុះកំដៅ។
  -សំបកះគ្រុនក្ដៅ រាក។
  -ផ្កាះព្យាបាលក្អកទំលាក់ស្លេស្មលើកកំលាំង។
+ **កំរិតប្រើប្រាស់** ៖ សំបក ១០ទៅ២០ក្រាម។
+ **ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជាភាគ៣។
  http://www.suansavarose.com/index.php?mo=3&art=169147
  http://ayurvedicmedicinalplants.com/plants/294.html

**រៀបរៀងដោយនិស្សិត ៖ សឿម វណ្ណសក្តិ**









## ខាន់ម៉ា , ធនម៉ា , ឃុនម៉ា

Nom Scientifique : ***Ancistrocladus tectorius(Lour) Merr.***

Famille : **ANCISTOCLADACEAE**

# ខាន់ម៉ា , ធនម៉ា , ឃុនម៉ា

Nom Scientifique : *Ancistrocladus tectorius(Lour) Merr.*

Famille : **ANCISTOCLADACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទវល្លិ៍វារតោងឡើង
  - **ស្លឹក** ៖ ស្លឹកឥតមានរោម រលោងវែង ច្រើនប្រមូលនៅផ្នែកខាងចុងវល្លិ៍ ដែលមានបណ្តោយប្រវែងពី ១០-៣០ សម ទទឹងប្រវែងពី ១-២សម
    ត្រួយខ្ចីពណ៌លឿងស្វាយ
    ស្លឹកអាចក្រេងប្រក់ដំបូលខ្ទម ដុតមិនឆេះ
  - **ផ្កា ផ្លែ** ៖ ផ្កាដុះជាកញ្ចុំឥតមានទង ពណ៌ក្រហមចែកជាពីរផ្កា មួយមានប្រាំស្រទាប់ និង ១០ កេសរ ផ្លែមាន ៥ ស្រទាប់ទទឹង ១សម ពណ៌ក្រហម
+ **កន្លែងដាំដុះ** ៖ ច្រើនដុះដោយខ្លួនឯងនៅក្នុងព្រៃស្រោង
+ **សមាសធាតុគីមី** ៖ ក្នុងស្លឹកមាន ជាតិប្រេង Ocimen ៣៥ភាគរយ និងមានជាតិក្រអូប ។
+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល និង ឫស
+ **ការប្រើប្រាស់** ៖ ព្យាលបាលឈឺឆ្អឹងខ្នងស្អីក និងធ្វើអោយស្ត្រីក្រោយឆ្លងទន្លេ ឆាប់មានកំលាំង រឺ ប្រើព្យាបាលជំងឺគ្រុនចាញ់រាគមូល
+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី ៨-១៦ក្រាម ដាំទឹកផឹក រឺ ត្រាំស្រា
+ **ឯកសារយោង** ៖ ស្រង់ពីសៀវភៅរុក្ខជាតិឱសថកម្ពុជា(ភាគ៥)
  ក្រសួងសុខាភិបាលមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណឆ្នាំ២០១០
  www.google.com/ancistrocladus tectorius

**រៀបរៀងដោយនិស្សិត ៖ និល ច័ន្ទធារត្ន**







**ខ្យូស - ខ្ជូស - ខ្ជួស**

Nom Scientifique : ***Calycopteris floribunda Lamk***

Famille : **COMBRETACEAE**

# ខ្យស - ខ្វស - ខ្វស

Nom Scientifique : *Calycopteris floribunda Lamk*

Famille : **COMBRETACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទវល្លិ៍ ដុះជាគុម្ព មែកខ្ចីមានរោម មានកំពស់ពី ២-៤ម៉ែត្រ។

- **ស្លឹក** ៖ ពណ៌បៃតង រាងពងក្រពើស្រួចចុង ដុះទល់ទងគ្នាប្រវែងពី៥-១២ស.ម ទទឹង ៣ -៥ស.ម ស្លឹកវាស្វិតរាងក្រាស់ (ស្រដៀងស្លឹកសង្កែ) ស្លឹកខ្ចីមានរោមទន់ ទាំងសងខាងស្លឹកមានប្រវែងពី៥-១០មម ហើយមានរោមទន់។

- **ផ្កាផ្លែ** ៖ ផ្កា៖ ដុះជាចង្កោម មានផ្កាច្រើន ដុះចេញពីចុងមែក ឬ ប្រគាបស្លឹកជិតចុងមែក។ គួរផ្កាមានប្រវែង ២០សម។
ផ្លែ៖ មានរាងពងក្រពើ មានរោម និងមានគ្រាប់១គ្រាប់ រយៈផ្កា ៣ខែ ផ្លែ៤ខែ។

+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯង តាមចិញ្ចើមផ្លូវថ្នល់ ឬតាមដំបូក។

+ **សមាសធាតុគីមី** ៖ ស្លឹកជាតិ Talin 7% និង 0,20-0,25% ជាតិ Calycopterin។

+ **ផ្នែកប្រើប្រាស់** ៖ ដើម ស្លឹក ឬស ប្រមូលផលបានរាល់រដូវ។

+ **ការប្រើប្រាស់** ៖ -ដើម - ស្លឹក៖ ធ្វើជាថ្នាំប៉ូវ និងសំអាតឈាម ធ្វើជាតែ អោយស្ត្រីផឹក ក្រោយសំរាលកូន អោយបាន ១៥ថ្ងៃ។
-ឫស៖ ព្យាបាលពស់ចឹក បន្ធូរការឈឺចាប់ក្នុងពោះ ចុកសៀត រាគ គ្រុនចាញ់ លាបដំបៅក្លាយ បាយបាន ទំលាក់ព្រូន។

+ **កំរិតប្រើប្រាស់** ៖ ពី៣០-៥០ក្រាម ក្នុងមួយថ្ងៃ (ដើម - ឫស)។
ស្លឹក ១៥-៣០ក្រាម ក្នុងមួយថ្ងៃ។

+ **ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជាភាគ១ បោះពុម្ពឆ្នាំ ២០០៨។
http://www.suansavarose.com/index.php?mo=3&art=169147
http://ayurvedicmedicinalplants.com/plants/294.html

**រៀបរៀងដោយនិស្សិត ៖ សុខ សោភា**









## ខ្យូសរមៀត វល្លិ៍

Nom Scientifique : ***Combretum latifolium Blume***

Famille : **COMBRETACEAE**

# ខ្យូសរមៀត ទល្លី

Nom Scientifique : ***Combretum latifolium Blume***

Famille : **COMBRETACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាវល្លិ៍ឈើដើមរាងមូល ពណ៌ប្រផេះស ប្រវែងពី១០-១៥ម ។

- **ស្លឹ** ៖ ទោល ដុះទល់ទង រាងជាស៊ុតប៉ិចចុងមានប្រវែងពី៩-១៥ស.ម ទទឹងពី៦-៨ស.ម ។

- **ផ្កា** ៖ កញ្ចុំផ្កាចេញនៅប្រគាបស្លឹក រីចុងមែកប្រវែង ពី៦-៧ស.ម។ ផ្កាតូចៗ ពណ៌លឿងភាវមានកល្លិនក្រអូប ។

- **ផ្លែ** ៖ ផ្លែរាងជាស៊ុត ឬមូលមានបន្ទះស្លាប៤ មានគ្រាប់តែ១ ផ្លែក្រខ្ចីមានពណ៌ហាមភាវ ។

+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯងស្ទើរគ្រប់តំបន់ ។ បន្តពូជដោយគ្រាប់ ។

+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ ។

+ **ផ្នែកប្រើប្រាស់** ៖ ផ្លែ ដើម ស្លឹក ។ជាវល្លិ៍ឈើដើមរាងមូល ពណ៌ប្រផេះស ប្រវែងពី១០-១៥ម ។

+ **ការប្រើប្រាស់** ៖ ផ្លែៈ ប្រើជាថ្នាំប៉ូវ ។
ស្លឹកៈ ឈឺច្រមុះ ទំពារផ្តិពិស បិត បូស រលាកភ្លើង ជំងឺតំរង់នោម ។
ដើម មែកៈ បង្កើនឈាម កូនខ្ចី ហាត់ហាវ ។

+ **កំរិតប្រើប្រាស់** ៖ ១០ក្រាមក្នុង១ថ្ងៃ ។

+ **ឯកសារយោង** ៖ http://www.cactuspedia.info/schede/EUPHORBIA/Euphorbia_lactea/Euphorbia_lactea/Euphorbia_lactea.htm
http://www.aujardin.org/euphorbia-lactea-t48415.html
http://www.mi-aime-a-ou.com/euphorbia_lactea_cristata.php

**រៀបរៀងដោយនិស្សិត ៖ សាម សុផានី**






# ដើមខ្នុរព្រៃ

Nom Scientifique : ***Artocorpus Rigidus Blume***
Famille : **MORACEAE**

# ដើមខ្នុរព្រៃ

Nom Scientifique : ***Artocorpus Rigidus Blume***
Famille : **MORACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាដើមឈើធំ មានកម្ពស់១០-២៥ម៉ែត្រ មែកខ្ចីមានរោមរឹងពណ៌លឿង។
  - **ស្លឹក** ៖ បន្ទះស្លឹករឹង ស្លឹកទោលដុះឆ្លាស់ទង មានខ្នាយស្មបប្រវែងមួយសង់ទីម៉ែត្រ មានរោមពណ៌លឿងៗផ្ទៃខាងក្រោមទ្រនុងស្លឹកលេចចេញច្បាស់
  - **ផ្កា** ៖ ចេញនៅចុងមែក ផ្កាពណ៌លឿងប្រវែង ១-២.៥០ ស.ម
  - **ផ្លែ** ៖ មានទំហំពី៧-១៥ស.ម មានបន្លាវែងៗ គ្រាប់មានទំហំ១-២ស.ម ចេញផ្កាផ្លែពីខែមេសា-មិថុនា។
+ **កន្លែងដាំដុះ** ៖ ដុះក្នុងព្រៃស្រោង តាមជន្លងអូរ តំបន់ភ្នំ បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយទេ។
+ **ផ្នែកប្រើប្រាស់** ៖ ស្លឹក ខ្លឹម ផ្លែ
+ **វិធីប្រើប្រាស់** ៖ ស្ងួតប្រើពី១០-១៥ក្រាម ដាំផឹកក្នុងមួយថ្ងៃ។
+ **ឯកសារយោង** ៖ http://www.cactuspedia.info/schede/ Artocorpus Rigidus Blume/ Moraceae
  http://www.aujardin.org/ Artocorpus Rigidus Blume-t48415.html
  http://www.mi-aime-a-ou.com/Artocorpus Rigidus Blume .php

**រៀបរៀងដោយនិស្សិត ៖ ដួង មាលា**






# ដើមខ្លុង

Nom Scientifique : ***Dipterocarpus tuberculatus***

Famille : **EUPHORBIACEAE**

# ដើមខ្លុង

Nom Scientifique : *Dipterocarpus tuberculatus*

Famille : **EUPHORBIACEAE**

**+លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើធំនិងជាវុក្ខជាតិមានកំពស់ខ្ពស់ពី២០មទៅ៣០ម
សំបកឈើស្តើងមានពណ៌ប្រផេះរាងស។

**- ស្លឹក** ៖ ស្លឹកធំរាងពងក្រពើមានទ្រនុងស្របគ្នា
ស្លឹករាងក្រាស់ដុះស្របគ្នាមានទ្រនុងស្របគ្នានៅស្លឹក១០ទៅ១២ទ្រនុងស្លឹក។

**- ផ្កា** ៖ ផ្កាចាប់ពីខែកុម្ភៈដល់មិនា
ផ្កាតូចៗរាងត្រែតែសតិចៗ

**- ផ្លែ** ៖ ផ្លែនិមួយៗមានស្លាបពីរត្រមែងគល់។

**+ កន្លែងដាំដុះ** ៖ ដុះនៅតំបន់ត្រូពិចដែលមានអាកាសធាតុក្តៅហើយសើម
សំបូរដុះនៅតាមព្រៃទំនាបនិងតាមដីចំនោទរឺដីជំរាល
ខ្លុងធន់នឹងទឹកជំនន់រឺដីសើមខ្លាំងហើយវាកំរដុះនៅតំបន់ថ្មនិងដីស្ងួតណាស់។

**+ សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយទេ។

**+ ផ្នែកប្រើប្រាស់** ៖ សាច់ឈើនិងជ័រនិងស្លឹក។

**+ ការប្រើប្រាស់** ៖ ជ័រដុតយកជ័រទឹកសំរាប់បិទទូករឺធ្វើច្រឡុះ
ព្យាបាលឆ្អឹងបាក់និងឬសដូងបាទនិងរមាស់(ផ្សំជាមួយរុក្ខជាតិផ្សេងទៀត)
សាច់ឈើសំរាប់ផ្ទះនិងគ្រឿងសង្ហារឹមផ្សេង
ស្លឹកកាលពីបុរាណទុកខ្ចប់បាយត្រីសាច់។ព្យាបាលថ្លើម។

**+ គំរិតប្រើប្រាស់** ៖ ពុំមានការចងក្រងច្បាស់លាស់។

**+ ឯកសារយោង** ៖ http://www.digplanet.com/wiki/Dipterocarpus

**រៀបរៀងដោយនិស្សិត ៖ ឌី ធារី**





# ដើមខ្វាវធំ

Nom Scientifique : ***Haldina cordifolia Roxd. Ridsdale***

***Syn : Adina cordifolia Hok. F***

Famille : **RUBIACEAE**

# ដើមខ្វាទធំ

Nom Scientifique : ***Haldina cordifolia Roxd. Ridsdale***

***Syn : Adina cordifolia Hok. F***

Famille : **RUBIACEAE**

\+ **លក្ខណៈរុក្ខជាតិ** ៖ ជាឈើប្រភេទកណ្តាល ដល់ធំ។

\- **ស្លឹក** ៖ ពណ៌បៃតងចាស់ ផ្ទៃខាងលើស្លឹករលោង ផ្ទៃខាងក្រោមស្លឹកពណ៌បៃតងស្លេក និង មានរោម ទន់ ស្លឹកស្និត។

\- **ផ្កាផ្លែ** ៖ ពណ៌លឿង ដុះពី 1-3 ផ្ការាងជាផ្នុក ( ដូចផ្កាក្ទម្ពទេស ) ចេញតាមប្រគាបស្លឹក។

\+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯង នៅតំបន់ព្រៃ, ភាគច្រើនប្រទះឃើញនៅតំបន់ខ្ពង់រាប

\+ **សមាសធាតុគីមី** ៖ សំបកដើមមាន ៧,២៩-៩,២៧% នៃ Tanin និង 0,0៩% នៃ Adinin

\+ **ផ្នែកប្រើប្រាស់** ៖ សំបកដើម និង ឫស

\+ **ការប្រើប្រាស់** ៖ - សំបកដើម : ធ្វើថ្នាំលាងរបួស ព្យាបាលទាស់ក្រោយឆ្លងទន្លេ

- ឫស : ថ្នាំរាគ រាគមូល រោគសើស្បែក
- ត្រួយ : ព្យាបាលឈឺក្បាល
- ស្លឹកស្រស់ : បុកពូតយកទឹក ដាក់ដំបៅសំលាប់មេរោគ

\+ **កំរិតប្រើប្រាស់** ៖ ពី ២០-៣០ក្រាម ទឹក ១លីត្រ និង ទឹក៣យកទឹក១ ក្នុង១ថ្ងៃ។

\+ **ឯកសារយោង** ៖ សៀវភៅ រុក្ខជាតិឱសថកម្ពុជា បោះពុម្ពឆ្នាំ ២០០៨។

**រៀបរៀងដោយនិស្សិត ៖ តាំង សៀលិញ**










## វល្លិខ្លែងពណ៌

Nom Scientifique : ***Bauhinia bassacensis Pierre ex Gagnep***

Famille : **FABACEAE (Leguminosae)**

# វល្លិខ្លែងពណ៌

Nom Scientifique : ***Bauhinia bassacensis Pierre ex Gagnep***
*Synonyme* : ***Bauhinia pulla Graib***
Famille : **FABACEAE (Leguminosae)**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាវល្លិឈើធំវារនឹងដីរុំតោងឡើង
  - **ស្លឹក** ៖ ស្លឹកទោលដុះឆ្លាស់ទងព្រែកផែកដូចក្រចកជើងគោ
  - **ផ្កា** ៖ ពណ៌លឿងភាវជាចង្កោមត្របកផ្កាប្រាំប្រវែង ៣ស/ម ទទឹង៧-៩ស/ម
  - **ផ្លែ** ៖ ចំណែកផ្លែវិញមានរាងសំប៉ែត គល់រៀវរីកចុង ទទឹង៣ស/ម បណ្ដោយ៧-១០ស/ម
+ **កន្លែងដាំដុះ** ៖ ដុះតំបន់ភ្នំ ខ្ពង់រាបដីបូក។ បន្តពូជដោយគ្រាប់
+ **សមាសធាតុគីមី** ៖ មិនទាន់បានស្រាវជ្រាវឃើញនូវឡើយ
+ **ផ្នែកប្រើប្រាស់** ៖ ដើម គ្រាប់ រឹស
+ **ការប្រើប្រាស់** ៖ -ដើមនិងរឹសប្រើប្រាស់ជាថ្នាំក្រពះពោះវៀន រាក រាកមូល បន្សាបពុលអាហារ រោគក្រោយសំរាលកូនផ្សះស្បូន។
  -ហើយនៅខាងវេជ្ជសាស្ត្រ អាចប្រើព្យាបាល diabète,infection,inflammation
+ **កំរិតប្រើប្រាស់** ៖ ២០-៣០ក្រាមដាំទឹកផឹកក្នុងមួយថ្ងៃ
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ១បោះពុម្ពនៅឆ្នាំ១៩៩៦
  -http://cultursheet.org/fabaceae:bauhinia:bassacensis
  -http://www.nchi-n/m-nih-gov/pubmed
  -http://www.wikilibo.com/mages/thumb/d/d9/Bauh…
  -http://toptropicals-com/pics/garden/08/bauhin…

**រៀបរៀងដោយនិស្សិត ៖ មូ តាំងគីម**







# ដើមខ្លែងគង់

Nom Scientifique : ***Wrightia Tomentosa Roem-schult***

Famille : **APOCYNACEAE**

# ដើមខ្លែងគង់

Nom Scientifique *:* ***Wrightia Tomentosa Roem-schult***

*Famille :* ***APOCYNACEAE***

+ **លក្ខណៈរុក្ខជាតិ** ៖ រុក្ខជាតិកំពស់ ១០ - ១៥m មែកមានរោមទន់ ។

- **ស្លឹក** ៖ ដុះទល់ទង រាងពងក្រពើស្រួចចុង មានរោមទន់ច្រើន រឺ តិចនៅផ្នែកខាងលើ ខាងក្រោម ។ ស្លឹកមានរោមពណ៌ស ស្លេកជាងខាងលើ ប្រវែងពី ៦-១៥cm ទទឹងពី ៣-៦cm ។

- **ផ្កាផ្លែ** ៖ ផ្កា : ពណ៌ស ផ្កាឈូក ឬ លឿងបន្តិច ដុះជាចង្កោមនៅចុងមែក ផ្កាបែកចេញជា ៥ ត្របក។

- **ផ្លែ** ផ្លែ : មាន ២ ជាប់គ្នា ពណ៌បៃតងចាស់ មានចង្អូរ ១ ចំកណ្តាលជ្រៅ ប្រវែងពី ១៣-២៨cm ទទឹងពី ១០-១៨mm អាចមានពី ៣-៨cm គ្រាប់ច្រើនមានពណ៌កាហ្វេ ផ្កាពីខែ ៣-៨ ផ្លែពីខែ ៨-២

+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯងនៅដីទួល ព្រៃរបោះតាមភូមិ តាមដំបូក ។

+ **ផ្នែកប្រើប្រាស់** ៖ ប្រើ ដើម ឫស និង ស្លឹក យកប្រើបានគ្រប់រដូវ។

+ **ការប្រើប្រាស់** ៖ នៅប្រទេសចិន ដើម និង ឫស ព្យាបាលពស់មានពិសចឹក ។ នៅឥណ្ឌាសំបកដើម ព្យាបាលឈឺពោះពេលមានរដូវ និងឈឺតំរងរោម ។ នៅថៃ សំបក ដើម ប្រើជាថ្នាំ ជួយរំលាយអាហារ ។សាច់ដើមព្យាបាលឈឺប្រមាត់។ជរព្យាបាលរាកមូល។ ស្លឹកស្រស់ បុកព្យាបាលឫស។

+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ ២ បោះពុម្ពឆ្នាំ ២០០៨
http://www.floracafe.com/Search_PhotoDetails.aspx?Photo=All&Id=2641

**រៀបរៀងដោយនិស្សិត ៖ ទ៉ាន់ សុគន្ធា**







## ដើម គោម្ពួយ ឬ គោម្ពួយសសៃ ១០០

Nom Scientifique : ***Euonymus cochinchinensis Pierre***

Famille : **CELASTRACEAE**

# ដើម គោមួយ ឬ គោមួយសសៃ១០០

Nom Scientifique : ***Euonymus cochinchinensis Pierre***

Famille : **CELASTRACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាដើមឈើតូច មានកំពស់ពី ៨-១០.ម មានមែកច្រើន ។ សំបកដើមមានសសៃសស្វិត នៅពេលដែលគេកាត់ ។
- **ស្លឹក** ៖ ស្លឹកទោលដុះទល់ទងរាងដូចផ្លែលំពែង ឬស៊ុតស្រួចចុង មានបណ្ដោយ ៦-១៧ស.ម ទទឹងមាន ៤-៨ស.ម ។
- **ផ្កា** ៖ រាងជាចង្កោមខ្មែង ចេញពីប្រគាបស្លឹក ឬចុងមែក ។
- **ផ្លែ** ៖ ជាប្រភេទផ្លែស្ងួត មានទទឹង ៩-១២ម.ម កំពស់ ៩-១០ម.ម មាន ៣-៥ក្លែប សំបកផ្លែស្វិត ។
- **គ្រាប់** ៖ មានគ្រាប់វែង មានប្រវែង ៥-៦ម.ម ។

+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯងនៅព្រៃភ្នំ បន្តពូជដោយគ្រាប់ ។
+ **ផ្នែកប្រើប្រាស់** ៖ សំបក ដើម ។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ ។
+ **ការព្យាបាល** ៖ យកសំបកទៅត្រាំស្រា សំរាប់បាយឆ្ងាញ់ ជួយរំលាយអាហារ ឈឺឆ្អឹងឆ្អែង ជំនួយសសៃ ជំនួយក្រពះ លើកកំលាំង ធ្លាក់ស ។
+ **កំរិតប្រើប្រាស់** ៖ - សំបក ១០-១៥ ក្រាម ដាំផឹក ឬ ត្រាំស្រា
- ដើម ១៥-៣០ ក្រាម ដាំផឹក ឬ ត្រាំស្រា ។
+ **ឯកសារយោង** ៖ មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ
www.flickr.com

**រៀបរៀងដោយនិស្សិត ៖ អាន រដ្ឋា**







# ដើម ក្រុខ ឬ ក្រុខធំ

Nom Scientifique : *Aporosa Filicifolia Baill*
*A.sphoerosperma Gagnep*,
Famille : **EUPHORBIACEAE**

# ដើម គ្រុខ ឬ គ្រុខធំ

Nom Scientifique : ***Aporosa Filicifolia Baill***

***A.sphoerosperma Gagnep***

Famille : **EUPHORBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាដើមឈើមធ្យម មានកំពស់ពី ៨ ទៅ ១០ ម មែកខ្ចីមានពណ៌រោមផ្កាយ រោមត្នោត
  - **ស្លឹក** ៖ ស្លឹកទោលដុះឆ្លាស់ទង , រាងពងក្រពើទូលាយ មាន ប្រវែង ៦ទៅ ១០ស.មទទឹង ១០ទៅ១៦ ស.មបណ្តោយ
  - **ផ្កា** ៖ អត់ទងចេញតាមប្រកៀបស្លឹក រឺ តាមកន្លែងដែលស្លឹកជ្រុះ ផ្កាមានភេទតែមួយ
    ផ្កាឈ្មោលមានទំហំធំមានចង្កោមផ្តុំគ្នាជាកួរវែង
    ផ្កាញីមានទំហំតូចចង្កោមផ្តុំគ្នាជាកួរខ្លី
  - **ផ្លែ** ផ្លែស្ងួត រាងដូចស៊ុត គ្រាប់ទុំអាចច្របាច់បែក
+ **កន្លែងដាំដុះ** ៖ ដុះតាមព្រៃរបោះ
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ នៅឡើយ
+ **ផ្នែកប្រើប្រាស់** ៖ ឬស , ដើម , ស្លឹក
+ **ការប្រើប្រាស់** ៖ ជំងឺផ្លូវភេទនិង រាគមូល
+ **កំរិតប្រើប្រាស់** ៖ ១៥ ទៅ ៣០ ក្រាម
+ **ឯកសារយោង** ៖ បញ្ជី រុក្ខជាតិឱសថកម្ពុជា ឆ្នាំ ២០១២

**រៀបរៀងដោយនិស្សិត ៖ ថា ម៉ុនណា**










# គ្រៀលធំ , ទ្រាលធំ

Nom Scientifique : ***Uvaria rufa blume***

Famille : **ANNONACEAE**

# គ្រៀលធំ , ទ្រាលធំ

Nom Scientifique : *Uvaria rufa blume*

Famille : **ANNONACEAE**

**+លក្ខណៈរុក្ខជាតិ** ៖ ដើមឈើវល្លិជាចុល្លព្រឹក្ស ដុះតោងជាមួយដើមដទៃប្រវែង៥ម ជាដើមឈើសាច់រឹង ហើយមែកខ្ចីមានរោមពណ៌ត្នោតគ្របដណ្ដប់។

**- ស្លឹក** ៖ ស្លឹកទោលដុះឆ្លាស់គ្នា ផ្ទៃស្លឹកមានរោម ហើយស្និលស្លុតទូលាយ។ ទទឹងពី៣-៦សមប្រវែង៧-១៥សមហើយចុងស្លឹកស្រួចគល់ស្លឹករាងផែក។

**- ផ្កាផ្លែ** ៖ ផ្កាចេញជាចង្កោម ខ្ចីនៅម្ខាងម្នាក់នៃស្លឹក ហើយពណ៌ក្រហមចាស់។ ពេលរីកមាន៦ត្របក។ រាងជា២ជាន់ ចំនែកជាន់ទី៣ត្របកកាលិករាងជាស៊ុត។
ផ្លែមូលជាចង្កោមរួមទង ផ្លែមានពី៦-៩រាងមូលដូចស៊ុត រឺ រាងដូចត្រុល ហើយពេលទុំពណ៌ក្រហមស្រស់។

**+ កន្លែងដាំដុះ** ៖ ព្រៃមានពន្លឺថ្ងៃ ដុះតាមជើងភ្នំ ដុះដោយខ្លួនឯង។

**+សមាសធាតុគីមី** ៖ មិនទាន់ស្រាវជ្រាវឃើញ។

**+ ផ្នែកប្រើប្រាស់** ៖ ផ្លែ ខ្លឹមឬស ឬស។

**+ ការប្រើប្រាស់** ៖ ផ្លែព្យាបាលចែងថ្ងៃ រមាស់។ ខ្លឹមឬសដាំទឹកផឹកព្យាបាលគ្រុន។ ឬសព្យាបាលស្គមស្គូត ចេញទឹកដោះ បំបាត់ឈឺសាច់ដុំ រោគសន្លាក់ឆ្អឹង បំបាត់ការនឿយហត់ លើកកំលាំង។

**+ ឯកសារយោង** ៖ - លោកគ្រូឱសថបុរាណ
- www.stuartxchange.org/Hilagak.html \

**រៀបរៀងដោយនិស្សិត ៖ ផាន់ សុខហ្គេក**









# គ្រាំពុក-អំពុក-ក្រំពុក

Nom Scientifique : ***Catunaregam uliginosa Poir***

Famille : **RUBIACEAE**

# ក្រាំពុក-អំពុក-ក្រាំពុក

Nom Scientifique : *Catunaregam uliginosa Poir*

Famille : **RUBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទដើមឈើខ្នាតតូចមានកំពស់ពី៥-១០ម៉ែតតាមដើមមានបន្លាស្រួចវែងប្រវែងពី១-២សង់ទីម៉ែតបែកច្រើន។
  - **ស្លឹក** ៖ រាងពងក្រពើ រាវគល់ពណ៌បៃតងខ្ចីស្លឹកច្រើននៅចុងៗមែក ស្លឹកស្ថិតមានប្រវែងពី១៥-២០សង់ទីម៉ែត ទទឹងពី២,៥-១០សង់ទីម៉ែត។
  - **ផ្កាផ្លែ** ៖ -ផ្កាពណ៌សរដុះមួយៗនៅចុងមែកមានពីប្រភេទ ១មានទង ១អត់ទង មាន៦ត្របកក្លិនក្រអូប។
    -ផ្លែរាងមូលប្រវែងពី៥-៦សង់ទីម៉ែតពេលទុំពណ៌លឿង គ្រាប់ច្រើនតូចពណ៌ខ្មៅរលោងប្រវែង៥mm ទទឹង៣mm ចេញផ្កាខែ៣នឹងខែ៦ ផ្លែខែ៦នឹងខែ៩។
+ **កន្លែងដាំដុះ** ៖ ប្រទះឃើញដុះតាមមាត់ទឹក ឬ ព្រៃរបោះ
+ **សមាសធាតុគីមី** ៖ -ផ្លែនិងស្លឹកមានជាតិ Tanin
+ **ផ្នែកប្រើប្រាស់** ៖ ផ្លែ និងឫស
+ **ការប្រើប្រាស់** ៖ -នៅឥណ្ឌាផ្លែវាមិនទាន់ទុំយកគ្រាប់ចេញហាលថស្ងួតព្យាបាលរាក រាកមួល។
  -ឬសវាដាក់ក្នុងបីរព្យាបាលរាក និង រាកមួល។
+ **កំរិតប្រើប្រាស់** ៖ មួយថ្ងៃប្រើពី១០ ទៅ ១៥ក្រាមដាំទឹកផឹក
+ **ឯកសារយោង** ៖ -សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ១ (មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ) បោះពុម្ពឆ្នាំ២០០៨។

**រៀបរៀងដោយនិស្សិត ៖ ហាច គឹមឡេង**







# ឃ្លាយ, ឆ្លាយ,ឃ្លៃ

Nom Scientifique : ***Enkleia siamensis nervling*,**

Famille : **THYMELAEACEAE**

# ឃ្លាយ, ឆ្លាយ,ឃ្លៃ

Nom Scientifique : *Enkleia siamensis nervling*,

Famille : **THYMELAEACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាចុល្លព្រឹក្សស្ទើរវល្លិ៍ មានកំពស់2-5ម មានមែកមានពណ៌ត្នោតមានរោមតិចៗ ជូនកាលមានដៃតោង។
- **ស្លឹក** ៖ ស្លឹកទោល ទល់ទងរាងពងក្រពើ ផ្ទៃខាងលើ ពណ៌បៃតង ផ្ទៃខាងក្រោម ពណ៌ប្រផេះ។
- **ផ្កាផ្លែ** ៖ -កញ្ចុំផ្កាចេញនៅចុងមែក ផ្កាពណ៌លឿងភាវ។
  -ផ្លែរាងមូលស្រួចចុងហើយមានកូនស្លឹកមួយគូពេលទុំជ្រុះងាយប៉ើងតាមខ្យល់ ក្នុងមួយផ្លែមានមួយគ្រាប់។

+ **កន្លែងដាំដុះ** ៖ ដាំនៅតំបន់ខ្ពង់រាប, ព្រៃល្បោះ, ជាយព្រៃ ។ល។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ។
+ **ផ្នែកប្រើប្រាស់** ៖ ដើម, ផ្លែ, មើម។
+ **ការប្រើប្រាស់** ៖ -ផ្លែ-គ្រាប់ ៖ ព្យាបាលជំងឺសរសៃប្រសាទ ខ្លន ទល់លាមក (បញ្ចុះលាមក ហើយធ្វើអោយក្អួត)។
  -ដើម៖ យកទៅដំអោយទក់មូរជក់ ព្យាបាលឬសដូងច្រមុះ ដាំទឹកហូប ព្យាបាលក្អក ហឺត រលាកទងសួត ឃ្លង់ រមាស់។
  -មើម-ឫស ៖ មានជាតិធ្វើអោយ បញ្ចុះលាមក បញ្ចុះហើមធំពោះ។
+ **កំរិតប្រើប្រាស់** ៖ -ដើម ៖ ដាំទឹកហូប 20-30ក្រាមក្នុងមួយថ្ងៃ។
  - ផ្លែនិងមើម ៖ 0,1-0,2ក្រាម ជាថ្នាំគ្រាប់ប្រើតែម្តងគត់ក្នុង1ថ្ងៃ។
+ **ឯកសារយោង** ៖ http://www.herbstohealth.blogspot.com/2009/04/enkleia-siamensis-nervling-po-tao-hai.html
  http://www.ajol.info/index.php/nqjhm/article/view/12686/63919

**រៀបរៀងដោយនិស្សិត ៖ ឆាយ ចន្ទរ៉ា**







# ដើមគ្រោមជាទញ្ញី

Nom Scientifique : *Psycotria pseudoixora*,

Famille : **RUBIACEAE**

# ដើមគ្រាមជាទញ្ញី

Nom Scientifique : ***Psycotria pseudoixora,***

Famille : **RUBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទចុល្លព្រឹក្ស រឺជាប្រភេទដើមឈើតូចដែលមានកំពស់០.៥ម៉ែត្រទៅ ១ម៉ែត្រ។
  - **ស្លឹក** ៖ ស្លឹករបស់វា មានរាងដូចស៊ុត ប៉ុនបាតដៃ ហើយដុះផ្ទុយគ្នា មានពណ៌បៃតង
  - **ផ្កាផ្លែ** ៖ ផ្កាវាប្រមូលផ្តុំនៅចុងមែក ហើយរៀបជាលំដាប់។
+ **កន្លែងដាំដុះ** ៖ ដាំនៅតំបន់ដែលត្រូពិចដែលមានអាកាសធាតុក្តៅហើយសើម
+ **សមាសធាតុគីមី** ៖ Action morphine.
+ **ផ្នែកប្រើប្រាស់** ៖ គេយកឫសទៅស្ងោរផឹក
+ **ការប្រើប្រាស់** ៖ ជួយសំរួលស្ត្រីក្រោយសំរាលកូន
+ **កំរិតប្រើប្រាស់** ៖ មិនទាន់មានឯកសារណាបញ្ជាក់នៅឡើយ
+ **ឯកសារយោង** ៖

- List of Medicinal plants in Cambodia, Pro. CHENG SUNKAENG. 2012.
- Zipcode Zoo.com/Key/Plant/Psychotria.Genus.asp

រៀបរៀងដោយនិស្សិត ៖ តិក គីម







# ដើមចង្គូរត្មាត រឺ សង្គូតត្មាត រឺ ត្រក្គូតត្មាត

Nom Scientifique : *Stereospermum cylindricum Pierre ex Dop*

Famille : **BIGNONIACEAE**

# ដើមចន្ទរត្នាត , សន្ទតត្នាត រឺ ត្រកួតត្នាត

Nom Scientifique : *Stereospermum cylindricum Pierre ex Dop*
Famille : **BIGNONIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទព្រឹក្ស (arbuste) ដែលមានកំពស់ប្រហែលពី១០-២៥ម ព្រមទាំងសំបកបែកក្រម៉រពណ៌ប្រផេះត្នោត និងជាឈើមានខ្លឹមរឹងបំផុត
- **ស្លឹក** ៖ ប្រភេទស្លឹកមួយជាន់ (ស្លាបបក្សីមួយជាន់) ទទឹងប្រហែល៤-៦សម និងបណ្តោយ
៦-៨សម, ស្លឹករាងស៊ុតស្រួចចុងហើយមានកូនស្លឹក១១ដែលទ្រនុងស្លឹកអត់ចំកណ្តាល និងមានធ្មេញរណារតិចៗនៅចុងកូនស្លឹក
- **ផ្កាផ្លែ** ៖ ផ្កាតូចប៉ុនកូនដៃ (ដូចសណ្តែកកួរ) ដុះជាចង្កោមរីកញុំទល់ទងវែង និងមានត្របកផ្ការីកចុង។ ចំនែកឯផ្លែរាងមូលដុះជាកួរវែងស្រួចចុង មានគ្រាប់ច្រើន(គ្រាប់មានស្លាប) និងកោងរមួលប្រេះពេលទុំ។
+ **កន្លែងដាំដុះ** ៖ ដុះនៅក្នុងព្រៃល្បោះ រឺ ព្រៃក្រាស់ជ្រុះស្លឹក
+ **សមាសធាតុគីមី** ៖ នៅក្នុងស្លឹកនិងមែកមានសារធាតុ Lignan glycoside , Phenolic glycoside និង Iridoid glycoside
+ **ផ្នែកប្រើប្រាស់** ៖ សំបកដើម, ឫស, ស្លឹក, ផ្កា
+ **ការប្រើប្រាស់** ៖ សំបកដើមប្រើសំរាប់ព្យាបាលរវើរវាយ, ទាស់កូនខ្ចី, ផ្សះក្រពះ, angina pectoris , haemorrhoid ។ ស្លឹកនិងផ្កា ដាំផឹកបញ្ចុះកំដៅ ព្រមទាំងឫសព្យាបាលឈឺសន្លាក់។
+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់សំបកដាំផឹកពី១០-២០ក្រាម/មួយថ្ងៃ
+ **ឯកសារយោង** ៖ -ដកស្រង់ពីសៀវភៅបញ្ជីឱសថកម្ពុជា-សៀវភៅMedicinal Plants of Cambodia (Habitat Chemical Constituents and Ethnobotanical Uses) Lavit Kham
-សៀវភៅរុក្ខជាតិនៅប្រទេសកម្ពុជាឆ្នាំ 2000
-http://www.ncbi.nlm.nih.gov/pubmed

**រៀបរៀងដោយនិស្សិត ៖ នួន សុធារី**







## ចង្កេះសេក,ផ្តិលមាស

Nom Scientifique : ***Erythroxylum cambodianum pierre,***

Famille : **ERYTHROXYLACEAE**

# ចង្កេងសេក,ឆ្អិលមាស

Nom Scientifique : ***Erythroxylum cambodianum pierre***

Famille : **ERYTHROXYLACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ចុល្លព្រឹក្ស ខ្ពាតតូច មានកំពស់ពី០.៥-១ម សម្បកដើមពណ៌ត្នោត មានស្នាមទងស្លឹក ។
  - **ស្លឹក** ៖ ទោលដុះឆ្លាស់ទង រាងស៊ិតត្រឡប់ទ្រវែង មានប្រវែងពី ៣-១១ស.ម ទទឹង ២-៤ ស.មផ្ទៃស្លឹករាប ពណ៌បៃតងចាស់ ។
  - **ផ្កា,ផ្លែ** ៖ –ជាចង្កោម ចេញពីប្រគាបស្លឹក ឬ មែកចង្កោមនីមួយៗ មានផ្កាពី ២-៨ ផ្កាតូចៗពណ៌សរាង ដូចដួង មាន៥ផែក កេសរឈ្មោល មាន១០ កេសរញីមាន៣ –ជាប្រភេទផ្លែសាច់ រាងស៊ិតតូចៗ ពេលទុំពណ៌ក្រហមស្រស់ មានមួយគ្រាប់

+ **កន្លែងដាំដុះ** ៖ មានដុះនៅតំបន់ព្រៃល្បោះ ទីវាលល្បាយខ្សាច់នៅតំបន់ភ្នំ ។ បន្តពូជដោយគ្រាប់

+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ ។

+ **ផ្នែកប្រើប្រាស់** ៖ ឫស
+ **ការប្រើប្រាស់** ៖ ឫស ៖ បញ្ចុះទឹកនោម ទំលាក់គ្រួសតាមផ្លូវនោម ។ ដុសជីកបញ្ចុះលាមក។
+ **កំរិតប្រើប្រាស់** ៖ ឫស ប្រើ ១៥ក្រាម ដាំផឹក
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជា មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ ឆ្នាំ២០០៩

**រៀបរៀងដោយនិស្សិត ៖ សួន ស៊ាកលី**







# ស្មៅចង្កេះអន្ទ្រង

Nom Scientifique : ***Desmmodium triquetrum,***

Famille : **FABACEAE**

# ស្មៅចង្កេះអន្រ្កង

Nom Scientifique : ***Desmmodium triquetrum*,**

Famille : **FABACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទស្មៅ កំពស់ពី 20-50cm ដើមមានបីជ្រុង។

- **ស្លឹក** ៖ ដុះចេញពីថ្នាំង មានពីរគន្លាក់។ នៅគល់ទងស្លឹកមានកូនស្លឹក តូចមួយនៅ គន្លាក់ ហើយទើបបន្ត ទៅចុងសន្លឹក។ មានសន្លឹកធំជាងវែង ហើយទាល។
- **ផ្កា** ៖ ពណ៌ស្វាយ ដុះចេញពីចុងមែក ពី 10-15 ផ្កា។
- **ផ្លែ** ៖ មានរាងដូចផ្លែសណ្តែកបារាំង សំប៉ែតប្រវែងពី 2-4cm មានគ្រាប់ពី 4-7 គ្រាប់។

+ **កន្លែងដាំដុះ** ៖ ដុះតាមធម្មជាតិ ជើងភ្នំ ខ្ពង់រាប។
+ **សមាសធាតុគីមី** ៖ ស្លឹកក្រៀមមានពី 7.1- 8.6% (Tanin)
+ **ផ្នែកប្រើប្រាស់** ៖ ប្រើស្លឹករុក្ខជាតិទាំងមូល
+ **ការប្រើប្រាស់** ៖ ផ្តាសាយ, រំលាកបំពង់ក, ពោយដៃជើង, ទាចទឹក, ក្មេងពិសអាចម៍កុក, របេងសួត, ព្រូនទំពក់, រលាកក្រលៀន, បូសស្វួត។
+ **កំរិតប្រើប្រាស់** ៖ ដើមស្រស់ 30-60g, ដើមស្ងួត15-30g
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជា ឆ្នាំ2006

**រៀបរៀងដោយនិស្សិត ៖ ថន សុធារី**







## ដើមចាក់ក្រឡេក រឺ កំពុងរសើប

Nom Scientifique : ***Dioecercis erythroclada(kurz) tirveng,***

***Gardenia erythroclada kurz***

Famille : **BEBIACEAE**

# ដើមចាក់ក្រឡេករ៉ី កំពុងរសើប

*Nom Scientifique :* ***Dioecercis erythroclada(kurz) tirveng, Gardenia erythroclada kurz***

*Famille :* **BEBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើមធ្យមមានកំពស់ពី 10m-15m ដើមនិងមែកមានបន្លា និង មានរោមទន់ ពណ៌ក្រហមត្នោត(ដូចពណ៌ច្រេះដែក) គ្របដណ្តប់។
  - **ស្លឹក** ៖ ស្លឹកទោលដុះទល់ទងគ្នា រាងពងក្រពើ ស្រួចគល់ប្រវែងពី 9cm-16cm មានរោមទាំងសងខាង។
  - **ផ្កា** ៖ ផ្កាតូចៗពណ៌បៃតងខ្ចី ជាចង្កោមចេញពីប្រគាបស្លឹកចុងមែក។
  - **ផ្លែ** ៖ ផ្លែរាងពងក្រពើ ទ្រវែងមានទ្រនុងតាមបណ្តោយផ្លែនៅខាងចុងផ្លែ មានត្របកដូចស្លាបកង្ហារ។
+ **កន្លែងដាំដុះ** ៖ ដុះតាមតំបន់ភ្នំ ខ្ពង់រាបដែលមានពន្លឺគ្រប់គ្រាន់ បន្តពូជដោយគ្រាប់
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ។
+ **ផ្នែកប្រើប្រាស់** ៖ ដើមនិងសំបក។
+ **ការប្រើប្រាស់** ៖ ដើមនិងសំបក : ដាំផឹក ព្យាបាលឈាមដើរមិនស្រួល ឈឺពោះ ជំងឺតំរងនោម បុកបិត របួសថ្មីៗ ឃាត់ឈាម ជំនួយសរសៃ។
+ **កំរិតប្រើប្រាស់** ៖ ពី១០ក្រាម ទៅ ៥០ក្រាម ដាំទឹកផឹក។
+ **ឯកសារយោង** ៖ តាមគ្រូបុរាណក្នុងការចុះអង្កេតស្រាវជ្រាវរុក្ខជាតិឱសថខេត្តរតនៈគិរី។

**រៀបរៀងដោយនិស្សិត ៖ ជី ណាលីន**









# សត្បា-រ៉ាកទើក-ចំប៉ីភ្នំ

Nom Scientifique : ***Alstonia scholaris R-Br***

Famille : **APOCYNACEAE**

# សត្បា-រ៉ាកទើក-ចំប៉ីភ្នំ

Nom Scientifique : *Alstonia scholaris R-BrEchites Scholaris L*

Famille : **APOCYNACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើធំមានកំពស់រហូតដល់៤០ម៉ែតដើមវាមានជ័រពណ៌ស សំបកពណ៌ប្រផេះ ប្រេះធ្លុតបណ្តោយដើម

- **ស្លឹក** ៖ រាងផ្លែលំពែងទ្រវែងចុងស្លឹកទាលខ្លះរាងស្រួច ស្លឹកក្រាស គែមស្លឹកពេញលេញ មានសរសៃទទឹងងតូចៗញឹកស្របគ្នា ទទឹងស្លឹកប្រវែងពី១-៣សមស្លឹកដុះចេញព ស្លឹកតែមួយទល់ទប់គ្នាជារង្វង់មានពី៥-៩ស្លឹក

- **ផ្កាផ្លែ** ៖ ផ្លែមូលទ្រវែងប្រវែងប្រហែល៣០សម ចេញជាគូសំយុងចុះក្រោមពេលទុំប្រេះ បែកដោយខ្លួនឯង
ផ្កាតូចៗជាកញ្ចុំពណ៌ស ចេញនៅចុងមែក

+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯងនៅតាមវាលទំនាប ខ្ពង់រាមតំបន់ភ្នំ នឹង ភ្នំដែលមានកំពស់ក្រោម ៧០០ម នឹងគេយកមកដាំបន្តពូជដោយគ្រាប់

+ **សមាសធាតុគីមី** ៖ Alcaloïde ditamine, echitamine, echitenines, alstovenine, venenatine,et Chlorogenic acid.

+ **ផ្នែកប្រើប្រាស់** ៖ សំបក ដើម ជ័រ

+ **ការប្រើប្រាស់** ៖ សំបក ព្យាបាលរលាកផ្លូវដង្ហើម គ្រុនក្តៅ ក្អក ចុកពោះ អាហារមិនរលាយ រាករ៉ាំរ៉ៃនឹងមូល ស្ងោរយកទឹកបាញ់គូថព្យាបាលឬសដូងបាត ខ្ទះឈាមក្រហម រោគសើរស្បែក រោគបេះដូង ជំនួយទឹកដោះ ខ្សោយកំលាំង ទឹកនោមផ្អែម គ្រុនចាញ់រំលាយស្លេស ធ្មេញដង្កូវស៊ី ហើយ ឈឺ។

+ **កំរិតប្រើប្រាស់** ៖ សំបកប្រើ១ថ្ងៃ ពី ១ក្រាមទៅ ៣ក្រាម ជាថ្នាំដាំផឹកម្សៅ ឬ ត្រាំស្រា

+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ បោះពុម្ពឆ្នាំ ២០០៨ ភាគ ២

**រៀបរៀងដោយនិស្សិត ៖ ហេង ហួង**







# ដើម ប្រត់ឥសី កប៉ុញ លំពាន់

Nom Scientifique : *Aglaonema siamense*
Famille : **ARACEAE**

# ដើម ប្រត់ឥសី កប៉ុញ លំពាន់

Nom Scientifique : *Aglaonema siamense*

*Famille : ARACEAE*

+ **លក្ខណៈរុក្ខជាតិ** ៖ ជាស្មៅតូចម្យ៉ាងកំពស់35-40cmមានរាងដូចក្អាត

- **ស្លឹក** ៖ រាងស៊ុតទ្រវែងស្រួចចុងប្រវែង 15 – 20 cmទទឹង5-7cmខាងគល់ស្លឹករាងមូលទ្រនុងកណ្តាលពណ៌រាងស

- **ផ្កាផ្លែ** ៖ កញ្ចុំផ្កាចេញពីប្រកៀបស្លឹក( Axillary ) ឬខាងចុង( terminal )ខ្នងផ្កា3,5- 4,5cm រាងមូលស៊ីឡាំង មានអ៊ិចៗពណ៌សផ្កាឈ្មោល នៅដាច់ពីផ្កាញីខណ្ឌដោយផ្កា Neuter។ ប្រភេទផ្លែមានទឹកច្រើនមានសាច់រុំគ្រាប់ ហើយមានគ្រាប់ច្រើន រាងទ្រវែង 12-18mm ទទឹង 7-10mm មានអ៊ិចៗពណ៌ស

+ **កន្លែងដាំដុះ** ៖ ដុះនៅក្រោមដើមឈើក្នុងព្រៃក្រាស់ឬព្រៃស្រោងត្រជាក់នៃប្រទេសឥណ្ឌូចិនគេនិយមដាំដើមនេះឬក្នុងសួនសំរាប់លំអ

+ **សមាសធាតុគីមី** ៖ មិនទាន់ស្រាវជ្រាវ

+ **ផ្នែកប្រើប្រាស់** ៖ ដើម

+ **ការប្រើប្រាស់** ៖ ប្រើប្រាស់ក្នុងការបន្ទន់លាមក

+ **កំរិតប្រើប្រាស់** ៖ ដើមស្រស់ ប្រើប្រាស់ពី15-30g

+ **ឯកសារយោង** ៖ សៀវភៅ DYPON PAULINE

**រៀបរៀងដោយនិស្សិត ៖ លាច សេងហៀង**







# ដើមចំរៀក

Nom Scientifique : ***Albizia lebbckoides (DC )Benth***

Famille : **FABACEAE**

# ដើមចំរៀក

Nom Scientifique : ***Albizia lebbckoides (DC )Benth***

Famille : **FABACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាដើមឈើធំមានកំពស់អាចដល់២០m។
  - **ស្លឹក** ៖ ជាស្លឹករួមរាងស្លាប២ជាន់មានកូនស្លឹកពី១៨ទៅ២២គូស្លឹកពណ៌បៃតងស្រាលស្លឹករីងប្រវែង២ទៅ២,៥cmទទឹង០,៥ទៅ០,៧cm
  - **ផ្កាផ្លែ** ៖ កញ្ចុំផ្កាជាចង្កោមរាងដូចសាជីផ្កាមូលៗតូចៗនិងផ្លែសំប៉ែតវែងប្រវែង១៣cmទទឹង១,៨ទៅ២cmស្រួចចុងស្រួចដើម
+ **កន្លែងដាំដុះ** ៖ ដុះស្ទើរគ្រប់តំបន់
+ **សមាសធាតុគីមី** ៖ Saponins et Tannis
+ **ផ្នែកប្រើប្រាស់** ៖ សំបកឬស
+ **ការប្រើប្រាស់** ៖ ឈឺពោះឈឺស្បូនរាកប្រកាំងផ្សះដំបៅគ្រប់ប្រភេទធ្លាក់សកាមរោគ
+ **កំរិតប្រើប្រាស់** ៖ ស្ងួត១៥ទៅ២០ក្រាមត្រាំស្រាឬដាំទឹកផឹក
+ **ឯកសារយោង** ៖ ដកស្រង់ចេញពីរុក្ខជាតិឱសថកម្ពុជាភាគ៣

**រៀបរៀងដោយនិស្សិត ៖ មាស អ៊ីសានីវ៉ា**







# ចំបក់ប្រាំង

Nom Scientifique : ***Elaeocarpus hygrophilus Kurz***

Famille : **ELAEOCARPACEAE**

# ចំបក់ប្រាំង

Nom Scientifique : *Elaeocarpus hygrophilus Kurz*

Famille : **ELAEOCARPACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិមានកំពស់ ២០ ទៅ ២៥ ម៉ែត្រ បែកមែកសាខា ។
  - **ស្លឹក** ៖ រាងស៊ុតទ្រវែង រលោងស្វិត គែមស្លឹកមានធ្មេញដូចទឹករលក. ដុះឆ្លាស់ទងស្លឹក ដុះច្រើននៅខាងចុងមែក ។
  - **ផ្កា** ៖ កញ្ចុំផ្កា ដុះចេញតាមប្រគាបស្លឹកដែលជ្រុះ មានទងពី ៣-៥ ម.ម ពណ៌ស ។
  - **ផ្លែ** ៖ រាងពងក្រពើពណ៌បៃតងខ្ចី អាចទទួលទានបាន។
+ **កន្លែងដាំដុះ** ៖ ដុះនៅតាមមាត់ជ្រោះ មាត់អូរ តំបន់ភ្នំ ។ បន្តពូជដោយគ្រាប់ ។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ។
+ **ផ្នែកប្រើប្រាស់** ៖ សំបក ។
+ **ការប្រើប្រាស់** ៖ សំបកដាំទឹកផឹក លាងលោហិត ពេលស្ត្រីឆ្លងទន្លេហើយ រហូតដល់ ១៥ថ្ងៃ ឬសដូងបាត ។
+ **កំរិតប្រើប្រាស់** ៖ ពី ១០ - ១៥ ក្រាម ដាំទឹកផឹកក្នុង ១ថ្ងៃ ។
+ **ឯកសារយោង** ៖ ដកស្រង់ចេញពីសៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ ១។

**រៀបរៀងដោយនិស្សិត ៖ លី ទ៉ាន់ឌី**







## ចំបក់

Nom Scientifique : ***Irvingia malayana div-ex Benn.hamandiana Pierre.***

*Famille :* ***IRVINGIACEAE(I XONANTHACEAE)***

# ចំបក់

Nom Scientifique : *Irvingia malayana div-ex*
*Benn. hamandiana Pierre.*
Famille : *IRVINGIACEAE (IXONANTHACEAE)*

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិមធ្យម កំពស់ប្រហែល ៤០ម។
- **ស្លឹក** ៖ ស្លឹកទោល រាងស៊ុត ពណ៌បៃតងចាស់។
- **ផ្កាផ្លែ** ៖ ផ្កា៖ ពណ៌សដូចក្រែម មានប្រវែងរហូតដល់ ៣mm។
ផ្លែ៖ រាងដូចស៊ុត គ្រាប់រឹង សាច់ក្នុងគ្រាប់ពណ៌សប្រវែងរហូតដល់ ៦ mm។
+ **កន្លែងដាំដុះ** ៖ ប្រទះឃើញនៅព្រៃល្បោះ ព្រៃស្បោង បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ ស្លឹកជាតិ Talin 7% និង 0,20-0,25% ជាតិ Calycopterin។
+ **ផ្នែកប្រើប្រាស់** ៖ សាច់ក្នុងគ្រាប់ មានរសប្រេង។
+ **ការប្រើប្រាស់** ៖ ជំនួយសសៃពួរ ជំនួយសន្លាក់ ជំនួយតំរង់នោម ទំលាក់ព្រូន សម្រកទំងន់។
+ **កំរិតប្រើប្រាស់** ៖ ផឹកបរិមាណតិច។
+ **ឯកសារយោង** ៖ សៀវភៅសព្វវចនានុក្រម និងគោលភេសជ្ជកម្មថៃ របស់វុលិ វុលិធម្មវិជ្ជ
http://en.wikipedia.org/wiki/Irvingia
http://www.oc:encydia.com

**រៀបរៀងដោយនិស្សិត ៖ ស៊ុយ ស្រីនិច**







## ចំបក់ប្រាំង

Nom Scientifique : *Elaeocarpus hygrophilus*

Famille : **ELAEOCARPACEAE**

# ចំបក់ប្រាំង

Nom Scientifique : *Elaeocarpus hygrophilus*

Famille : **ELAEOCARPACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិ មានកំពស់ពី ២០-២៥ ម៉ែត្រ បែកមែកសាខា ។
- **ស្លឹក** ៖ រាងស៊ុតទ្រវែង រលងស្វិត, គែមស្លឹកមានធ្មេញដូចទឹករលក, ដុះឆ្លាស់ទង ស្លឹកដុះច្រើននៅចុងមែក។
- **ផ្កាផ្លែ** ៖ កញ្ចុំផ្កា ដុះចេញតាមប្រគាបស្លឹកដែលជ្រុះ មានទងពី ៣-៥ មីលីម៉ែត្រ ពណ៌ស។
ផ្លែរាងពងក្រពើ ពណ៌បៃតងខ្ចី អាចទទួលទានបាន ។
+ **កន្លែងដាំដុះ** ៖ ដុះនៅមាត់ជ្រោះ មាត់អូរ, តំបន់ភ្នំ។ បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ ។
+ **ផ្នែកប្រើប្រាស់** ៖ សំបក ។
+ **ការប្រើប្រាស់** ៖ សំបកដាំទឹកផឹក លាងលោហិត ពេលស្ត្រីឆ្លងទន្លេហើយ រហូតដល់១៥ថ្ងៃ, ឬសដូងបាត។
+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី ១០-១៥ ក្រាម ដាំទឹកផឹកក្នុង១ថ្ងៃ។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិ ឱសថកម្ពុជា ភាគ១ (មជ្ឈមណ្ឌលជាតិ ស្រាវជ្រាវ វេជ្ជសាស្ត្រ បូរាណ)
http://www.google.com.kh/search?q=elaeocarpus

**រៀបរៀងដោយនិស្សិត ៖ ហាច រត្ន័ពិសី**







# ដើមឆ្កែស្រែង, កែស្រែង

Nom Scientifique : ***Cananga Latifolia Finet et Gagnep,***

*Famille :* **ANNONACEAE**

# ដើមឆ្កែស្រែង, កែស្រែង

Nom Scientifique : ***Cananga Latifolia Finet et Gagnep***

Famille : **ANNONACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើមានកំពស់ពី ១០ - ២០ ម មែកខ្ចីមានរោមទនដំបូងពណ៌លឿងបន្ទាប់មកក្លាយជាពណ៌ប្រផេះបន្ទាប់មកជ្រុះរោមអស់មែករលីង។
  - **ស្លឹក** ៖ ពណ៌បៃតងរាងពងក្រពើស្រួចចុងមានរោមសងខាងដុះឆ្លាស់ទងទងស្លឹកខ្ចីមានប្រវែង ៨ - ១០ mm ទំរង់ស្លឹកជាមធ្យមបណ្តោយពី ១០ -១៦ Cm ទទឹង ៨-១២Cm (ស្លឹកមានក្លិនស្រដៀងស្លឹកកន្ទ្រោក ឆ្អេះ)។
  - **ផ្កា ផ្លែ** ៖ ដុះពី ១ - ៣ ផ្កាទល់ទងជាមួយស្លឹកនៃមែកខ្ចី
+ **កន្លែងដាំដុះ** ៖ មានដើមកំណើតនៅកម្ពុជាហើយច្រើនដុះនៅតាមព្រៃរបោះ,ព្រៃ ក្រាស់មធ្យមជារុក្ខជាតិដុះដោយខ្លួនឯង។ ប្រមូលផលបានគ្រប់រដូវ។
+ **ផ្នែកប្រើប្រាស់** ៖ ដើម, សំបក , ឬស។
+ **សមាសធាតុគីមី** ៖ Polyphenol Glycosides
+ **ការព្យាបាល** ៖ ដើមស្ងោរផឹកសម្រាប់បញ្ចុះកំដៅ។សំបកមានធាតុមួយដែលអាចបំបាត់រោគ វិលមុខ ។ សាច់ដើមកោសជាកំទេចតូចៗ ហាលស្ងួត មូរជក់សម្រាប់ព្យាបាល រោគច្រមុះ ។ ផ្លែស្រែងលាយជាមួយមុខឈ្នាងសម្រាប់ព្យាបាលរោគរបេងស្ងួត។
+ **កំរិតប្រើប្រាស់** ៖ ពី ១០ - ១៥ ក្រាមក្នុងមួ១ថ្ងៃ។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជា ស្រាវជ្រាវដោយមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ នៃក្រសួងសុខាភិបាល (បោះពុម្ពឆ្នាំ ២០០៨ , ភាគ១)

**រៀបរៀងដោយនិស្សិត ៖ សុវណ្ណា រតនា**







# ស្មាក្របីស្លឹកធំ ឬ ផ្កែស្រែខ្មៅ

Nom Scientifique : ***Miliusa velutina(Dun) Hook.f et Thoms***

Famille : **ANNONACEAE**

# ស្នាក្របីស្លឹកធំ ឬ ផ្តៅស្រែខ្មៅ

Nom Scientifique : *Miliusa velutina(Dun) Hook.f et Thoms*
Famille : **ANNONACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាដើមឈើមានកំពស់ពី ៦ម៉ែត្រ ដល់ ៨ម៉ែត្រ ជួនអាចដល់៣០ម៉ែត្រ បែកមែកច្រើន មែកខ្ចីមានរោមពណ៌លឿង ។
  - **ស្លឹក** ៖ ស្លឹកទោលដុះឆ្លាស់ទង បន្ទះស្លឹករាងជាស៊ុតធំ បណ្តោយមានប្រវែង ១៥ ទៅ ៣០សង់ទីម៉ែត្រ ទទឹងមានប្រវែង ១០ ទៅ ២០ សង់ទីម៉ែត្រ មានទងស្លឹកខ្លីផ្ទៃទាំងសង់ខាង មានរោមទន់ ផ្ទៃខាងក្រោមលេចចេញទ្រនុងច្បាស់ៗ ។
  - **ផ្កាផ្លែ** ៖ កញ្ចុំផ្កាចេញនូវចុងមែកមានផ្កា ២ ទៅ ៣ពណ៌បៃតងភាវមានទងវែង មានកូនស្លឹក២ អមទងផ្កា។ ផ្លែរាងស៊ុតត្រឡប់ គ្របដណ្តប់ដោយរោមពណ៌ដី។ ខែប្រាំងរុក្ខជាតិនេះជ្រុះស្លឹកអស់ពីដើម ។
+ **កន្លែងដាំដុះ** ៖ ដុះតាមព្រៃរបោះ ព្រៃល្បាស់ ដីសើមតាមដងអូរ ។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ ។
+ **ផ្នែកប្រើប្រាស់** ៖ ស្លឹក សំបក ដើម ឬស ។
+ **ការប្រើប្រាស់** ៖ ស្លឹក: ព្យាបាលឈឺភ្នែក
  សំបក: រលាកច្រមុះ
  ផ្សះក្រពះបញ្ចុះសត្វល្អិតក្នុងពោះជំងឺសើរស្បែកបន្ទន់លាមក ។
  ដើម: កោសជក់ ព្យាបាលរលាក់ច្រមុះ
  ឬស: ជាមើមព្យាបាលដំបៅក្រពេះ ឬសដូងបាត ឬសដូងវិល ផ្សះដំបៅស្បូន ។
+ **កំរិតប្រើប្រាស់** ៖ ៣ ទៅ ១០ ក្រាម ស្ងោរផឹកមួយថ្ងៃ ។
+ **ឯកសារយោង** ៖ បញ្ជីឈ្មោះរុក្ខជាតិឱសថកម្ពុជា ។

**រៀបរៀងដោយនិស្សិត ៖ ឆេង សុភ័ក្ត្រ**








# ចន្ទល់ពងមាន់

Nom Scientifique : ***Gardenia obtusifolia Roxb***

Famille : **RUBIACEAE**

# ចន្លល់ពងមាន់

Nom Scientifique : ***Gardenia obtusifolia Roxb***
Famille : **RUBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាចុល្លព្រឹក្សដែលមានកំពស់ពី២-៥ម។ សំបកដើមមានស្នាមប្រេះកាត់ទទឹង មានពណ៌ប្រផេះ។
  - **ស្លឹក** ៖ ស្លឹកទោល ដុះឆ្លាស់ទង រាងស៊ុតត្រឡប់ គែមស្លឹកពេញ ស្លឹកច្រើនដុះជាកញ្ចុំនៅចុងមែក។
  - **ផ្កាផ្លែ** ៖ ផ្កាចេញនៅចុងមែក មាន៥ត្របកពណ៌ស ពេលជិតរោយមានពណ៌លឿងទុំ។ ផ្លែនៅចុងមែកមានមួយទៅ៤ផ្លែ រាងមូល ជាផ្លែសាច់មានពណ៌ត្នោតអុចៗស មានគ្រាប់ច្រើន។
+ **កន្លែងដាំដុះ** ៖ ដុះតាមព្រៃល្បោះ, ជើងភ្នំ។ បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ។
+ **ផ្នែកប្រើប្រាស់** ៖ ដើម
+ **ការប្រើប្រាស់** ៖ រក្សាគភ៌ អោយកូនកើតបានស្រួល។ ឆ្លងទន្លេហើយហូបមិនអោយឈឺចង្កេះ ជំនួយបេះដូង។
+ **កំរិតប្រើប្រាស់** ៖ ស្ងួតប្រើ15-30ក្រាម ដាំផឹក។
+ **ឯកសារយោង** ៖ សៀវភៅ រុក្ខជាតិឱសថកម្ពុជាភាគ៣

**រៀបរៀងដោយនិស្សិត ៖ឆេង សុភា**





# ជម្ពូក្រហម

Nom Scientifique : ***Bixa Orellana Linn***

Famille : **BIXACEAE**

# ជំពូក្រហម ( ជំពូជ្រលក់ស្បូត្រ )

Nom Scientifique : *Bixa Orellana Linn*
Famille : **BIXACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាចុល្លព្រឹក ពណ៌បៃតងជានិច្ចមានកំពស់៥ ទៅ ៦ម៉ែត្រ។

- **ស្លឹក** ៖ ស្លឹកទោលដុះឆ្លាស់ទងវលោង រាងពងក្រពើស្រួចចុងខាងគល់ទងស្មើរតែ ជារាងបេះដូងបណ្តោយ ១០ ទៅ ២០សម. ទទឹង ៥ ទៅ ១២សម.។

- **ផ្កាផ្លែ** ៖ ផ្កាពណ៌ស ឬ សផ្កាឈូកទំហំ៥ ទៅ ៦សម. ចេញជាចង្កោមនៅចុងមែក។ ផ្លែរាងជាស៊ុត ឬ ស្មើរមូលទំហំ ៩សម. ជាប្រភេទផ្លែស្ងួត គ្របទៅដោយបន្លាទន់ៗវែង និងមានរោមរឹងនៅពេលទុំ។

+ **កន្លែងដាំដុះ** ៖ នៅតាមតំបន់ដីទួលតំបន់ភ្នំនិងដាំធ្វើរបង ឬ លំអ៕

+ **សមាសធាតុគីមី** ៖ សាច់រុំគ្រាប់មានផ្ទុកជាតិទឹក ២០ ទៅ ៣០% ស្ករ Tannin ប្រេងក្រអូប Carotenoide 45%។ពណ៌ក្រហមមានជាតិ Bixin Carotenoide Acide Caboxylique Annatro ឬRocon ឬ Orpean។

+ **ផ្នែកប្រើប្រាស់** ៖ ឬស សំបកដើម ស្លឹក ផ្លែ គ្រាប់។

+ **ការប្រើប្រាស់** ៖ ស្លឹក: ប្រើជាថ្នាំបញ្ចុះកំដៅដោយបុកពូតយកទឹកលាបលើខ្លួនប្រាណក្មេងដែល កំពុងគ្រុនក្តៅ។ស្លឹកស្រស់បុកលាយប្រេងដូង កំដៅអោយក្តៅបន្ទាប់មក បំពោកលើពោះ ដើម្បីព្យាបាលហើមពោះ មួល ព្រូន ។

ឬស: ប្រើជាថ្នាំបន្ទន់លាមក បញ្ចុះកំដៅ ការពារការលាប់នៃជំងឺផ្សេងៗ

ផ្លែខ្ចី: ជាថ្នាំធ្វើអោយស្បែកទន់ គេប្រើព្យាបាលឃ្លង់ ។

សំបកដើម: ដាំទឹកព្យាបាលក្តៅខ្លួន ហៀរសំបោរ ។

គ្រាប់: ឆុងទឹកផឹក សំរាប់កាត់ស្លេស្ម ហើយគេប្រើវាក្នុងការព្យាបាល ហឺត

សាច់រុំគ្រាប់: គេព្យាបាលឆ្អល់ពោះ មួល គ្រុនក្តៅ ឈឺក្បាល ឈឺ-ក ប្រមេះទឹកបាយ រលាកភ្លើង និង ឃ្លង់ ។

**រៀបរៀងដោយនិស្សិត ៖ ពេន សណ្តាប់**







# ដើមជន្លាត់ដៃ, ជន្លាត់ដៃ

Nom Scientifique : ***Euphorbia lacteal,***

Famille : **Euphorbiaceae**

# ដើមជន្លាត់ដៃ, ជន្លាត់ដៃ

Nom Scientifique : ***Euphorbia lacteal,***

Famille : **Euphorbiaceae**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រទាលមួយប្រភេទ ដែលមានពណ៌ខៀវចាស់ មានតួចៗច្រើន មានបន្លាជ័រសដូចទឹកដោះស្រស់, ច្រើនដាំធ្វើរបងភូមិ, របងវត្ត (ស្រុកក្រៅ)។ ដើមនេះមានប្រភពមកពីប្រទេស India
  - **ស្លឹក** ៖ ដុះជាជួរត្រង់ទៅលើដែលមានវិជ្ជមាត្រ ៥ Cm ដែលមានរាងទ្រវែងផែកពណ៌បៃតង ដុះចេញទៅក្រៅ
  - **ផ្កា** ៖ បន្លាតូចៗតែស្រួច ដែលដុះជាគូឃ្លាតចេញពីគ្នាដែលមានបណ្តោយប្រវែង ២-៦ mm
+ **កន្លែងដាំដុះ** ៖ ដាំនៅតំបន់ដែលត្រូពិចដែលមានអាកាសធាតុក្តៅហើយសើម
+ **សមាសធាតុគីមី** ៖ carboxylic acid , stigmasterol , β-sitosteryl-3-0-scleropyrate, stigmasteryl-3-0-scleropyrate, β-sitosterol, two new esters & two well-known-sterol
+ **ផ្នែកប្រើប្រាស់** ៖ សាច់ខាងក្នុងដោយចិតចោលស្រទាប់ខាងក្រៅ ជ័រមានជាតិពុល និង គ្រោះថ្នាក់ចំពោះភ្នែក
+ **ការប្រើប្រាស់** ៖ ព្យាបាលចំពោះ Inflammation
+ **កំរិតប្រើប្រាស់** ៖ មិនទាន់មានការស្រាវជ្រាវ
+ **ឯកសារយោង** ៖
  http://www.cactuspedia.info/schede/EUPHORBIA/Euphorbia_lactea/Euphorbia_lactea/Euphorbia_lactea.htm
  http://www.aujardin.org/euphorbia-lactea-t48415.html
  http://www.mi-aime-a-ou.com/euphorbia_lactea_cristata.php

**រៀបរៀងដោយនិស្សិត ៖ ហេង ឬរី**







# វល្លិ៍ជោគ

Nom Scientifique : ***Embelia sp,***

Famille : **MYRSINACEAE**

# វល្លិ៍ជោគ

Nom Scientifique : ***Embelia sp,***

Famille : **MYRSINACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាវល្លិ៍ឈើមួយប្រភេទ ដែលមានសាច់រឹងនិងមានដើមធំ សំបកខ្មៅនៅពេលដើមចាស់ ។
  - **ស្លឹក** ៖ មានរាងដូចស៊ុត ដុះឆ្លាស់គ្នា
  - **ផ្កា** ៖ ផ្កាតូចៗ ។
  - **ផ្លែ** ៖ ផ្លែមូលតូចៗមានចង្កោមជាកួរ។
+ **កន្លែងដាំដុះ** ៖ ដាំនៅតំបន់ត្រូពិចដែលមានអាកាសធាតុក្តៅហើយសើម នៅព្រៃរបោះ ឬព្រៃស្មោង (ក្នុងស្រុក)
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ។
+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល
+ **ការប្រើប្រាស់** ៖ បង្កើនទឹកដោះ,បំបាត់ឈឺពោះ,ថ្នាំជំនួយសរសៃ
+ **កំរិតប្រើប្រាស់** ៖ ១៥-៣០ក្រាមក្នុងមួយថ្ងៃ
+ **ឯកសារយោង** ៖ +បញ្ជីរុក្ខជាតិឱសថកម្ពុជា២០១២, សាស្ត្រាចារ្យ CHENG Sun Kaing
  +គ្រូបង្រៀនផ្នែកឱសថបូរាណ

**រៀបរៀងដោយនិស្សិត ៖ ប៊ុន មយុរី**







# ជន្លួសដើមតូច ( ដូនភាយ )

Nom Scientifique : ***Lepisanthes rubiginose (Roxb) Leenh***

Famille : **SAPINOACEAE**

# ជន្លួសដើមតូច ( ជូនភាយ )

Nom Scientifique : *Lepisanthes rubiginose (Roxb) Leenh*
Famille : **SAPINOACEAE**

\+ **លក្ខណៈរុក្ខជាតិ** ៖ ជាដើមតូចមានកំពស់ 5-10ម មែកខ្ចីមានរោមច្រើន។

- **ស្លឹក** ៖ រួមរាងស្លាបប្រវែង 20-40 សម កូនស្លឹកដុះទល់ទងគ្នា មានរាងស៊ុតទ្រវែង ។ ស្លឹកមានទទឹងប្រវែង 3-8សម មានរោមទាំងសងខាង។
- **ផ្កាផ្លែ** ៖ ផ្កាចេញនៅចុងមែកមានពណ៌លឿងភ្លាវ ផ្លែសាច់រាងស៊ុត ពេលចាស់ពណ៌ស្វាយក្រមៅពេលទុំពណ៌ខ្មៅ។

\+ **កន្លែងដាំដុះ** ៖ ដុះនៅព្រៃល្បោះ នឹងបន្តពូជដោយគ្រាប់។

\+ **សមាសធាតុគីមី** ៖ មិនទាន់ស្រាវជ្រាវនៅឡើយ។

\+ **ផ្នែកប្រើប្រាស់** ៖ គ្រាប់ ឬស ដើម។

\+ **ការប្រើប្រាស់** ៖ ស្លឹក : ទំពារបិទបូស.រលាកភ្លើង ខ្ទៃរពេល។

-ឬស : ក្អួកមាន់ របេង ពិសក្តៅ ឈឺចង្កេះ កិនអោយទៅជាម្សៅសំរាប់ព្យាបាលគ្រុនក្តៅដាំទឹកផឹកសំរាប់កូនក្មេងកើតជ្រាំងនិងដំបៅក្នុងមាត់។

-ដើម: ផ្សះស្បូន។

\+ **កំរិតប្រើប្រាស់** ៖ ប្រើពី 10-30 ក្រាម ដាំផឹកក្នុង1ថ្ងៃ។

\+ **ឯកសារយោង** ៖ សៀវភៅ រុក្ខជាតិឪសថកម្ពុជា ភាគ1

**រៀបរៀងដោយនិស្សិត ៖ គី ដារ៉ា**







## ដើម ជ្រោយ

Nom Scientifique : ***Casearia grewiae folia Vent***

Famille : **FLACOURTIACEAE (SAMYDACEAE)**

# ដើម ច្រោយ

Nom Scientifique : *Casearia grewiae folia Vent*

Famille : **FLACOURTIACEAE (SAMYDACEAE)**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើកណ្តាល មានកំពស់ពី ១០-១២m មានបន្ទាត់ផ្ចិតរហូតដល់ ៥0m មែកខ្ចីមានរោម។
  - **ស្លឹក** ៖ ស្លឹកឆ្លាស់គ្នារាងទ្រវែង ស្រួចចុង បណ្តោយ១០-១៦cm ទទឹង៤-៦cm ខាងលើពណ៌បៃតងចាស់រលោង ខាងក្រោមពណ៌បៃតងខ្ចីមានរោមទន់។
  - **ផ្កា** ៖ ផ្កាជាច្រើនចេញតាមប្រគាបស្លឹកហូរហែរ តាមបណ្តោយមែកនីមួយៗ។
  - **ផ្លែ** ៖ មានរាងពងក្រពើទ្រវែង មានបន្ទាត់ផ្ចិត ២២-២៥មីលីម៉ែត រលោងមាន៦ជ្រុងពេលទុំពណ៌លឿង។
+ **កន្លែងដាំដុះ** ៖ មានដុះនៅដីទំនាប មាត់ទន្លេ តាមជើងភ្នំ។ល។
+ **សមាសធាតុគីមី** ៖ -(E)-((E)-9,10hydroxy-5(1-oxo-tetrahydro-furan-3yl)-hexa-7-enyl)-methyl-but-2-enoic acid

  -(E)-((E)-9,10-dihydroxy-6(1-oxo-3,4dihydrofuran-3yl) hex-7-enyl)-3-methyl-but-3-endate
+ **ផ្នែកប្រើប្រាស់** ៖ ឫស, សំបកដើម, ស្លឹក។
+ **ការប្រើប្រាស់** ៖ ឫសនិងសំបកដើម: ដាំផឹកសំរាប់ស្ត្រីឆ្លងទន្លេហើយ និងព្យាបាលស្ត្រីកូនខ្ចីទាស់សសៃ។ នៅប្រទេសថៃគេប្រើឫសព្យាបាលថ្លើមពិស បេស្នំ។សំបកដើម: សំរាប់បំរុងធាតុ និងបំរុងកំលាំង។ស្លឹក: គ្រុនក្តៅ, គ្រុនអាបេស្នំ, រោគសើរស្បែក។
+ **គំរិតប្រើប្រាស់** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ ។
+ **ឯកសារយោង** ៖ មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ។

**រៀបរៀងដោយនិស្សិត ៖ ហេង សុធាដា**







# ដើមឈើទាល

Nom Scientifique : ***Dipterocarpus dyeri***

Famille : **DIPTEROCARPACEAE**

# ដើមឈើទាល

Nom Scientifique : ***Dipterocarpus dyeri***

Famille : **DIPTEROCARPACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ឈើទាលជាប្រភេទដើមឈើធំ ឈើសំណង់ ឈើសាងសង់ ឈើធ្វើផ្ទះសំបែង ជាទូទៅឈើនេះមានកំពស់ខ្ពស់ ខ្លះមានកំពស់រហូតដល់៣០ម៉ែត្រក៏មានដែរ ។
  - **ស្លឹក** ៖ ទំរង់ស្លឹករាងទ្រវែង ស្លឹកនីមួយៗដុះឆ្លាស់គ្នាចេញពីមែក និង មានទ្រនុងឈមគ្នា ។
  - **ផ្កាផ្លែ** ៖ ផ្លែរបស់វាមានស្លាបពីរ ពេលធ្លាក់មកវិលដូចកង្ហារ ។
+ **កន្លែងដាំដុះ** ៖ ដុះនៅតំបន់ខ្ពង់រាបនៅខេត្តមួយចំនួនដូចជា កំពង់ចាម កំពង់ស្ពឺ ក្រចេះ ស្ទឹងត្រែង ចំនែកឯនៅតំបន់ភ្នំមិនសូវសំបូរទេ ។
+ **សមាសធាតុគីមី** ៖ α-gurjunene និង allo-aromadendrene
+ **ផ្នែកប្រើប្រាស់** ៖ សំបកដើម និង ជ័រ ។
+ **ការប្រើប្រាស់** ៖ រុក្ខជាតិនេះគេចុះដើមយកជ័រ រួចលាយជាមួយជ័ររុក្ខជាតិដទៃទៀតដូចជា ជ័រចុង រួចយកស្លជាមួយប្រេង ឬ ក្រមួនដើម្បីយកមកលាបលើ របួសបោកទង្គិចនឹងអ្វីមួយ ថ្លោះក្រិច បាក់ឆ្អឹង ដំបៅ ។ ខ្លះទៀតគេយកសំបកវាមកធ្វើថ្នាំឈឺធ្មេញ ថ្នាំជំនួយកំលាំង និង ប្រទាលត្រអះ(តែមិនសូវជួបប្រទះទេ) ។
+ **កំរិតប្រើប្រាស់** ៖ ប្រហែលចាប់ពី១០ក្រាម ទៅ ៣០ក្រាម ។
+ **ឯកសារយោង** ៖ ពត៌មានទទួលបានពីគ្រូឱសថបុរាណ

Journal of Tropical Forest Science 1(1) : 11 – 15
http://myais.fsktm.um.edu.my/6055/1/JTFS-1-1-88-11-15.pdf

**រៀបរៀងដោយនិស្សិត ៖ ឈា សុធារម្យ**







# ញភ្នំ ឬ ញព្រៃ

**Nom Scientifique : Morinda tomentosa Heyne ex Roth.**

**Famille : RUBIACEAE**

# ញ្ញូរភ្នំ ឬ ញ្ញូរព្រៃ

**Nom Scientifique : Morinda tomentosa Heyne ex Roth.**
**Famille : RUBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទរុក្ខជាតិឈើតូច ឬ មធ្យម កំពស់ប្រហែល ៥-១២ម៉ែត្រ ដើមចាស់សាច់ពណ៌លឿង
- **ស្លឹក** ៖ រលោង រាងពងក្រពើ រៀវគល់ស្រួចចុង ដុះទល់ទង ប្រវែង ៨-២០សម ទទឹង៣-៨សម
- **ផ្កាផ្លែ** ៖ ផ្កាពណ៌ស ខ្លះដុះចេញពីប្រគាបស្លឹក ខ្លះដុះទល់ទងជាមួយស្លឹក ផ្លែដូចញរស្រុកតែតូចៗ មានកំពកភ្នែកមួយ មានគ្រាប់តែមួយ ពេលទុំមានពណ៌ស

+ **កន្លែងដាំដុះ** ៖ តំបន់មានពន្លឺថ្ងៃដូចជាក្នុងព្រៃរបោះ ឬ ព្រៃតូចៗតាមសងខាងផ្លូវ ហើយគេក៏អាចយកមកដាំក្នុងភូមិបានដែរ (ផ្លូវទៅវីនសៃខេត្តរតនគីរី)
+ **សមាសធាតុគីមី** ៖ ឫសមាន Glucosid Morinda
សំបកដើមមាន Tanin (Activité anti-oxydant et anti-convulsivant)
+ **ផ្នែកប្រើប្រាស់** ៖ ឫស និង សំបកដើម
+ **ការប្រើប្រាស់** ៖ ឫស ព្យាបាលលើសឈាម ឈឺសន្លាក់ជើង ឈឺចង្កេះ។
តាមក្បួនឱសថបូរាណខ្មែរ ថ្នាំត្រាំស្រានៃញរព្រៃ សំរាប់ព្យាបាលក្អួត ពិសេសក្នុងករណីអាសន្នរោគ និង អាចដាំ ឬ ឆុងទឹកក្តៅព្យាបាលគ្រុនចាញ់។
សំបកដើម ដាំទឹកហូបសំរាប់ស្ត្រីឆ្លងទន្លេហើយ។
+ **ឯកសារយោង** ៖ កំរងរុក្ខជាតិឱសថ ស្តីពីការចុះអង្កេតស្រាវជ្រាវក្នុងខេត្តមណ្ឌលគីរី រុក្ខជាតិឱសថកម្ពុជា បោះពុម្ពឆ្នាំ ២០០៦

**រៀបរៀងដោយនិស្សិត ៖ ជា សុគាំង**







# ដង្ខៀបក្អាម

Nom Scientifique : ***Antidesma ghaesembilla Gaertn***

Famille : **EUPHORBIACEAE**

# ដង្កៀបក្តាម

Nom Scientifique : *Antidesma ghaesembilla Gaertn*

Famille : **EUPHORBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិតូច មធ្យម កំពស់ ៣ ទៅ ៨ ម ។

- **ស្លឹក** ៖ ស្លឹកដុះឆ្លាស់ទង ទងស្លឹកមានរោមតិចៗ មានរាងពងក្រពើ ទំហំជាមធ្យម ទទឹងពី ៤០ទៅ៥៥មម បណ្តោយពី ៧០ទៅ៩០មម ។

- **ផ្កាផ្លែ** ៖ ផ្កា ជាចង្កោមគូច្រើន ឬ តិច ហើយគូនីមួយៗ មានផ្កាល្អិតៗ ។
ផ្លែ មូលតូចល្អិតៗ ប្រហែល ៤ទៅ៥មម ផ្គុំជាកញ្ចុំ ឬ ចង្កោម រសជាតិជូរ ។

+ **កន្លែងដាំដុះ** ៖ ដុះខ្លួនឯង នៅតាមតំបន់ទំនាប និង ខ្ពង់រាប ។

+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយទេ ។

+ **ផ្នែកប្រើប្រាស់** ៖ សំបកដើម បំពង់ ស្លឹក ផ្កា ផ្លែ ។

+ **ការប្រើប្រាស់** ៖ ផ្លែ ហូបបាន រសជាតិជូរ ព្យាបាល ក្អក ហើមសួត ។
ផ្កា ព្យាបាលជំងឺឈឺសន្លាក់ដៃជើង
សំបក ព្យាបាលរាគ និង ធ្វើជាថ្នាំប៉ូវ និង ជាថ្នាំផ្សះ
ស្លឹក ស្រស់យកមកបិទ ព្យាបាលឈឺក្បាល
ឫសដូងបាត យកសំបកដង្កៀបក្តាមស្ងួត ៣០ក្រាម សំបកពង្រ៣០ក្រាម និង មើមប៉ប្រក ១៥ក្រាម ដាំទឹកហូប
ស្ត្រីឆ្លងទន្លេហើយ ប្រើសំបកដង្កៀបក្តាមផ្សំជាមួយរុក្ខជាតិផ្សេងទៀត ដាំទឹកហូប

+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ ៣០ក្រាម ។

+ **ឯកសារយោង** ៖ កំរងរុក្ខជាតិឱសថ ស្តីពីការចុះអង្កេតស្រាវជ្រាវក្នុងខេត្តមណ្ឌលគីរី ដោយ និស្សិតជំនាន់ទី៣១ ឆ្នាំ ២០១០-២០១១ ។

**រៀបរៀងដោយនិស្សិត ៖ សេង ណារ៉ៃឡេន**








# ដើមដង្ហិតធំ

Nom Scientifique : *Cassia alata Linn*

Famille : **CAESALPINIACEAE**

# ដើមដង្ហិតធំ

Nom Scientifique : *Cassia alata Linn*

Famille : **CAESALPINIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិតូចម្យ៉ាងបែកមែកទទឹងដើម។

- **ស្លឹក** ៖ ស្លឹកស្ថិតផ្គុំដោយកូនស្លឹក ៨-១២គូ។ កូនស្លឹកដុះទល់ទងរាងដូចស៊ុតទ្រវែង ឬ រាងដូចស៊ុតរលោងមូលចុងដើម។

- **ផ្កាផ្លែ** ៖ ផ្កាពណ៌ លឿងជាចង្កោម ផ្លែជាកូរវែងពណ៌ខ្មៅរលោង សំប៉ែតក្រាស់រាងគន្លាក់ៗ ហើយមាន គ្រាប់រាងបួនជ្រុង។

+ **កន្លែងដាំដុះ** ៖ ដុះគ្រប់ទីកន្លែងក្នុងដីសើម ឬ ដាំក្នុងសួនធ្វើជាឱសថ ។

+ **សមាសធាតុគីមី** ៖ Anthracénosides.

+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល ។

+ **ការប្រើប្រាស់** ៖ គេងមិនលក់ ញ័រទ្រូង បែកញើសខ្លាំង រាគហើមពោះ បាយមិនឆ្ងាញ់ បូសដំបៅ រោគតាមផ្លូវនោម ឈាមរដូវធ្វើទុក្ខ។

+ **កំរិតប្រើប្រាស់** ៖ -ម្សៅស្ងួតផឹកក្នុងកំរិត ៣ ទៅ ៨ក្រាម ឬដាំទឹកផឹកពី ៥០០ ទៅ ៦០០ម.ល សំរាប់ព្យាបាល គេងមិនលក់ ញ័រទ្រូង និង បែកញើសខ្លាំង។
-សំបកជាមួយ និងស្ករត្នោតដាំផឹកពី ៥០០ ទៅ ៦០០ម.ល សំរាប់ព្យាបាល រាគ ហើមពោះ និង បាយមិនឆ្ងាញ់។

+ **ឯកសារយោង** ៖
- http://www.phytomania.com/cassia.htm
- រុក្ខជាតិឱសថកម្ពុជា ( ក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិស្រាវជ្រាវ វេជ្ជសាស្ត្របូរាណ ) បោះពុម្ពដោយថវិកាជាតិ ឆ្នាំ ២០០៦ ។

**រៀបរៀងដោយនិស្សិត ៖ អៀ សុមន្ទី**









## ដូនភាយ

Nom Scientifique : *Lepisanthes rubiginosa (Roxb). Leenh*

Famille : **SAPINDACEAE**

# ដូនភាយ

Nom Scientifique : *Lepisanthes rubiginosa (Roxb). Leenh*

Famille : **SAPINDACEAE**

+**លក្ខណៈរុក្ខជាតិ** ៖ ដើមឈើតូចមានកំពស់៥-១០ម៉ែត្រ មែកខ្ចីមានរោមច្រើន ។

- **ស្លឹក** ៖ រូមរាងស្លាបទ្រវែង ២៤-៤០ស.ម កូនស្លឹកដុះទល់ទងគ្នារាងស៊ុតទ្រវែង មានទទឹង៣-៦ស.ម បណ្តោយ ៨-១២ស.ម មានរោមទាំងសងខាង ។
- **ផ្កា** ៖ ផ្កាតូចៗពណ៌សក្បុស ចេញទៅចុងមែក ប្រែទៅពណ៌លឿងភាវពេលជិតរោយ ។
- **ផ្លែ** ៖ ផ្លែតូចៗ រាងស៊ុតទ្រវែង ពេលខ្ចីមានពណ៌បៃតង ហើយប្រែជាពណ៌ស្វាយក្រមៅ នៅពេលទុំ (អាចហូបបាន) ។

+ **កន្លែងដាំដុះ** ៖ ដុះក្នុងព្រៃល្បោះនៃទ្វីបអាស៊ី និង អូស្ត្រាលីផ្នែកក្តៅ ។ បន្តពូជដោយគ្រាប់

+**សមាសធាតុគីមី** ៖ Saponins, Flavonides, Phenolic, Proanthocyanidines, នៅក្នុងសំបកដើមមាន: Glucoside , Tetrasaccharide , Rubiginoside, Triterpenoid Saponins.

+ **ការប្រើប្រាស់** ៖ គ្រាប់ ឫស ដើម ស្លឹក

+ **ការព្យាបាល** ៖
- ស្លឹកទំពារបិទឫស រលាកភ្លើង ខ្វែររោល។
- ឫសព្យាបាលក្អកមាន់ របេង ពិសក្តៅ ឈឺចង្កេះ។
កិនអោយទៅជាម្សៅលាបថ្ងាសដើម្បីបញ្ចុះកំដៅ និង បំបាត់ឈឺក្បាល បំបាត់រមាស់ ដាំទឹកញ៉ាំចំពោះកូនក្មេងកើតជ្រាំង ដំបៅក្នុងមាត់
-ដើមសំរាប់ផ្សះស្បូន។

+ **កំរិតប្រើប្រាស់** ៖ ១០ ទៅ ៣០ក្រាម ដាំផឹកក្នុងមួយថ្ងៃ

+ **ឯកសារយោង** ៖
- សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ៣ ឆ្នាំ ២០០៩
- www.asianplant.net/sapindaceae/Lepisanthes_rubiginosa

**រៀបរៀងដោយនិស្សិត ៖ នន់ ដាលី**







# ស្មៅប្រម៉ាត់មនុស្ស

Nom Scientifique : ***Andrographis Paniculata Nees,***

Famille : **ACANTHACEAE**

# ស្មៅប្រម៉ាត់មនុស្ស

Nom Scientifique : ***Andrographis Paniculata Nees,***
Famille : **ACANTHACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ តិណជាតិមានរាង៤ជ្រុង ដុះឈរត្រង់ ថ្នាំងធំ បែកមែកច្រើន ។
  - **ស្លឹក** ៖ ស្លឹកពណ៌បៃតង មានរាងដូចផ្លែលំពែង ស្រួចចុង ដុះទល់ទងគ្នា ប្រវែង ៦-៧ ស.ម, ៣ស.ម តែមស្លឹករលោង ។
  - **ផ្កា** ៖ តូចពណ៌ស ត្របកផ្កាខាងលើផែកជា ៣ ត្របកជាប់គ្នា មានចំណុចស្វាយបន្តិច ត្រង់កណ្តាល ត្របកផ្កាខាងក្រោម ១ តែឯងកោងចុះ មានគេសរ ១ រាងកោង មានរោមស ខាងចុងពណ៌ស្វាយ។
+ **កន្លែងដាំដុះ** ៖ ដុះខ្លួនឯងនៅដីវាល ដីទំនេរ ពិសេសនៅតំបន់ភ្នំ ឬ គេដាំធ្វើជាថ្នាំ ។
+ **សមាសធាតុគីមី** ៖ ក្នុងដើម ឬ ស្លឹក មានជាតិជ័រ Tanin និងស្ករ ក្នុងស្លឹកមានជាតិ Deoxyandrogapholide 0.1%, Homoandrographolide 1.5%, Neoandrographolide 0.2%, Homoandrographolide, Panicolide, Andrographan, Andrographosterin ឬ មាន Mono-o- méthylewithin, Andrographin, Panicolide, Apigenic-7, 4-dimethyl-ester, រុក្ខជាតិទាំងមូលមាន 14-deoxy-11-oxoandrographolide, 14-deoxy-11-12-dideshydroandrographolide et Panniculide A.B.C ។
+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល, ប្រមូលផលពេលមិនទាន់មានផ្កា ប្រើស្រស់ ឬ ក្រៀម ។ មានរស់ជាតិល្វីងខ្លាំង ធាតុត្រជាក់ ។
+ **ការប្រើប្រាស់** ៖ ផ្តាសាយ, ក្អក, គ្រុនក្តៅ, រលាកបំពង់ក, រលាកសួត, រលាកប្លោកនោម, ធ្លាក់ស, ឈឺពោះពេលមានរដូវ, ព្យាបាលរោគលើសឈាម, រាគមូល, ចុះរាគ, រលាកពោះវៀន, បូសពិស, ពស់ចឹក(ប្រើស្រស់បុកបិទ) ។
+ **កំរិតប្រើប្រាស់** ៖ រុក្ខជាតិស្ងួត ប្រើ ៦-១០ ក្រាម ដាំទឹកផឹកក្នុងមួយថ្ងៃ រុក្ខជាតិស្រស់ប្រើ ១០-២០ ក្រាម ដាំទឹកផឹក្នុងមួយថ្ងៃ ។
+ **ឯកសារយោង** ៖ - Medicinal Plants of Cambodia, P127
  - http://www.ehow.com/facts_5518643_benefits-andrographis-paniculata-nees.html

**រៀបរៀងដោយនិស្សិតៈ ឈុន ខាសនា**







# ដើមជើងគោ

Nom Scientifique : *Bauhinia hirsute weinm*

Famille : **FABACEAE**

# ដើមជើងគោ

Nom Scientifique : *Bauhinia hirsute weinm*

Famille : **FABACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើតូចកំពស់ ២ - ៥ម មែកខ្ចីមានរោមពណ៌កាហ្វេ។

- **ស្លឹក** ៖ ស្លឹករាងមូលទ្រវែងស្រដៀងក្រចកជើងគោមានទ្រនុង ៧ - ៩ ផ្នែកខាងគល់រាងបេះដូង ខាងលើស្លឹករលោង ខាងក្រោមមានរោមពណ៌កាហ្វេ។

- **ផ្កាផ្លែ** ៖ ផ្កា ជាកញ្ចុំចេញពីគល់ត្របគាបស្លឹក មានផ្កាពណ៌ស្វាយ រឺ ស ទៅតាមប្រភេទនៃដើម។
ផ្លែជាប្រភេទផ្លែតូចសំប៉ែតប្រវែង ៦ - ៩សម មានគ្រាប់ពី ៥ - ១០។

+ **កន្លែងដាំដុះ** ៖ ដាំដុះនៅតំបន់ត្រូពិចដែលមានអាកាសធាតុក្តៅហើយសើម ឬ ដុះនៅតាមតំបន់វាលទំនាប នឹង ដាំលំអរតាមដងវិថី និង គេហដ្ឋាន។ល។

+ **សមាសធាតុគីមី** ៖ Bark contains Tannic acid, Glucose and a.Grownish gum.

+ **ផ្នែកប្រើប្រាស់** ៖ ស្លឹក, សំបក, ឬស។

+ **ការប្រើប្រាស់** ៖ -ស្ងោរ សំបកដើមហូបព្យាបាលរលាកក្រពះ និង លាងកមរមាស់រោគសើរស្បែក។
- ស្លឹក គេស្ងោរសំរាប់ជ្រលក់ពណ៌លើសូត្រ, អំបោះ, រឺ វត្ថុផ្សេងៗដែលគេចង់អោយមានពណ៌ស្រស់ស្អាត ដោយស្លឹកវាមានរសជាតិជូរ។
- ឬស ស្ងោរហូបព្យាបាលរលាកថ្លើម, រលាកក្រពះ។

+ **កំរិតប្រើប្រាស់** ៖ ១៥ - ៣0mg ដាំទឹកហូប។

+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ៤ (មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្រ្តបូរាណ) បោះពុម្ពឆ្នាំ២០០៨

**រៀបរៀងដោយនិស្សិត ៖ តាន់ ថាសនា**






# ដើមដូនទន្សាយ, ដូងព្រះគម

Nom Scientifique : ***Phoenic humilis Royle***

Famille : **ARECACEAE**

# ដើមដូងទន្សាយ, ដូងព្រះគម

Nom Scientifique : ***Phoenic humilis Royle,***

Famille : **ARECACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទតាលព្រឹក្សស្ទើរគ្មានដើម ដុះលូតលាស់ពី១០-២០សម។

- **ស្លឹក** ៖ ស្លឹកដុះចេញពីគល់ជារង្វង់គូទខ្លៅ ប្រវែង១មមឬលើស ជារាងស្លាបបក្សីកូនស្លឹកតូចវែងហើយស្រួចចុង មានស្ទើរជាមួយបន្លានៅខាងក្រោមស្លឹករាងខ្លីៗ កូនស្លឹកមានបណ្តោយ ២០-៣០សម ទទឹង ៧-១៤មម។

- **ផ្កា** ៖ ជាផ្កាខ្នុរតូច ក្បៀប រីក របើកចេញជាផ្កាខ្នែង ទងស្វែង រីទងធ្លាក់វែងប្រហែល ២០-៥០សម។

- **ផ្លែ** ៖ ផ្លែតូចរាងស៊ុត ពណ៌លឿងពណ៌ក្រហម ហូបបាន។ គ្រាប់វាមានទទឹង ៥មម និងបណ្តោយ ១០មម។

+ **កន្លែងដាំដុះ** ៖ ដុះនៅកន្លែងដីវាលក្បែរជើងភ្នំ។ គេយកមកដាំដើម្បីលំអ។

+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ

+ **ផ្នែកប្រើប្រាស់** ៖ ផ្លែ គម។ គេយកគម ដោយគាស់ កាត់រឹសនិងកាត់ធាងចេញ រួចលាងទឹកឱ្យស្អាតពុះចិតជាចំណិតស្តើងៗ ហាលថ្ងៃឲស្ងួតទុកប្រើ។

+ **ការប្រើប្រាស់** ៖ ផ្លែវាព្យាបាលរាគ និងស្រវឹងស្រា។
គម ដាំទឹកផឹក ព្យាបាលក្រពះ ខ្យល់ស្រើត ឫសដូងបាត។

+ **កំរិតប្រើប្រាស់** ៖ គមស្ងួត: ២០-៣០ក្រាមដាំទឹកផឹកក្នុងមួយថ្ងៃ។
២០-៥០គ្រាប់សំរាប់ផ្លែទុំ។

+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជា បោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ ឆ្នាំ២០១០។

**រៀបរៀងដោយនិស្សិត ៖ ឈឿង ថាសុមិនា**





## ដកដាវ

Nom Scientifique : ***Spatholobus***

Famille : **FABACEAE**

# ដកដាច

Nom Scientifique : ***Spatholobus***

Famille : **FABACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ឈ្មោះ ចុល្លព្រឹក្ស ឬ ព្រឹក្សតូចម្យ៉ាង កំពស់ 6-18 ម វាមានរសជាតិល្វីង ។ រុក្ខជាតិនេះអាចក្លាយជាវល្លិ៍ធំបាន ។ ឈើសំរាប់សង់ផ្ទះ ធ្វើគ្រឿងសង្ហារឹមក្នុងផ្ទះ, បរិភោគបាន ។
+ **កន្លែងដាំដុះ** ៖ ដុះក្នុងព្រៃស្រោង តាមមាត់ស្ទឹង លើដីមានជាតិកំលាសិលាទំនាប ឬ លើភ្នំទាបៗនៃប្រទេសឥណ្ឌា និងឧបទ្វីបឥណ្ឌូចិន។
+ **ផ្នែកប្រើប្រាស់** ៖ ដើម
+ **ការព្យាបាល** ៖ ស្ពឹកដៃជើង ,បំបាត់ការឈឺចាប់ស្ត្រីមានរដូវ សំរួលចលនាឈាមរត់។
+ **កំរិតប្រើប្រាស់** ៖ 10-20 g
+ **ឯកសារយោង** ៖ http://www.oswaldasia.org/spatholobus

**រៀបរៀងដោយនិស្សិត ៖ ឃុន ណាទីន**





# ដើមអផ្ទក់ ឬ ក្រឡែត

Nom Scientifique : ***Olax Scandens Roxb .***

Famille : **OLACACEAE**

# ដើមអផ្ទក់ ឬ ក្រឡិត

Nom Scientifique : *Olax Scandens Roxb.*

Famille : **OLACACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាចុល្លព្រឹក្សវិល្លិមានប្រវែងរហូតដល់៥ម៉ែតរឺលើសមែខ្ចីពណ៌បៃតងមានរោមខ្លីៗ។
  - **ស្លឹក** ៖ ទោលឆ្លាស់ទងរាងផ្លែលំពែងទ្រវែងគែមស្លឹកពេញស្លឹករលោងប្រវែង៦ទៅ១០cm ទទឹង២,៥-៤cm។
  - **ផ្កាផ្លែ** ៖ -ផ្កា ៖ជាកញ្ចុំចេញពីប្រគាបស្លឹក ជាចង្កោម ផ្កាពណ៌ស។
    -ផ្លែ ៖រាងមូលស្រួចចុងមានគំរបដូចមួកក្នុងផ្លែមានសាច់រុំគ្រាប់។
+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯងនៅគ្រប់ទីកន្លែងបន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ។
+ **ផ្នែកប្រើប្រាស់** ៖ ស្លឹក សំបកដើម រឹស ដើម។
+ **ការប្រើប្រាស់** ៖ -ស្លឹក ៖បុកបំពោកក្បាលផ្កាសាយតឹងច្រមុះ។
  -ដើម ៖បង្កើនឈាមជំនួយបេះដូងជំនួយកំលាំង។
  -សំបកដើម៖ផ្សំជាមួយរុក្ខជាតិដទៃទៀតដុសជាមួយទឹកអង្ករបន្តក់ភ្នែកកន្ទុយថ្លែន
  -រឹស ៖ដាំផឹកគ្រុនក្តៅទំលាក់ព្រូន។
  -សាច់ឈើ ៖បន្សាបជាតិពុលកាមរោគស្លេកស្លាំងបង្កើនឈាមក្រហម។
+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី ១៥ ទៅ ៣០ក្រាម។
+ **ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជាភាគ២បោះពុម្ពដោយក្រសួងសុខាភិបាលមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ២០០៨។

**រៀបរៀងដោយនិស្សិត ៖ ទេខ ដាលី**







## ដើម ដកពរ

Nom Scientifique : *Markhamia stipulacea*

Famille : **BIGNONIACEAE**

# ដើម ជកពារ

Nom Scientifique : *Markhamia stipulacea*

Famille : **BIGNONIACEAE**

+ **លក្ខណៈរុក្ខជាតិ** : ជាដើមឈើមធ្យមមានកំពស់ពី ១០ ទៅ ១៥ ម មែកខ្ចីគ្របដណ្តប់ដោយរោមពណ៌ ត្នោត។
  - **ស្លឹក** : រោមស្លាបសេស មានពី ៧ ទៅ ១១ កូនស្លឹក ។ កូនស្លឹករាងស៊ុតទ្រវែង ចុងចុង មានប្រវែងពី ១២ ទៅ ២០ស.ម ទទឹង ៤ ទៅ ៧ ស.ម ។
  - **ផ្កាផ្លែ** : កញ្ចុំផ្កានៅចុងមែក ក្នុង ១កញ្ចុំមានពី ៤ ទៅ ១០ ផ្ការីកបន្តបន្ទាប់ ផ្កាមានពណ៌លឿង ស្វាយ ប្រវែង ៥ ទៅ ៨ ស.ម ។ និង ផ្លែជាកូរវែង ជាប្រភេទផ្លែស្ងួតមានរោម មានគ្រាប់ច្រើន ចេញផ្កានៅខែ កុម្ភៈ និង ខែ មេសា។
+ **កន្លែងដាំដុះ** : ដុះនៅព្រៃល្បោះ តំបន់ភ្នំ ។ បន្តពូជ ដោយគ្រាប់។
+ **សមាសធាតុគីមី** : មិនទាន់មានការស្រាវជ្រាវ នៅឡើយ។
+ **ផ្នែកប្រើប្រាស់** : ផ្កា សំបក ស្លឹក។
+ **ការប្រើប្រាស់** :
  - ស្លឹក ៖ ព្យាបាលគ្រុនក្តៅ ស្អក ក ។
  - សំបក និង ដើម ៖ ផ្សំជាមួយរុក្ខជាតិផ្សេងទៀតព្យាបាលធ្លាក់ ស ។
  - ផ្កា ៖ ព្យាបាល ទឹកនោមផ្អែម ។
+ **កំរិតប្រើប្រាស់** : ប្រើប្រាស់ពី ២០ ទៅ ៣០ ក្រាម ដាំទឹកផឹកក្នុង ១ ថ្ងៃ ។
+ **ឯកសារយោង** : http://www.google.com.kh/search?q=Markhamia+stipulacea&hl=km&prmd=imvns&source=lnms&tbm=isch&ei=-MjRT8uEO8SViAe52-CUAw&sa=X&oi=mode_link&ct=mode&cd=2&ved=0CEMQ_AUoAQ&biw=1279&bih=594

រៀបរៀងដោយនិស្សិត ៖ ម៉ិចចំណាន ប្រណិត







## ដៃខ្លាដើម

Nom Scientifique : ***Gandenia Angkorensis***

Famille : **RUBIACEAE**

# ដៃខ្លាដើម

Nom Scientifique : ***Gandenia Angkorensis***
Famille **RUBIACEAE**

:

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទចុល្លព្រឹក្ស

- **ស្លឹក** ៖ មានរាងជាលំពែងមានពណ៌បៃតងផ្ទៃក្រោមស្លឹកមានទ្រនុងច្បាស់

+ **កន្លែងដាំដុះ** ៖ ដុះក្នុងព្រៃនៃព្រះរាជាណាចក្រកម្ពុជាលាវសៀម
+ **សមាសធាតុគីមី** ៖ មិនមានពត៌មានជាក់លាក់
+ **ផ្នែកប្រើប្រាស់** ៖ ដើម ឬស ស្លឹក មែក
+ **ការប្រើប្រាស់** ៖ ស្លឹក មែក១០ទៅបញ្ចុះទឹកនោម (diuretic) រលាកស្បូន(inflammatory of uterus) ព្រាយក្រឡាភ្លើង(eclampsia)
+ **ឯកសារយោង** ៖ បញ្ជីឱសថរុក្ខជាតិកម្ពុជា២០១២

**រៀបរៀងដោយនិស្សិត ៖ ផេង សុភ័ក្រ**







# ទល្លីដោះគន់

Nom Scientifique : ***Tetracera scandens (Linn)***

Famille : **DILLENIACEAE**

# វល្លិ៍ដោះគន់

Nom Scientifique : *Tetracera scandens (Linn)*

Famille : **DILLENIACEAE**

| | | |
|---|---|---|
| + **លក្ខណៈរុក្ខជាតិ** | ៖ | ជាប្រភេទវល្លិ៍សំបកគគ្រើមពណ៌ត្នោត។ស្លឹករាងទ្រវែងមានសរសៃឆ្មារ ពណ៌ត្នោតបៃតង។ដើមទន់ភ្លន់រស់រវើក ផ្តល់នូវខ្សែចំណងដ៏រឹងមាំបាន។ |
| - **ស្លឹក** | ៖ | ស្លឹករាងពងក្រពើប្រវែងពី 4-10cm ទទឹងពី 2,5-5cmគល់ស្លឹកមូលស្ទិត |
| - **ផ្កាផ្លែ** | ៖ | ផ្កាមាន4-5 sépales ovales មានប្រវែង3-4 mm, 3 pétales ovales et blancs ប្រវែងពី 4-5 mm |
| + **កន្លែងដាំដុះ** | ៖ | ជាប្រភេទវល្លិ៍សំបកគគ្រើមពណ៌ត្នោត។ស្លឹករាងទ្រវែងមានសរសៃឆ្មាល ពណ៌ត្នោតបៃតង។ដើមទន់ភ្លន់រស់រវើក ផ្តល់នូវខ្សែចំណងដ៏រឹងមាំបាន។ |
| + **សមាសធាតុគីមី** | ៖ | Tannins, Betulin និង Betulimic acid ។ |
| + **ផ្នែកប្រើប្រាស់** | ៖ | ឬស វល្លិ៍ និង ស្លឹក |
| + **ការប្រើប្រាស់** | ៖ | -ទឹកក្នុងដើមមានគុណភាពព្យាបាលរោគកន្ទួលចេញនៅលើស្បែក។<br>-ស្លឹក និង មែកខ្ចីៗ បុកឲ្យល្អិតធ្វើជាថ្នាំបិតបំពោកលើរបួស ពស់ចឹក។<br>-ឬស ប្រើលាបខាងក្រៅព្យាបាលរលាកភ្លើង ដាំទឹកផឹកព្យាបាល ក្អកធ្លាក់ឈាម និង ជាថ្នាំសំរាប់ស្ត្រីឆ្លងទន្លេហើយ។ |
| + **កំរិតប្រើប្រាស់** | ៖ | ពី ១៥ ក្រាម ទៅ ៣០ក្រាម ក្នុងមួយថ្ងៃ |
| + **ឯកសារយោង** | ៖ | -សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ១ (មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្រ បូរាណ) បោះពុម្ពឆ្នាំ២០០៨<br>http://www.plantes-botanique.org/espece_Tetracera_scandens |

**រៀបរៀងដោយនិស្សិត ៖ ហេង ជុងហ៊័រ**









# ដើមត្បាល់ដែក

Nom Scientifique : ***Peliosanthes teta Andrews***

Famille : **CONVALLARIACEAE**

# ដើមត្បាល់ដែក

Nom Scientifique : ***Peliosanthes teta Andrews***

Famille : **CONVALLARIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ តិណជាតិដុះជាគុម្ពរស់នៅបានយូរឆ្នាំ មានឫសវែង មានពណ៌សទំហំ ២-៣ម.ម មានជាទឹកច្រើន។
  - **ស្លឹក** ៖ ដុះចេញពីគល់ទងវែងរាងផ្លែលំពែង មានទ្រនុងស្របច្រើនរាងផ្នត់ធ្នូតៗ តាមបណ្ដោយ។
  - **ផ្កា** ៖ កញ្ចុំផ្ការាងជាកួរប្រវែង ៨-១៥ស.ម ផ្កាស្ថិតនៅផ្នែកខាងលើ២ភាគ៣នៃទង។ ផ្កានិមួយៗមានទងប្រវែង ១-៣ម.ម មានកេសរ ៦ ជាប់គ្នា ផ្កានៅខែវិច្ឆិកា។
  - **ផ្លែ** ៖ មានផ្លែជាផ្លែសាច់ រាងជាស៊ុត ជាចង្កោមចេញពីគល់។
+ **កន្លែងដាំដុះ** ៖ ដុះនៅតំបន់ព្រៃភ្នំដែលមានដីសើម ក្រោមដើមឈើធំ មាត់ជ្រោះ។ល។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ។
+ **ផ្នែកប្រើប្រាស់** ៖ ឫស(រសផ្អែម សារធាតុត្រជាក់)។
+ **ការប្រើប្រាស់** ៖ ដាំហូបប៉ូវកំលាំង កបនឹងជំងឺក្អកមានស្លេស្ម ឈឺទ្រូង ដួលប៉ះទង្គិច ឈឺឆ្អឹងជំនី។
+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ស្ងួតពី ១៥-២០ក្រាម ដាំទឹកផឹក ឬត្រាំស្រា។
+ **ឯកសារយោង** ៖
  - រុក្ខជាតិឱសថកម្ពុជា ភាគ៣ ឆ្នាំ២០០៩ នៃមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ។
  - //tropicalflowers.la.coocan.jp/Asparagaceae/Peliosanthes teta/Peliosanthes teta.htm

**រៀបរៀងដោយនិស្សិត ៖ ជិន សុជាតិ**







## ចន្ទ័រាប, ឆាយនីគាខ

Nom Scientifique : ***Homalomena aromatica***

Famille : **ARACEAE**

# ចន្ទ័រាប, ឆាយនីគាខ

Nom Scientifique : ***Homalomena aromatica***

Famille : **ARACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិដែលរស់បានយូរឆ្នាំមានកំពស់ ២៥ស.ម ដើមរាងជាបំពង់មានលក្ខណៈ ហឹរ ក្តៅ មានរសជាតិល្វីង និង ក្លិនក្រអូបប្រហើរ។
- **ស្លឹក** ៖ ដុះចេញពីដើមរឺមើម និងមានរាងបេះដូងស្លាបព្រួញមានប្រវែងបណ្តោយ ១៥-២០ស.ម និងទទឹង ៨.១២ស.ម មានស្រទបគល់រាងទ្រវែង។
- **ផ្កាផ្លែ** ៖ ខួរផ្ការាងស្ទើរស៊ីឡាំងមានពណ៌បៃតងលឿង ផ្លែមានសាច់ ទឹកច្រើនគ្រាប់ច្រើនរាងទ្រវែង។

+ **កន្លែងដាំដុះ** ៖ ដុះនៅតំបន់ត្រូពិចដែលមានអាកាសធាតុក្តៅហើយសើមជាពិសេស នៅតំបន់ភ្នំខ្ពង់រាប និងកន្លែងសើម ក្បែរមាត់ទឹក។
+ **សមាសធាតុគីមី** ៖ Two new sesquiterpene alcohols, homalomenol C and homalomenol D, besides (–)-α-cadinol and (–)-T-muurolol, have been isolated from the roots of *Homalomena aromatica*.
+ **ផ្នែកប្រើប្រាស់** ៖ ដើម និង ឬស ចិតជាចំនិតហាលថ្ងៃអោយស្ងួត។
+ **ការប្រើប្រាស់** ៖ ប្រើក្នុងការព្យាបាលថ្លើម ក្រលៀន បំបាត់ការឈឺចាប់ រោគសើរស្បែក ឈឺសន្លាក់ ខ្សោយចង្កេះ ជង្គង់ ស្ពឹកស្រពន់ចុងជើង កំចាត់ពួកផ្សិត ប្រើជាប្រេងក្រអូប និង ប្រើជាថ្នាំសុខភាពពាន់ឆ្នាំ។
+ **កំរិតប្រើប្រាស់** ៖ ៥-១០ក្រាម នៃដើម រឺ ឬស ដាំផឹក រឺ ត្រាំស្រាផឹក។
+ **ឯកសារយោង** ៖ -លោកគ្រូឱសថបុរាណ: ថៃ តេកស្រ៊ុន
  - Medicinal Plants of Vietnam, Cambodia and Laos

រៀបរៀងដោយនិស្សិត ៖ ខាន់ សុម៉ានីតា






# ដើមត្រថុក ឬតាថុក

Nom Scientifique : ***Costus speciosus***

*Famille :* ***COSTACEAE***

# ដើមត្រថុក ឬតាថុក

Nom Scientifique : ***Costus speciosus***

*Famille :* ***COSTACEAE***

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិដែលមានមើម ដើមមូល មានទឹកច្រើន កំពស់ ១.២ ម៉ែត្រ។
  - **ស្លឹក** ៖ ស្លឹកទោល រលោង រាងដូចផ្លែលំពែង ដុះវិលជុំវិញដើម ទទឹងស្លឹក ៦.៧ Cm បណ្ដោយ ១៥.២០ Cm។
  - **ផ្កាផ្លែ** ៖ កញ្ចុំផ្កាចេញនៅចុងមែក, គ្មានទង, ផ្កាពណ៌ស ឬ ពណ៌រាងដូចត្រែ រីកស្រស់ស្អាត រីកម្ដង ១ ឬ ២ ត្របកផ្កាពណ៌ក្រហម។
  ជាប្រភេទផ្លែស្ងួតពណ៌ក្រហម មានគ្រាប់ច្រើនពណ៌ខ្មៅរលោង។
+ **កន្លែងដាំដុះ** ៖ មានឃើញដុះនៅលើដីសើមស្ទើរគ្រប់តំបន់។
+ **សមាសធាតុគីមី** ៖ Furostanol glycosides, coumarins, saponins និង diosgenin
+ **ផ្នែកប្រើប្រាស់** ៖ មើម ឫស។
+ **ការប្រើប្រាស់** ៖ មើម : បញ្ចុះទឹកនោម ព្យាបាលហើមទឹក ធ្លាក់ស រោគឆ្លងតាមផ្លូវទឹកនោម ដំបៅខ្ទុះ រលាក ហើម ទម្លាក់ព្រូន រលាករន្ធប្រចៀកមានខ្ទុះ បន្ទន់លាមក បន្តក់ ឈឺភ្នែក អាហារមិនរលាយ ពស់ចឹក ក្អក់មាន់ នោមទាស់ គ្រុនផ្ដាសាយ ទាចទឹក។
  ឫស : ទម្លាក់ព្រូន ទម្លាក់ស្លេស្ម ក្អក និងរោគសើរស្បែក។ រោគសើរស្បែកដោយយកមើមត្រថុកស្ងោ លាង។
+ **កំរិតប្រើប្រាស់** ៖ មើមស្ងួត ៣-១០ ក្រាម ដាំផឹកក្នុង១ថ្ងៃ។
  មើមស្រស់ ២០-៥០ក្រាម ដាំផឹកក្នុង១ថ្ងៃ។
+ **ឯកសារយោង** ៖ ដកចេញពីសៀវភៅរុក្ខជាតិឱសថកម្ពុជាភាគទី១ ទំព័រទី១០១ ឆ្នាំ២០០៨

**រៀបរៀងដោយនិស្សិត ៖ ឡាយ សុខរក្សា**







**ដើមត្រឡាត់ រឺ តាឡាត់**

Nom Scientifique : ***Canariume albume***

Famille : **BURSERACEAE**

# ដើមត្រឡាត់ រឺ គាឡាត់

Nom Scientifique : *Canariume albume*

Famille : **BURSERACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិដើមធំ ។

- **ស្លឹក** ៖ ស្លឹកសមាស ឆ្លាស់ប្រវែង ៣៥សម រឺ វែងជាងនោះ មួយធាងមានស្លឹក ៣-៦គូស្លឹកស្រួចចុងគ្របដណ្ដប់ដោយរន្ធធ្មារខ្ចីប្រផេះ

- **ផ្កាផ្លែ** ៖ ផ្លែលើស្លឹកពណ៌បៃតងខ្ចីជាងខាងក្រោម។ ផ្ការាងមូលក្រពុំជាកញ្ចុំ ២-៣ ផ្កានៅចុងមែកទងវែង។ រូបរាងពងក្រពើ ប្រវែង ៤៥មម ទទឹង ២០-២៥មម ស្រួចចុងបន្តិចៗ គ្រាប់ផ្លែរឹងនៅពេលទុំ រាងពងក្រពើគ្មានជ្រុង រលោង ខាងក្នុងមានបីថត។

+ **កន្លែងដាំដុះ** ៖ ជារុក្ខជាតិដុះខ្លួនឯង លើដីទួល តំបន់ភ្នំ។

+ **សមាសធាតុគីមី** ៖ 1,2% Protides ; 12%Hydrate de carbone ; 0,2% Calcium ; 0,06%Phospore ; 0,021% Vitamine C .45% Sabiéne ; 16,7% Terpinéne ; 10,8% Terpineol ; 9% Alpha-épinéne ; 4,9% Alpha-terpinéne.

+ **ផ្នែកប្រើប្រាស់** ៖ ផ្លែខ្ចី ផ្លែចាស់ គ្រាប់ផ្លែ។ ផ្លែមានរសជាតិជូរ ផ្អែមចត់ មិនពុល។

+ **ការប្រើប្រាស់** ៖ ផ្លែស្ងួតគេប្រើជួយក្រពះក្នុងការរំលាយអាហារ។បន្សាបស្រានៅពេលស្រវឹង។ផ្លែប្រើព្យាបាលក្អកស្លេស្ម ឈឺបំពង់ក។គ្រាប់ទំលាក់ព្រូន។

+ **កំរិតប្រើប្រាស់** ៖ បៀម ១ផ្លែ ៤ទៅ៥ថ្ងៃ

+ **ឯកសារយោង** ៖ សៀវភៅឱសថបុរាណកម្ពុជា ភាគ២

រៀបរៀងដោយនិស្សិត ៖ គុន បុប្ផា








# ដើមត្រសេក

Nom Scientifique : *Peltophorum dasyrrhachis (Miaq) Hurz*

Famille : **FABACEAE**

# ដើមត្របសេក

Nom Scientifique : ***Peltophorum dasyrrhachis (Miaq) Hurz***

Famille : **FABACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាដើមមានកំពស់រហូតដល់ ៣០ ម៉ែត្រ។
  - **ស្លឹក** ៖ ស្លឹករួមស្លាបពីដងដុះឆ្លាស់ទងប្រវែង ១៥-៤០ ស.ម។ ស្លាបតូចមានពី ៥-៩គូ ដែលមានកូនស្លឹកពី ៦-១៦ គូ រាងស៊ុតត្រវែង១ពី ១០-១៥ ម.ម ទទឹង ៥-១០ ម.ម។
  - **ផ្កាផ្លែ** ៖ -កញ្ចុំផ្កាចេញពីប្រគាបស្លឹក ជាចង្កោម កួរធ្លាក់សំយាក មានប្រវែង១ពី ១៥-៣០ ស.ម។
    -ផ្លែជាកួរសំប៉ែតទុំពណ៌ក្រហមត្នោត គ្រាប់វាតំរៀបតាមបណ្តោយផ្លែ។
+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯង នៅតាមព្រៃល្បោះតាមមាត់ផ្លូវ ជាយព្រៃ បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ។
+ **ផ្នែកប្រើប្រាស់** ៖ សំបក ដើម
+ **ការព្យាបាល** ៖ រាគមួល ហើមពោះ រាគអាចម៍ ក្អួត ទំលាក់រដូវ ឆ្លងទន្លេហើយ ទាស់រាកចេញទឹកដោះ។
+ **កំរិតប្រើប្រាស់** ៖ ១០-២០ ក្រាម ដាំផឹក។
+ **ឯកសារយោង** ៖ -សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ៣ (មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្រ្តបូរាណ) បោះពុម្ពឆ្នាំ២០០៩
  -www.google.fr, htt:www.stuartxchange.org/Hilagak.html

**រៀបរៀងដោយនិស្សិត ៖ ម៉ន ច័ន្ទម៉ាលីកា**







# គ្រសៀត , គន្ធី

Nom Scientifique : *Vitex Negundo L*

Famille : **VERBENACEAE**

# គ្រសៀត , គន្ធី

Nom Scientifique : *Vitex Negundo L*

*Famille :* **VERBENACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាដើមចុល្លព្រឹក កំពស់ ២ទៅ ៨ម៉ែត្រ សំបកពណ៌ក្រហមត្នោត

- **ស្លឹក** ៖ ស្លឹកដូចម្រាមដៃមាន៥ស្លឹក ដុះទល់ទងគ្នា ស្លឹកនីមួយៗ ប្រវែង៤ទៅ១០សង់ទីម៉ែត្រ ផ្ទៃក្រោមស្លឹកមានរោម

- **ផ្កា** ៖ ផ្កាពណ៌ស ពេលរីកប្រែទៅជាពណ៌ខៀវ, ផ្លែមូលដូចស៊ុតហើយស្រួច ទំហំ៤មីលីម៉ែត្រ ពេលទុំពណ៌ខ្មៅ រឺ ស្វាយរាងក្រហមតិចៗ

+ **កន្លែងដាំដុះ** ៖ តំបន់ត្រូពិច និងតំបន់ដែលមានអាកាសធាតុក្តៅហើយសើម

+ **សមាសធាតុគីមី** ៖ Flavonoids casticin , chrysoplenol D, luteolin ,iso- orientin.
ស្លឹក : Essential oils, phellandrene, pinene,sabinene, resin.
Iridoid ដែលមាននៅក្នុង V negudo រួមមាន: Iridoid glycosides aucubin, agnuside , 2´-þ-hydroxybenzoyl mssaenosidic acide, 6´-þ- hydroxybenzoyl mssaenosidic, nishindaside.

+ **ផ្នែកប្រើប្រាស់** ៖ ឬស ផ្កា គ្រាប់ ស្លឹក

+ **ការប្រើប្រាស់** ៖ ឬស ៖ ពិបាករំលាយអាហារ រលាកពោះវៀន ឈឺសន្លាក់ កើតព្រូន បូស ឃ្លង់ បំបាត់ស្លេស បញ្ចុះទឹកនោម, ផ្កា ៖ រាគ ក្តៅខ្លួន ជំងឺថ្លើម, គ្រាប់ ៖ ជំងឺសើរស្បែក ឃ្លង់ តំបៅមាត់, ស្លឹក ៖ ក្អក ហឺត

+ **កំរិតប្រើប្រាស់** ៖ ស្លឹក ៖ ១,៥ក្រាម ទៅ៣ក្រាម, ស្លឹកស្ងួត ៖ ៣០០មីលីក្រាម ទៅ៦០០មីលីក្រាម ទឹកដមនៃផ្លែ ៖ ១០ml ទៅ២០ ml ដាំរំងាស់យកទឹក ៖ ៥០ ml ទៅ១០០ ml

+ **ឯកសារយោង** ៖
www pyronergen.com/other-products/chaste tree-tea htm
Vitex negundo-wikipedia ,the free encyclopedia.htm
Medicinal use and biological activities of vitex negundo.htm, medicinal plants of cambogia

រៀបរៀងដោយនិស្សិត ៖　ឌុយ ម៉ួយខេង








# ដើមថ្កូវ

Nom Scientifique : *Anthocephalus chinensis*

Famille : **RUBIACEAE**

# ដើមថ្កូវ

Nom Scientifique : ***Anthocephalus chinensis***
Famille : **RUBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើ មានកំពស់ពី ៦ ដល់ ១៥ ម៉ែត្រ។

- **ស្លឹក** ៖ ស្លឹកទោល ឆ្លាស់ទង ទទឹង ៨ សង់ទីម៉ែត្រ បណ្តោយ ១៥ សង់ទីម៉ែត្រ។ ផ្ទៃខាងលើរលោងពណ៌បៃតង។

- **ផ្កាផ្លែ** ៖ កញ្ចុំផ្កាចេញពីប្រគាបស្លឹករាងមូលក្រឡុំ។ ផ្កាពណ៌លឿងជាមួយផ្លែដ៏ច្រើន ពណ៌លឿងមានបន្ទាត់ផ្ចិត ៦ សង់ទីម៉ែត្រ។ ផ្លែបរិភោគបាន សំបកផ្លែមានរោម។

+ **កន្លែងដាំដុះ** ៖ ដុះនៅក្នុងព្រៃរបោះ វាលទំនាប ពាសពេញកម្ពុជា។ គេដាំសំរាប់យក ម្លប់ក្នុងភូមិ ឬមាត់ទន្លេ។ ដើមវាលូតលាស់លឿន ធ្វើជាក្រដាសបាន។

+ **សមាសធាតុគីមី** ៖ Cadambine, 3Alpha dihydrocadambine, Isodihydrocadambine, Cadamine, Isocadamine, Acide cadambagénique.

+ **ផ្នែកប្រើប្រាស់** ៖ ដើម ស្លឹក និង សំបកដើម។

+ **ការប្រើប្រាស់** ៖ - សំបកដើម និង ដើម ដាំទឹកផឹកមានប្រសិទ្ធភាព ប្រឆាំងរាល់ការឈឺចុកចាប់។
-ទឹករបស់ផ្លែនិង ទឹកដាំរបស់សំបកដើមប្រើជាថ្នាំបញ្ចុះកំដៅ គេតែងតែយកមកបំពោកលើថ្ងាសកូនក្មេង។
- ស្លឹកថ្កូវសំងួត រួចដក់ ព្យាបាលឈឺក្បាល និង ប្រតិកម្មរលាកច្រមុះ។
-បង្កើនគ្រាប់ឈាមក្រហម ព្យាបាលទាស់ពេលកូនខ្ចី ឃាត់ឈាម និង ព្យាបាលស្បូន(ដំណឹងពីគ្រូបូរាណ)។

+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី ១៥ ទៅ ៣០ ក្រាម។

+ **ឯកសារយោង** ៖ -មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ
–http://08hachi.blogspot.com/2011/08/anthocephalus-cadamba.html
-http://en.wikipedia.org/wiki/Cephalanthus_chinensis

**រៀបរៀងដោយនិស្សិត ៖ ម៉េង ឡុចធី**







# វល្លិ៍ ថ្លឹង ឬ គោតព្រុំ

Nom Scientifique : *Aganomerion polymorphum*

Famille : **APOCYNACEAE**

# វល្លិ ថ្នឹង ឬ កោតព្រុំ

Nom Scientifique : *Aganomerion polymorphum*

Famille : **APOCYNACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ -ជាវល្លិ៍វារតោងឡើងដើមឈើ មានជ័រពណ៌ស។
- **ស្លឹក** ៖ -ទោល ទល់ទង គែមស្លឹកពេញ រាងផ្លែលំពែង ឬ រាងស៊ុតទ្រវែង ទទឹង២-៨ស.ម បណ្ដោយ 4-៦ស.ម។
- **ផ្កា** ៖ -កញ្ចុំផ្កាចេញនៅចុងបមក ផ្កាពណ៌ក្រហមលាយស។
- **ផ្លែ** ៖ -១ គូវែង ចេញពីទងតែមួយទល់គ្នា គ្រាប់មានរោមស ដូចសំឡីនៅខាងអាចប៉ើង រសាត់តាមខ្យល់។

+ **កន្លែងដាំដុះ** ៖ -ដុះនៅតាមទីទួល ដំបូក តំបន់ភ្នំ បន្តពូជដោយគ្រាប់។

+ **ផ្នែកប្រើប្រាស់** ៖ -ឬសវល្លិ៍។

+ **ការប្រើប្រាស់** ៖ -វល្លិ៍ : ព្យាបាលឈាមខ្ពស់ កាត់ស្លេស្ម ផ្សះដំបៅរលួយ
-ឬស : ខ្យល់ស្រឹត ចុកពោះ ចុកសាច់ដុំ
-ស្លឹក : រសជាតិជូរ គេនិយមប្រើជាគ្រឿងសម្លរ និង ស្ងោរសំរាប់លាងរបួស និង ដំបៅ និង រោគសើរស្បែក។

+ **កំរិតប្រើប្រាស់** ៖ -ប្រើប្រាស់ពី១៥-៣០គ្រាប់ ដាំផឹកក្នុងមួយថ្ងៃ។

+ **ឯកសារយោង** ៖ -រុក្ខជាតិឱសថកម្ពុជា ភាគ១ ឆ្នាំ២០០៨។

**រៀបរៀងដោយនិស្សិត ៖ ច័ន្ទ ចច្ចិកា**









# ដើមទន្ត្រានខេត្ត ឬ បារាំងសេស

Nom Scientifique : ***Eupatorium odoratum L.***

Famille : **ASTERACEAE**

# ដើមទន្រ្ទានខេត្ត ឬ បារាំងសេស

Nom Scientifique : ***Eupatorium odoratum L.***

*Famille :* **ASTERACEAE**

**+ លក្ខណៈរុក្ខជាតិ** ៖ គុម្ពព្រឹក្សកំពស់ពី ១-៣ ម រស់បានច្រើនឆ្នាំ ដើមមូលមានថ្នាំង ពណ៌បៃតងខ្ចី មែកមួយគូដុះចេញពីថ្នាំង ដើមមានបណ្តូលស្តោត។

**- ស្លឹក** ៖ ទោល ដុះទុលទង ចេញពីថ្នាំង ស្លឹកមានរាងជាផ្លែលំពែង គែមស្លឹកមានធ្មេញរណាធំៗ មានរោមទាំងសងខាង ទ្រនុងដុះបណ្តោយស្លឹកមាន ៣ខ្សែ។

**- ផ្កា** ៖ កញ្ចុំផ្កាចេញពីចុងមែក មានពណ៌ផ្កាឈូកខ្ចី ឬ ពណ៌ស។

**+ កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯង តាមដីវាលទំនេរ។

**+ សមាសធាតុគីមី** ៖ carboxylic acid , stigmasterol ,
β-sitosteryl-3-0-scleropyrate, stigmasteryl-3-0-scleropyrate,
β-sitosterol, two new esters & two well-known-sterol

**+ ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល។

**+ ការប្រើប្រាស់** ៖ ស្លឹកៈ ឃាត់ឈាម រាគមូល រាគអាចម៍កូនក្មេង រលាកអញ្ចាញធ្មេញ កើតបូស កាត់បន្ថយជាតិពិសពស់ខាំ (ដោយទំពារស្លឹកស្តោះ) រមាស់ (ដាំទឹកងូត) ជញ្ជ្រាំ រុក្ខជាតិទាំងមូល បាចក្នុងស្រែដើម្បីកំចាត់សត្វផ្ញើរ ប្រាណ (ប៉ារ៉ាស៊ីត)
ឫសៈ ធ្លាក់ស (រួមជាមួយរុក្ខជាតិដ៏ទៃ) គ្រុណចាញ់ (រួមជាមួយរុក្ខជាតិដ៏ទៃ)

**+ កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី ១០-៣០ក្រាម ដាំទឹកផឹក ក្នុងមួយថ្ងៃ (ស្លឹក ឬ ឫស)។

**+ ឯកសារយោង** ៖ http://giangduongykhoa.wordpress.com/2008/10/05
សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ១ (មជ្ឈមណ្ឌលស្រាវជ្រាវវេជ្ជសាស្រ្តបូរាណ)

**រៀបរៀងដោយនិស្សិត ៖ ហាន សុលីតា**








# ដើមទ្រមូងរឺ គ្រមូង

Nom Scientifique : *Garcinia oliveri Perre*

Famille : **Clusiaceae ou Gutifereae**

# ដើម ទ្រមូង រំទ្រមូង

Nom Scientifique : *Garcinia oliveri Perre*
Famille : **CLUSIACEAE OU GUTIFEREAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើធំ មានកំពស់រហូតដល់ ៣០ ម៉ែត្រ មានជ័រពណ៌លឿង។

- **ស្លឹក** ៖ ស្លឹកខ្ចីគេនិយមប្រើជាម្ហូរសំរាប់ស្ល ។

- **ផ្កាផ្លែ** ៖ ផ្លែស្រដៀងនឹងផ្លែមង្ឃុត មានរសជូរ អាចញាំបាន។

+ **កន្លែងដាំដុះ** ៖ ដុះនៅព្រៃពាក់កណ្តាលស្រោម ព្រៃរបោះ ជាយព្រៃ ។

+ **សមាសធាតុគីមី** ៖ Acide Hydroxycitrique

+ **ផ្នែកប្រើប្រាស់** ៖ សំបក

+ **ការប្រើប្រាស់** ៖ - សំរាប់ព្យាបាលជំងឺ ក្រពះ ។
  - គ្រេច, Hematoma (external use) ។

+ **កំរិតប្រើប្រាស់** ៖ ១៥- ៣០g

+ **ឯកសារយោង** ៖ www.pricasplan.com
www.Cambodiaforester.us

**រៀបរៀងដោយនិស្សិត ៖ ប៊ូរ សុម៉ាល័យ**










# ទ្រមូងសេក

Nom Scientifique : ***Suregada multiflora Baill***

Famille : ***EUPHORBIACEAE***

# ទ្រមូងសេក

Nom Scientifique : ***Suregada muliflora Baill***

Famille : ***EUPHORBIACEAE***

+ **លក្ខណៈរុក្ខជាតិ** ៖ ចុលព្រឹក្ស មានកំពស់ ៣-១០ម
  - **ស្លឹក** ៖ មានរាងស៊ុតទ្រវែង ប្រវែងពី ៩-១៩ ស.ម ទទឹងពី ៣-៦ ស.ម ក្រាស់,រឹង , រលោង ពណ៌បៃតងចាស់ , ដុះឆ្លាស់ទង។ ,
  - **ផ្កាផ្លែ** ៖ ផ្កាដុះជាកញ្ចុំ មានប្រមានពី ៥-១០ ដុះទល់ទងនឹងស្លឹក , ផ្លែខ្ចីពណ៌បៃតង ទុំពណ៌លឿងចាស់ ផ្លែរាងមូលប្រវែង២ ស.ម មាន៣ក្លែប
+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯង តាមតំបន់ភ្នំ ខ្ពង់រាប ក្បែរផ្លូវ ក្បែរភូមិ ព្រៃរបោះ ។
+ **សមាសធាតុគីមី** ៖ Multiflorénol , bauerenol , triterpène , alcohol-epimultiflorénol et diterpènes…etc
+ **ផ្នែកប្រើប្រាស់** ៖ សំបក
+ **ការប្រើប្រាស់** ៖ សំបកធ្វើឲ្យធ្មេញរឹងមាំ, រលាកអញ្ចាញធ្មេញ, បញ្ចុះទឹកនោម, បញ្ចុះលាមក ។
+ **វិធីប្រើប្រាស់** ៖ លាងទឹកស្អាតហាលឲ្យស្ងួត ១៥-៣០ ក្រាម ក្នុង១ថ្ងៃ ។
+ **ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជាចងក្រងដោយ គណៈកម្មការស្រាវជ្រាវ នៃមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ ។

រៀបរៀងដោយនិស្សិត ៖ ត្អួន លក្ខិណា






# ទំពូងភ្លើង

Nom Scientifique : *Croton oblongifolius Roxb*
*Croton joufra Mig*
*Croton sublyratus kurs*

Famille : **Euphorbiaceae**

# ទំពូងឡើង

Nom Scientifique : ***Croton oblongifolius Roxb***
***Croton joufra Mig***
***Croton sublyratus kurs***
Famille : **Euphorbiaceae**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាចុល្លព្រឹក្ស ដើមត្រង់ ជាឈើតូច មានកំពស់ ១ ទៅ ៤ ម៉ែត្រ វាតែងតែជ្រុះស្លឹកតាមរដូវ។
- **ស្លឹក** ៖ ស្លឹកទោល ដុះឆ្លាស់ទង រាងផ្លែលំពែងវែង ទទឹង ៤ទៅ៦ ស.ម បណ្តោយ១០ទៅ ១៥ ស.ម។
- **ផ្កា** ៖ កញ្ចុំផ្កាចេញនៅចុងមែក ឬ ប្រគាបស្លឹក ជាចង្កោមកួរខ្លី ជាផ្កាតូចៗ ពណ៌ស.លឿង មានផ្កាញី មានផ្កាឈ្មោលផ្សេងគ្នា ស្ថិតនៅលើកញ្ចុំតែមួយ
-**ផ្លែ** ៖ ផ្លែជាផ្លែស្រួយមាន ៣ ក្លែប។

+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯងតាមជាយព្រៃ ដើមឈើធំ ព្រៃពាក់កណ្តាលស្រោង តំបន់ព្រៃភ្នំ បន្តពូជដោយគ្រាប់។

+ **សមាសធាតុគីមី** ៖ ស្លឹកមាន Plaunotol សំរាប់ព្យាបាលដំបៅក្រពះ (peptic ulcer)។

+ **ផ្នែកប្រើប្រាស់** ៖ សំបក ដើម ស្លឹក ផ្កា។

+ **ការប្រើប្រាស់** ៖ សម្បក ដើម ស្លឹក : ព្យាបាលរាក រដូវមិនទៀង ព្យាបាលរោគដំបៅក្រពះ ជំនួយឈាម ឆ្លងទន្លេ ផ្សះស្បូន ដើរខ្យល់ ជំនួយកំលាំង
-ផ្កា : ទំលាក់ព្រូន។

+ **កំរិតប្រើប្រាស់** ៖ -សម្បកដើម ស្លឹកស្ងួត ១០ ទៅ ១៥ ក្រាម ដាំទឹក
-ដើម ១៥ ទៅ ៣០ ក្រាម។

+ **ឯកសារយោង** ៖ -សៀវភៅរុក្ខជាតិឱសថកម្ពុជា (មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្រ បូរាណ) បោះពុម្ពឆ្នាំ២០០៨។

**រៀបរៀងដោយនិស្សិត ៖ សៀ រុក្ខា**







# ដើមទំពូង រឺ តាពូង

Nom Scientifique : ***Croton jusfra***

Famille : **EUPHOBIACEAE**

# ដើមទំពូង រឺ តាពូង

Nom Scientifique : *Croton jusfra*

Famille : **EUPHOBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាចុល្លព្រឹក្ស បែកមែកច្រើនមានកំពស់១-៤ម។
- **ស្លឹក** ៖ ស្លឹកខ្ចី ត្រួយពណ៌ក្រហមត្នោត ស្លឹកចាស់ពណ៌បៃតង ស្លឹកទុំពណ៌លឿងទឹកក្រូច ស្លឹកទោលដុះឆ្លាស់ទង រាងទ្រវែង ទំហំទទឹង ៥-១០សម បណ្តោយ ៩-៣០។
- **ផ្កាផ្លែ** ៖ - កញ្ចុំផ្កាជាចង្កោមក្បូរ ចេញនៅចុងមែក ផ្កាតូចៗ ពណ៌ បៃតង។
  - ផ្លែជាប្រភេទផ្លែ ស្ងួត មានថត៣។
+ **កន្លែងដាំដុះ** ៖ មានដុះគ្រប់ទីកន្លែង នៅប្រទេសកម្ពុជា ដែលមានពន្លឺគ្រប់គ្រាន់។
+ **សមាសធាតុគីមី** ៖ Alkaloid និង acid សំខាន់ៗទៀត។
+ **ផ្នែកប្រើប្រាស់** ៖ ស្លឹក ផ្លែ ឬស សំបក។
+ **ការប្រើប្រាស់** ៖ - ស្លឹក: ដាំទឹកផឹកព្យាបាលកមរមាស់។
  - គ្រាប់: មានជាតិពុលគេប្រើលាបរិតខាងក្រៅព្យាបាលផ្លោះគ្រេច ហើមសន្លាក់។
  - សំបកដើម: ព្យាបាលឈឺថ្លើមរាំរ៉ៃ។
+ **កំរិតប្រើប្រាស់** ៖ ពី ២០-៣០gទឹកបី យកទឹកមួយក្នុង ១ថ្ងៃ។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជា មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្រ្តបូរាណ បោះពុម្ពដោយថវិការជាតិឆ្នាំ ២០០៨ ភាគ១។

**រៀបរៀងដោយនិស្សិត ៖ វ៉ន សំភ័ស្ត**









# ដើមទឹកដោះខ្លាតូច

Nom Scientifique : ***Halorrhena pubeseu***

Famille : **APOCYNACEAE**

# ដើមទឹកដោះខ្លាតូច

Nom Scientifique *:* ***Halorrhena pubeseu***

Famille : **APOCYNACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិប្រភេទដើម ជាប្រភេទចុល្លព្រឹក្សាសំរាប់លំអរ មានដើមមូលតូច មានកំពស់ ៣ម៉ែត

- **ស្លឹក** ៖ ធំល្មមវែងនៅចុងស្លឹកនិង មូល ទងស្លឹកដុះទល់គ្នា ទងស្លឹកខ្លី ប្រវែង ១០-២០cm

- **ផ្កាផ្លែ** ៖ មានត្របកផ្កា ៥មានប្រវែង ២-៣cm មានផ្កាពណ៌ស ស្អាត មានរាងប៉ោងកណ្តាត្របកផ្កាមូលក្រឡង់ ដែលធ្វើឲយើងនឹកឃើញដល់ផ្កាចំប៉ី

+ **កន្លែងដាំដុះ** ៖ វាដុះខ្លួនឯង នៅតំបន់ Tropical Asian

+ **សមាសធាតុគីមី** ៖ ដើមមានសារធាតុAlcaloïde ប្រហែល ៣០ប្រភេទដែលញែកចេញពីគ្នាមានឪសថច្រើនបំផុត មាន7-ergosten-3-ol និង y-stigmastenol

+ **ផ្នែកប្រើប្រាស់** ៖ សំបក

+ **ការប្រើប្រាស់** ៖ រាគ រាគរ៉ាំរ៉ៃ ជម្ងឺសន្លាក់ដៃជើង

+ **គំរិតប្រើប្រាស់** ៖ មួយថ្ងៃប្រើពី ៣ ទៅ ៨ក្រាមដាំទឹកផឹក

+ **ឯកសារយោង** ៖ htt/www.bgbm-org/herbarium
www.flowersofindia.net/catalog/slides/indrajao-html

**រៀបរៀងដោយនិស្សិត ៖ ហាក់ ផល្លីណែត**







# ដើមទឹកដោះខ្លាធំ

Nom Scientifique : ***Holarrhena antidysenterica (L.) Well***

Famille : **APOCYNACEAE**

# ដើមទឹកដោះខ្លាធំ

Nom Scientifique : ***Holarrhena antidysenterica (L.) Well***

Famille : **APOCYNACEAE**

**+ លក្ខណៈរុក្ខជាតិ** ៖ រុក្ខជាតិធំ១២-១៥ម។ មែកតូចពណ៌ប្រផេះមានរន្ធខូចតូចៗ និងជ័រពណ៌ សច្រើន។

**- ស្លឹក** ៖ ធំរាងដូចផ្លែលំពែង ស្រួចគល់ ស្រួចចុង។ ស្លឹកវាទល់ទងគ្នា សរសៃទ្រនុងស្លឹក ពណ៌លឿងមានរោមទន់ច្រើន។

**- ផ្កា** ៖ ពណ៌ស ជាកញ្ចុំរួមទងចេញពីប្រគាបស្លឹក ឬចុងមែកផ្កាក្រអូប។

**- ផ្លែ** ៖ ប្រភេទផ្លែស្ងួតមូល វែង ចេញជាគូរៗ ពេលទុំបែកចេញគ្រាប់ ហើយនៅចុងក្រោយមានកញ្ចុំរោមទន់ល្មើយ ពណ៌សដូចសំលីអាចប៉ើងតាមខ្យល់បាន។

**+ កន្លែងដាំដុះ** ៖ ជួបប្រទះនៅតំបន់ភ្នំ ខ្ពង់រាប ដុះ មាត់ព្រៃក និងនៅក្បែរផ្លូវ បន្តពូជដោយ គ្រាប់។

**+ សមាសធាតុគីមី** ៖ សំបកដើមមាន ១,៥-៣% នៃជាតិ alcaloide និងមាន alcaloides ផ្សេងទៀតដូចជា: Conessine, Norconessine, Conessimine, Iso conessimine, Kurchine, Conlmine, Conamine, Conkurcine, Halarrhine, Holarrhimine។

**+ ផ្នែកប្រើប្រាស់** ៖ មានសំបក ដើម ស្លឹក និងគ្រាប់ ។

**+ ការប្រើប្រាស់** ៖ - ស្លឹក: រសល្វីងផ្អែមតិចៗ បញ្ចុះព្រូន -គ្រាប់: រសចត់ល្វីង ព្យាបាលរោគ -សំបកដើម: រសល្វីងចត់ បិតឈាម ព្យាបាលស្លេស, ជាថ្នាំព្យាបាលទឹកនោមផ្អែម, គ្រុនចាញ់ រាកមូល ផ្សំជាថ្នាំ ក្រោយសំរាលកូនប៉ូវកំលាំង ធ្លាក់ស។

**+ កំរិតប្រើប្រាស់** ៖ - ដើមប្រើពី ១០-១៥ក្រាម ដាំផឹកក្នុងមួយថ្ងៃ។ -សំបកប្រើពី ៣-១០ក្រាម ដាំផឹកក្នុងមួយថ្ងៃ។ -ម្សៅប្រើពី ៣-៦ក្រាម ដាំផឹកក្នុងមួយថ្ងៃ។ ប្រើច្រើនពេកធ្វើឲ្យច្របូកច្របល់ក្នុងពោះ និងពាក់ព័ន្ធដល់សរសៃប្រសាទ

**+ ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជាភាគ១ ក្រសួងសុខាភិបាល-មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណបោះពុម្ពឆ្នាំ ២០០៨

**រៀបរៀងដោយនិស្សិត ៖ សាម ម៉ូនីកា**










# ទ្រាលស្វា

Nom Scientifique : ***Uvaria rufa Blumem, Uvaria solanifolia Presl. Uvaria setigera Blanco, Uvaria ridleyi King.***

*Famille :* ***ANNONACERE***

# ទ្រលស្វា

Nom Scientifique : ***Uvaria rufa Blume, Uvaria solanifolia Presl. Uvaria setigera Blanco, Uvaria ridleyi King.***

*Famille :* ***ANNONACERE***

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទវល្លិ៍ឈើតោងឡើងដើមឈើធំ អាចមានប្រវែង ៥-៦ ម៉ែត្រ។

- **ស្លឹក** ៖ ស្លឹករាងពងក្រពើទ្រវែង ប្រវែងប្រហែល ៨-១៦ ស.ម បណ្ដោយ។ ស្លឹកស្រួចចុង គល់ស្លឹករាងបេះដូង។ ស្លឹកខ្ចី និង ផ្ទៃខាងក្រោមនៃស្លឹក មានរោមខ្លីៗ ពណ៌ទង់ដែង។

- **ផ្កាផ្លែ** ៖ ផ្កាដុះចេញពីប្រកៀបមែក ផ្កាពណ៌ក្រហម មានក្លិនក្រអូប មានអង្កត់ផ្ចិតប្រហែល ១,៥-២ ស.ម។ ផ្លែរាងមូលទ្រវែង មានទងរួមជាចង្កោមជុំ។ ពេលទុំពណ៌ក្រហម មានសាច់ ពណ៌ស គ្រាប់ពណ៌ខ្មៅ មានរសជាតិជូរ។

+ **កន្លែងដាំដុះ** ៖ ជារុក្ខជាតិមានដុះនៅតំបន់ព្រៃភ្នំ និង ព្រៃល្បោះ។

+ **សមាសធាតុគីមី** ៖ -សំបកមានជាតិ alcaloïde (action parasympathique de group atropinique)។
-មានសារធាតុ sesquiterpènes [alpha-humulène (50%) et benzyl-benzoate

+ **ផ្នែកប្រើប្រាស់** ៖ ឫស។

+ **ការប្រើប្រាស់** ៖ ឫសស្ងោរផឹក ជាថ្នាំជំនួយកំលាំង សំរាប់ស្ត្រីឆ្លងទន្លេហើយ។ នៅហ្វីលិពីនប្រើ ឫស ត្រាំស្រា ជាថ្នាំជួយអោយស្បូនកន្ត្រាក់ នៅពេលឆ្លងទន្លេ។

+ **កំរិតប្រើប្រាស់** ៖ ពី១៥ ទៅ ៣០ ក្រាម។

+ **ឯកសារយោង** ៖ -សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ១ (មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្រ បូរាណ) បោះពុម្ពឆ្នាំ២០០៨

**រៀបរៀងដោយនិស្សិត ៖ អ៊ឹម សំខាន់**







# ដើមទន្សែ

Nom Scientifique : ***Caryota urens Linn,***

Famille : ***ARECACEAE***

# ដើមទន្សែ

Nom Scientifique : *Caryota urens Linn,*

Famille : ***ARECACEAE***

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិជំពូកស្លារស់នៅយូរឆ្នាំ ដើមមូលត្រង់មានកំពស់ពីដី១០-១៥មែត្រ វិជ្ជមាត្រ ៤០-៥០cm។
  - **ស្លឹក** ៖ ស្លឹករូបធំវែងមានប្រវែងពី២-៣ម ដុះមានលក្ខណៈជារោមបក្សី ចុងស្លឹកមានធ្មេញរណារមិនស្មើរគ្នា គល់ស្លឹកស្រួចអោបជាប់ដើម។
  - **ផ្កា** ៖ ផចេញពីស្រទាប់ស្លឹកដុះជាស្នែង ផ្ការនីមួយៗរាងដូចសក់ក្រង ធ្លាក់សំយុងចុះក្រោមជាច្រើន។
  - **ផ្លែ** ៖ មូលពេលចាស់ពណ៌ក្រហម ពេលទុំពណ៌ខ្មៅមានសំបកក្រាស់ ទឹកនៅក្នុងផ្លែមានជាតិធ្វើអោយរមាស់។
+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនវា តាមចំការ ដីទំនេរក្បែរភូមិ។
+ **លក្ខណរូប-គីមី** ៖ Moisture, Amylose, Starch granule, Starch granule shape, Phenols, bulk density.
+ **ផ្នែកប្រើប្រាស់** ៖ ស្រទបស្លឹក។
+ **ការប្រើប្រាស់** ៖ ស្រទប : ព្យាបាលរោគរាគ រាគចេញឈាម រដូវមកពុំរៃ រាគមូល។
+ **កំរិតប្រើប្រាស់** ៖ ១ថ្ងៃប្រើ២០ក្រាមដុតកិនជាម្សៅផឹក រឺដាំផឹក។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឪសថកម្ពុជា ២០០៩
  Natural Product Radiance Vol 3(3) May- June 2004.

**រៀបរៀងដោយនិស្សិត ៖ ហ៊ុន ឌីឡុង**







# ដើមត្រាច រឺ ឡាព្រះ

Nom Scientifique : ***Lasia spinosa (L) Thwaites***

Famille : **ARACEAE**

# ដើមត្រាវ រឺ ទ្វារព្រះ

Nom Scientifique : *Lasia spinosa (L) Thwaites*

Famille : **ARACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ តិណជាតិមានមើមនៅក្រោមដី មានកំពស់រហូតដល់មួយម៉ែត្រ ។
  - **ស្លឹក** ៖ ស្លឹកទោលរាងឆែកជ្រៅៗ ទ្រនុងស្លឹកខាងក្រោមមានបន្លា ទងស្លឹកវែងរហូតដល់មួយម៉ែត្រមានបន្លា ។
  - **ផ្កា** ៖ ជាផ្កាខ្ទរ វែងរមូលខាងចុង ពណ៌ត្នោតបៃតង ផ្កាមានប្រវែង ៩សម ពេលរីកពណ៌ ស៊ីជម្ពូបៃតង ទងផ្កាវែងមានបន្លា។
  - **ផ្លែ** ៖ ផ្លែសាច់ពណ៌បៃតង រាងបីជ្រុង។
+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯង តាមមាត់ទឹក មាត់ជ្រោះ តំបន់ព្រៃភ្នំ ។
+ **សមាសធាតុគីមី** ៖ មានសារធាតុពុល Cyanide ។
+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល ពិសេសដើមលាងទឹក ហាន់ហាលទុកប្រើ ។
+ **ការប្រើប្រាស់** ៖ - ដើមព្យាបាល ក្អក ទំលាក់ស្លេស្ម ដាំទឹកងូតព្យាបាលរមាស់ ហឹត ចែងថ្ងៃ :
  - ស្លឹក : ឈឺពោះ ព្យាបាលក្អក ទម្លាក់ស្លេស្ម ចុកពោះ ។ ប្រើខាងក្រៅ រមាស់ រោគសើស្បែក ។
  - ឬសព្យាបាលឈឺក ។
  - មើមដាំផឹករព្យាបាល រលាកក្រពះ អាហារមិនរលាយ ឈឺសន្លាក់ឆ្អឹង ។ បុកបិតខាងក្រៅព្យាបាល ពស់ចឹក រលាកក្រពេញឈាមស (Lymphadenitir) របេងក្រពេញឈាមស (tuberculosis lymphadenopathy) បូស ពិស អាប់សែ ។
+ **កំរិតប្រើប្រាស់** ៖ ១៥-៦០ ក្រាម ដាំទឹកផឹក ។
+ **ឯកសារយោង** ៖ ដកស្រង់ចេញពីសៀវភៅរុក្ខជាតិឱសថកម្ពុជា ភាគទី៤ បោះពុម្ពផ្សាយឆ្នាំ ២០១០

**រៀបរៀងដោយនិស្សិតៈ លាង សុខឃីម**









## ឆ្នា

Nom Scientifique : *Acacia hamandiana(Pirre)Gagnep*

Famille : **FABACEAE**

# ធ្នា

Nom Scientifique : *Acacia hamandiana(Pirre)Gagnep*

Famille : **FABACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទរុក្ខជាតិមធ្យមពី៦មែត្រទៅ១២មែត្រសំបកដើមពណ៌ត្នោតប្រផេះដើមនឹងមែកមានបន្លះរឹងជាច្រើន។
- **ស្លឹក** ៖ ស្លឹកស្លាបគូ។កូនស្លឹកតូចៗរាងស៊ុតទ្រវែង។
- **ផ្កា** ៖ កញ្ចុំផ្កាចេញទៅចុងមែកជាចង្កោមលឿងភាវរាងដូចផ្កាកន្ទំថេតជាប្រភេទផ្កាផ្ទុក។
- **ផ្លែ** ៖ ផ្លែគូរាងមិនត្រង់។
+ **កន្លែងដាំដុះ** ៖ ច្រើនដុះនៅតាមព្រៃទំនាបតាមភ្លឺស្រែតាមដងផ្លូវជិតមាត់ទឹក។
+ **សមាសធាតុគីមី** ៖ មានសាធាតុplyyphenolsម្យាងច្រើនដល់ទៅ៤២%ព្រមទាំងQuinic acide,Makic acide មានផងដែរ។
+ **ផ្នែកប្រើប្រាស់** ៖ សំបក។
+ **ការប្រើប្រាស់** ៖ - សំបកយកមកដាំទឹកផឹកព្យាបាលរលាកក្រពះពោះវៀន រាគ។
+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី៨ក្រាមទៅ១០ក្រាមដាំផឹក១ថ្ងៃ។
+ **ឯកសារយោង** ៖ ស្រង់ពីសៀវភៅរុក្ខជាតិឱសថកម្ពុជា(ភាគទី២) ក្រសួងសុខាភិបាលមជ្ឈមណ្ឌលស្រាវជ្រាវវេជ្ជសាស្ត្របូរាណឆ្នាំ 2008។

**រៀបរៀងដោយនិស្សិត ៖ គង់ សុជានី**







**ធ្លក**

*Nom Scientifique :* ***Parinari annamensis Hance***

*Famille :* **ROSACEAE**

# ធ្លក

*Nom Scientifique :* ***Parinari annamensis Hance.***

*Famille :* **ROSACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទរុក្ខជាតិមធ្យមមានកំពស់10-20មមានសំបកដើមក្រាស់ពណ៌ប្រផេះមានប្រេះជាស្នាមជ្រៅៗ។
  - **ស្លឹក** ៖ ទោលដុះឆ្លាស់ទងមានរាងជាស៊ុតផ្ទៃស្លឹកផ្នែកខាងក្រោមមានពណ៌សផ្ទៃខាងលើមានពណ៌បៃតង។មានប្រវែងពី៦-១៥ស.មទទឹង៤-៩ស.ម។
  - **ផ្កា ផ្លែ** ៖ : កញ្ចុំផ្កានៅចុងមែកផ្កាតូចៗពណ៌ស។
  :រាងដូចស៊ុតមានពណ៌ជី (សាច់អាចហូបបាន)។
+ **កន្លែងដាំដុះ** ៖ ដុះនៅព្រៃល្បោះដីទួលតាមភ្នំទាបៗ។ បន្តពូជដោយគ្រាប់ ។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ ។
+ **ផ្នែកប្រើប្រាស់** ៖ សំបក នឹង ផ្លែ។
+ **ការប្រើប្រាស់** ៖ សំបក ព្យាបាលទាស់ស្ត្រីឆ្លងទន្លេរួច ធ្លាក់ស ស្បូនស្រុត រមាស់លើស្បែកឈឺលោកក្តៅ ដាំទឹកហូបព្យាបាលហើត ។
  សំបកដើមបុកដាក់ស្នំនៅកន្លែងឈឺចាប់គ្រាំក្នុង ខ្ទាំឈាម ហើម ។
+ **កំរិតប្រើប្រាស់** ៖ ស្ងួត១០-២០ក្រាមដាំផឹក។
+ **ឯកសារយោង** ៖ សៀវភៅកំរងរុក្ខជាតិឱសថភាគ ៣ ។

រៀបរៀងដោយនិស្សិត ៖ ក្រូយ គឹមសួរ







## ជញ្ជក់ឆ្អេះ នគរអាន បន្លារទន្ទ្រានគរ

Nom Scientifique : ***Ageratum conyzoides L***

Famille : **ASTEACEA**

# ជញ្ជក់ឆ្កេះ នគរអាន បន្ទាទន្ទ្រានគរ

Nom Scientifique : ***Ageratum conyzoides L***
Famille : **ASTEACEA**

+ **លក្ខណៈរុក្ខជាតិ** ៖ តិណជាតិ មានកំពស់ពី25 -30 ស.ម ។

- **ស្លឹក** ៖ ដុះទល់ទង រាងស៊ុត កែមស្លឹកមានដូចធ្មេញរណា មានរោម ។

- **ផ្កាផ្លែ** ៖ ផ្កាពណ៌ស មានខ្លះពណ៌ស លាយស្វាយ ជាកញ្ចុំនៅចុងមែក។
ផ្លែ មានពណ៌ខ្មៅ ។

+ **កន្លែងដាំដុះ** ៖ ដុះនៅគ្រប់កន្លែង មានសើម បន្តពូជដោយគ្រាប់ ។

+ **សមាសធាតុគីមី** ៖ មិនទាន់បានស្រាវជ្រាវនៅឡើយ ។

+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល

+ **ការប្រើប្រាស់** ៖ សំរាប់ព្យាបាល រលាក អាល់លែកស៊ីច្រមុះ ហូរឈាម របួស កើតបូស ក្អក ។ បុកបំពោក ឬដាំទឹកងូតសំរាប់ព្យាបាលកូនក្មេងដែលមានបូសខ្ទុះ ឬរោកសើរស្បែក ព្យាលបាលស្ត្រីក្រោយពេលឆ្លងទន្លេ មានការធ្លាក់ឈាម គ្រុនក្តៅ ឈឺក្បាល វិលមុខ រលាកថ្លើម ចែងថ្ងៃ គ្រុនចាញ់ ជំងឺរលាកតាមផ្លូវនោម។ ល។

+ **កំរិតប្រើប្រាស់** ៖ ប្រើពី15-30ក្រាមដាំទឹកផឹកក្នុងមួយថ្ងៃ ។

+ **ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជាភាគ៣/ក្រសួងសុខាភិបាលមជមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្រ្តបូរាណ បោះពុម្ពដោយថវិការជាតិឆ្នាំ២០០៩
List of Medicinal Plants in Cambodia 2012.

**រៀបរៀងដោយនិស្សិត ៖ ប្រាជ្ញ កែវពិសី**







## នាងនួន

Nom Scientifique : ***Dalbergia bariensis pierre (Dalbergia oliveri)***

*Famille :* ***FABACEAE***

# នាងនួន

Nom Scientifique *: **Dalbergia bariensis pierre (Dalbergia oliveri)***

*Famille :* ***FABACEAE***

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិឈើមធ្យម អាចមានកំពស់ពី ២០ - ៣៥ម, ដើមមានលក្ខណៈរឹង និងធំ, ដើមមានពណ៌លឿងផ្កាឈូក ពណ៌ត្នោត ពណ៌ក្រហមមានសសៃខ្មៅ នឹងពណ៌លឿងស្វាយ ។
  - **ស្លឹក** ៖ ស្លឹកមានប្រវែង ៣ - ៥ ស.ម នឹងបណ្តោយ ១ - ២ ស.ម។
  - **ផ្កាផ្លែ** ៖ ផ្លែមានរាងទ្រវែងដែលមានពី ១ - ២ គ្រាប់ ។
+ **កន្លែងដាំដុះ** ៖ ដុះខ្លួនឯង តាមខ្ពង់រាប និងតាមជ្រលងភ្នំ ព្រៃរបោះ ។
+ **សមាសធាតុគីមី** ៖ មិនទាន់រកឃើញ ។
+ **ផ្នែកប្រើប្រាស់** ៖ មែក, សំបក ។
+ **ការប្រើប្រាស់** ៖ ព្យាបាលគ្រុនក្តៅ ដាក់ពណ៌ស្រាថ្នាំ ។
+ **គំរិតប្រើប្រាស់** ៖ មិនទាន់រកឃើញ ។
+ **ឯកសារយោង** ៖ បញ្ជីរុក្ខជាតិឱសថកម្ពុជា, គំរោងដាំដុះកូនឈើកម្ពុជា

**រៀបរៀងដោយនិស្សិត ៖ សេង វណ្ណី**







# នាងខ្មៅ តឹកមន

Nom Scientifique : *Dichroa febrifuga Lour*

Famille : **HHDRANGEACEAE**

# នាងខ្មៅ គឹកមន

Nom Scientifique : *Dichroa febrifuga Lour*

Famille : **HYDRANGEACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ចុល្លព្រឹក្ស កំពស់ ១ ទៅ ២ម ដើមរលោង មែកខ្ចី ពណ៌ទឹកប៊ិចស្វាយ ។ ឫសវែងតូចក្រញេងក្រញ៉ង់ មានពណ៌លឿង ។
  - **ស្លឹក** ៖ ដុះទល់ទងគ្នា ទ្រវែងស្រួចចុង មានប្រវែងពី ១៣ទៅ២០សម ទទឹង៣៥ទៅ៤០សម គែមស្លឹកមានធ្មេញ ផ្ទៃស្លឹកមានរោមតិចៗ ឬ អត់រោម ទងស្លឹក ពណ៌ស្វាយ ។
  - **ផ្កាផ្លែ** ៖ ផ្កា ដុះជាកញ្ចុំចេញនៅចុងមែក ឬ ប្រគាបស្លឹក ផ្កាពណ៌ខៀវ ស្វាយលាយស ។ ផ្លែ សាច់ រាងមូល មានវិជ្ជមាត្រ ៥មម ពណ៌ទិកប៊ិចស្វាយ ។
+ **កន្លែងដាំដុះ** ៖ ដុះនៅតាមតំបន់ព្រៃភ្នំ ដែលមានដីសើម មាត់ជ្រោះ ក្រោមម្លប់ឈើ ។
+ **សមាសធាតុគីមី** ៖ alcaloid 0,1-0,15%, α-β-γ-dichroin, dichroidin, 4-quinazolone(ceto-4-dihydroquinazolin), dichrin, dichroidin, belliferone, dichroin B, Febribugin(dichroin B=β- nig γ-dichroin), isofebrifugin(dichroin A=α dichroin).
+ **ផ្នែកប្រើប្រាស់** ៖ ឫស ស្លឹក មែក ។
+ **ការប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល ព្យាបាលគ្រុនចាញ់ គ្រុនលោះ ក្អក ពុលអាហារ ។ ឫស ព្យាបាលគ្រុនចាញ់ បញ្ចុះកំដៅ កាត់ស្លេស្ម បញ្ចុះទឹកនោម ក្អក ។
+ **កំរិតប្រើប្រាស់** ៖ កំរិតប្រើ ៦ទៅ១២ក្រាម ដាំផឹក។
+ **ឯកសារយោង** ៖ កំរងរុក្ខជាតិឱសថ ស្តីពីការចុះអង្កេតស្រាវជ្រាវក្នុងខេត្តមណ្ឌលគីរី ដោយនិស្សិតជំនាន់ទី៣១ ឆ្នាំ ២០១០-២០១១ ។

**រៀបរៀងដោយនិស្សិត ៖ នៃ សៀកម៉េង**







# បូរព្រឹក្ស

Nom Scientifique : *Cassia Javanica Linn*,

Famille : **FABACEAE**

# បូរព្រឹក្ស

Nom Scientifique : ***Cassia Javanica Linn*,**

Famille : **FABACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទរុក្ខជាតិឈើមធ្យម មានកំពស់ពី១៥ទៅ២០ម៉ែត្រ

- **ស្លឹក** ៖ ប្រភេទស្លាបបក្សីមានពី៥ទៅ ១២គូ។ ស្លឹកមានរាងពងក្រពើស្រួចចុង។

- **ផ្កាផ្លែ** ៖ ដុះជាកញ្ចុំ ចេញពីប្រគាបស្លឹក មែកអត់ស្លឹក គូរផ្កាមានប្រវែង ១០ទៅ១៥ស.ម ទងផ្កាពី ៣-៥ស.ម ផ្កាពណ៌ផ្កាឈូក ផ្កាពណ៌ស រឺ ផ្កាលឿង លាយផ្កាឈូក។

+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនវាផ្ទាល់នៅជើងភ្នំបូកគោ មានដាំនៅសួននានា។

+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ។

+ **ផ្នែកប្រើប្រាស់** ៖ សាច់ឈើ ផ្លែ សំបកដើម។

+ **ការប្រើប្រាស់** ៖ - ផ្លែ៖ ធ្វើថ្នាំបញ្ចុះ។ សំបកដើមបុកលាបរមាស់។
- សាច់ឈើ៖ ធ្វើថ្នាំអោយស្ត្រីផឹកពេលឆ្លងទន្លេ។

+ **កំរិតប្រើប្រាស់** ៖ -សាច់ផ្លែ៖ ១៥ក្រាម ក្នុង១ថ្ងៃ ដាំផឹក
- សាច់ឈើពី ១០-១៥ក្រាម ក្នុង១ថ្ងៃ ដាំផឹក

+ **ឯកសារយោង** ៖ ក្រសួងសុខាភិបាលមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ

**រៀបរៀងដោយនិស្សិត ៖ ស៊ុយ សុវណ្ណារិទ្ធ**





# ដើមបំពង់រឿង អង្កាសីលឈ្មោល ហ្លួងរាជ

Nom Scientifique : ***Gomphia Serrata***

Famille : **OCHNACEAE**

# ដើមបំពង់រឿង, អង្គាសីលឈ្មោល ឃ្លងរាជ

Nom Scientifique : ***Gomphia Serrata***
Famille : **OCHNACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិមានកំពស់ពី ៦ ទៅ ១០ ម។
   - **ស្លឹក** ៖ ជាស្លឹកទោលដុះឆ្លាស់ទង រាងទ្រវែងស្រួចចុង ទំហំទទឹង ២៦ សម និង បណ្តោយ ៦០ សម។
   - **ផ្កា** ៖ ដុះនៅចុងមែក រឺ ប្រគាបស្លឹក ជាចង្កោមមាន ៥ ទៅ ៦ ផ្កា ពណ៌លឿង។
   - **ផ្លែ** ៖ ផ្លែរមទង រាងមូល ដូចស៊ុត មានទំហំ ៦x៤,៥ មម មានមួយគ្រាប់ ពេលទុំមានពណ៌ស្វាយក្រមៅ។
+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯងតាមព្រៃល្បោះ តំបន់ខ្ពង់រាប ភ្នំ បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ មាន Oleoresine et Polyphenols.
+ **ផ្នែកប្រើប្រាស់** ៖ ដើម ជ័រ ឫស ស្លឹក។
+ **ការប្រើប្រាស់** ៖ ជ័របៀមធ្មេញរឹងមាំ រលាកជើងធ្មេញ និងជួយសំអាតធ្មេញ។
   ដើម ទឹកនោមផ្អែម និង បន្សាបជាតិពុល។
   ឫសនិងស្លឹក ព្យាបាលឈឺក្រពះ។
+ **កំរិតប្រើប្រាស់** ៖ ប្រើពី ១០ ទៅ ១២ ក្រាម។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជា បោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ។
   www.asianplant.net/Ochnaceae/Gomphia_serrata.htm

**រៀបរៀងដោយនិស្សិត ៖ ស្រាយ សេងស៊ីម**







## បប្រ៉ក

Nom Scientifique : ***Drynaria quercifolia (L.) J Sm***

Famille : **POLYPODIACEAE**

# បប្រ៉ក

Nom Scientifique : ***Drynaria quercifolia (L.) J Sm***
Famille : **POLYPODIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាបណ្ណង្គជាតិផ្ញើប្រាណលើដើមឈើ រឺ លើផែនថ្ម ។
- **ស្លឹក** ៖ ជាផ្ទាំងវែងមានផែកច្រើន។ ស្លឹកមាន២ប្រភេទប្រភេទតូចមានប្រវែង ៣០-៥០ស.មទទឹង ១៥ស.ម។ មួយប្រភេទទៀតមានស្លឹកធំ មានប្រវែងរហូត ១.៤ម ទទឹង ៣០-៥០ស.ម។ ស្លឹកមានផែកៗដូចស្លាបសត្វ។
+ **កន្លែងដាំដុះ** ៖ ដុះនៅតាមដើមឈើ រឺ ផ្ទាំងថ្ម បន្តពូជដោយស្ព័រ។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ
+ **ផ្នែកប្រើប្រាស់** ៖ មើម
+ **ការប្រើប្រាស់** ៖ ជំនួយកំលាំង រលាកសន្លាក់ដៃជើង ហ៊ឹងត្រចៀក ឈឺតំរង់នោម សំរកហើមគ្រុនចាញ់ ធ្លាក់ស។ល។
+ **កំរិតប្រើប្រាស់** ៖ ប្រើ ៦-១២ ក្រាម ក្នុង១ថ្ងៃ។
ត្រាំស្រា ១៥ក្រាម ក្នុង១ថ្ងៃ សំរាប់ជំងឺសន្លាក់ដៃជើង។ របួសបោកទង្គិចបាក់ឆ្អឹង ប្រើ១៥ក្រាម ដាំទឹកផឹក ហើយយកមើមស្រស់ៗបុកបិទពីក្រៅ។
+ **ឯកសារយោង** ៖ សៀវភៅកំរងរុក្ខជាតិឱសថភាគ២ ឆ្នាំ២០០៨

**រៀបរៀងដោយនិស្សិត ៖ សេខ វណ្ណា**







# ព្រះអំចាត់

Nom Scientifique : ***Zanthoxylum rhetsa DC.***

*Famille :* ***RUTACEAE***

# ព្រះភំចាត់

Nom Scientifique : ***Zanthoxylum rhetsa DC.***

*Famille :* ***RUTACEAE***

+ **លក្ខណៈរុក្ខជាតិ** ៖ ព្រឹក្សតូចកំពស់ ៧ -១២ម៉ែត្រ ដើមនិងមែកមានបន្លាមាំក្រាស់រាងសារជីធំគល់។

- **ស្លឹក** ៖ រួមផ្សំប្រភេទស្លាបបក្សីសេលច្រើនផ្តុំនៅចុងមែក កូនស្លឹកមាន ៧ -១២ គូ រាងផ្លែលំពែង គែម រាងធ្មេញរណារតិចៗ ។

- **ផ្កាផ្លែ** ៖ ផ្កាវាតូចៗ ចេញជាចង្កោមបែកខ្នែង មានភេទតែមួយ ផ្កាញី ផ្កាឈ្មោលនៅផ្សេងគ្នា ។ ផ្លែប្រភេទស្ងួតស្រួយ តូចមូល មានគ្រាប់មួយប្រេះចំហ ឃើញគ្រាប់ពណ៌ខ្មៅរលោងដែលមានជាតិប្រេង ដំបូលក្លិន ដូចសំបកក្រូចសើច បន្ទាប់មក ហិរធ្ងលខ្លាំង ។

+ **កន្លែងដាំដុះ** ៖ ដុះខ្លួនឯងនៅតំបន់ភ្នំព្រៃក្រាស់ជ្រុះស្លឹក ជាយព្រៃ មានពន្លឺថ្ងៃ ។

+ **ផ្នែកប្រើប្រាស់** ៖ សំបក (ដើម ឬស) មែក ស្លឹក ប្រើប្រាស់ ឬសម្ងួតក្នុងម្លប់ទុកប្រើ។

+ **សមាសធាតុគីមី** ៖ មាន Alkaloids: Budrungaine, Budragainine.

+ **ការប្រើប្រាស់** ៖ សំបកឬស ៖ដាំផឹកព្យាបាល រាំងរដូវ រដូវមិនទៀង ទំលាក់ព្រូន ។ សំបកដើម៖ ព្យាបាល ឈឺសន្លាក់ឆ្អឹងខ្សោយក្រពះ ។ មែក និង ស្លឹក ៖ ព្យាបាលផ្តាសាយ ឈឺសន្លាក់ឆ្អឹងសំណល់រោគ ក្រោយគ្រុនស្វិតដៃជើង ( Sequela of poliomyclitis ) ស្លឹក៖ បុកបិតឬសស្មោរលាង ព្យាបាលរបួសបាក់ឆ្អឹងរបួសចេញឈាម ពស់ចឹក រលាកភ្លើង រលាកទឹកក្តៅ ពឹស បួស ។

+ **កំរិតប្រើប្រាស់** ៖ សំបកឬស សំបកដើម ៖៥ -១៥ ក្រាមដាំទឹកហូប ។ មែក និង ស្លឹក ៖១០-១៥ក្រាមដាំផឹក ។

+ **ឯកសារយោង** ៖ ដក់ស្រង់ពីសៀវភៅរុក្ខជាតិឱសថកម្ពុជា ភាគ៤ (២០១០) http://www.biotik.org/india/species/z/zantrhet/zantrhet_10_en.html

**រៀបរៀងដោយនិស្សិត ៖ ញឹម សុភារី**







# ប៉ះខ្លប,ព្រះខ្លប,សំពះ

Nom Scientifique : ***Mimosa pudica L.***

*Famille :* ***LEGUMINOSAE-MIMOSOIDEAE***

# ប៉ះខ្លប,ព្រះខ្លប,សំពះ

Nom Scientifique : ***Mimosa pudica L.***

*Famille :* ***LEGUMINOSAE-MIMOSOIDEAE***

**+ លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិកំពស់ ៣០-៤០ Cm ដុះលាតសន្ធឹងលើដីដែលដុះនៅវាលដីទំនាប។

**- ស្លឹក** ៖ សមាសប្រជុំរូមទង ស្លឹកខ្លបរហ័សពេលមានអ្វីប៉ះ។ ផាងមួយមានស្លឹកតូចៗ ១២-២០ សន្លឹក។

**- ផ្កា** ៖ កញ្ចុំផ្កាដុះចេញពីប្រគាបស្លឹកផ្កាតូចៗប្រមូលផ្តុំមូលញឹកជិតគ្នា ហើយផ្កាមានពណ៌ផ្កាឈូកលាយស្វាយ។

**- ផ្លែ** ៖ ផ្លែជាកញ្ចុំរូមទង រាងវែងមានស្នាមរបាំងនៃគ្រាប់ ហើយផ្លែមានរោម។

**+ កន្លែងដាំដុះ** ៖ គឺជាប្រភេទស្មៅដុះទន្ទ្រានលើដីទំនេរ។

**+ សមាសធាតុគីមី** ៖ -Alcaloïde: Mimosine

-C−glucosyl flavone: 2'' O-rhamnosyl-orientin et 2'' O-rhamnosyl-isoorientin

-Mucilage

**+ ផ្នែកប្រើប្រាស់** ៖ គេប្រើរុក្ខជាតិទាំងមូល ដោយមុននឹងប្រើប្រាស់ត្រូវលាងសំអាត រួចហាន់ជាចំនិតហាលសំងួត។ គេអាចប្រមូលផលគ្រប់រដូវ។

**+ ការប្រើប្រាស់** ៖ -មានប្រសិទ្ធភាពលើប្រភេទរលាក (Antiphlogistique)

-បន្ថយការឈឺចាប់

-បញ្ចុះទឹកនោម

-គេអាចប្រើវាក្នុងការព្យាបាល៖ គ្រុនក្តៅ, គេងមិនលក់, ឈឺសន្លាក់ដៃជើង, ឈឺក្នុងឆ្អឹង, ស្ពឹកស្រពន់ដៃជើង, ចុករោយខ្នងចង្កេះ និង បញ្ចុះសំពាធឈាម (Hypertensive)

**+ កំរិតប្រើប្រាស់** ៖ កំរិតប្រើប្រចាំថ្ងៃ ពី១៥-៣០g ដោយដាំទឹកផឹក។

**+ ឯកសារយោង** ៖ កំរងរុក្ខជាតិឱសថក្នុងការចុះអង្កេតស្រាវជ្រាវខេត្តកំពត ឆ្នាំ ២០០៧-២០០៨

**រៀបរៀងដោយនិស្សិត ៖ ហុង ម៉ាណែត**







**ម៉ែនប៉ោះស្រោម,**

Nom Scientifique : ***Physalis angulata L.***

*Famille :* ***SOLANACEAE***

# ម៉េងប៉ោះស្រោម,

Nom Scientifique : ***Physalis angulata L.***

*Famille :* ***SOLANACEAE***

+ **លក្ខណៈរុក្ខជាតិ** ៖ រុក្ខជាតិ ស្មៅ មានកំពស់ 50-100cm។
  - **ស្លឹក** ៖ រាងពងក្រពើរ ស្រួចចុង ពណ៌បៃតងខ្ចីគែមស្លឹកមានរាងជាធ្មេញរណាដុះឆ្លាស់ទង។
  - **ផ្កា** ៖ ពណ៌លឿងខ្ចី ឆែតជា៥ ។
  - **ដើម** ៖ មានរាងជ្រុងបែកមែកសាខា ។
  - **ផ្លែ** ៖ រាងមូល មានស្រោមខ្យល់ រុំពីក្រៅ ពេលទុំពណ៌លឿងថ្លា មានរសជាតិផ្អែម ហូបបាន ។
+ **កន្លែងដាំដុះ** ៖ ដុះដោយគ្រាប់ ដោយខ្លួនឯង គ្រប់កន្លែងដីសើម ។
+ **សមាសធាតុគីមី** ៖ alcaloïde និង អាស៊ីតមួយចំនួនទៀត ។
+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល ។
+ **រសជាតិ** ៖ ល្វីង ត្រជាក់ ( ចំពោះ ដើម មែក រឹស) ។
+ **ការប្រើប្រាស់** ៖ ឈឺបំពង់ក ផ្ដាសាយ ដំបៅក្រពះ ក្អកមាន់ ក្អកហឺត បញ្ចុះទឹកនោម ស្បូនស្រុត បិតបូស មហារីក គ្រុនក្ដៅ ឈឺសន្លាក់ដៃជើង ទឹកនោមផ្អែម លើសឈាម ។
+ **គំរិតប្រើប្រាស់** ៖ លាងទេកអោយស្អាត ហាលស្ងួត ដាំទឹកផឹកពី 10-15g ក្នុងមួយថ្ងៃ ផឹកធម្មតា ។ ស្លឹកខ្ចីអាចប្រើជាបន្លែស្ងួរហូបបាន ។
+ **ឯកសារយោង** ៖ http://www.cactuspedia.info/schede/EUPHORBIA/Euphorbia_lactea/Euphorbia_lactea/Euphorbia_lactea.htm
http://www.aujardin.org/euphorbia-lactea-t48415.html
http://www.mi-aime-a-ou.com/euphorbia_lactea_cristata.php

**រៀបរៀងដោយនិស្សិត ៖ ឡេង ច័ន្ទឌីភា**








# ចាក់ដោត

Nom Scientifique : ***Siphonodon celastrineusGriff***

*Famille :* **CELASTRACEAE**

# បាក់ដោក

Nom Scientifique : *Siphonodon celastrineusGriff*

*Synonymes :* ***Siphonodon pyrifprmisMerr***

***Xanthophyllum subglobosumElm***

*Famille :* **CELASTRACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើមធ្យមសំបកដើមចាស់ពណ៌ប្រផេះត្រើមៗបែកមែកសាខា។
- **ស្លឹក** ៖ ពណ៌បៃតងចាស់ក្រាស់ស្វិតរាងមូលទ្រវែងគែមស្លឹកមានធ្មេញរណារដុះឆ្លាស់ទង។
- **ផ្កា** ៖ ជាប្រភេទផ្កាដែលមានភេទតែមួយជាមួយភេទឈ្មោលនឹងភេទញីនៅលើដើមតែមួយ។
- **ផ្លែ** ៖ រាងមូលដូចសាជីទំហំប៉ុនមេដៃពេលទុំពណ៌លឿងលាយក្រហមព្រឿងៗមានរស់ជាតិផ្អែមៗ។

+ **តំបន់ដុះ**: ៖ ជួបប្រទះនៅតំបន់ភ្នំព្រៃរល្បោះព្រៃស្មោង។យើងអាចរកឃើញនៅប្រទេសកម្ពុជាឥណ្ឌាមីយ៉ាន់មានួងវៀតណាម។

+ **សមាសធាតុគីមី** ៖ Oleanane-triterperne; 3beta-acetoxyl-1 1alpha-benzoyloxy-13beta-hydroxyolean 12onequinone-mathidetriterpern: pristimerin

+ **ផ្នែកប្រើប្រាស់** ៖ ដើមឬស

+ **ការប្រើប្រាស់** ៖ ឬសនិងដើមព្យាបាលម្រេញលឿងហើមបន្ទន់លាមក។ ឬសព្យាបាលពិសឬសខាងក្នុង ឬសល្មើម ឬសស្ងួត បំប៉នឆ្អឹង ចែងថ្ងៃ រោគលើស្បែក ឈឺចុកចាប់។

+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី១៥ទៅ៣៩ក្រាមដាំទឹកផឹក១ថ្ងៃ។

+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ១នៃមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្រ្តបូរាណ www.pngplants.org/PNGtrees/TreeDescriptions/Siphonodon_celastrineus_Griff.htm lhwww.qsbg.org/Database/Botanic_Book%20full%20option/Search_detail.asp?Botanic

**រៀបរៀងដោយនិស្សិត រឿន វិឆ្ន័យ**

 



# ដើមចាក់ជខ រឺ ពុតជខ

Nom Scientifique : ***Gardenia Sootepensis Hutch.***

Famille : **RUBIACEA**

# ដើមចាក់ដេង រឺ ពុតដេង

Nom Scientifique : *Gardenia Sootepensis Hutch.*

Famille : **RUBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិមធ្យមកំពស់ពី ៩ ទៅ ១៥ ម៉ែត្រ។ ដើមមានជ័រពណ៌លឿង។ ដើមមានសំបកក្រាស់ គន្លាក់ទទឹងដើម។
  - **ស្លឹក** ៖ ស្លឹកទោលដុះឆ្លាស់ជារាងស៊ុត ទាលខាងចុងរាងស្រួចខាងទងស្លឹកផ្ទៃលើមានស្នាមធ្មតទ្រុតត្រង់ទ្រនុងស្លឹកមានប្រវែងពី២២ ទៅ ៣០ cm ទទឹង ១២ទៅ ១៨ cm ខ្នាយស្ទប។
  - **ផ្កា** ៖ ទោលចេញពីប្រគាបស្លឹក៥ត្របកពណ៌ស លឿងមាន៥ត្របក ក្រោយមកពណ៌លឿងស្រស់ មានក្លិនក្រអូប។
  - **ផ្លែ** ៖ ជាផ្លែរាងស៊ុត ផ្លែមានទ្រនុង ៥ ជ្រុង មិនរលោង។
+ **កន្លែងដាំដុះ** ៖ ដាំនៅតំបន់ដែលត្រូពិចដែលមានអាកាសធាតុក្តៅហើយសើម ។
+ **សមាសធាតុគីមី** ៖ - នៅមែកមាន: Sesquiterpene, Sootepdienone, Flavones, Benzoic acid Benzoic acid derivatives.
  -នៅក្នុងផ្លែ : D-mannitol, Beta-sitosterol, Deacetylasperulosidic acid methyl ester, Geniposidic acid, Geniposide, Scandoside methyl ester, Dimeric molecule of quinide, Geniposidic acid, Geniposide, scandoside methyl ether.
  -នៅក្នុងពកត្រួយមាន : Cytotoxic 3,4 –SecocyclartaneTriterpenes(anticancer).
+ **ផ្នែកប្រើប្រាស់** ៖ ដើម។
+ **ការប្រើប្រាស់** ៖ រក្សាគភ៌(ដើម) ចុកពោះ, ហើម, បន្ទន់លាមក, សំរួលនោម, ឆ្លងទន្លេបានស្រួល។
+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី ៣០ ទៅ ៥០ក្រាម ដាំផឹកក្នុងមួយថ្ងៃ។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ០៣បោះពុម្ពឆ្នាំ២០០៩រៀបរៀងនិងចងក្រងដោយគណ:កម្មការស្រាវជ្រាវនៃមជ្ឈមណ្ឌលវេជ្ជសាស្ត្របុរាណ។
  http://www.scincedirect.com/scince/qrcticle/pii/S0031942297011084

**រៀបរៀងដោយនិស្សិត ៖ លី្សា សុធារេន**






# ដើមបាតផ្តិល

Nom Scientifique : ***Polyalthia evecta (Pierre) Finet et Gagnep***

Famille : **ANNONACEAE**

# ដើមបាតផ្ទិល

Nom Scientifique : ***Polyalthia evecta (Pierre) Finet et Gagnep***

Famille : **ANNONACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាចុល្លព្រឹក្សខ្នាតតូចមានកំពស់០,៥-១ម៉ែត្រ មានឫសពណ៌ខ្មៅ។
  - **ស្លឹក** ៖ ជាស្លឹកទោលដុះឆ្លាស់ទងរាងស៊ុតទ្រវែង បណ្ដោយ៦-១២សង់ទីម៉ែត្រ ទទឹង២-៥សង់ទីម៉ែត្រ។
  - **ផ្កា** ៖ ផ្កាទោលចេញពីប្រគាបស្លឹកពណ៌លឿង។
  - **ផ្លែ** ៖ ជាចង្កោមរួមទង ផ្លែនីមួយៗរាងមូលពណ៌ក្រហមគ្នោតពេលទុំ។
+ **កន្លែងដាំដុះ** ៖ ដុះតាមព្រៃល្បោះ ព្រៃគុម្ពោត និង ក្រោមដើមឈើដែលមានពន្លឺថ្ងៃ។
+ **សមាសធាតុគីមី** ៖ _19-(2-furyl)nonadeca-5,7-diynoic acid,
  _19-(2-furyl)nonadeca-5-ynoic acid,
  _1-(2-furyl)pentacosa-7,9-diyne,
  _ester 21-(2-furyl)heneicosa-14,16-diyne-19-(2-furyl)nonadeca-5,7-diynoate
+ **ផ្នែកប្រើប្រាស់** ៖ ឫសមានរសល្វីង។
+ **ការប្រើប្រាស់** ៖ ស្ត្រីខ្វះទឹកដោះបំបៅកូន ឈឺពោះ រមួលក្រពើ ទាស់សរសៃ បន្សាបពុល បន្ទន់លាមក និង ព្យាបាលជំងឺមហារីក។
+ **កំរិតប្រើប្រាស់** ៖ ឫសស្ងួតប្រើពី ៨-១៥ក្រាម ដាំទឹកផឹក។
+ **ឯកសារយោង** ៖ សៀវភៅកំរងរុក្ខជាតិឱសថកម្ពុជា ឆ្នាំ២០០៩ (ភាគ៣)
  http://www.ncbi.nlm.nih.gov/m/pubmed/16441071/

**រៀបរៀងដោយនិស្សិត ៖ ណារ៉ា គន្ធី**







# បាយម៉ាត

Nom Scientifique : ***Conyza balsamiferal.***

Famille : **ASTERACEAE**

# បាយម៉ាត

Nom Scientifique : ***Conyza balsamiferal.***

Famille : **ASTERACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាចុល្លព្រឹក្សពណ៌បៃតងខ្ចាតតូច កំពស់ ១-៣ម៉ែត្រ ដើមដុះត្រង់មានរោមឬរុក្ខ ជាតិដែលមានរោមដូច សូត្រ។
- **ស្លឹក** ៖ ស្លឹករាងជាផ្លែលំពែង ទ្រវែងឬ រាង ដូចផ្លែលំពែង គែមរាងធ្មេញរណារ។
- **ផ្កាផ្លែ** ៖ -ផ្កានៅខាងចុង ផ្កាតូចៗច្រើនពណ៌លឿង ភាវ។ ផ្លែមានរោមពណ៌ស មានជ្រុង៥។ -ផ្លែតូចៗ ស្ងួតរឹង ច្រើនរលោង។

+ **កន្លែងដាំដុះ** ៖ គឺជាប្រភេទរុក្ខជាតិដុះឯងៗ ពាសពេញប្រទេសកម្ពុជា។
+ **សមាសធាតុគីមី** ៖ Volatile oil 0.1 -0.4%, - l-borneol, 25%, l-camphor 75%, limonene, saponins, sesquiterpene and limonene, tannins, sesquiterpine alcohol; palmitin; myristic acid. នៅក្នុងស្លឹកមានជាតិ : biflavonoid3-0-7 biluteolin, sesquiterpenoids.
+ **ផ្នែកប្រើប្រាស់** ៖ ស្លឹក ដើម ឬសខ្ចីមុនពេលចេញផ្កា
+ **ការប្រើប្រាស់** ៖ - រុក្ខជាតិទាំងមូលព្យាបាលទាស់ចុកខ្នង ឈឺពោះក្រោយពេលសំរាលកូន និងក្រោយពេលមករដូវ រលាកប្លោកនោម គ្រួសតំរងនោម រលាកសន្លាក់ឆ្អឹង និងគន្លាក់ដៃជើង គ្រុន ផ្កាសាយ ក្អក។

  - ឬស និង ស្លឹក ប្រឆាំងនឹងគ្រុនក្តៅ ឈឺពោះ និង ឈឺក្រពះ

  - ស្លឹកឃាត់ឈាម បាយបាន បំប៉នសុខភាពក្រោយពេលសំរាលកូន បញ្ចេញញើស បញ្ចេញស្លេស់ បណ្តេញខ្យល់ក្នុងពោះ ស្ពឹកស្រពន់ គ្រុនចាញ់ ទឹកនោមផ្អែម ណែនទ្រូង និង សំរាប់បន្តក់ដាក់ភ្នែកករណីឈឺភ្នែក។
+ **កំរិតប្រើប្រាស់** ៖ ស្លឹក៦-១៦ក្រាម ដាំផឹក ៣ដងក្នុង១ថ្ងៃ។ ឬស ១៥-៣០ក្រាមដាំផឹក៣ដងក្នុង១ថ្ងៃ។
+ **ឯកសារយោង** ៖ កំរងរុក្ខជាតិឱសថក្នុងការចុះអង្កេតស្រាវជ្រាវខេត្តមណ្ឌលគីរី ឆ្នាំ ២០១០-២០១១

**រៀបរៀងដោយនិស្សិត ៖ ហាក់ គីមហួច**









# ដើមបាយម៉ាតឆ្កេះ

Nom Scientifique : ***Blumea Lacera***

Synonyms : ***Blumea runcinata***

Famille : **ASTERACEAE**

# ដើមបាយម៉ាតឆ្កេះ

Nom Scientifique : ***Blumea Lacera***

Famille : **ASTERACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទស្មៅមានដើមត្រង់អាចមានកំពស់ដល់ ១.៥ ម វាមានក្លិនឆ្ងួលខ្លាំងហើយវារស់បានរយៈពេល ១ឆ្នាំ។
- **ស្លឹក** ៖ ស្លឹកទោលដុះឆ្លាស់ទង រាងពងក្រពើទ្រវែង ឬ ស៊ុតត្រលប់ ខ្លះមានគែមស្លឹកឆែកក្លែបៗនិងមានរោមខ្លីៗជុំវិញ គ្មានទងស្លឹកឬមានទងស្លឹកខ្លី។
- **ផ្កា** ៖ ផ្កាជាកញ្ចុំរាងកំប៉ោយ ទំហំ៣-៤ mm មានពណ៌លឿង ហើយ ទងផ្កាចេញតាមត្រគៀបស្លឹក ឬ ខាងចុងនៃដើម។
- **ផ្លែ** ៖ ផ្លែមានរោមកំប៉ោយពណ៌ស គ្រាប់ប៉ើងតាមខ្យល់ដោយសាររោមកំប៉ោយ។

+ **កន្លែងដាំដុះ** ៖ ដុះនៅតំបន់ខ្ពង់រាប ដុះតាមទីវាលមានស្មៅដុះដែលមានពន្លឺគ្រប់គ្រាន់ ឬដុះក្រោមដើមឈើធំពន្លឺចូលដល់។
+ **សមាសធាតុគីមី** ៖ Camphor, diester of coniferyl alcohol, acetylenic compounds, a thiophene Derivative, campesterol, hentriacontane, hentriacontanol, α-amyrin and Its acetate, Luperol and its acetate and β-sitosterol.
+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល។
+ **ការប្រើប្រាស់** ៖ បញ្ចុះកំដៅ បំបាត់ការឈឺចុកចាប់ ឈឺក្បាល ក្អក រលាកទងសួត បញ្ចុះទឹកនោម ធ្លាក់ស ឬសដូងបាត រាគក្រហាយ កើតលឿង ជា antiinflammatoire, antibaterien, antifongique.
+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី ៥-១០ ក្រាម ផុងផឹក។
+ **ឯកសារយោង** ៖ 

-គ្រូឱសថបូរាណ

-សៀវភៅ PROSEA Plant Resources of South-east Asia 12

-សៀវភៅ Compendium of Medicinal plants use in Malaysia.

-http://ayurvedicmedicinalplants.com/index.php?option=com

**រៀបរៀងដោយនិស្សិត ៖ ថន ស្រីម៉េង**









## បេង

Nom Scientifique : ***Afzelia xylocarpa (Kurz) Craib***
***Syn: Pahudia xylocarpa Kurz***

Famille : **FABACEAE**

# បេង

Nom Scientifique : *Afzelia xylocarpa (Kurz) Craib*
Famille : **FABACEAE**

+**លក្ខណៈរុក្ខជាតិ** ៖ ជាដើមឈើធំ មានកំពស់រហូតដល់ ៣០ម៉ែត្រ។

- **ស្លឹក** ៖ រួមប្រភេទរោមបក្សីគត់គូ ដុះឆ្លាស់ទង កូនស្លឹកមាន ៣-៥គូ រាងស៊ុតទ្រវែង ទទឹង៤-៥ស.ម បណ្តោយ៥-៩ស.ម។
- **ផ្កា** ៖ កញ្ចុំផ្កានៅចុងមែក គម្របផ្កាពណ៌បៃតងភាវ មានបួនត្របក ពណ៌ក្រហមមានតែមួយ។
- **ផ្លែ** ៖ សំប៉ែត ពណ៌ត្នោត សំបករឹងដូចឈើ មានពីរថត គ្រាប់រឹងមាន ៧-៨គ្រាប់ ពណ៌ត្នោតក្រមៅមួយកំណាត់ ពណ៌ទឹកក្រូចមួយកំណាត់។

+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯងតាមតំបន់ភ្នំ ព្រៃរបោះ។ បន្តពូជដោយគ្រាប់។

+**សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ។

+ **ផ្នែកប្រើប្រាស់** ៖ សំបកដើម ខ្លឹម ឬស គ្រាប់។

+ **ការប្រើប្រាស់** ៖ -សំបកដើមព្យាបាលស្ពឹកដៃជើង ធ្វើអោយឈាមរត់ស្រួល។
-ខ្លឹមព្យាបាលឡើងឈាម។
-ឬសធ្វើជាថ្នាំជំនួយកំលាំង។
-គ្រាប់ដុសលាបបូស ដុតអោយឈ្ងុយដាំហូបដូចតែ។
-គ្រាប់ស្ងោរបៀមព្យាបាលឈឺធ្មេញ។

+ **កំរិតប្រើប្រាស់** ៖ ស្ងួត ១៥ ទៅ ២០ ក្រាម ដាំផឹក។

+ **ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជា ភាគ ៣ ឆ្នាំ២០០៩។

**រៀបរៀងដោយនិស្សិត ៖ ស្រេង ស្រីឡែន**







# ប្រគ្រាបធំ-ប្រគ្រាបដរី

Nom Scientifique : ***Elephantopus Seaber L***

Famille : **ASTERACEAE**

# ប្រក្រាបធំ-ប្រក្រាបដីរី

Nom Scientifique : ***Elephantopus Seaber L***
Famille : **ASTERACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ តិណជាតិមានកំពស់ពី ២០-២៥ ស.ម ។

- **ស្លឹក** ៖ ទោលរាងផ្លែលំពែងទទឹង ២-៦ ស.មបណ្តោយ ១០-២៥ ស.មមានរោមរឹងលើផ្ទៃសងខាង តែមស្លឹកធក រាងជាទឹក រលកដុះជាកញ្ចុំក្រាបទៅលើដី ។
- **ផ្កាផ្លែ** ៖ កញ្ចុំផ្កាដុះបែកជាខ្នែងចេញពីទងតែមួយ ផ្កាតូចៗ ពណ៌ស្វាយភ្លាវ ឬផ្កាឈូក ជាប្រភេទផ្កា ផ្នុក ក្តោបដោយកូនស្លឹក ២-៣ ផ្លែស្ងួត រោមរាងទ្រវែង ១០ ជ្រុង

+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯងនៅកន្លែងសើម ដីទំនេរក្រោមដើមឈើធំ ។

+ **សមាសធាតុគីមី** ៖ ផ្កា, ដើម និងស្លឹកមាន Brucein luteolin -7- glucoside, មាន: flavonoid, elephantopin, molephantin, molephantinin, isodeoxyelephantopin, 11,13 dyhydrodeoxyelephantopin, deoxyelephantopin.

+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល ។

+ **ការប្រើប្រាស់** ៖ - រុក្ខជាតិទាំងមូល : បញ្ចុះទឹកនោម, បញ្ចុះកំដៅ, បំបាត់ឈឺចាប់, បន្ទន់លាមក, បំបាត់ហើមរលាក, បង្កើនសមត្ថភាពផ្លូវភេទ ។ មិនឃ្លានអាហារ, ហើមជើង, ជំងឺកាមរោគ, គ្រុនក្តៅ, ជំងឺស្ងួត, ឈាមច្រមុះ, ឈឺពោះ, ក្អួតចង្អោរ, រាគមូល, ហើមទឹក, ខាន់លឿង, ធ្លាក់ស, រលាក ស្រោមពង, ស្លេកស្លាំងខ្វះឈាម, ស្ត្រីឆ្លងទន្លេហើយ, ប្រើថ្នាំ បំប៉នសុខភាព, ផ្សះបូស, អាប់សែ, ពស់ចឹក, សត្វល្អិតទិច ឬខាំ, ទំលាក់ព្រូនចង្កឹះ, របួស, កមរមាស់, បុកបិតពីក្រៅ ។
- ឬសស្រស់ : ប្រើដើម្បីបំបាត់ក្អួត, ឈឺទ្រូង, គ្រុនក្តៅ,បង្កើនទឹកនោម ។
ឬសបុកលាយទឹកផឹក ព្យាបាលធ្លាក់ស, ស្លេកស្លាំងខ្វះឈាម, គ្រុនចាញ់ ។

+ **កំរិតប្រើប្រាស់** ៖ ស្រស់ ៣០-៦០ ក្រាម ដាំទឹកផឹងក្នុងមួយថ្ងៃ ស្ងួត ១៦-២០ ក្រាម ដាំទឹកផឹងក្នុងមួយថ្ងៃ ។

+ **ឯកសារយោង** ៖ - សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ ១ - ២០០៨ http://www.ijp-online.com

**រៀបរៀងដោយនិស្សិត ៖ ខ៉ាន់ ច័ន្ទមករា**







# ដើម ប្របា្រាបធំ-ប្របា្រាបដំរី

Nom Scientifique : ***Elephantopus Scaber L.***

Famille : **ASTERACEAE**

# ដើម ប្រក្រាបធំ-ប្រក្រាបដំរី

Nom Scientifique : ***Elephantopus scaber L.***

Famille : **ASTERACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ តិណជាតិមានកំពស់ពី ២០-២៥cm។
  - **ស្លឹក** ៖ ទោល, រាងផ្លែលំពែង ទទឹង ២-៦cm បណ្តោយ១០-២៥cm មានរោមរឹងលើផ្ទៃសងខាងគែមស្លឹកធកករាងជាទឹករលកដុះជាកញ្ចុំក្រាបទៅនឹងដី។
  - **ផ្កា** ៖ កញ្ចុំផ្កាដុះបែកជាខ្នែងចេញពីទងតែមួយ ផ្កាតូចៗពណ៌ស្វាយភ្លាវឬផ្កាឈូកជាប្រភេទផ្កាផ្នុក ក្តោបដោយកូនស្លឹក ២-៣។
  - **ផ្លែ** ៖ ផ្លែស្ងួតមានរោមរាងទ្រវែងមាន១០ជ្រុង។

+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯងនៅកន្លែងសើម ដីទំនេរក្រោមដើមឈើធំ។

+ **សមាសធាតុគីមី** ៖ ផ្កា ដើម ស្លឹក មាន phantomolin, bruceinluteolin-7-glucoside, scarbertopin, flavonoid, deoxyelephantopin, isoscabertopin, 11;13 Dyhydro Deoxyelephantopin, Sesquiterpene lactones

+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល។

+ **ការប្រើប្រាស់** ៖ រុក្ខជាតិទាំងមូលៈ ព្យាបាល បញ្ចុះទឹកនោម, បន្ថយកំដៅ, ហើមជើង, កាមរោគ, ជំងឺស្ងួត, ឈាមច្រមុះ, ឈឺពោះ, ក្អួត, រាគមូល, ខាន់លឿង, ធ្លាក់ស, ផ្សះបូស, រលាកស្រោមពង, ស្លេកស្លាំងខ្វះឈាម, អាប់សែរ, ពស់ចឹក, ទំលាក់ព្រូនចង្កឹះ ឬសស្រស់ៈ ប្រើដើម្បីបំបាត់ក្អួត, ឈឺទ្រូង, គ្រុនក្តៅ, ទឹកនោម ឬសបុកលាយទឹកផឹក ព្យាបាលធ្លាក់ស, ស្លេកស្លាំងខ្វះឈាម, គ្រុនចាញ់

+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី ៣០-៦០ ក្រាម ស្រស់ ដាំទឹកផឹកក្នុង១ថ្ងៃ។
  ប្រើប្រាស់ពី ១៦-២០ ក្រាម ស្ងួត ដាំទឹកផឹកក្នុង១ថ្ងៃ។

+ **ឯកសារយោង** ៖ មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ។
  http://www.ijp-online.com

**រៀបរៀងដោយនិស្សិត ៖ សេខ ស៊ីវនី**







# វល្លិ៍ប្រឡៅពពែ , ក្រឡាំពែ

Nom Scientifique : ***Aganosma marginata (Roxb.)G.Don***

Famille : **APOCYNACEAE**

# វល្លិ៍ប្រឡៅពពៃ , ក្រឡាំពៃ

Nom Scientifique : *Aganosma marginata (Roxb.)G.Don*

Famille : **APOCYNACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទវល្លិ៍ឈើ ។
- **ស្លឹក** ៖ ទល់ទងរាងដូចផ្លែលំពែង ទងស្លឹកមានពណ៌ក្រហម មានទទឹងពី៤,៥-១២ cm បណ្តោយពី២- ៤ cm ។
- **ផ្កាផ្លែ** ៖ ផ្កាពណ៌សក្រអូបចេញនៅចុងមែក បែកចេញជា ៥។ ផ្លែមូលវែងមួយគូៗគ្រាប់មានរោមឆ្មារៗ។
+ **កន្លែងដាំដុះ** ៖ ដុះក្នុងព្រៃស្មោង តំបន់ភ្នំ និងជារុក្ខជាតិស្រទាប់ក្រោមប្រទេសកម្ពុជា។
+ **សមាសធាតុគីមី** ៖ Alcaloide
+ **ផ្នែកប្រើប្រាស់** ៖ ស្លឹក ផ្កា ផ្លែ និង ឬស។
+ **ការប្រើប្រាស់** ៖ ស្លឹក ផ្កា ផ្លែ ប្រើសំរាប់រំលាយអាហារ បញ្ចុះទឹកនោម សំលាប់មេរោគ។ ឬសស្ងោរផឹកសំរាប់ព្យាបាលប្រព័ន្ធតំរងនោម គ្រុន រដូវមិនទៀង។ រុក្ខជាតិទាំងមូលក្រៀមធុង រឺ ស្ងោរជាថ្នាំសំរាប់លើកកំលាំង។ ស្លឹកខ្ចីអាចធ្វើបន្លែស្ល ហូបបាន។
+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់មិនអោយលើសពី១ក្រាម សំរាប់១គីឡូក្រាមនៃទំងន់ខ្លួន។
+ **ឯកសារយោង** ៖ កំរងរុក្ខជាតិឱសថក្នុងការចុះអង្កេតស្រាវជ្រាវ ក្នុងខេត្តកំពត ឆ្នាំ២០០៧ ២០០៨។ កំរងរុក្ខជាតិឱសថក្នុងការចុះអង្កេតស្រាវជ្រាវ ក្នុងខេត្តព្រះសីហនុ ឆ្នាំ ២០០៨ ២០០៩។

**រៀបរៀងដោយនិស្សិត៖ ឡុង ស៊ីថា**






# ច្រាំជំឡឹខ

Nom Scientifique : *Terminalia corticosa*

Famille : **COMBRETACEAE**

# ប្រាំជំឡឹង

Nom Scientifique : *Terminalia corticosa*

Famille : **COMBRETACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើធំពី ៨-២០ម វិជ្ឈមាត្រពី ០,៧-១ម មែកខ្ចីមានរោមពណ៌ក្រហមភ្លាវ មែកចាស់រលោង ។
  - **ស្លឹក** ៖ ស្លឹកទល់ទង ឬ ស្ទើរទល់ រាងអេលីបទូលាយ ( ទាលសងខាង ប៉ោងកណ្ដាល ) បណ្ដោយពី ៧-១៥ស.ម ទទឹងពី ៦-១០ស.ម ។ ផ្ទៃខាងលើមានរោមតិចៗ ផ្ទៃខាងក្រោមមានរោមពណ៌ក្រហមភ្លាវ ជូនកាលផ្ទៃទាំងសងខាងស្មើគ្នាតាមសរសៃស្លឹក និងទ្រនុងស្លឹក ។ ទងស្លឹករលោងប្រវែង ១ស.ម ។
  - **ផ្កា** ៖ កញ្ចុំផ្កាជាចង្កោមវែង ចេញពីប្រគាបមានផ្កាច្រើន ។ កញ្ចុំផ្កាប្រវែងពី ១០-១៥ស.ម មានរោមផ្កាយ ។ ផ្កានីមួយៗ មានប្រវែង០,៥ស.ម មាន ទាំងភេទញី និង ឈ្មោល តំរៀបគ្នាយ៉ាងញឹក មានរោមយ៉ាងច្រើន
  - **ផ្លែ** ៖ ផ្លែ មានស្លាបពីរ ស្តើង ហើយ ស្វិត ពណ៌លឿងត្នោត មានគ្រាប់នៅកណ្ដាល ។ផ្លែ ប្រវែង ៣-៣,៥ស.ម ទទឹង ៣ស.ម មានគ្រាប់តែមួយរាងទ្រវែង បណ្ដោយ ១ស.ម ទទឹង ២ម.ម
+ **កន្លែងដាំដុះ** ៖ ច្រើនដុះនៅតំបន់ខ្ពង់រាប ដីទួល ល្បាយខ្សាច់ និង ថ្ម
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ
+ **ផ្នែកប្រើប្រាស់** ៖ សំបក ឬស
+ **ការប្រើប្រាស់** ៖ គ្រូបុរាណខ្លះនិយមប្រើជាថ្នាំ រាក ជំនួយកម្លាំង ទាស់
+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី ១០-២០ក្រាម
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថបុរាណរបស់លោកគ្រូឱសថបុរាណ

**រៀបរៀងដោយនិស្សិត ៖ ទឹង ស្រីមុំ**







## ផ្ចឹក

Nom Scientifique : ***Shorea obtusa wall***

*Famille :* ***DIPTEROCARPACEAE***

# ធ្នឹក

Nom Scientifique : ***Shorea obtusa wall***

*Famille :* ***DIPTEROCARPACEAE***

+ **លក្ខណៈរុក្ខជាតិ** ៖ ជាដើមឈើធំ មានកំពស់ ១៥ - ៣0m សំបកពណ៌ប្រផេះត្នោត ប្រេះតាមបណ្ដោយដើម មានជ័រពណ៌លឿង ។
  - **ស្លឹក** ៖ រាងទ្រវែង មានបណ្ដោយពី ៧ - ១៥ ស.ម ទទឹងពី ៣ - ៦ ស.ម ផ្ទៃខាងលើរលីង ផ្ទៃខាងក្រោមមានរោមតិច ។
  - **ផ្កា** ៖ កញ្ចុំផ្កានៅខាងមែក រាងជាចង្កោមក្ងរបី ជាតូចៗពណ៌លឿងភាវ ។
  - **ផ្លែ** ៖ ផ្លែមានប្រវែង ១,៨ ស.ម មានស្លាបធំ៣ ប្រវែង ៤ - ៥ ស.ម ស្លាបតូច២ ផ្លែមានរោម ។
+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯង នៅតំបន់ព្រៃស្បោះ ស្ងួត មានឧព្ទេធពី ២០០ - ១០០ម ។ បន្តពូជដោយគ្រាប់ ។
+ **សមាសធាតុគីមី** ៖ មាន ទាននិនស ច្រើន ។
+ **ផ្នែកប្រើប្រាស់** ៖ ជ័រ, ខ្លឹម, សំបក, ឬស ។
+ **ការប្រើប្រាស់** ៖ ជ័រៈ អោយជ្រូកស៊ីកុំអោយមានកូន ។
  សំបកៈ ស្ត្រីក្រោយឆ្លងទន្លេ ដើម្បីជំនួយសុខភាព ។
  ខ្លឹមៈ ផ្សះ ធ្លាក់ស ចំរើនអាយុ ។
  ឬសៈ ប្រើជាថ្នាំពន្យាកំនើត ។
+ **កំរិតប្រើប្រាស់** ៖ ប្រើពី ១០ - ២០ ក្រាម ដាំទឹកហូបក្នុងមួយថ្ងៃ ។
+ **ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជា ភាគ៣

**រៀបរៀងដោយនិស្សិត ៖ ម៉ៀង ធារី**










## ផ្ដៅដំបង

Nom Scientifique : *Calamus rudentum* **Lour.**

Famille : **ARECACEAE**

# ផ្តៅដំបង

Nom Scientifique : ***Calamus rudentum* Lour.**

Famille : **ARECACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទវល្លិ មានបន្លា មានរាងមូលមានប្រវែង ៥-២០m ដើមចាស់មានអង្កត់ផ្ចិត ២,៥-៣,៥ Cm សំបករបស់វាមានអង្កត់ផ្ចិតពី៤-៧ Cm៕
  - **ស្លឹក** ៖ មានបន្លា មានពី១០គូរទៅ២០គូរ(ស្លឹកសេស) គែមស្លឹកមានធ្មេញរណាតូចៗ៕
  - **ផ្កា** ៖ ពណ៌សតូចៗ ជាចង្កោម ដុះចេញពីស្រទាប់ ធាងស្លឹក៕
  - **ផ្លែ** ៖ ផ្លែមានរាងមូលតូចៗទំហំ1,8cmx1,2cm ជាចង្កោម មានច្រើនថ្នាក់។ ពេលខ្ចីមានពណ៌ខៀវ និង ពេលទុំមានពណ៌លឿង ៕
+ **កន្លែងដាំដុះ** ៖ ដាំនៅតំបន់ត្រូពិចដែលមានអាកាសធាតុក្តៅហើយសើម៕
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ៕
+ **ផ្នែកប្រើប្រាស់** ៖ -គល់ ឬសធ្វើជាឱសថ៕
  -ផ្លែអាចទទួលទានបាន មានរស់ជាតិ ជូរ ផ្អែម ចត់៕
  -ដើមខ្ចីអាចធ្វើជាបន្លែ ស្លរជាម្ហូបផ្សេងៗ។
  -ដើមចាស់ធ្វើជាគ្រឿងសង្ហារឹមផ្សេងៗ ដូចជា តុ ទូ កៅអី។
+ **ការប្រើប្រាស់** ៖ - គល់ ឬសប្រើសំរាប់បញ្ចុះកំដៅ ផ្សះ កាមរោគ និង ថ្នាំកូនខ្ចី។
+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី 15 – 30g ៕
+ **ឯកសារយោង** ៖ -សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ១ដោយមជ្ឈមណ្ឌលស្រាវជ្រាវវេជ្ជសាស្ត្របុរាណឆ្នាំ ២០០៨។
  -Field guide of the rattans of Cambodia_*Calamus rudentum* Lour.
  -www.nafri.org.la/document/ntfphandbook/eng/69_301-322.pdf
  -ពត៌មានមួយចំនួនបានពីគ្រូថ្នាំបុរាណ៕

**រៀបរៀងដោយនិស្សិត ៖ ធឿន ចន្ធី**







# ផ្តៅស្វាស៊ីស្លឹក, ដើមថ្លាញ

Nom Scientifique : ***Stenochlaenapalustris (Burm.f.)Bedd.***

***Synonym: Polypodium palustre Burm.f.***

Famille : **BLECHNACEAE,FOUGÈRES, POLYPODIACÉES**

# ផ្ទៅស្វាស៊ីស្លឹក, ដើមថ្លាញ

Nom Scientifique : ***Stenochlaenapalustris (Burm.f.)Bedd.***
***Synonym: Polypodium palustre Burm.f.***
Famille : **BLECHNACEAE,FOUGÈRES, POLYPODIACÉES**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិវល្លិមួយប្រភេទវាលើឈើព្រៃស្ពាច់, មានប្រវែងប្រហែល ១.៣-១.៨ម។ ប្រែពណ៌ពី ក្រហម ទៅ បៃតងខ្ចី រួច ដូរមក បៃតងចាស់។
  - **ស្លឹក** ៖ ស្លឹករាងទ្រវែងប្រវែង១០-១៥សមទទឹង៣-៤សមស្រួចចុងផ្ទៃខាងលើរលោង ផ្ទៃខាងក្រោមរាងគ្រើម។
  - **ផ្កាផ្លែ** ៖ គ្មាន
+ **កន្លែងដាំដុះ** ៖ ច្រើនមានដុះឥណ្ឌា ម៉ាឡេស៊ី អូស្ត្រាលីខាងជើង,ប៉ូលីនេស៊ី, ប៉ែកអាស៊ីមានដុះនៅតំបន់ភ្នំ ពិសេសខេត្តរតនគិរី និងមណ្ឌលគិរី ,ដែលវាភាគច្រើនចូលចិត្តដុះនូវកន្លែងមានសំនើម និង មានពន្លឺគ្រប់គ្រាន់។
+ **សមាសធាតុគីមី** ៖ ការស្រាវជ្រាវនូវពុំទាន់ច្បាស់នៅឡើយ ។
+ **ផ្នែកប្រើប្រាស់** ៖ គេប្រើដើម និង ស្លឹក ។
+ **ការប្រើប្រាស់** ៖ ដើម នឹង ស្លឹក គេស្ងោរផឹកដើម្បីបញ្ចុះ កំដៅ, Anti-fongique,ធ្លាក់ស, រាគមួល ជា ពិសេសនៅអាស៊ីគេច្រើនប្រើធ្វើជាបន្លែ ។
+ **កំរិតប្រើប្រាស់** ៖ 750មីលីក្រាម/kg។
+ **ឯកសារយោង** ៖

http://www.ars-grin.gov/cgi-bin/npgs/html/taxon.pl
http://www.prota.org
http://www.plantcare.com
http://www.Fernatic.Free.Fr
http://www.palmaris.org

រៀបរៀងដោយនិស្សិត ៖ វ៉ែន ពៅ







**ពន្លា**

Nom Scientifique : ***Microcos tomentosa Sm***

Famille : **TILIACEAE**

# ពន្លា

Nom Scientifique : *Microcos tomentosa Sm*

Famille : **TILIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទដើមឈើតូច រឺជាដើមដែលបែកមែកសាខាច្រើន ដែលមានកំពស់ពី4-5m ។
  - **ស្លឹក** ៖ ស្លឹកមានរោម ហើយស្លឹកមានតែ១ (feuilles simples)មានរាងមូលនៅគល់ តែស្រួចនៅខាងចុង ។
  - **ផ្កា** ៖ នៅលើផ្កាតែ១ អាចមានកេសរញី និងឈ្មោលនៅជាមួយគ្នា (bisexuelle) ។
  - **ផ្លែ** ៖ មានរាងតូចៗស្ថិតនៅជាប់កញ្ចុំៗ និងមានពណ៌បៃតង ។
+ **កន្លែងដាំដុះ** ៖ ដុះនៅលើដីវាល ជាពិសេសប៉ែកខាងជើងនៃប្រទេសកម្ពុជា ។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ ។
+ **ផ្នែកប្រើប្រាស់** ៖ ឫស , ផ្លែទុំ, សំបក ។
+ **ការប្រើប្រាស់** ៖ ឫស: សំរាប់ផុងទឹកផឹក សំរាប់ព្យាបាលក្អក
  ផ្លែទុំ: អាចហូបបាន
  សំបក: សំរាប់ធ្វើខ្សែពួរ ដោយសារមានសរសៃធ្មារៗច្រើនស្វិត ។
+ **ឯកសារយោង** ៖ កំរងរុក្ខជាតិឱសថក្នុងការចុះអង្កេតស្រាវជ្រាវនៅខេត្តមណ្ឌលគិរីឆ្នាំ 2010-2011 ។

**រៀបរៀងដោយនិស្សិត ៖ សុត ដានី**






# ស្មៅពពកក្រឡប់ រឺ ស្មៅស្រឡប់ពពក

Nom Scientifique : *Desmodium Styracifolii.*

Famille : **FABACEAE OU LEGUMINOSAE**

# ស្មៅពពកគ្រឡប់ រឺ ស្មៅស្រឡប់ពពក

Nom Scientifique : ***Desmodium Styracifolii.***

Famille : **FABACEAE OU LEGUMINOSAE**

**+ លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទស្មៅវាលលើដី មានពណ៌ស-ប្រផេះ (មានរោម) ។

**- ស្លឹក** ៖ មានពពធំកណ្តាលជួនមានតែមួយរាងស្មើរមូល រឺ ចុងត្រឹមសរសៃសងខាង រាងស្លាប ហើយទៀងទាត់ ផ្ទៃខាងខ្នងគ្របដោយរោមទន់ៗពណ៌ស។

**- ផ្កា** ៖ ជាកញ្ចុំនៅចុង និង នៅតាមក្លៀកទងផ្កា។
ផ្កាតូចៗពណ៌ស្វាយភាវគ្របកផ្ការាងដូចមេអំបៅ។

**- ផ្លែ** ៖ មានកួរ មានស្នាមគ្រាប់៣-៦គន្លាក់នៅម្ខាងគ្របដោយរោមទំពក់។

**+ កន្លែងដាំដុះ** ៖ ដុះនៅកន្លែងដីទំនាប ដីទំនេរ ជំរាលភ្នំ នៃប្រទេសកម្ពុជា ថៃ ឡាវ វៀតណាម ភូមា ចិន ភាគខាងត្បូង។

**+ សមាសធាតុគីមី** ៖ មិនទាន់ស្រាវជ្រាវ ។

**+ ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល ។

**+ ការប្រើប្រាស់** ៖ -រលាកផ្លូវនោម ក្រួសផ្លូវនោម ហើមនៃវក្កំ។
-ខាន់លឿងនៃថ្លើម រលាកថង់ប្រមាត់ ក្រួសប្រមាត់។

**+ កំរិតប្រើប្រាស់** ៖ ប្រើពី២០-៦០ក្រាម ដាំផឹក។

**+ ឯកសារយោង** ៖
-Manual of common-use in traditional Chinese medicine (1992).
-Chinese medicinal Herbs of Hong Kong Vol 4 (1988).

**រៀបរៀងដោយនិស្សិត ៖ ឃឹម សុវ៉ាមី**







# ពពាលខែ

Nom Scientifique : ***Terminalia calamansanail ( Blanco ) Rolfe***

*Famille :* ***COMBRETCEAE***

# ពពាលខែ

Nom Scientifique : ***Terminalia calamansanail ( Blanco ) Rolfe***

*Famille :* ***COMBRETCEAE***

+ **លក្ខណៈរុក្ខជាត** ៖ ជាដើមឈើធំ មានកំពស់ពី២៥ ទៅ៣០ម សំបកដើមពណ៌ប្រផេះ ប្រេះតាមបណ្តោយដើម។
  - **ស្លឹក** ៖ ទោលដុះឆ្លាស់ទង រាងជាស៊ុតត្រឡប់ ខាងលើពណ៌បៃតងរលោង ខាងក្រោមពណ៌បៃតងភាវ ។ប្រវែងពី១៥ទៅ២០ស.ម ទទឹង ៦ទៅ ១០ ស.ម ផ្តុំគ្នានៅចុងមែក។
  - **ផ្កាផ្លែ** ៖ ជាកួរវែងចេញនៅចុងមែក ឬ ពីប្រគាបស្លឹក ផ្កាមានពណ៌លឿងភាវ ។ មានស្លាបពីទល់គ្នារាងដូចសត្វមេអំបៅ។
+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនវានៅតំបន់ព្រៃល្បោះភ្នំទាបៗ។បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ មានសារធាតុ phenolic យ៉ាងច្រើន ។
+ **ផ្នែកប្រើប្រាស់** ៖ សំបក។
+ **ការប្រើប្រាស់** ៖ រាកមូល ជំនួយកំលាំង សំរួលឈាម រាំរដូវ ជ្រាំង ស្បូនស្រុត ។
+ **កំរិតប្រើប្រាស់** ៖ ១០ ទៅ ២០ ក្រាម ដាំផឹកឬត្រាំស្រា ។
+ **ឯកសារយោង** ៖ ស្រង់ពីសៀវភៅរុក្ខជាតិឱសថកម្ពុជា(ភាគ ៣) ក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិស្រាវជ្រាវ វេជ្ជសាស្រ្តបុរាណឆ្នាំ២០០៩ ។

**រៀបរៀងដោយនិស្សិត ៖ ក. ពិសិទ្ធ សោភណ័**







# ដើមពពេល

Nom Scientifique : ***shorea roxburghi G Don***

***shorea cochinchinensis pierre***

Famille : **DIPTEROCARPACEAE**

# ដើមពពេល

Nom Scientifique : ***shorea roxburghi G Don***

***shorea cochinchinensis pierre***

Famille : **DIPTEROCARPACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទដើមឈើធំ មានកំពស់១០-១៥ m

- **ស្លឹក** ៖ រាងមូលពងក្រពើឬ វែងប្រវែង៨ -១៥ cm ទទឹង៤ -៦cm ពណ៌ស្វាយ មានរោមសសៃនៅលើស្លឹក ពិសេសផ្ទៃកមុខក្រោយ។

- **ផ្កាផ្លែ** ៖ កញ្ចុំផ្កា រោមគ្មាន ប្រវែង៧ -៨ cm ទងផ្កាលឿងកំ ១-៥cm មានកេរសរ១៤ -១៧រុំពទ្ធ័ដោយម្សៅមានរោម វាចេញផ្កានៅខែ មករា និង កុម្ភះ

+ **កន្លែងដាំដុះ** ៖ មានដុះនៅក្នុងព្រៃល្បោះ ព្រៃស្រោង ព្រៃភ្នំ តំបន់ដែលមានខ្សាច់ច្រើន

+ **សមាសធាតុគីមី** ៖ Tanins and phenolic substance

+ **ផ្នែកប្រើប្រាស់** ៖ សំបក ផ្កា

+ **ការប្រើប្រាស់** ៖ សំបកពពេលប្រើព្យាបាលរាគមូល ផ្កាពពេលប្រើបន្ថយកំដៅ ជំនួយបេះដូង

+ **កំរិតប្រើប្រាស់** ៖ ប្រជាជនកម្ពុជាភាគច្រើនគេនិយមប្រើសំសបកពពេលដាក់ក្នុងបំពង់ត្នោតដើម្បីកុំអោយឡើងពពុះធ្វើអោយទឹកត្នោតថ្លា។

+ **ឯកសារយោង** ៖ Medicinal plants of Cambodia by lavit kham2004
-http// wiki .answers .com /Q/ what -is - French - name for shorea .co chinchinsis

**រៀបរៀងដោយនិស្សិត ៖ អ៊ុក រត្ន័មុនី**








# ពពូលថ្ម , ថ្វាយ

Nom Scientifique : ***Vitex Pubescens Vahl***

Famille : **VERBENACEAE**

# ពពូលថ្ម , ថ្វាយ

Nom Scientifique : ***Vitex Pubescens Vahl***

Famille : **VERBENACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទដើមឈើមធ្យមមានកំពស់ពី 20-30m ដែលមានអង្កត់ផ្ចិតប្រហែលពី 40-70cm មែកខ្ចីមានទ្រនុង មានរោមតិចៗ។
  - **ស្លឹក** ៖ ស្លឹកដុះរួមទងមានកូនស្លឹក3-5 មានស្លាបអមទងស្លឹក ដុះទល់ទង។ ស្លឹករាងទ្រវែងមានបណ្តោយពី 3-25cm និងទទឹងពី 1,5-10cm ។
  - **ផ្កា** ៖ ផ្កាជាកញ្ចុំចេញនៅចុងមែក មានប្រវែងពី 20-35cm ពណ៌ស បៃតងឬស្វាយ។
  - **ផ្លែ** ៖ ផ្លែរាងមូលមានអង្កត់ផ្ចិតពី 5-8mm ផ្លែខ្ចីមានពណ៌បៃតង ផ្លែទុំមានពណ៌ខ្មៅឬស្វាយ។
+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯង នៅតំបន់ភ្នំ និង ខ្ពង់រាប។បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវច្បាស់លាស់។
+ **ផ្នែកប្រើប្រាស់** ៖ សំបកដើម ស្លឹកខ្ចី គ្រាប់ ។
+ **ការប្រើប្រាស់** ៖ - សំបកដើម : ជំនួយកំលាំង និងបំបាត់គ្រុនក្តៅ ។
  - គ្រាប់ : ទំលាក់ព្រូននិងបំបាត់ឈឺពោះ។
  - ស្លឹកខ្ចី : ជាតិចំរាញ់ពីស្លឹកប្រើជាថ្នាំជំនួយរំលាយអាហារ បាយឆ្ងាញ់។
+ **កំរិតប្រើប្រាស់** ៖ ប្រើផ្នែកស្ងួតពី 15-20g ក្នុងមួយថ្ងៃ ។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជារបស់ក្រសួងសុខាភិបាលនៃមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ ភាគ2 ឆ្នាំ២០០៨
  - http://www.mendeley.com
  - http://en-wikipedia.org/wiki/vitex_pinnata

**រៀបរៀងដោយនិស្សិត ៖ ថា ផានី**






# ពពូលសំឡី រឺ ស្រឡី

Nom Scientifique : *Vitex quinata (Lour.)F.N.Williams*

Famille : **VERBENACEAE**

# ពពូលសំឡី រឺ ស្រឡី

Nom Scientifique : *Vitex quinata (Lour.)F.N.Williams*

Famille : **VERBENACEAE**

**+ លក្ខណៈរុក្ខជាតិ** ៖ ជាដើមឈើដែលមានកំពស់រហូតដល់ ២៥m មែកខ្ចីជ្រុង មានរោមតិចៗ រឺ គ្មាន។

**- ស្លឹក** ៖ ស្លឹករូមទងមាន៥សន្លឹក រាងស្រួចចុង, ជួនកាលមានរោម ជួនកាលអត់រោម ដុះទល់ទង ទងស្លឹកមានប្រវែងពី ៤-២០cm។

**- ផ្កាផ្លែ** ៖ ផ្កាៈ ចេញជាកញ្ចុំ មានពី ២០-២៥cm ផ្កាមានពណ៌លឿងតិចៗ។
ផ្លែៈ ពេលទុំមានពណ៌ខ្មៅ ទំហំ ៦mm។

**+ កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯងនៅតំបន់ខ្ពង់រាប ភ្នំ និង បន្តពូជដោយគ្រាប់។

**+សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ ។

**+ ផ្នែកប្រើប្រាស់** ៖ សំបកដើម ឬស។

**+ ការប្រើប្រាស់** ៖ សំបកដើមៈ ដាំទឹកផឹក រឺ ត្រាំស្រា ជាថ្នាំប៉ូវ ឆុងទឹកផឹកជាថ្នាំ រំលាយអាហារ និង ព្យាបាលឈឺសន្លាក់ដៃ ជើង។
ស្លឹកៈ ព្យាបាលផ្តាសាយ ឈឺសន្លាក់ដៃ ជើង។

**+ កំរិតប្រើប្រាស់** ៖ មិនទាន់មានការស្រាវជ្រាវ ។

**+ ឯកសារយោង** ៖
- www.google.com.kh/image?q=Vitex+quinata......
- www.pngplants.org/PNGtrees/TreeDescription/Vitex_quinata_Lour_N_F William.html
- សៀវភៅរុក្ខជាតិ (ភាគ២) ទំព័រ២៧៧.

**រៀបរៀងដោយនិស្សិត ៖ ពៅ លក្ខណា**









# ដើមពុទ្រាព្រៃ, ភ្លិនឆា, កន្ទ្រា, ពុទ្រាឈ្លូស

Nom Scientifique : ***Harrrisonia perforata ( Blanco ) Merr***

*Famille :* ***SIMAROUBACEAE***

# ក្លិនធា - ព្យុទ្រាឈ្លូស - ព្យុន្ធ្រាព្រៃ - កន្ទ្រា

Nom Scientifique : *Harrrisonia perforata ( Blanco ) Merr*

*Famille :* ***SIMAROUBACEAE***

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិប្រភេទឈើតូច ដុះជាគុម្ពមានកំពស់ ៣-៦ម៉ែត្រ ដើមពណ៌ប្រផេះ មែកខ្ចីក្រហមស្វាយក្រម៉ៅមានបន្លាតាមមែក។
- **ស្លឹក** ៖ ស្លឹកចាស់ពណ៌បៃតង ស្លឹកខ្ចីពណ៌ក្រហម ដុះពីរជួរអមធាងមានពី៩ទៅ១៥សន្លឹកស្លឹកនីមួយៗមានរាងពងក្រពើស្រួចខាងចុងគែមមានធ្មេញរណា។
- **ផ្កា** ៖ ផ្កាពណ៌សដុះជាកញ្ចុំ ត្របកផ្កានីមួយៗមានប្រវែង៦-៨ស.ម មានត្របក ៥មានរោមក្នុងផ្កាមានកេរសឈ្មោល១០ តូចៗព័ទ្ធជុំវិញ កេរសញី ធំមួយ នៅចំកណ្ដាល។
- **ផ្លែ** ៖ ផ្លែពណ៌ក្រហម ចេញផ្កា ចេញផ្លែគ្រប់រដូវ។

+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯង និងតាមតំបន់ព្រៃរបោះ។

+ **សមាសធាតុគីមី** ៖ ក្នុងស្លឹក និងផ្លែមាន Limonoid A,B and D-seco-16-nor-type ones, 5,6-dehydrodesepoxyharperforin C2 et harrpernoid B&C. ក្នុងមែកមាន Perforatinolone A, B,C & D, Peucenin-7 méthyl ether,Eugenin, O-méthylloptaeroxyline, perforatic acid, Saikochromone, greveichromenol.

+ **ផ្នែកប្រើប្រាស់** ៖ សំបក ដើម មែក ស្លឹក ផ្លែ ។

+ **ការប្រើប្រាស់** ៖
- គេយកសំបកដើម មែក ស្លឹក ដាំទឹកផឹកព្យាបាលរោគមូល គ្រុនចាញ់ ឈឺឆ្អឹងឆ្អែងគ្រុនពោះវៀន ស្ត្រីរដូវមិនទៀង។
- ផ្លែ មានប្រសិទ្ធភាព Anti-tobacco mosaic virus activity et in vitro cytotoxicity against A539 et HL60 និងអាចព្យាបាលឫសនៅបាតជើង ផងដែរ។
- មែក មានប្រសិទ្ធភាព Antimycobacterial et Antiplasmodial activities,
- ជាពិសេសរុក្ខជាតិនេះក៏មាន Action Anticacéreux ផងដែរ។

+ **កំរិតប្រើប្រាស់** ៖ ២០ - ៣០ ក្រាមក្នុងមួយថ្ងៃ

+ **ឯកសារយោង** ៖ កំរងរុក្ខជាតិឱសថស្ដីពីការចុះអង្កេតស្រាវជ្រាវក្នុងខេត្តមណ្ឌលគិរី ២០១០ - ២០១១។

**រៀបរៀងដោយនិស្សិត ៖ ហ៊ុយ ធារ៉ាំង**







# ពុទ្រា

Nom Scientifique : ***Schleicheria oleosa (Lour) Oken***

*Famille :* ***SAPINDACEAE***

# ពង្រ

Nom Scientifique : ***Schleicheria oleosa (Lour) Oken***

*Famille :* ***SAPINDACEAE***

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទដើមឈើធំ មានកំពស់រហូតដល់ 30m ។
  - **ស្លឹក** ៖ ប្រភេទស្លាបបក្សីដុះ ជាគូពី2 ដល់ 4គូ ភាគច្រើន 3គូ ស្លឹកគ្មានទង រាងពងក្រពើ ឬ ពងក្រពើ ទ្រវែង 18cm មានរោមនៅខាងក្រោម។
  - **ផ្កា** ៖ ដុះជាចង្កោមប្រវែង 15-18cm មានកូនស្លឹក 5-6សន្លឹកនៅខាងចុង។
  - **ផ្លែ** ៖ ទំហំប៉ុនចុងម្រាមដៃ រាងមូលប្រវែង 2-5 cm សំបកគ្រើមៗ។
+ **កន្លែងដាំដុះ** ៖ ពង្រមានពូជមកពីឥណ្ឌា និងមានដាំនៅឡាវ ថៃ កម្ពុជា វៀតណាម។
+ **សមាសធាតុគីមី** ៖ គ្រាប់មាន glucoside, Cyanogenetic, ក្រពីងគ្រាប់មាន58-60% លឿង រសល្វីង ក្នុងជាតិប្រេងនេះមាន 0,03% និងផ្លែទាំងមូលមាន0,62% acide cyanhydric។
+ **ផ្នែកប្រើប្រាស់** ៖ សំបក ដើម និងប្រេង គ្រាប់ ។
+ **ការប្រើប្រាស់** ៖ ព្យាបាលគ្រុនចាញ់, បិតកន្លែងហើម, កើតពីស, បូសដែលមានខ្ទុះ, កមរមាស់, បំបាត់អង្គែក្បាល, និងធ្វើអោយដុះសក់, ឬសដូងបាត, ស្បូនស្រុត, រលាកក្រពះ ។
+ **កំរិតប្រើប្រាស់** ៖ សំបកដើម 20-30gដាំទឹក ។ លាបខាងក្រៅតាមចំនួនសមល្មម។
+ **ឯកសារយោង** ៖ ស្រង់ពីសៀវភៅរុក្ខជាតិឱសថកម្ពុជា(ភាគទី២) ក្រសួងសុខាភិបាលមជ្ឈមណ្ឌលស្រាវជ្រាវវេជ្ជសាស្ត្របូរាណឆ្នាំ 2008។

**រៀបរៀងដោយនិស្សិត ៖ ទ៉ា រតនា**







# ព័ន្ធតាឡី -ព័ន្ធលី -ប្រាំដំឡើង

Nom Scientifique : *Terminalia corticosa Pierre ex lanessan*

Famille : **TERMINALIA MUCRONATA CRAIB ET HUTCH**

# ព័ន្ធតាឡី -ព័ន្ធលី -ប្រាំដំឡើង

Nom Scientifique : *Terminalia corticosa Pierre ex lanessan*

Famille : **TERMINALIA MUCRONATA CRAIB ET HUTCH**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទរុក្ខជាតិដើមត្រង់មានពណ៌អុជៗច្រើន ហើយសំបកវាមានឆ្នូតបញ្ឈរនៅគល់។ វាមានកំពស់ទៅដល់៤០ ម៉ែត្រ។ចំនែកជាប្រភេទរុក្ខជាតិដើមត្រង់មានពណ៌អុជៗ ច្រើនហើយសំបកវាមានឆ្នូតបញ្ឈរនៅគល់។ វាមានកំពស់ទៅដល់៤០ ម៉ែត្រ។ចំនែកត្រួយ និងមែកខ្ចីរបស់គ្របដណ្តប់ដោយខ្លីៗពណ៌ត្នោតជាច្រើន និងមានរន្ធសំរាប់ ខ្យល់ចេញចូល។
- **ស្លឹក** ៖ ដុះទល់ទងគ្នា រាងវែងស្រួចខាងចុង។ ស្លឹករបស់វាស្តើង រលោងមានទ្រនុងនៅកណ្តាលយ៉ាងរឹងមាំ គ្របដណ្តប់រោមឆ្មារពណ៌ត្នោតជាច្រើន និងមានក្រពេញនៅទងស្លឹកខាងលើ។
- **ផ្កាផ្លែ** ៖ ផ្កាមានពណសចេញជាបញ្ចុំចេញពីប្រគាបស្លឹក គូរផ្កាធ្លាក់ ត្រយោងចុះក្រោម ទងផ្កាមានប្រវែង០.៥ ម៉ែត្រ។ ចំនែកផ្លែមានលក្ខណៈស្ងួតមិនជាប់សំបក មានពណ៌ត្នោតលឿងទុំ។

+ **កន្លែងដាំដុះ** ៖ វាដុះនៅតំបន់ក្តៅហើយសើម៕

+ **សមាសធាតុគីមី** ៖ មិនទាន់មានឯកសារស្រាវជ្រាវនៅឡើយ។

+ **ផ្នែកប្រើប្រាស់** ៖ សំបក

+ **ការប្រើប្រាស់** ៖ សំបកសំរាប់ព្យាបាលរលាកបំពងក ជំនួយអោយចេញទឹកដោះសំរាប់ស្រ្តីក្រោយពេលសម្រាលកូន និងជំងឺ Ascite

+ **កំរិតប្រើប្រាស់** ៖ សំបកស្ងួតអាចដាំទឹកផឹកបានចាប់ពី១០-១៥ក្រាម ក្នុងមួយថ្ងៃ។

+ **ឯកសារយោង** ៖ -បញ្ជីរុក្ខជាតិឱសថកម្ពុជា List of medicinal plant in Cambodia 2009 Pr. CHENG SUN KAING
- http: //www.biotik.org/laos/species/ t / terco / terco_en.html

**រៀបរៀងដោយនិស្សិត ៖ ទាវ សុភារី**





# ដើមព្រាលខ្សែ , ព្រាលចន្លុះ

Nom Scientifique : ***Colona auriculata ( Desv. ) Craib.***

*Famille :* ***TILIACEAE***

# ដើមព្រាលខ្មែរ , ព្រាលចន្លុះ

Nom Scientifique : ***Colona auriculata ( Desv. ) Craib.***

*Famille :* ***TILIACEAE***

+ **លក្ខណៈរុក្ខជាតិ** ៖ ជាគុម្ពព្រឹក្ស កំពស់ ពី ២-៣ m ។

- **ស្លឹក** ៖ ទោល ដុះឆ្លាស់ទង រាងស៊ុតទ្រវែងស្រួចចុងមានរោមទន់ ជាពិសេសនៅផ្ទៃស្លឹកខាងក្រោម ទំហំស្លឹក : ទទឹងពី ២,៥-៥ Cm និង បណ្តោយពី ៧-២០ Cm។

- **ផ្កាផ្លែ** ៖ -ផ្កា : កញ្ចុំផ្កាចេញតាមប្រគាបស្លឹកមាន ១ ទៅ ៣ ផ្កា , ផ្កាពណ៌លឿងលាយពណ៌ត្នោតអុចៗ ។
-ផ្លែ : ផ្លែមូល មានទ្រនុងលយស្តើង សំប៉ែត , តាមក្លែបនីមួយៗមានគ្រាប់ច្រើន ។

+ **កន្លែងដាំដុះ** ៖ ដុះនៅតាមដីសើម ដីវាល ព្រៃល្បោះ ព្រៃល្បាស់ និង មាត់ទឹក ។ បន្តពូជដោយគ្រាប់ ។

+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ ។

+ **ផ្នែកប្រើប្រាស់** ៖ ឫស ។

+ **ការប្រើប្រាស់** ៖ បំបាត់ឈឺឆ្អឹង , ជំនួយសរសៃ , ចេញទឹកដោះ ។

+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី ១៥-២០ g ( ស្ងួត ) ដាំផឹក ។

+ **ឯកសារយោង** ៖
-http//www.google.com/colona auriculata/image.
-http//herbstohealth.blogspot.com/2009/03/colona auriculata-desv-craibpo-phraan.html
-សៀវភៅរុក្ខជាតិឱសថកម្ពុជា ២០០៩ ភាគ ៣ ( ទំព័រ ៩៥ )

រៀបរៀងដោយនិស្សិត ៖ ផៃ ម៉ុណ្ណា







# ព្រះគ្នៅ

Nom Scientifique : ***Termainalia nigrovenulosa Pierre exlanesse***

*Famille :* ***COMBRETACEAE***

# ព្រះខ្មៅ

Nom Scientifique : ***Termainalia nigrovenulosa Pierre exlanesse***
*Famille :* ***COMBRETACEAE***

+ **លក្ខណៈរុក្ខជាតិ** ៖ ជាដើមឈើធំមានកម្ពស់ ១០- ៣០ម មានបន្ទាត់ផ្ចិត ០,៥ - ១ម បែកមែកនៅកម្ពស់ ៦ - ១០ម សំបកពណ៌ប្រផេះ ដើមមានបន្លាវែង
- **ស្លឹក** ៖ ស្លឹកទោល ដុះទល់ទងបន្ទះស្លឹករាងស៊ុត រឺផ្លែលំពែង មានប្រវែង ៨ - 10 ស.ម ទំហំប្រវែង ៥- ៦ ស.ម
- **ផ្កា** ៖ កញ្ចុំផ្កាចេញនៅចុងមែក ផ្កាតូចៗពណ៌ស
- **ផ្លែ** ៖ ផ្លែទ្រវែងមានប្រវែង ២,៥ ស.ម មានស្លាប ៣ មានពណ៌បៃតងស្រស់ ពេលស្ងួតមានពណ៌ខ្មៅ មានគ្រាប់មួយប្រវែង ៦.៧ ស.ម

+ **កន្លែងដាំដុះ** ៖ ដុះនៅតំបន់ភ្នំ ខ្ពង់រាប និងព្រៃល្បស់ បន្តពូជដោយគ្រាប់
+ **សមាសធាតុគីមី** ៖ ពុំទាន់មានការស្រាវជ្រាវ
+ **ផ្នែកប្រើប្រាស់** ៖ សំបក ដើម
+ **ការប្រើប្រាស់** ៖ សំបក ដើមសម្រាប់ព្យាបាលរាកមូល(មានជាតិចត់)ផ្សះពោះវៀន រលាកពោះវៀន រលាកស្ងួត ផ្សះដំបៅ(ដាំទឹកហូប សំបក ដើម )
+ **កំរិតប្រើប្រាស់** ៖ ពុំទាន់មានឯកសារសរសេរច្បាស់លាស់
+ **ឯកសារយោង** ៖ ដកស្រង់ចេញពីសៀវភៅរុក្ខជាតិ ឱសថកម្ពុជា(ក្រសួងសុខាភិបាលមជ្ឍមណ្ឌលស្រាវជ្រាវ វេជ្ជសាស្ត្រ បុរាណ) បោះពុម្ពឆ្នាំ២០០៨

**រៀបរៀងដោយនិស្សិត ៖ ចណ្ណា ស៊ីណា**







# ព្រះកំចាត់

Nom Scientifique : ***Zanthoxylum rhetsa DC.***

*Famille :* **RUTACEAE**

# ព្រះកំចាត់

Nom Scientifique : ***Zanthoxylum rhetsa DC.***
*Famille :* **RUTACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាព្រឹក្សតូច មានកំពស់ពី៧-១២ម៉ែត្រ ដើមនិងមែកមានបន្លាមាំក្រាស់ហើយមានរាងជាសាជីធំគល់។
  - **ស្លឹក** ៖ ជាប្រភេទស្លាបបក្សីច្រើនផ្គុំគ្នានៅចុងមែក កូនស្លឹកមាន៧-១២គូ រាងផ្លែលំពែងតែមរាងធ្មេញរណារតិចៗ។
  - **ផ្កា** ៖ ផ្កាតូចៗចេញជាចង្កោមបែកខ្នែង ផ្កាញី និង ផ្កាឈ្មោលនៅផ្សេងគ្នា។
  - **ផ្លែ** ៖ ផ្លែប្រភេទស្ងួតស្រួយ រាងតូចមូល មានគ្រាប់មួយប្រះចំហឃើញគ្រាប់ពណ៌ខ្មៅរលោង មានជាតិប្រេង ដំបូងក្លិនដូចសំបកក្រូចសើច បន្ទាប់មកហិរឆួលខ្លាំង។

+ **កន្លែងដាំដុះ** ៖ ដុះខ្លួនឯងនៅជំរាលភ្នំ ព្រៃក្រាស់ជ្រុះស្លឹក ជាយព្រៃដែលមានពន្លឺថ្ងៃ។

+ **សមាសធាតុគីមី** ៖ Acaloïde (Budrungaine, Budrungainine)

+ **ផ្នែកប្រើប្រាស់** ៖ សំបកដើម សំបកឫស មែក ស្លឹក ប្រើស្រស់ រឺ សំងួតក្នុងម្លប់ទុកប្រើ។

+ **ការប្រើប្រាស់** ៖
  - សំបកឫស ដាំផឹកព្យាបាលរាំងរដូវ រដូវមិនទៀង ព្រូន
  - សំបកដើម ព្យាបាលរាគ ឈឺសន្លាក់ឆ្អឹង ខ្សោយក្រពះ
  - មែក និង ស្លឹក ព្យាបាលផ្តាសាយ ឈឺសន្លាក់ឆ្អឹង សំនល់រោគក្រោយគ្រុនស្វិតដៃជើង
  - ស្លឹកបុកបិត រឺ ស្ងោរលាង ព្យាបាលរបួសបាក់ឆ្អឹង របួសចេញឈាម ពស់ចឹក រលាកភ្លើង រលាកទឹកក្តៅ ពីស បូស។

+ **កំរិតប្រើប្រាស់** ៖
  - សំបកឫស និង សំបកដើមពី៥-១៥ក្រាមដាំទឹកផឹក
  - មែក និង ស្លឹកពី១០-២៥ក្រាមដាំទឹកផឹក។

+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ៤/រៀបរៀងដោយមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ បោះពុម្ពដោយថវិការជាតិ ឆ្នាំ២០១០

**រៀបរៀងដោយនិស្សិត ៖ នី ច័ន្ទរស្មី**






# ព្រីងធំ - ព្រីងដោះក្របី

Nom Scientifique : *Syzygium cumini (L) Skeels*

Famille : **MYRTACEAE**

# ព្រីងធំ - ព្រីងដោះក្របី

Nom Scientifique : *Syzygium cumini (L) Skeels*

Famille : **MYRTACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ចុល្លព្រឹក្ស ឬ វល្លិ៍ ដុះលើដី ឬ ដុះចេញតាមដើមឈើ មានប្រវែង១០ម៉ែត្រ
- **ស្លឹក** ៖ រូមផ្សំបែបកង្ហារ ទងវែង ១០-១២ស.ម រាងអេលីប មានស្លឹក៥-៧
- **ផ្កាផ្លែ** ៖ កញ្ចុំផ្កាចេញជាកូនបែកខ្នែងរលោង ប្រវែង ១០-២០ស.ម រាងតូចមូល ឬ រាងស៊ុតមាន ៥-៦ផ្លែ មានពណ៌លឿង ទឹកក្រូច ពេលទុំពណ៌ខ្មៅ

+ **កន្លែងដាំដុះ** ៖ មានដុះនៅតាមព្រៃល្បោះ ព្រៃក្រាស់ មាត់អូរ ឬ លើកោះ
+ **សមាសធាតុគីមី** ៖ Betulenic acid , glycoside ,saponins
+ **ផ្នែកប្រើប្រាស់** ៖ វល្លិ៍ សំបកដើម ស្លឹក ជ័រ ប្រើស្រស់ ឬ ស្ងួត
+ **ការប្រើប្រាស់** ៖ -សំបកដើមព្យាបាលក្អក រលាកទងសួត ហឺត របួសបោកទង្គិច ឈឺឆ្អឹងឆ្អែង
-ស្លឹកដាំទឹកផឹក ព្យាបាលគ្រុនចាញ់ ផ្តាសាយ ក្អក ហើមអញ្ចាញធ្មេញ
-ជ័រសំរាប់លាបផ្សះរបួសដំបៅ
+ **កំរិតប្រើប្រាស់** ៖ - សំបកដើមស្ងួត១៥-៣០ក្រាម ដាំផឹក ឬ ត្រាំស្រា
- ស្លឹកស្ងួត ២០-៣០ក្រាមដាំផឹក
+ **ឯកសារយោង** ៖ ដកស្រង់ចេញពីសៀវភៅ រុក្ខជាតិឱសថកម្ពុជាភាគ៣ ចងក្រងដោយ មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ ឆ្នាំ ២០០៦
-www.google.com / plant medicinal

**រៀបរៀងដោយនិស្សិត ៖ អ៊ុំម សីលវត្តី**







# ដើមភ្លាំងភ្លែង

Nom Scientifique : ***Hymenocardia punetata Wall ex lindl,***

Famille : **EUPHORBIACEAE**

# ដើមត្នំត្នែង

Nom Scientifique : *Hymenocardia punetata Wall ex lindl,*

Famille : **EUPHORBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាចុល្លព្រឹក្ស មានកំពស់១- ៣m មែកខ្ចីមានរោមពណ៌ លឿង

- **ស្លឹក** ៖ ស្លឹកទោលដុះឆ្លាស់ទង រាងជាស៊ុតប្រវែង ៥-៦Cm ទទឹងពី ៣-៣,៥Cm ផ្ទៃខាងក្រោយមានរោម ទងស្លឹកប្រវែង៨-១៥mm មានរោមពណ៌លឿង និងមានខ្នាយស្មបរាងម្ជុល

- **ផ្កាផ្លែ** ៖ ផ្កា:កញ្ចុំផ្កា ចេញនៅតាមអ័ក្សមែក ផ្កាពណ៌បៃតងខ្មៅតូចៗ ផ្លែ:មានស្លាប២ក្រាស់ និងមានគ្រាប់២

+ **កន្លែងដាំដុះ** ៖ ដុះនៅតាមព្រៃរនាម តាមព្រៃរបោះ និង បន្តពូជដោយផ្លែ

+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ

+ **ផ្នែកប្រើប្រាស់** ៖ សំបក ដើម និង ផ្លែ

+ **ការប្រើប្រាស់** ៖ -សំបក ព្យាបាលរាកមូល
-ផ្លែស្ងោរសំរាប់លាងរបួស
-ដើម ជាថ្នាំបង្កើនគ្រាប់ឈាម ជំនួយសុខភាពស្ត្រីក្រោយពេលឆ្លងទន្លេ ផ្សះរបួស និង ជំងឺសើរស្បែកមានខ្ទុះ

+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី ២០- ៣០ក្រាម ដាំទឹកផឹកក្នុង១ថ្ងៃ

+ **ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជាភាគ៣ បោះពុម្ពឆ្នាំ២០០៩

**រៀបរៀងដោយនិស្សិត ៖ ឈួន សុខលីនដា**







## ភ្លូធំ

Nom Scientifique : ***Dilleniaovata wall.exhook.f.et.thomson***

Famille : ***DILLENIACEAE***

# ឆ្លូធំ

Nom Scientifique : ***Dilleniaovata wall.exhook.f.et.thomson***

*Famille :* ***DILLENIACEAE***

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើធំមានកំពស់ពី១០-២០ម៉ែត្រសំបកប្រផេះ ពេលសំបកចាស់ប្រេះ ទទឹង។
  - **ស្លឹក** ៖ ពងក្រពើស្រួចរឺមូលប្រវែងពី១៥-១៨សម ទទឹងពី៧-១៥សម មានរោមនៅខាង ក្រោម។
  - **ផ្កាផ្លែ** ៖ -ផ្កាៈពណ៌លឿងដុះមួយៗនៅចុងមែកទំហំពី១០-១៥សមមានត្របកចេញផ្កាពីខែ២-៥។
    -ផ្លែៈមូលមានច្រើនស្រទាប់ប្រវែង៤-៥សម ទទឹង៣-៤សម។
+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯងនៅក្នុងព្រៃ ភ្នំខ្ពង់រាប។
+ **សមាសធាតុគីមី** ៖ ស្លឹកជាតិ Talin 7% និង 0,20-0,25% ជាតិ Calycopterin។
+ **ផ្នែកប្រើប្រាស់** ៖ ផ្លែនិង សំបកដើម។
+ **ការប្រើប្រាស់** ៖ -ផ្លែៈធ្វើថ្នាំបំបាត់ការស្រេកទឹក។
  -សំបកដើមៈដាំទឹកផឹកព្យាបាលរោគនិងរាកមូល(ដោយយកប៉ុន៣ធ្លាប់ដៃដាំទឹក៣យកទឹក១ផឹកមួយថ្ងៃ៣ដង)សំបកដើមផ្សំជាមួយរុក្ខជាតិដ៏ទៃទៀតធ្វើជាថ្នាំឬដូងបាត ផ្សះស្បូន។
+ **កំរិតប្រើប្រាស់** ៖ ពី១៥-៣០ក្រាមដាំទឹកផឹកក្នុង១ថ្ងៃ។
+ **ឯកសារយោង** ៖ -រុក្ខជាតិឱសថកម្ពុជាភាគ២, បោះពុម្ពឆ្នាំ ២០០៨។
  -កំរងរុក្ខជាតិឱសថស្តីពីការចុះអង្កេតស្រាវជ្រាវក្នុងខេត្តរតនៈគិរី និស្សិតឆ្នាំទី៥ ជំនាន់៣២ ឆ្នាំ២០១១ - ២០១២

**រៀបរៀងដោយនិស្សិត ៖ ឡាយ សុវណ្ណារី**







# ភ្លាំង, ភ្លីងភ្លាំង

Nom Scientifique *:* ***Glycosmispentaphylla (Retz) Correa***

Famille : **RUTACEA**

# ផ្លាំង, ផ្លីខផ្លាំង

Nom Scientifique : ***Glycosmispentaphylla (Retz) Correa***

Famille : **RUTACEA**

+ **លក្ខណៈរុក្ខជាតិ** ៖ ចុល្លព្រឹក្ស មានកំពស់ពី ២-៥ ម៉ែត្រ មែកមានពណ៌ក្រហមព្រឿងៗមានស្នាមប្រេះ

- **ស្លឹក** ៖ ឆ្លាស់ទង ១ធាងមានពី ៣-៧ សន្លឹក ខ្លះមានស្លឹកតែ ១ ឬ ២ រាងស៊ុតទ្រវែង ៣-១០៩ស.ម បណ្តោយ ៦-២០ ស.ម គែមមានទឹករលក ទងស្លឹកខ្លី ។

- **ផ្កា** ៖ កញ្ចុំផ្កាពណ៌ស ចេញនៅចុងមែក ឬប្រគាបស្លឹកចុងមែករាងជាឆ័ត្រ ។

- **ផ្លែ** ជាប្រភេទផ្លែសាច់ រាងមូលមានទំហំ ៦ មម ពេលទុំពណ៌ក្រហម ស្រាល ថ្លា មានរសផ្អែមអាចហូបបាន ។ មានគ្រាប់ ១ គ្រាប់រាងមូល ។

+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯង តាមព្រៃរបោះ ព្រៃស្រោង ដីទំនេរក្នុងភូមិ ក្រោមដើមឈើធំៗ ។ បន្តពូជដោយគ្រាប់ ។

+ **សមាសធាតុគីមី** ៖ ស្លឹកមាន Alkaloids glycosine (aborine), skimmainine.។ សំបកមាន Alkaloids glycosine, glycosmin (acrystalline glucoside) noracromycine, des-N-methyl-acromicisne, des- N-methyl-noracromycine ។

+**ផ្នែកប្រើប្រាស់** ៖ មែក និងស្លឹក ដើម ឬស ។

+ **ការប្រើប្រាស់** ៖ - មែក និងស្លឹក: មានសារធាតុសំលាប់មេរោគ streptococcus, staphylococcus, bacillus ។ គេនិយម ដាំផឹកលាយជាមួយរុក្ខជាតិផ្សេងទៀត ជាថ្នាំជំនួយសុខភាព ស្ត្រីក្រោយសំរានកូន ស្លឹកបុក បំពោក របួសពស់ចឹក ឬ ស្វោ ត្រាំ ។
-ដើម: បញ្ចេញទឹកដោះ ដុសទឹកអង្គរ ផឹក ទប់ធ្លាក់ឈាម ចុកពោះ ដាំផឹក ព្យាបាលរោគស្ទះសរសៃឈាម (ឡើងឈាម) ជំនួយសរសៃ ។

+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី២០-៣០ ក្រាមក្នុងមួយថ្ងៃ ។

+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ២ ឆ្នាំ ២០០៨។

**រៀបរៀងដោយនិស្សិត ៖ សៅ លីហ៊ុយ**





# វល្លិ៍មហាមេឃ

Nom Scientifique : ***Merremia vitifolia (Burm. f.) Hallier f.***
***Ipomoea vitifolia Sw.***

Famille : **CONVOLVULACEAE**

# វល្លិមហាមេឃ

Nom Scientifique : ***Merremia vitifolia (Burm. f.) Hallier f.***

***Ipomoea vitifolia Sw.***

Famille : **CONVOLVULACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទវល្លិធំ គ្មានរោម វារតោង អាចបានប្រវែងដល់ទៅ ២៥ ម៉ែត្រ ។ តួដើមស្តើងទ្រវែង មានវិជ្ជមាត្រ តូចជាង ២ សម។
  - **ស្លឹក** ៖ ជាប្រភេទស្លឹក orbiculaire មានរាងមូល ជាបេះដូង ឬ ជាត្រីកោណ ហើយផែកៗ ចំនែក លើស្លឹកមានរោម និង មានទងស្លឹកប្រវែងពី ២ ទៅ ១៥ សម
  - **ផ្កា** ៖ ប្រភេទផ្កា ១-៣(-៥) កញ្ចុំផ្កា រាង ovoïde ហើយទងផ្កាមួយៗក្នុង កញ្ចុំផ្កាប្រវែង ៨ ទៅ ២០ មម ។ គ្រួបកផ្ការាងទ្រវែង ឬ រាង ovale-oblong និង មានចំនុចក្រពេញថ្លា មានប្រវែង ១២ ទៅ ២០ មម ។ ស្រទាប់ផ្ការាងជីឡាវ និង មានប្រវែងពី ៤ ទៅ ៦ សម។
  - **ផ្លែ** ៖ ផ្លែមានប្រវែង ២០ ទៅ ២៥ ក្រាស់ និង មានពណ៌សខាងក្នុង។
+ **កន្លែងដាំដុះ** ៖ ដុះនៅតំបន់ព្រៃក្រាស់ៗ នៃប្រទេសកម្ពុជា ជាពិសេសនៅតាមព្រៃតំបន់មានសមុទ្រ
+ **សមាសធាតុគីមី** ៖ Glycosides
+ **ផ្នែកប្រើប្រាស់** ៖ តួដើម (ជាអង់គ្លេស៖ stalks)
+ **ការប្រើប្រាស់** ៖ - ស្ងោររំងាស់ដើមប្រើសំរាប់លាប និង ផឹក ដើម្បីព្យាបាលអុតធំ និង គ្រុនចាញ់។ ក្នុងដើមមាន propriété astringent ហើយជាញឹកញាប់ គេបន្តក់ព្យាបាលភ្នែករលាក
+ **គំរិតប្រើប្រាស់** ៖ មិនមានការបញ្ជាក់ច្បាស់លាស់ក្នុងឯកសារ។
+ **ឯកសារយោង** ៖ http://www.globinmed.com/index.php?option=com_content&view=article&id=100602:merremia-vitifolia-burmf-hallier-f&catid=377:m

**រៀបរៀងដោយនិស្សិត ៖ ឡិត រដ្ឋលីណា**







# មីងហាំង-មហាំង

Nom Scientifique : ***Diospyros ehretioides Wallich ex. G. Don***

Famille : **EBENACEAE**

# មើងមាំង-មមាំង

Nom Scientifique : *Diospyros ehretioides Wallich ex. G. Don*

Famille : **EBENACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាដើមតូចមានកំពស់ពី 10-15ម ដើមត្រង់ សំបកពណ៌ត្នោតក្រមៅ។

- **ស្លឹក** ៖ ស្លឹកធំទោល ឆ្លាស់ទង រាងស៊ុត គែមស្លឹករាងរលកពណ៌បៃតងចាស់។

- **ផ្កាផ្លែ** ៖ ដុះជាកញ្ចុំផ្កា ។ ផ្លែមានរាងមូលមានអុជៗ ដូចម៉ាកក្លៀ។

+ **កន្លែងដាំដុះ** ៖ ដុះតាមព្រៃភ្នំ, ព្រៃរបោះទូទៅ។ បន្តពូជដោយគ្រាប់។

+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ។

+ **ផ្នែកប្រើប្រាស់** ៖ ដើម ,ឫស។

+ **ការប្រើប្រាស់** ៖ ព្យាបាលពិស, របេង, ក្តៅក្នុង, ជំនួយស្ងួត ជំនួយកំលាំង, ឫសដូងរិល, ក្រពះ,បាយបាន ឫសដូងស្ពុយច្រមុះ ផ្សំជាមួយរុក្ខជាតិដទៃទៀត ប្រើជាថ្នាំរាំងខែ រោគក្រោយសំរាលកូន។

+ **កំរិតប្រើប្រាស់** ៖ ប្រើ15-30ក្រាម ដាំផឹកក្នុងមួយថ្ងៃ។

+ **ឯកសារយោង** ៖ សៀវភៅ រុក្ខជាតិឱសថកម្ពុជាភាគ២

**រៀបរៀងដោយនិស្សិត ៖ ភាង មួយហួង**







# មេជ័រ-ជ័រឆក់-ជ័របាញ់

Nom Scientifique : ***Strophanthus Caudatus (L.) Kurz***

*Famille :* ***APOCYNACEAE***

# មេជ័រ-ជ័រឆក់-ជ័របាញ់

Nom Scientifique : ***Strophanthus Caudatus (L.) Kurz***

*Famille :* ***APOCYNACEAE***

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទដើមឈើដែលមានជ័រ មែកខ្ចីមូលមានពណ៌បៃតង មានអុជ។
  - **ស្លឹក** ៖ ធំវែងស្រួចចុងបន្តិច មានប្រវែង ១២-៣២ស.ម ទទឹង ៤-១០ស.ម ដុះទល់ទង
  - **ផ្កាផ្លែ** ៖ មាន ៥ត្របក សគល់ ពណ៌ក្រហមខាងចុងវែងអន្លាយ កេសរពណ៌លឿងផ្កាដុះចេញពីមែកផ្កាចេញរវាងខែ៥ និង ខែ១២។
  - **ផ្លែ** ៖ ផ្លែមួយទងមាន២ ព្រែកទទឹងក្បាលជាប់គ្នា មានស្នាមចង្អូរមួយនៅក្រោមផ្លែទាំង២
+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនវានៅតំបន់ព្រៃភ្នំ ព្រៃរបោះ ទីវាលដែលមានពន្លឺថ្ងៃគ្រប់គ្រាន់ គេអាចប្រមូលផលបានគ្រប់រដូវ។
+ **សមាសធាតុគីមី** ៖ មិនទាន់ស្រាវជ្រាវនៅឡើយ
+ **ផ្នែកប្រើប្រាស់** ៖ ប្រើគ្រាប់ ជ័រ ស្លឹក។
+ **ការប្រើប្រាស់** ៖ - គ្រាប់៖ មានជាតិចំរាញ់ធ្វើថ្នាំចាក់ព្យាបាលរោគបេះដូង។ (មានជាតិពុលខ្លាំង)
  - ជ័រ៖ មានជាតិពុល ផ្សំជាមួយជាតិពិសដ៏ទៃទៀត លាបមុខព្រួញជ័រឆក់សំរាប់បាញ់សត្វ។
  - ស្លឹក៖ បុកលាយជាមួយស្ករត្នោតកំដៅអោយក្តៅឧណ្ហៗ យកមកបិទលើរបួស។
+ **ឯកសារយោង** ៖ ក្រសួងសុខាភិបាលមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ

**រៀបរៀងដោយនិស្សិត ៖ អ៊ឹង លីដា**






# ម្រាមដៃនាងសិតា

Nom Scientifique : ***Schefflera elliptica (Blume)Harm***

Famille : **ARALIACEAE**

# ម្រាមដៃនាងសិតា

Nom Scientifique : *Schefflera elliptica (Blume)Harm*

Famille : **ARALIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ចុល្លព្រឹក្ស ឬ វល្លិ៍ ដុះលើដី ឬ ដុះចេញតាមដើមឈើ មានប្រវែង១០ម៉ែត្រ
  - **ស្លឹក** ៖ រួមផ្សំបែបកង្ហារ ទងវែង ១០-១២ស.ម រាងអេលីប មានស្លឹក៥-៧
  - **ផ្លែ** ៖ ផ្លែ រាងតូចមូល ឬ រាងស៊ុតមាន ៥-៦ផ្លែ មានពណ៌លឿង ទឹកក្រូចពេលទុំពណ៌ខ្មៅ
  - **ផ្កា** ៖ ផ្កា កញ្ចុំផ្កាចេញជាកូនបែកខ្នែងរលោង ប្រវែង ១០-២០ស.ម
+ **កន្លែងដាំដុះ** ៖ មានដុះនៅតាមព្រៃល្បោះ ព្រៃក្រាស់ មាត់អូរ ឬ លើកោះ
+ **សមាសធាតុគីមី** ៖ Betulenic acid , glycoside ,saponins,
+ **ផ្នែកប្រើប្រាស់** ៖ វល្លិ៍ សំបកដើម ស្លឹក ជ័រ ប្រើស្រស់ ឬ ស្ងួត
+ **ការប្រើប្រាស់** ៖ -សំបកដើមព្យាបាលក្អក រលាកទងសួត ហឺត របួសបោកទង្គិច ឈឺឆ្អឹងឆ្អែង
  -ស្លឹកដាំទឹកផឹក ព្យាបាលគ្រុនចាញ់ ផ្តាសាយ ក្អក ហើមអញ្ចាញធ្មេញ
  -ជ័រសំរាប់លាបផ្សះរបួសដំបៅ
+ **កំរិតប្រើប្រាស់** ៖ -សំបកដើមស្ងួត១៥-៣០ក្រាម ដាំផឹក ឬ ត្រាំស្រា
  -ស្លឹកស្ងួត ២០-៣០ក្រាមដាំផឹក
+ **ឯកសារយោង** ៖ ដកស្រង់ចេញពីសៀវភៅ រុក្ខជាតិឱសថកម្ពុជាភាគ៣ ចងក្រងដោយ មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ ឆ្នាំ ២០០៦
  -www.google.com / plant medicinal

**រៀបរៀងដោយនិស្សិត ៖ អ៊ឹម ស្រីម៉ៅ**







## ចេខគ្រេខ

Nom Scientifique : ***Hibiscus surattensis L.***

Famille : **Malvaceae**

# ចេចគ្រេច

Nom Scientifique : ***Hibiscus surattensis L.***

Famille : **MALVACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទស្មៅដុះត្រង់ មានបន្លាកោង រោមច្រើន កំពស់ពី ៦០ ទៅ១២០សម។
- **ស្លឹក** ៖ គែមស្លឹករាងធ្មេញរណាឆែកជា ៥ទៅ ៧ គល់ស្លឹករាងបេះដូង ទងវែងរោមច្រើន គ្រើមគ្រាត។
- **ផ្កាផ្លែ** ៖ ផ្កាពណ៌លឿងស្រស់ នៅកណ្តាលពណ៌ក្រហម ផ្កាជាបំពង់រីកចុងមាន ៥ត្របក ស្មើងជាបំពងរីកចុងដូចផ្កាត្រកួន ផ្ការីកចេញពីប្រគាបស្លឹក ។ ផ្លែរាងជាសាជីចុងស្រួចមានចង្អូរជ្រៅ មានរោមក្រាស់រឹងមាន៥ក្លែប ក្នុងក្លែបនីមួយៗពេញដោយគ្រាប់តូចៗពណ៌ខ្មៅ ផ្លែខ្ចីពណ៌បៃតង ពេលទុំពណ៌ត្នោត ។
+ **កន្លែងដាំដុះ** ៖ ដុះតាមវាលទំនាប និងលើភ្នំ ។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ
+ **ផ្នែកប្រើប្រាស់** ៖ ដើម ស្លឹក និងផ្កា ។
+ **ការប្រើប្រាស់** ៖ ព្យាបាលជំងឺ គេប្រើផ្កាបំបាត់ការឈឺចាប់ជំងឺទ្រូងដើម និងស្លឹកដាំទឹកលាង ឬលាបទ្វារមាសហើមរលាក និងព្យាបាលជំងឺសើរស្បែក ។
+ **កំណត់ចំណាំ** ៖ ស្លឹកមានរសជាតិជូរ គេអាចយកមកស្លរម្ជូរបាន ។
+ **ឯកសារយោង** ៖ សៀវភៅ រុក្ខជាតិឱសថកម្ពុជា
http://www.cactuspedia.info/schede/Malvaceae/Hibiscus surattensis L.htm

**រៀបរៀងដោយនិស្សិត ៖ វ៉ា ចាន់ដានិត**







# រកាដែក

Nom Scientifique : ***Bombax ceiba Linn.***
***Bombax malabaricum Linn.***
Famille : **BOMBACACEAE**

# រការដែក

Nom Scientifique : *Bombax ceiba Linn.*
*Bombax malabaricum Linn.*
Famille : **BOMBACACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទរុក្ខជាតិធំ មានកំពស់២០-៣០ម តែងរង្គោះស្លឹកតាមរដូវ។ ដើមរាងមូលសំបកដើមពណ៌ប្រផេះគ្របដណ្តប់ដោយបន្លារាងសាជី ។

- **ស្លឹក** ៖ ទងនៃស្លឹកមានប្រវែង១០-៣០ស.ម មួយទងមានជសន្លឹក ស្លឹកមានរាងទ្រវែងដូចលំពែងស្រួចចុង ទំហំ១០-១៦ x ៣-៥ស.ម និងគ្មានរោម។

- **ផ្កា ផ្លែ គ្រាប់** ៖ ផ្កា៖ ផ្កាទោលមានទំហំធំ ពណ៌ក្រហម ដុះនៅផ្នែកខាងចុង មែកមាន ៥ត្របកផ្កា រាងពងក្រពើទ្រវែង និងមានរោម នៅពេលក្រពុំត្របកផ្កា រមូលចូលគ្នា។
ផ្លែ៖ ផ្លែប្រវែង១០-១៥ស.ម សំបករឹងរាងទ្រវែងសំយ៉ុងចុះក្រោម មាន៥សន្ទះបណ្តោយផ្លែ ព្រមទាំងមានរោមដូចសូតពណ៌ស។
គ្រាប់៖ មានចំនួនច្រើន រាងមូលទ្រវែង រលោង ពណ៌ត្នោត មានប្រវែងប្រហែល ៦ម.ម និងផ្ទុកទៅដោយសំលី។

+ **កន្លែងដាំដុះ** ៖ រុក្ខជាតិនេះត្រូវបានគេឃើញមានដុះនៅគ្រប់ទីកន្លែង ក្នុងស្រុក និងក្នុងព្រៃ។

+ **សមាសធាតុគីមី** ៖ Flavonol glycosides, Acide cyanhydrique, Acide palmitique, Acide stéarique, Calcium, Fibres, Hydrates de carbone, Phosphore.

+ **ផ្នែកប្រើប្រាស់** ៖ ឬស ស្លឹក ពន្លក កំពកនៃដើម រឺមែក សំបកដើម និងគ្រាប់។

+ **ការប្រើប្រាស់** ៖ -ឬស:ព្យាបាលរាគបញ្ចុះទឹកនោម ក្អួក ឈឺពោះបណ្តាលមកពីរាគមូល និងអសមត្ថភាពផ្លូវភេទ។
-ស្លឹក:ដោយឆុងផឹក ព្យាបាល លើសឈាម និងខ្វះកាល់ស្យូមក្នុងឈាម។
-ពន្លក:ព្យាបាល ដំបៅក្រអូមមាត់។
-កំពកដើម:ព្យាបាលរលាកស្រោមសួត សត្វទិច និងបញ្ចុះនោម។
-គ្រាប់:ព្យាបាលបញ្ចុះកំដៅ បំបាត់ការឈឺចាប់នោមឈាម និងធ្លាក់រដូវមកច្រើន។

+ **កំរិតប្រើប្រាស់** ៖ ពី១០-២០ក្រាម ក្នុងមួយថ្ងៃ។ ជ័រ ៤-៨ក្រាម ក្នុងមួយថ្ងៃ។

+ **ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជាភាគ២ បោះពុម្ពឆ្នាំ ២០០៨។
កំរងរុក្ខជាតិឱសថស្តីពីការចុះអង្កេតស្រាវជ្រាវក្នុងខេត្តកោះកុង ២០១០។

**រៀបរៀងដោយនិស្សិត ៖ អែម ច័ន្ទរស្មី**







## សំបុកចាស រំបុកចាស

Nom Scientifique : ***Helicteres angustifolia DC***
Famille : **STERCULIACEAE**

# សំបុកចាស របុកចាស

Nom Scientifique : ***Helicteres angustifolia DC***
Famille : **STERCULIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ គុម្ពព្រឹក្សតូចរាវ មានកំពស់ ១ទៅ១៥ម ដើមខ្ចីមានរោម ។

- **ស្លឹក** ៖ ស្លឹករោលដុះឆ្លាស់ រាងជាផ្លែលំពែងទ្រវែងខាងលើរលោង ពណ៌បៃតងចាស់ ខាងក្រោមមានរោម ។
- **ផ្កាផ្លែ** ៖ ផ្កា ចេញពីប្រគាបស្លឹក ពណ៌ក្រហម រឺ ស្វាយ ផ្កាមាន ៥គ្រាប់ ក្នុងត្របកនីមួយៗ មានផែកកណ្តាល ។
ផ្លែ រាងមូលទ្រវែង មានចង្អូរ និង ទ្រនុង ៥គ្រាប់ ពណ៌កាហ្វេ ពេលទុំពណ៌ខ្មៅ ។

+ **កន្លែងដាំដុះ** ៖ រុក្ខជាតិទាំងមូលប្រមូលផលគ្រប់រដូវ លាងស្អាត ហាន់ខ្ចី ហាលស្ងួតទុកប្រើ ។
+ **សមាសធាតុគីមី** ៖ Roots, two triterpenoids of oleanolic acid, βhydroxyolean-12-en-27-benzoyloxy-28
-oate(1), 3β-0-(p-hydroxy-(E)-cinnamoyl)-12 oleanen-28-oic acid(2).
+ **ផ្នែកប្រើប្រាស់** ៖ ដើម ឬស មើម មានរសជាតិ ល្វីង ផ្អែម ។
+ **ការប្រើប្រាស់** ៖ កបនឹងជំងឺគ្រុនចាញ់ គ្រុនក្តៅឡើងអត់ចុះ រលាកបំពង់ក កញ្រ្ជិល រាក រាកមូល រលាកពោះវៀន រមាស់ឬសដូងបាត ឈឺក្បាល ពស់ចឹក ក្អកក្រឡទែន ។
+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី ១០ ទៅ ១៥ ក្រាម ដាំទឹកផឹក ក្នុង មួយថ្ងៃ ។
+ **ឯកសារយោង** ៖ កំរងរុក្ខជាតិឱសថក្នុងការចុះអង្កេតស្រាវជ្រាវនៅខេត្តរតនៈគីរី ដោយនិស្សិតជំនាន់ទី ៣២ ឆ្នាំ ២០១១ ២០១២ ។

រៀបរៀងដោយនិស្សិត ៖ ចាន់ ដានី







# រលួយចាយ

Nom Scientifique : ***Eryhrina Veriegata L.***

Famille : **Syn,Erythrina indica lam.**

# រលួយបាយ

Nom Scientifique : *Eryhrina Veriegata L.*

Famille : **Syn,Erythrina indica lam.**

+ **លក្ខណៈរុក្ខជាតិ** ៖ ឈើមធ្យមមានកំពស់10ម៉ែត្រសំបកប្រេះៗពណ៌បៃតងលាយស។

- **ស្លឹក** ៖ មានបន្លាដុះឆ្លាស់គ្នាមួយទងមានបីសន្លឹក កូនស្លឹកនីមួយៗរាងត្រីកោណ ខែ3-ខែ5ជំរុះស្លឹកដើមចេញផ្កា។

- **ផ្កាផ្លែ** ៖ : ពណ៌ក្រហមជាចង្កោមចេញនៅចុងមែក :ផ្លែពណ៌បៃតងមូលវែងស្រួចចុងគ្រាប់រាងដូចគ្រាប់សណ្តែក។

+ **កន្លែងដាំដុះ** ៖ ដុះតាមតំបន់មាត់សមុទ្រ ដាំជាគ្រឿងលំអ ដាំជារបងនិងយកស្លឹកធ្វើជាអាហារ។ បន្តពូជដោយគ្រាប់ និង កាប់មែកដាំ។

+ **សមាសធាតុគីមី** ៖ ស្លឹក ដើមមានជាតិalcaloidឈ្មោះErythrina ដែលកាត់ផ្តាច់ការបញ្ជាពីខួរក្បាល។

+ **ផ្នែកប្រើប្រាស់** ៖ សំបក នឹង ស្លឹក(ស្លឹកមានជាតិល្វីងតិចៗរាងចត់) ។

+ **ការប្រើប្រាស់** ៖ ព្យាបាលជំងឺបេះដូង(ភយ័)គេងមិនលក់ កូនក្មេងរលាកពោះវៀន រាក រាកមូល ស្លឹកខ្ចីឆាជាមួយពងមាន់ញ៉ាំ ស្លឹកចាស់បុកបិតកន្លែងឬសដូងបាត ស្លឹកព្យាបាលគ្រុណទំលាក់ព្រូនចង្កឹះឬសដូងបាត ឈឺតាមសន្លាក់ លីញឲ្យក្រៀមជាថ្នាំត្រជាក់ ស្លឹកចាស់ រោលផ្សែងភ្លើងជ្រលក់ស្រាបិតដំបៅកាចសត្វខាំហើយក្លាយជួយបឹតខ្ទុះឲ្យស្ងួត ទឹកពូតពីស្លឹកស្រស់បន្តក់ភ្នែកព្យាបាលភ្នែកក្រហមភ្នែកពប្រៀកបំបាត់រលាក។ផ្កា ទំលាក់ឈាមរដូវ ផ្លែជំនួយទឹកប្រមាត់ សំបកដើមព្យាបាលស្លេស់ ទំលាក់ប្រមេះគ្រាប់បាយព្យាបាលគ្រុនហើមភ្នែក។

+ **កំរិតប្រើប្រាស់** ៖ 4-6 ក្រាមដាំផឹកក្នុងមួយថ្ងៃ។

+ **ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជាភាគ២បោះពុម្ពឆ្នាំ២០០៨។

**រៀបរៀងដោយនិស្សិត ៖ សាយ រ៉ាវីន**








# ដើមរលាយឈាមតូច

Nom Scientifique : *Cnetis palala (Lour) Merr*

Famille : **CONNARACEAE**

# ដើមរលាយឈាមតូច

Nom Scientifique : ***Cnetis palala (Lour) Merr***

Famille : **CONNARACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ល្អព្រឹក សំបកដើមពណ៌ប្រផេះខ្មៅ មែកខ្ចីមានរោមអាចមានប្រ វែងលើសពី 10m

- **ស្លឹក** ៖ ស្លឹករួមស្លាបដុះឆ្លាស់ទង មានកូនស្លឹកពី 15-55 សន្លឹករាងស៊ុតទ្រវែង ត្រួយពណ៌ក្រហមស្រាល។ ស្លឹកពណ៌បៃតងចាស់ ផ្ទៃខាងក្រោមពណ៌បៃតងប្រផេ

- **ផ្កា** ៖ ផ្កាជាចង្កោមចេញពីប្រតាបស្លឹក ឬចុងមែកពណ៌លឿងខ្ចី។

- **ផ្លែ** ៖ ផ្លែរាយឬចង្កោមរាងជាស៊ុតវៀវស្រួចចុងមានរោមពណ៌លឿងបៃតងលាយក្រហម មានគ្រាប់មួយពេលទុំប្រេះមួយចំហៀងឃើញគ្រាប់ពណ៌ខ្មៅ។

+ **កន្លែងដាំដុះ** ៖ ដុះនៅតំបន់ភ្នំព្រៃល្បោះ ព្រៃល្បាស់ ដីលាយខ្សាច់។បន្តពូជដោយគ្រាប់។

+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ។

+ **ផ្នែកប្រើប្រាស់** ៖ ឬស ស្លឹក។

+ **ការប្រើប្រាស់** ៖ ឬស: ព្យាបាលរោគផ្លូវនោម គ្រុនចាញ់ ជំនួយសុខភាពស្ត្រីក្រោយពេលសំរាលកូន មូល ឈឺក្រពះ។ ប្រើខាងក្រៅ បកខ្ចប់កំដៅលើភ្លើងស្អំលើរបួសផ្លោះគ្រេច។

+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី ១០ ទៅ ១៥ ក្រាម ដាំផឹក។

+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជា បោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ។

**រៀបរៀងដោយនិស្សិត ៖ តាន់ គីមស៊ី**







# ដើមរាជព្រឹក្ស

Nom Scientifique : ***Cassia fistula. Linn***

Famille : **CAESALPINIACEAE (Fabaceae)**

# ដើមរាជព្រឹក្ស

Nom Scientifique : ***Cassia fistula. Linn***

Synonyme : ***Cassia exelsa, cassia rhombifolia***

Famille : **CAESALPINIACEAE (Fabaceae)**

**+លក្ខណៈរុក្ខជាតិ** ៖ ជាចុល្លព្រឹក្សកំពស់៧ទៅ ១៥ម៉ែត្រ មានមែកសន្ទឹងទៅខាង បែកមែកច្រើនមានពណ៌ស និង ប្រផេះ។

**- ស្លឹក** ៖ ស្លឹកធំៗរួមផ្សំស្លាបបក្សីជាគូៗ មួយធាងៗមានកូនស្លឹក៥-៨គូ ស្លឹករាងដូចស៊ុត។

**- ផ្កា** ៖ ជាកញ្ចុំរំយោលវែង ២០-៤០សង់ទីម៉ែត្រ សំយ៉ុងចុះក្រោម ចេញតាមមែក ផ្កាពណ៌លឿងខ្ចីស្រស់។

**- ផ្លែ** ៖ រាងជាបំពង់មូលវែង មិនប្រេះ ប៉ុនម្រាមដៃ ទងខ្លី ផ្លែទុំពណ៌ខ្មៅមាន២៥-១០០សន្ទះ ទទឹងផ្លែពណ៌ស សាច់ផ្លែពេលទុំមានរសជាតិផ្អែមស្អិតពណ៌ក្រមៅ គ្រាប់នៅចន្លោះសន្ទះរលុងពេលទុំ។

**+ កន្លែងដាំដុះ** ៖ ជារុក្ខជាតិដុះដោយធម្មជាតិ និង និយមដាំលំអនៅលើដីមិនលេចទឹក ព្រោះផ្កាមានពណ៌ស្រស់។

**+ សមាសធាតុគីមី** ៖ សាច់ក្នុងផ្លែមានជាតិស្ករ Mucilage, Oxalate de Ca, Acides organiques, Rhíne, 1,8-dihydroxy-3méthyl-anthraquinone, Flavonoide, Glycoside, Acide chrysophanique, Flavonoides, Extraite de cassia fistula: anthraquinones

**+ ការប្រើប្រាស់** ៖ -សាច់ខាងក្នុងផ្លែទុំប្រើសំរាប់ព្យាបាលទល់លាមក-មួល គ្រុនចាញ់ គ្រុនក្តៅប្រគ្រីវ រលាកសន្លាក់ ស្អកក ឈឺចាប់ពេលមានរដូវ ឫសដូងបាត ស្អឹកស្រពន់ ខ្ទិន។

- ស្លឹកដាំផឹកព្យាបាលទល់លាមក ស្លឹកបុកលាយប្រេងកាតលាបស្រែង
- ផ្កាហូបជាអន្លក់ ជាអាហារបន្ទន់លាមក (តិចបន្ទន់ ច្រើនបញ្ចុះ)
- សំបកដើម ដាំផឹកព្យាបាលរោគសើរស្បែកដូចជាពងខ្ទុះ ស្រែង ឃ្លង់ តាអក។

**+ កំរិតប្រើប្រាស់** ៖ - សាច់ក្នុងទុំ ៣-១០ក្រាម (ហូប), ព្យាបាលបន្ទន់លាមក ៥-១០ក្រាម (ផឹក)

**+ ឯកសារយោង** ៖
- www.tropilab.com/goldenshower
- សៀវភៅកំរងរុក្ខជាតិឱសថកម្ពុជា (ភាគទី៤)

**រៀបរៀងដោយនិស្សិត ៖ ឈួក ម៉ារីណា**







# រំដួល

Nom Scientifique : ***Melodorum fruticosum Lour***

Famille : ANNONACEAE

# រំដួល

Nom Scientifique : ***Melodorum fruticosum Lour.***
Famille : ***ANNONACEAE***

+ **លក្ខណៈរុក្ខជាតិ** ៖ ជាឈើមធ្យម មានកំពស់៥-៨ម៉ែត្រ សំបកដើមរលីងមានប្រេះ។
  - **ស្លឹក** ៖ ទោលដុះឆ្លាស់ទង រាងផ្លែលំពែងទ្រវែងស្រួចចុង ស្រួចគល់ ស្លឹកខាងលើរលោងតែមស្លឹកពេញ ខាងក្រោមស្លឹករាងស្រអាប់។ បណ្ដោយ៧-១៥ស.ម ទទឹង២-៣ស.ម។
  - **ផ្កាផ្លែ** ៖ ផ្កាទោលពណ៌លឿងខ្ចីក្រអូបចេញតាមប្រគាបស្លឹករីកចេញជា២ស្រទាប់ក្នុង១ស្រទាប់មាន៣ ត្របក ក្រាស់។
    ផ្លែតូចមូល ជាចង្កោម ដុះចេញពីទងផ្កាតែមួយ ពេលទុំពណ៌ក្រមៅ អាចបរិភោគបាន។
+ **កន្លែងដាំដុះ** ៖ ប្រទះឃើញមានដុះនៅតាមព្រៃក្រាស់ ព្រៃមធ្យម ព្រៃរបោះ និង ព្រៃតំបន់វាលដូចជា តំបន់អង្គរខេត្តសៀមរាប។
+ **សមាសធាតុគីមី** ៖ ប្រេងក្រអូប និង bioactive heptènes

+ **ផ្នែកប្រើប្រាស់** ៖ ផ្កាក្រៀម។
+ **ការប្រើប្រាស់** ៖ ផ្កា ជាថ្នាំលើកកំលាំង ប៉ូវឈាម ជំនួយបេះដូង ព្យាបាលខ្យល់ចាប់។
+ **កំរិតប្រើប្រាស់** ៖ ចំនួន ១៥ក្រាម ក្នុង១ថ្ងៃដាំទឹកផឹក។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជាឆ្នាំ២០០៦

**រៀបរៀងដោយនិស្សិត ៖ សេត វ៉ាហ្សាត**







# រំដេងព្រៃ

Nom Scientifique : ***Alpinia conchigera Grulf***

Famille : **ZINGIBERACEAE**

# រំដេងព្រៃ

Nom Scientifique : *Alpinia conchigera Grulf*

Famille : **ZINGIBERACEAE**

**+លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទស្មៅដុះជាគុម្ពមានកំពស់៨០ស.ម ។

**-ស្លឹក** ៖ ស្លឹកវាមានប្រវែង ១០ ទៅ ១៧ស.ម ទទឹង ៣ ទៅ ៥ស.ម រាងវែងស្រួចចុង។

**-ផ្កា** ៖ ផ្កាវាដុះនៅចុងជាគួរវែង ផ្កាតូចមានពី ១៥ ទៅ ២៥ ផ្កាពណ៌ទឹកក្រូច ។

**-ផ្លែ** ៖ ផ្លែតូចមូលមាន វិជ្ឈមាឌ ៨ ម.ម ពណ៌កាហ្វេក្រហម ផ្លែវាមានពី ៣ ទៅ ៥គ្រាប់ពណ៌លឿងកាហ្វេ មានរសជាតិហិរខ្លាំង ។

**+ កន្លែងដាំដុះ** ៖ ដុះនៅកន្លែងដីសើម និងនៅតាមជាយព្រៃ ដែលមានទឹកដក់រាក់ៗ ។

**+ សមាសធាតុគីមី** ៖ ពុំទាន់មានការស្រាវជ្រាវ ។

**+ ផ្នែកប្រើប្រាស់** ៖ មើម ។

**+ ការប្រើប្រាស់** ៖ ធ្វើឲ្យចេញញើស ក្អករាំរ៉ៃ ស្បែកលឿង ឈឺក្បាល វិលមុខ រលាកស្បូន ប្រើខាងក្រៅបុកបិតនៅកន្លែងឈឺសន្លាក់ដៃជើង ឈឺពោះ និងផ្លូវរំលាយអាហារខុសពីធម្មតា ។

**+ កំរិតប្រើប្រាស់** ៖ ដាំទឹក ៣ ទៅ ៥ ក្រាម/មួយថ្ងៃ ។

**+ ឯកសារយោង** ៖ ដកស្រង់ចេញពីសៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ៥

**រៀបរៀងដោយនិស្សិត ៖ អៀម សុខគីម**







# រំលាយស្វាង, ទម្លាយស្វាង

Nom Scientifique : *Micromelum falcatum (Lour.)Tanak,*

Famille : **RUTACEAE**

# រំលាយស្វខ, ទម្លាយស្វខ

Nom Scientifique : *Micromelum falcatum (lour).tanak,*

Famille : **RUTACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាចុល្លព្រឹក្សមានកំពស់ពី 2-4ម, ដើមសម្បុរសសំបកស្តើង, មែកខ្ចីមានអុជៗ។

- **ស្លឹក** ៖ រួមស្លាបសេសមានកូនស្លឹកពី 7-10សន្លឹក ដុះឆ្លាស់ទងរាងផ្លែលំពែង ទ្រនុងធំមិនចំកណ្តាល គែមស្លឹករាងទឹករលកប្រវែង 4-10ស.ម ទទឹង 2,5-3,5ស.ម។

- **ផ្កាផ្លែ** ៖ - កញ្ចុំផ្កានៅចុងមែកជាកញ្ចុំត្រឹម មានផ្កាតូចៗពណ៌ស ឬ ពណ៌លឿងភាវមានក្លិនក្រអូប។

- ទុំពណ៌លឿងទឹកក្រូច ឬ ក្រហមរាងមូលទ្រវែងបន្តិចមាន 2-3ក្លែប, 1ក្លែបមានគ្រាប់1 ។

+ **កន្លែងដាំដុះ** ៖ ច្រើនដុះតាមព្រៃល្បោះ ជាយព្រៃ បន្តពូជដោយគ្រាប់។

+ **សមាសធាតុគីមី** ៖ នៅក្នុងស្លឹកមានជាតិប្រេង, ក្នុងផ្កាមានAcid pussic…។

+ **ផ្នែកប្រើប្រាស់** ៖ ដើម, ស្លឹក។

+ **ការប្រើប្រាស់** ៖ - ស្លឹកព្យាបាលផ្កាសាយ, ហៀរសំបោរ, ពស់មានពិសចឹក, សត្វល្អិតទិច ឬខាំ។

- ស្លឹកទុំត្រាំស្រា, ព្យាបាលជំងឺសន្លាក់ដៃជើង។ដើមប្រើឈើ

- ដើមប្រើឈើសន្លាក់ដៃជើង ដួលបោកទង្គិច ត្រូវរដូវមិនទៀង ឬសដូងស្ងួតសក់ រលាកច្រមុះ ប្រើច្រើនអោយជ្រុះសក់។

+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី 6-12ក្រាមដាំទឹកហូប, ប្រើខាងក្រៅយកស្លឹកមកបិទពីលើ។

*ចំណាំ៖* ស្ត្រីមានគតិកុំពិសារ។

+ **ឯកសារយោង** ៖

http://www.theplantlist.org/tpl/record/tro-50064903
http:// www.zipcodezoo.com/Plants/M/Micromelum_falcatum/
http://www.katrane.com/telechargement/doc.../10-medicine-from-plants

**រៀបរៀងដោយនិស្សិត ៖ សុវណ្ណា ឌួចណាង**









# ដើមរលាយធំ

Nom Scientifique : ***Neonauclea sessilifolia (Roxb.)Merr.***

Famille : **RUBIACEAE**

# ដើមរលាយធំ

Nom Scientifique : ***Neonauclea sessilifolia (Roxb.)Merr..***

Famille : **RUBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ដើមឈើធំរលោងបែកមែកសាខា។

- **ស្លឹក** ៖ ស្លឹករាងពងក្រពើឬមូលឬមានរាងបេះដូង នៅខាងគល់ស្លឹកប្រវែងពី ៩-២៥cm ទទឹងពី៦-១៨cm ពណ៌បៃតងឬប្រផេះ ខាងលើស្លឹករលោង ស្លឹកស្វិត។

- **ផ្កាផ្លែ** ៖ ផ្កាមូលពណ៌លឿងខ្ចីមានកេសរជាច្រើនរុំជុំវិញពណ៌សរចេញនៅចុងមែកក្នុង ១ទងមានពី១-៥cm ទងផ្កាប្រវែងពី១,៥-៣cm

ផ្លែរាងដូចសាជីនៅខាងចុងផ្លែ ផ្លែមានប្រវែងពី៨-១០សម ទទឹងពី២-៣cm

+ **កន្លែងដាំដុះ** ៖ ដុះខ្លួនឯងនៅក្នុងព្រៃ ប្រមូលផលរាល់រដូវ បន្តពូជដោយគ្រាប់

+ **សមាសធាតុគីមី** ៖ Paconol,3,4-dihydroxybenzoic acid, scopoletin, anthraquinones chrysophanol, 4H-1-benzopyran-4-one, 5,7-dihydrozy-2-methyl, betasitosterol and stigmasterol glucoside

Two new triterpenoid saponins, 3-O-beta-S-glucopyranosyl-(1—2)-beta-D-quinovopyranosyl quinovic acid and …….

+ **ផ្នែកប្រើប្រាស់** ៖ សំបកសាច់ឈើ ឬស។

+ **ការប្រើប្រាស់** ៖ ស្លឹកស្រស់បុកបិទលើស្បែកព្យាបាលជម្ងឺសើស្បែក។ សាច់ឈើ

ស្ត្រីឆ្លងទន្លេរួច

ផឹក៣ថ្ងៃដើម្បីលាងឈាម។សំបក ព្យាបាលរលាកអញ្ចាញធ្មេញរាកក្អួកធ្លាក់ឈាមឈឺក្រពះ រលាកស្បូន គ្រាំគ្រា។ឬស ធ្វើជាថ្នាំឃាត់ឈាម

+ **កំរិតប្រើប្រាស់** ៖ ក្នុងមួយថ្ងៃប្រើពី១៥ ទៅ ២០ ក្រាម សំបកលាយដើម

+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជាមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ

-www.google.fr,/search?hl=fr&biw

htt/:www.biomedexperts.com/Abstract.brne/14600387/Two_triter…

**រៀបរៀងដោយនិស្សិត ៖ ឡាយ លាងស៊ីម**







# ធ្មឹកពាំង (ពាំងភ្នំ)

Nom Scientifique : *Shorea siamensis Miq*

Famille : **DIPTEROCARPACEAE**

# ធ្នឹករាំង (រាំងភ្នំ)

Nom Scientifique *:* ***Shorea siamensis Miq***

*Famille :* **DIPTEROCARPACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាដើមឈើធំ មានកំពស់១៥-២៥ ម ។ដើមមិនសូវត្រង់ សំបកពណ៌ប្រផេះត្នោត ប្រេះក្រហែង ជ្រៅៗ។
  - **ស្លឹក** ៖ រាងពងក្រពើទ្រវែងស្រួចចុង ខាងគល់ស្លឹករាងបេះដូង បណ្ដោយ១២-២០ ស.ម ទទឹងពី១០-១២ស.ម។
  - **ផ្កា** ៖ កញ្ចុំផ្កានៅចុងមែកជាចង្កោមក្លស់ទូលាយ (ផ្កាចេញមុនពេលលាស់ស្លឹក) ផ្កាពណ៌លឿងមាន ក្លិនក្រអូប រាងពងក្រពើ។ ផ្កានៅខែ៣ហើយផ្លែនៅខែ៤។
  - **ផ្លែ** ៖ ផ្លែរាងជាស៊ុត មានបន្ទះស្លាប៥ វែង៣ ខ្លី២។
+ **កន្លែងដាំដុះ** ៖ ដុះនៅតាមព្រៃល្បោះមានឧព្ភទពី១០-៦០ម។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ។
+ **ផ្នែកប្រើប្រាស់** ៖ សំបកដើម និង ត្រួយ។
+ **ការប្រើប្រាស់** ៖ ទាស់រាក។
+ **កំរិតប្រើប្រាស់** ៖ ប្រើពី៣០-៥០ក្រាម។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ៣

**រៀបរៀងដោយនិស្សិត ៖ គួច សុផាលិនដា**

 



## ឈាំខជ័យស្រែ - ឈាំខជ័យស្លឹកតូច

Nom Scientifique : ***Buchanania siamensis Mig***
Famille : **ANACHARDIACEAE**

# លាំងច័យស្រែ - លាំងច័យស្លឹកតូច

Nom Scientifique : ***Buchanania siamensis Mig***
Famille : **ANACHARDIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើតូចមានកំពស់ប្រហែល ៥-១០ម បែកមែកសាខា

- **ស្លឹក** ៖ រាងពងក្រពើទ្រវែង មូលចុងប្រវែងពី៤-៦មម ទងខ្លីមានប្រវែង២-៦មម ស្លឹកខ្ចុល នៅចុងមែក
- **ផ្កាផ្លែ** ៖ ផ្លែមានគ្រាប់តែមួយៗរកបាននៅខែមិនា។

+ **កន្លែងដាំដុះ** ៖ មានដុះនៅក្បែរផ្លូវ,ក្បែរភូមិ តាមភ្លឺស្រែ

+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយទេ។

+ **ផ្នែកប្រើប្រាស់** ៖ ឫស,ជ័រ

+ **ការប្រើប្រាស់** ៖ - ឫសព្យាបាលប្រេះបាតជើង,បាតដៃ
- ជ័រព្យាបាលលាប់កញ្ជ្រឹល។តាមចាស់ៗធ្លាប់និយមប្រើជាថ្នាំគង់ស្បែក ដោយផ្សំជាមួយថ្នាំផ្សេងទៀត។ការព្យាបាលលាប់កញ្ជ្រឹល យកជ័រដុស ជាមួយជាតិសនៃពងទា លាយទឹកដូងមួយពែង ផឹក។

+ **កំរិតប្រើប្រាស់** ៖ ឫស ១៥-២០ក្នុងមួយថ្ងៃដាំទឹកផឹក

+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជារបស់ក្រសួងសុខាភិបាល
នៃមជ្ឈមណ្ឌលជាតិស្រាវ
ជ្រាវវេជ្ជសាស្ត្របុរាណភាគ ២ ឆ្នាំ ២០០៨

**រៀបរៀងដោយនិស្សិត ៖ ធី រចនា**







# ល្ហុងខ្វងក្រហម

Nom Scientifique : ***Jatropha gossypifolia Linn.***

Famille : **EUPHORBIACEAE**

# ល្ហុងខ្វងក្រហម

Nom Scientifique : ***Jatropha gossypifolia Linn***

Famille : **EUPHORBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទរុក្ខជាតិដើមតូច កំពស់ពី១-២ម មានជ័រ។
  - **ស្លឹក** ៖ ផែកជាបីពណ៌ស្វាយ មានរោមតិចៗ នៅគែមស្លឹក ទងស្លឹកនិង ស្លឹកប្រវែងស្មើគ្នា ផាងនិងទ្រនុងស្លឹកពណ៌ក្រហមដូចគ្នា។
  - **ផ្កា** ៖ ផ្កាដុះឈរជាចង្កោមនៅចុងមែក ពណ៌ក្រហមមាន៥ត្របក។
  - **ផ្លែ** ៖ ផ្លែមានប្រវែងពី១-១,២ស.ម មាន៣ក្លែប ក្លែបនីមួយៗ មានចង្អូរពីក្រៅ១ និងគ្រាប់ខាងក្នុង១គ្រាប់។ គ្រាប់វាពណ៌ប្រផេះ ខាងគែមពណ៌ខ្មៅ។
+ **កន្លែងដាំដុះ** ៖ ដុះនៅតាមព្រៃរបោះ ដីចោលទំនេរក្បែរផ្លូវ ដែលមានពន្លឺថ្ងៃ។
+ **សមាសធាតុគីមី** ៖ ស្លឹកមានSaponin, ជ័រមានជាតិចតTanin និង ជ័រដើមមានជាតិប្រេងដែលអាចហូតបាន។
+ **ផ្នែកប្រើប្រាស់** ៖ ប្រើស្លឹក សំបក និង គ្រាប់។
+ **ការប្រើប្រាស់** ៖ ថ្នាំបញ្ចុះលាមក ធ្វើអោយក្អួត ពស់ចិក ក្អក
+ **កំរិតប្រើប្រាស់** ៖ ស្លឹកនិងដើម១០-២០ក្រាមដាំទឹកហូប
  គ្រាប់២០គ្រាប់យកទៅលីងរួចដាំទឹកហូប។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថបុរាណភាគ២ មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ ឆ្នាំ២០០៨

**រៀបរៀងដោយនិស្សិត ៖ ខាត់ សុធា**







# ឈាជផ្ទះ ដើម

Nom Scientifique : *Flueggea microcarpa Bl*

Famille : **Euphorbiaceae**

# លាជផ្ទះ ដើម

Nom Scientifique : ***Flueggea microcarpa Bl***

Famille : **Euphorbiaceae**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាចុល្លព្រឹក្សមួយប្រភេទមានកំពស់ពី ៣ ទៅ ៥ម៉ែត្រ។
  - **ស្លឹក** ៖ ស្ដើង មានរាងស៊ុតត្រលប់ ទោលដុះឆ្លាស់ទង មានខ្នាយស្ទប ។
  - **ផ្កាផ្លែ** ៖ ផ្កាជាកញ្ចុំ ដុះចេញពីប្រគាបស្លឹក ។ផ្លែសាច់រាងមូល មានពណ៌ស មានបីក្លែប ។
+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯងស្ទើរគ្រប់តំបន់ ។
+ **សមាសធាតុគីមី** ៖ នៅក្នុងសំបកដើមមាន Tannins ,Saponins
  នៅក្នុងឬសមាន Alcaloide
  រុក្ខជាតិនេះក៏មាន Flueggein និង Oganic alkali
+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល ។
+ **ការប្រើប្រាស់** ៖ ស្លឹក បុកលាបលើរបួស សំលាប់មេរោគ ។
  ឬសនិងដើម ព្យាបាលជំងឺគ្រុនក្ដៅ ទំលាក់ព្រូន ប្រមេះទឹកបាយ ស្វាយ ធ្លាក់ស ផ្សះពិស តាអក បូស រលាកភ្លើង ម្រេញ ពងបែក ប្រតិកម្មស្បែក ។
+ **កំរិតប្រើប្រាស់** ៖ ប្រើពី ១០ ទៅ ១៥ក្រាម ដាំទឹកផឹក ។ប្រើខាងក្រៅ ស្ងោរ លាង។
  ស្លឹកស្ងួតកិនអោយម៉ត់លាយប្រេងល្ង សំរាប់លាប ។
+ **ឯកសារយោង** ៖ សៀវភៅ រុក្ខជាតិឱសថកម្ពុជា
  http://www.cactuspedia.info/schede/EUPHORBIA/ Flueggea microcarpa Bl.htm

**រៀបរៀងដោយនិស្សិត ៖ ម៉ុក សារ៉ាត**







# វល្លិ៍លៃនពែន

Nom Scientifique : *Tetrastigma Planicaule (Hook f.) Gagnep*

*Famille :* ***VITACEAE***

# វល្លិ៍លៃនពៃន

Nom Scientifique *:* ***Tetrastigma Planicaule (Hook f.) Gagnep***

*Famille :* ***VITACEAE***

+ **លក្ខណៈរុក្ខជាតិ** ៖ ជាវល្លិ៍មានដើមសំប៉ែត ទទឹងមានរហូតដល់ 5សម
មានចង្អូរៗមែកសំប៉ែតតិចៗ មានចង្អូរដូចគ្នា រលោង ។
- **ស្លឹក** ៖ ស្លឹករាងជើងទា មានប្រាំសន្លឹក (កូនស្លឹកប្រាំ) កូនស្លឹកនីមួយៗរាងពងក្រពើទ្រវែង ស្រួចចុងគល់ ។
- **ផ្កាផ្លែ** ៖ កញ្ចុំផ្ការាងចង្កោមៗតូចៗផ្តុំគ្នាជាចង្កោមធំ ផ្កាតូចៗពណ៌សចេញពីប្រគាបស្លឹកចាស់ ផ្លែរាងមូល ពណ៌លឿង មានរសជូរ ។
+ **កន្លែងដាំដុះ** ៖ មានដុះនៅតាមព្រៃក្រាស់ ជាយព្រៃ ជំរាលភ្នំ ។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ ។
+ **ផ្នែកប្រើប្រាស់** ៖ វល្លិ៍ និង មែក ។
+ **ការប្រើប្រាស់** ៖ ឈឺឆ្អឹងឆ្អែង ឈឺក្បាលជង្គង់ ឈឺសន្លាក់ឆ្អឹង ឈឺចុកចាប់ពេញខ្លួន ។
+ **កំរិតប្រើប្រាស់** ៖ 30-75 ដាំទឹកហូប ឬត្រាំស្រា ។ប្រើខាងក្រៅយកមែក និងស្លឹកបុកបិត ពីលើកន្លែងឈឺ ។
+ **ឯកសារយោង** ៖ ក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ ។

**រៀបរៀងដោយនិស្សិត ៖ ហាក់ បញ្ញា**







# ល្ងៀងកូនខ៉ែត ឬ ល្ងៀងអាចម៍កូន

Nom Scientifique : *Cratoxylum formosum. Jack Dyer subsp. PruniflorumKurs*

Famille : **CLUSIACEAE**

# ល្មៀងកូនខ៉ែត ឬ ល្មៀងអាចម៍កូន

Nom Scientifique : ***Cratoxylum formosum. Jack Dyer subsp. PruniflorumKurs***

Famille : **CLUSIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទរុក្ខជាតិម្យ៉ាង ដែលដុះលូតលាស់ឡើងវិញជារៀងរាល់ឆ្នាំ។ វាអាចមានកំពស់រហូតដល់ ២០ម៉ែត្រ។ ដើម មែក ទង រាងទ្រវែង និង មានបន្លាវែងស្រួចនៅដើម។ ស្លឹកដុះទល់គ្នា រាងទ្រវែង តែនៅត្រង់កំពូលមានរាងស្រួច។
  - **ស្លឹក** ៖ ពណ៌ក្រហម រាងពងក្រពើ ប្រវែងពី ២៥ ទៅ ៤៥សង់ទីម៉ែត្រ។
  - **ផ្កា** ៖ ពណ៌ត្របែកព្រៃ ផ្កាឈូក គ្មានទង ដុះជាប់នឹងមែក។
  - **ផ្លែ** ៖ ពណ៌ក្រហម រាងពងក្រពើ។
+ **កន្លែងដាំដុះ** ៖ ភាគច្រើនដុះនៅតំបន់ត្រូពិច។
+ **សមាសធាតុគីមី** ៖ ស្លឹកផ្ទុកជាតិសរសៃ។
+ **ផ្នែកប្រើប្រាស់** ៖ មែក ស្លឹក ទង ផ្លែ គ្រាប់ ឬស។
+ **ការប្រើប្រាស់** ៖ រលាកក្រពះ អស់កំលាំង ល្ហិតល្ហៃ រលាកតំរងនោម។
+ **គំរិតប្រើប្រាស់** ៖ មិនមានឯកសារបញ្ជាក់ច្បាស់លាស់។
+ **ឯកសារយោង** ៖

http://asianplant.net
http://www.MaysFlower.com
http://www.sciencedirect.com/science/article
http://iadr.conflex.com/idar/2006Brisb/techprogram/abstract

រៀបរៀងដោយនិស្សិត ៖ លី កល្យាណា







# ដើមល្មុតស្រទាំ

Nom Scientifique : ***Sideroxylon Cambodianum Pierre***

*Famille :* ***SAPOTACEAE***

# ដើមល្មុតស្រទាំ

Nom Scientifique : ***Sideroxylon cambodianum Pierre***
*Famille :* ***SAPOTACEAE***

**+ លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទដើមឈើតូច ដែលមានកំពស់ពី ១០-១៥ម មែកវាមានបន្លាស្រួចៗ ឈើរបស់វាគេយកធ្វើជាសសរផ្ទះ។

**- ស្លឹក** ៖ ដុះចេញពីមែកមានស្លឹកតែមួយ ដែល ឆ្លាស់គ្នាទៅវិញទៅមក និងមានបន្លាស្រួចៗ។

**+ កន្លែងដាំដុះ** ៖ ដើមឈើនេះភាគច្រើនដុះនៅក្នុងព្រៃទិសខាងជើងនៃប្រទេសកម្ពុជា។

**+សមាសធាតុគីមី** ៖ មិនទាន់ដឹង ។

**+ ផ្នែកប្រើប្រាស់** ៖ ឬស និង មែកតូចៗ។

**+ ការប្រើប្រាស់** ៖ ស្ងោរឬស និងមែកតូចៗរយៈពេល៣០ ទៅ ៦០នាទី ជួយសំរួលឈាម និងជួយបង្កើនទឹកដោះ។

**+ កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ប្រហែលពី ២០ក្រាម ទៅ ៣០ក្រាម។

**+ ឯកសារយោង** ៖ Sec General References G37 and G79 ។

**រៀបរៀងដោយនិស្សិត ៖ ស្រី ពេជ្រ**







## ល្វាដី

Nom Scientifique : ***Ficus hispida Linn.f.***

Famille : **Moraceae**

# ល្វាដី

Nom Scientifique : ***Ficus hispida Linn.f.***

Famille : **MORACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ដើមឈើតូច មានកំពស់ពី៥ទៅ៨ម៉ែត្រ មែករឹងមាំ មែកខ្ចីមានរោមពណ៌ត្នោត ហើយមែកចាស់រលីង ។
  - **ស្លឹក** ៖ ស្លឹកទោលដុះទាល់ទង រាងស៊ុតត្រលប់ច្បិចចុង គែមស្លឹកមានធ្មេញរណា។ ស្លឹកមានរោមគគ្រាត ប្រវែង១១ទៅ១២សង់ទីម៉ែត្រ និងទទឹង៥ ទៅ ១២ សង់ទីម៉ែត្រទងស្លឹកមានប្រវែង១.៥ទៅ៣សង់ទីម៉ែត្រ។
  - **ផ្កាផ្លែ** ៖ ផ្លែមានរាងមូលមានទង ដុះជាប់នៅនឹងដើម ហើយពេលទុំផ្លែមានពណ៌លឿង។
+ **កន្លែងដាំដុះ** ៖ ដុះនៅក្នុងព្រៃល្បោះ តាមមាត់ទឹក។ បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ មាន Saponin ,Flavonoids,Steroids,Tannins,Alkaloids,Triterpenoids.
+ **ផ្នែកប្រើប្រាស់** ៖ ស្លឹក ផ្លែ សំបក ឫស។
+ **ការប្រើប្រាស់** ៖ - ផ្កាសាយ ឈឺបំពង់ក ជួយរំលាយអាហារ រាគមូល ឈឺសន្លាក់ គ្រុនចាញ់គ្រុនក្ដៅ រលាកទងសួត ឈឺធ្មេញ ឫសក្លៀក ត្រអក ដំបៅរលាក ជ្រុះសក់ឬសដូងបាត ការពារបេះដូង។ផ្នែកផ្លែព្យាបាលដំបៅ ខ្វះឈាមក្រហម ឬសដូងរិល ខាន់លឿង ឈាមតាមច្រមុះឈាមតាមបំពង់អាហារ។
+ **កំរិតប្រើប្រាស់** ៖ ដាំទឹកផឹករយះពេលពី១៥ទៅ៣០ថ្ងៃ។
+ **ឯកសារយោង** ៖ កំរងរុក្ខជាតិឱសថស្ដីពីការស្រាវជ្រាវក្នុងខេត្តមណ្ឌលគីរី។
  http://www.suansavarose.com/index.php?mo=3&art=169147
  http://ayurvedicmedicinalplants.com/plants/294.html

**រៀបរៀងដោយនិស្សិត ៖ ហេង ស៊ីឆន**







## ល្វាធំ

Nom Scientifique : *Ficus racemosa L.*
*Syn-Ficus glomerata Roxb.*
Famille : **MORACEAE**

# ល្វាធំ

Nom Scientifique : ***Ficus racemosa L.***
***Syn-Ficus glomerata Roxb.***
Famille : **MORACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើរស់បានយូរឆ្នាំ មានកំពស់ពី១៥-២០ម៉ែត្រ។

- **ស្លឹក** ៖ ខាងលើរលោង ពណ៌បៃតងចាស់ ខាង១ពណ៌បៃតងភ្លាវ រាងពងក្រពើរៀវគល់ស្រួចចុះ ឆ្លាស់ទង។ នៅលើស្លឹកចាស់មានពក១ (ដង្កូវរស់នៅខាងក្នុង) ទងស្លឹកមានប្រវែងពី ៩-១០សម បណ្ដោយស្លឹកប្រវែងពី១០-២០សម ទទឹងពី៦-១០សម គែមស្លឹករលោង។

- **ផ្កាផ្លែ** ៖ ផ្កា៖ តូច១ចេញជាចង្កោម បណ្ដាក់គ្នាជាគូគ្របដោយស្រទាប់ដូចស្រកា រួចក្លាយជាផ្លែ។
ផ្លែ៖ ចេញជាចង្កោមពីមែក និងដើម ផ្លែរាងមូល ពេលទុំពណ៌ក្រហម មានសត្វមមង់នៅខាងក្នុងផ្លែ។

+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯង តាមវាលរាប ឬគេដាំជាម្លប់។

+ **សមាសធាតុគីមី** ៖ -Flavonoids, tannins and polyphenolic compounds, triterpenoids, phytosterols, carbohydrates, alkaloids, cardiac glycosides.

+ **ផ្នែកប្រើប្រាស់** ៖ ប្រើជ័រ ស្លឹក ផ្លែ សំបកដើម ឬស។

+ **ការប្រើប្រាស់** ៖ -ផ្លែខ្ចី និងស្លឹកធ្វើជាអន្លក់ អោយចេញទឹកដោះច្រើន រាគ។
-ជ័រលាយជាមួយកំបោរលាបពីក្រៅ រមាស់កើតអាត់ បូស ។ ព្យាបាលរលាក ឬសដូងបាត ព្យាបាលឈឺក្រពះ គ្រុនពោះវៀន បន្សាបពុល និងពស់ចឹក។
-ស្លឹកព្យាបាលឈឺឆ្អឹងឆ្អែង គ្រុនចាញ់ ស្ត្រីឆ្លងទន្លេ អត់ទឹកដោះ ឬធ្វើជាម្សៅលាយទឹកឃ្មុំ ព្យាបាលប្រម៉ាត់។
-ផ្លែព្យាបាលមករដូវមិនទៀង ។

+ **គំរិតប្រើប្រាស់** ៖ -ស្ត្រីឆ្លងទន្លេហើយអត់ទឹកដោះ យកមែក ស្លឹក សំបក១០-២០ក្រាមដាំទឹកផឹក។
-គ្រុនចាញ់អោយយកស្លឹកដែលជ្រុះ ធ្លាក់ក្នុងភក់ រើសលាងអោយស្អាត ហាលអោយស្ងួត ហាន់អោយល្អិត លីងអោយឆ្អុយ ចំនួន១០០ក្រាម ដាំទឹកផឹក ព្រឹក.ល្ងាច រហូតដល់ ៥ថ្ងៃ។ -ជ័រលាយជាមួយទឹកឃ្មុំ ផឹកមុនពេលចូលដេក ព្យាបាលហឺត។

+ **ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជាភាគ២ បោះពុម្ពឆ្នាំ ២០០៨។
http://www.suansavarose.com/index.php?mo=3&art=169147

**រៀបរៀងដោយនិស្សិត ៖ ស៊ីម ណារុំ**

 



## វល្លិគុយ

Nom Scientifique : ***Willughbeiae cochinchinensis***

Famille : **APOCYNACEAE**

# វល្លិគុយ

Nom Scientifique : ***Willughbeiae cochinchinensis***

Famille : **APOCYNACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិប្រភេទវល្លិ៍ធំ តោងឡើងដើមឈើធំៗ។
  - **ស្លឹក** ៖ ទល់ទងរាងទ្រវែងស្រួចចុង ផ្ទៃកខាងលើពណ៌បៃតងចាស់។ មានទ្រនុងទទឹងច្បាស់ ផ្ទៃកខាងក្រោមពណ៌បៃតងខ្ចីជាងខាងលើ។
  - **ផ្កាផ្លែ** ៖ចេញពីប្រគាបស្លឹក មានពណ៌ស។
+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯង នៅតំបន់ព្រៃភ្នំ ព្រៃស្រោង និង មានតិចតួចនៅតាមព្រៃរបោះ។
+ **សមាសធាតុគីមី** ៖ មិនមានឯកសារ
+ **ផ្នែកប្រើប្រាស់** ៖ :វល្លិ៍, ឫស និង ជ័រ
+ **ការប្រើប្រាស់** ៖ ឫស និង វល្លិ៍ ព្យាបាលរាកមួល ជម្ងឺថ្លើម កន្ទាលត្រអាក ជំនួយកំលាំងស្ត្រីទើបឆ្លងទន្លេរួច ដោយដាំទឹកផឹក ឬ ត្រាំស្រា។
+ **កំរិតប្រើប្រាស់** ៖ ឫស និង វល្លិ៍ ប្រើកំរិត ១៥ - ៣០ក្រាម ដាំទឹកហូប។
+ **ឯកសារយោង** ៖ -សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ១ (មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ) បោះពុម្ពឆ្នាំ២០០៨
  -www.google.fr, htt:www.stuartxchange.org/Hilagak.html

**រៀបរៀងដោយនិស្សិត ៖ ភឿន ពុទ្ធិតា**








# វល្លិ៍អែម

Nom Scientifique : ***Streblus ilicifolius***

Famille : **MORACEAE**

# វល្លិ៍អែម

Nom Scientifique : *Albizia myriophylla Benth*

Famille : FABACEAE

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទវល្លិ៍ឈើ ដុះជាគុម្ពមានប្រវែងពី 2 - 4 ម៉ែត្រ សំបកដើម ពណ៌ត្នោត។
  - **ស្លឹក** ៖ ស្លឹករួមស្លាបពីរដង កូនស្លឹករាងដូចស៊ុត។ នៅខាងក្រោមទងស្លឹក មានបន្លារាង សំប៉ែត ស្រួចចុង។
  - **ផ្កាផ្លែ** ៖ ផ្ការាងជាកញ្ចុំមូល ចេញតាមចុងមែក ផ្កានិមួយៗ ដុះនៅចុងបែកជា 5 ផែកតូចៗ កេសរ វែងជាច្រើន ផ្កាមានក្លិនក្រអូប។ ផ្លែមានរាងសំប៉ែតវែង,ចុងផ្លែរៀវ ផ្លែចាស់ពណ៌ស្វាយ មានពី 5 – 8 គ្រាប់។
+ **កន្លែងដាំដុះ** ៖ ប្រទះឃើញមានដុះតាមតំបន់ខ្ពង់រាប, ជើងភ្នំ ព្រៃតំបន់មាត់សមុទ្រ។
+ **សមាសធាតុគីមី** ៖ មាន Glucose និង Sucrose
+ **ផ្នែកប្រើប្រាស់** ៖ : សំបក, ឬសផ្កា។ ប្រមូលផលបានរាល់រដូវ។
+ **ការប្រើប្រាស់** ៖ : -ឬស: ព្យាបាល ស្រេកទឹក
  - សំបក និង ដើម: ព្យាបាលក្អក, កាត់ស្លេស់, ព្យាបាលឈាមចេញតាមជើង ធ្មេញ, ជំនួយកំលាំង, ជួយសំរួលរស់ជាតិថ្នាំ។
  - ផ្កា: ជួយរំលាយអាហារ។
+ **កំរិតប្រើប្រាស់** ៖ ពី 10 – 29 ក្រាម ដាំផឹកក្នុង1ថ្ងៃ។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជា ភាគ 2 មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ 2006

**រៀបរៀងដោយនិស្សិត ៖ ថី នាងលក្ខ័**






# វល្លិ៍ចារក្រហម

Nom Scientifique : ***ButeaSuperbaRoxb***

Famille : **LEGUMINOSAE**

# វល្លិ៍ចារក្រហម

Nom Scientifique *:* ***ButeaSuperbaRoxb***

*Famille :* **LEGUMINOSAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទវល្លិ៍វារដើមរឹង។
    - **ស្លឹក** ៖ ដើមធំ ត្រាំទឹកមានចេញពណ៌ក្រហមអាចយកទៅជ្រលក់រាល់ប្រភេទអំបោះ និងក្រណាត។
    - **ផ្កា** ៖ ផ្កាវាមានពណ៌ក្រហម
+ **កន្លែងដាំដុះ** ៖ ភាគច្រើនមានដុះនៅតាមព្រៃរបោះនៃប្រទេសកម្ពុជា។
+ **សមាសធាតុគីមី** ៖ នៅក្នុងឫសមានសារជាតិដូចជា:Flavonoids, Flavonoid glucosides, Sterol glucosides, Sitosterol, Campesterol, Stigmasterol.
+ **ផ្នែកប្រើប្រាស់** ៖ ឫស ដើមនិងស្លឹក
+ **ការប្រើប្រាស់** ៖ - អាចលាយផ្សំជាមួយថ្នាំផ្សេងទៀត - ជាថ្នាំព្យាបាលពស់ចឹក
    - ភ្នែកឡើងបាយ: យកជ័រវល្លិ៍ចារក្រហម ៤ភាគ ខ្លឹមច័ន្ទក្រហម ១ភាគ អំបិលមូល ២ភាគ និងChebulicMyrobalarxls៣ភាគ លាយចូលគ្នាបុកឱ្យទៅជាម្សៅសម្រាប់ដាក់ភ្នែក។
    - ឫសដូងបាត:យកស្លឹកនិងដើមស្ងោរត្រាំចំណុចនោះ
    - ហើមបួសរីដំបៅ:ប្រើស្លឹកជាថ្នាំបិតរីលាប
    - ឫស និងដើម:ប្រើជំនួយសុខភាពបុរស
+ **កំរិតប្រើប្រាស់** ៖ ដើមប្រើប្រាស់ត្រឹមតែ ១៥-២០ក្រាមសម្រាបដាំផឹក
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជាភាព៣នៃក្រសួងសុខាភិបាលមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ_ឆ្នាំ ២០០៩។

**រៀបរៀងដោយនិស្សិត ៖ នេង សុគន្ធារ័ត្ន**







# វល្លិ៍ ជុយ

Nom Scientifique : ***Streptocaulon juventas*,**

Famille : **ASCCLEPIADACEAE**

# វល្លិ៍ ជុយ

Nom Scientifique : *Streptoculon juventas*

Famille : **ASCCLEPIADACEAECV**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាវល្លិ៍រឹងមានប្រវែងពី ២–៥ម មានឫសរាងជាមើម សំបកដើមមានពណ៌ក្រហម ត្នោតមែកខ្ចីមានរោម។
- **ស្លឹក** ៖ ទោលដុះទល់ទង រាងដូចស៊ុតច្បិចចុង មានរោមស ទន់ល្មើយ ទទឹង២–៩ ស.ម បណ្តោយ ៥–១៥ស.ម។
- **ផ្កាផ្លែ** ៖ -កញ្ចុំផ្កាចេញពីប្រគាបស្លឹក ជាចង្កោម ផ្កាតូចៗមានពណ៌លឿងស្រាល។ -ផ្លែ១គូ ទល់គ្នារូមទង ពេលទុំប្រេះចេញគ្រាប់ មានរោមកំប៉ោយដូចសំលី។ រុក្ខជាតិទាំងមូលមានជ័រពណ៌សដូចទឹកដោះ។
+ **កន្លែងដាំដុះ** ៖ នៅតាមដំបូក ព្រៃល្បាស់ ព្រៃល្បោះ ដីចំការទើបកាប់រានថ្មីៗ។
+ **សមាសធាតុគីមី** ៖ -សំបក និង ជ័រមាន Phenolic glycosides ច្រើន។ - មើម មាន Tamins pyrogalic។
+ **ផ្នែកប្រើប្រាស់** ៖ មើម ស្លឹក ដើម ។
+ **ការប្រើប្រាស់** ៖ - ខ្សោយថ្លើម ខ្វះឈាម ខ្សោយសរសៃប្រសាទ ដេកមិនលក់ បាយមិនបាន គ្រុនចាញ់ ឈឺសន្លាក់ឆ្អឹង ឈឺសរសៃ រដូវមិនទៀង ធ្លាក់ស ដុះឈាម ពស់ចឹក សក់ស្កូវមុនអាយុ រោគសើរស្បែក។
- មើមខ្ចីៗ បុកពូតយកទឹក អោយស្ត្រីសំរាលកូន ហើយផឹកដើម្បីមានទឹកដោះ ។
- ស្លឹក ដាំទឹកងូត ព្យាបាលកមរមាស់ ។ មើមអាចយកទៅព្យាបាលរោគក្រពះ។
+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី ១២–២០ក្រាម ដាំទឹកផឹកក្នុង១ថ្ងៃ។
+ **ឯកសារយោង** ៖ http://www.ncbi.nim.gov/pubmed/14519950
http://www.tropicos.org/Name/2608842

**រៀបរៀងដោយនិស្សិត ៖ លុន ឥន្ទ្រីណា**








# វល្លិ៍ដីស

Nom Scientifique : ***Dioscorea bulbifera L***

Famille : **DIOSCOREACEAE**

# វល្លិ៍ដំឡូងជីស

Nom Scientifique : ***Dioscorea bulbifera L***

Famille : **DIOSCOREACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិវល្លិ៍ មានមើមរាងមូល ឬ មូលទ្រវែង មានរឹសខ្ចីដុះជុំវិញមើម ដើមវាមូលរលោងពណ៌បៃតងភ្លាវ ឬ ក្រហមភ្លាវ មានមើមអាកាសជាច្រើន ចេញតាមប្រកៀបស្លឹក។
  - **ស្លឹក** ៖ ស្លឹកទោលដុះឆ្លាស់ទង រាងបេះដូង ធំស្រួចចុង មានទ្រនុងស្រប មានបណ្តោយ រហូតដល់៣៥cm ទទឹង៣២cm
  - **ផ្កា** ៖ កញ្ចុំផ្កាជាកួរវែង ផ្កាតូចៗ មានពណ៌បៃតងភ្លាវ មានប្រវែង២០–៣០cm
  - **ផ្លែ** ៖ ជាផ្លែស្ងួត មានស្លាបទទឹង៨–៩mm បណ្តោយ២០–២២mm ធ្លាក់ជាចង្កោមកួរវែង
+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯង លើដីទួល ស្ទើរគ្រប់ទីកន្លែង (បន្តពូជដោយគ្រាប់ និង មើម)
+ **សមាសធាតុគីមី** ៖ Glycocide et Saponin
+ **ផ្នែកប្រើប្រាស់** ៖ មើមក្នុងដីនិងមើមអាកាស(លាងសំអាតហាន់ហាលថ្ងៃ)
+ **ការប្រើប្រាស់** ៖ •មើម៖ ថ្នាំបញ្ចុះទឹកនោម ស្វាយ បូស
  •មើមស្ងួតកិនជាម្សៅប្រើជាថ្នាំលាបរមាស់ និង ថ្នាំឬសដូងបាត
  បើដាំទឹកផឹកព្យាបាលពកក របេងកូនកណ្តុរ ក្អកធ្លាក់ឈាម ស្បូនធ្លាក់ឈាម
  •ស្លឹកស្រស់៖បុកសំរាប់បិតលើកន្លែងអាប់សៃ
+ **កំរិតប្រើប្រាស់** ៖ ដាំផឹកក្នុងកំរិត៦–៩ក្រាម។
+ **ឯកសារយោង** ៖ •សៀវភៅកំរងរុក្ខជាតិឱសថក្នុងការចុះអង្កេតស្រាវជ្រាវនៅខេត្តព្រះសីហនុ
  •les plantes médicinales au Cambodge livre 2
  •medicinal plants of Cambodia

**រៀបរៀងដោយនិស្សិត ៖ ឈី តុលា**






## វល្លិ៍ខ្លោត

Nom Scientifique : *Thunbergia grandiflora Roxb.*

Famille : **ACANTHACEAE**

# វល្លិ៍គ្លោត

Nom Scientifique : ***Thunbergia grandiflora Roxb***

Famille : **ACANTHACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទវល្លិ៍តោង ដុះឡើងព័ទ្ធជុំវិញ មានមែកបែកសាខា ធ្លាក់សំយ៉ុងចុះក្រោម
  - **ស្លឹក** ៖ មានលក្ខណៈទល់គ្នា មានរាងបេះដូង មានកំពកស្លឹកមិនស្មើជ្រុង មានទងវែងៗ ៉
  - **ផ្កាផ្លែ** ៖ មានពណ៌ខៀវថ្លា រឺពណ៌ខៀវស្វាយរាងធំរលោងគ្មានរោម ផ្កាចាប់ពីខែមិនាដល់កញ្ញា ។
+ **កន្លែងដាំដុះ** ៖ គេប្រទះឃើញនៅតាមតំបន់ព្រៃ មានពន្លឺគ្រប់គ្រាន់ ។
+ **សមាសធាតុគីមី** ៖ ស្លឹក: សំបូរទៅដោយអំបិល ប៉ូតាស្យូម
  ផ្កា: សំបូរទៅដោយ acides aminés ដូចជា acide aspartique, valine, Flavonoides, apiyenin 7- glucuronide, lutéoline, anthocyanine, malvidine, saccharose, glucose et fructose.
+ **ផ្នែកប្រើប្រាស់** ៖ ស្លឹក និងផ្កា
+ **ការប្រើប្រាស់** ៖ គេនិយមយកស្លឹកព្យាបាលពស់ចិក យកស្លឹកស្រស់ យកទងចេញអោយអស់រួចគាប រឺបុកយកទឹកទៅលាប រឺម៉ាស្សាក្បែរកន្លែងពស់ចិក ពីលើចុះក្រោម ។ រីឯកាកវាយកទៅស្អំកន្លែងពស់ចិកតែម្តង ។ គេអាចយកស្លឹករបស់វាសុទ្ធ រឺលាយជាមួយនឹងស្លឹករបស់ Abelmoschus moschatus និងគ្រាប់របស់ clousena lansium ។
+ **កំរិតប្រើប្រាស់** ៖ ៣០ - ៥០ ក្រាមនៃស្លឹក
+ **ឯកសារយោង** ៖ List of medical plants in Cambodia 2009 ( Prof. CHENG SUN KAING)
  List of medicinal plants in Cambodia 2012

**រៀបរៀងដោយនិស្សិត ៖ ឡាយ សិកា**




# វល្លិ៍ត្រចៀកដំរីស្លឹកធាលធក

Nom Scientifique : ***Ohya obovata Decne***

Famille : **ASCEPIDACEAE**

# វល្លិ៍ត្រចៀកដំរីស្លឹកទាលធក

Nom Scientifique *: Ohya obovata Decne*

Famille : **ASCEPIDACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាវល្លិ៍ស្ទើជាបញ្ញើក្អែកដើមមូលមានថ្នាំងមានឫសជាប់នឹងដីផងនឹងមានឫសតាមដើមចាស់ភ្ជាប់អាស្រ័យនឹងដើមឈើដំទៃទៀតផង។
  - **ស្លឹក** ៖ ជាស្លឹកទោលរាងដូចបេះដូងត្រឡប់រលោងក្រាស់ស្វិតមានពណ៌បៃតងឬលឿងមានជ័រពណ៌ស។
  - **ផ្កា** ៖ កញ្ចុំផ្កាជាចង្កោមរាងដូចសាជីផ្កាមូលៗតូចៗមានពណ៌សឬសស៊ីជម្ពូចេញតាមប្រគាបស្លឹក។
  - **ផ្លែ** ៖ ផ្លែជាគូរមូលតូចវែងរាវមានរោមគ្របដណ្តប់។
+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯងតាមដើមឈើធំៗនៃព្រៃស្រោងឬព្រៃល្បោះ។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ។
+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល។
+ **ការប្រើប្រាស់** ៖ គ្រុនចាញ់ ក្តៅក្នុង ចេញទឹកដោះ ក្អួតចង្អោរ ឈឺចង្កេះ ផ្សះថ្លើម ធ្លាក់សត្រជាក់សាច់ ចុះនោម ជួយកម្លាំង ។
+ **កំរិតប្រើប្រាស់** ៖ ស្ងួត១០ទៅ២០ក្រាម ដាំទឹកផឹក។
+ **ឯកសារយោង** ៖ ដកស្រង់ចេញពីសៀវភៅរុក្ខជាតិឱសថកម្ពុជា ភាគ៣។

**រៀបរៀងដោយនិស្សិត ៖ ម៉ុម សាទរីយ**






# វល្លិត្រចៀកដំរីស្លឹកស្រួច

*Nom* Scientifique *:* ***Hoya parasitica***

Famille : **ASCLEPIADACEAE**

# វល្លិត្រចៀកជំរឺស្លឹកស្រួច

Nom Scientifique : ***Hoya parasitica***

Famille : **ASCLEPIADACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទវល្លិច្របល់ចូលគ្នា រឺ គុម្ព ប្រវែងកំពស់២ m រស់បានច្រើនឆ្នាំ
- **ស្លឹក** ៖ ស្លឹកក្រាស់ មូលទ្រវែងដូចពងក្រពើ
- **ផ្កាផ្លែ** ៖ : ផ្កាពណ៌សផ្កាឈូកដុះជាចង្កោមលូតលាស់ពីខែមេសា ដល់ខែមិថុនា
  : គ្មានផ្លែ
+ **កន្លែងដាំដុះ** ៖ ដុះនៅលើផ្ទាំងសិលាសើម រឺ លើដើមឈើ ដុះជាជង្រាល
+ **សមាសធាតុគីមី** ៖ មិនមានពត៌មានជាក់លាក់
+ **ផ្នែកប្រើប្រាស់** ៖ ប្រើរុក្ខជាតិទាំងមូល(មានរស់ជាតិល្វីងជូរ), ប្រើរុក្ខជាតិស្រស់ រឺ ស្ងួត
+ **ការប្រើប្រាស់** ៖ ប្រើព្យាបាលរលាកស្ងួត, រលាកទងសួត, រោគរាតត្បាតរលាកខួរក្បាល, ភ្នែកក្រហម, រលាកអាមីដាល់, សន្លាក់ឆ្អឹង, ជំងឺរលាកដោះ
+ **កំរិតប្រើប្រាស់** ៖ ១៥-30mg ស្ងួររំងាស់ដាំផឹក, ៦០-៩០mg
  គៀបច្របាច់យកទឹកនៃរុក្ខជាតិស្រស់សំរាប់ផឹកតាមមាត់.
  កិនរុក្ខជាតិស្រស់អោយម៉ត់លាបលើរបួស
+ **ឯកសារយោង** ៖ ពតិមានផ្តល់ដោយគ្រូឱសថបុរាណ ។

**រៀបរៀងដោយនិស្សិត ៖ គីម ពន្លក**







## វល្លិ៍ទន្លីខដំរី

Nom Scientifique : ***Ventilago gristata pierre.***

Famille : **RHAMANACEAE**

# ទល្លើទន្លីទដំរី

Nom Scientifique : *Ventilago gristata pierre*

Famille : **RHAMANACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទវល្លិ៍វែងមានមែកខ្លី រាងជ្រុងផតបន្ទាប់មកមូល មានពណ៌ប្រផេះខ្មៅ។
  - **ស្លឹក** ៖ ទោលដុះឆ្លាស់ទង រាងផ្លែលំពែង ទាលខាងគល់ច្បិចចុងប្រវែង៥-១២ស.ម ស្លឹករលោងមានទ្រនុងស្លឹកពី១០-១៣គូ។
  - **ផ្កា** ៖ ផ្កាជាចង្កោម ចេញពីប្រគាបស្លឹក ផ្កាតូចៗពី២-៣ម.ម មានពណ៌លឿងខៀវ។
  - **ផ្លែ** ៖ ផ្លែរាងស្លាបវែង សំប៉ែត ដូចកូនកាំបិត។
+ **កន្លែងដាំដុះ** ៖ ដុះនៅព្រៃភ្នំ ព្រៃល្បោះ បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ។
+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល។
+ **ការប្រើប្រាស់** ៖ ឈើសាច់ដុំ ឈើសន្លាក់ឆ្អឹងជុំនួយកំលាំង ឈើសរសៃ គ្រជាក់ចុកដៃចុកជើង។ ផ្សំជាមួយវល្លិ៍គ្រោកព្យាបាលជំងឺផ្លូវនោម។
+ **កំរិតប្រើប្រាស់** ៖ ស្ងួតប្រើពី១៥-៣០ក្រាម។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថបុរាណភាគ២នៃ មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ២០០៨

**រៀបរៀងដោយនិស្សិត ៖ ជា សុវណ្ណារ័ត្ន**







# វល្លិ៍ទឹក

Nom Scientifique : ***Cissus Rosea Royle***

Famille : **VITACEAE**

# វល្លិ៍ទឹក

Nom Scientifique : ***Cissus Rosea Royle***

Famille : **VITACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាវល្លិ៍ដុះតោងឡើងតាមដើមឈើធំៗតាមរយៈប្រមោយរបស់វា

- **ស្លឹក** ៖ មានរាងជាបេះដូង, មានកំរាស់ស្តើង, មានពណ៌បៃតងខ្ចី, មានទង, មានប្រមោយឈមទៅនិងស្លឹក។

- **ផ្កាផ្លែ** ៖ គ្មាន

+ **កន្លែងដាំដុះ** ៖ ព្រៃភ្នំ តំបន់ត្រូពិចដែលមានអាកាសធាតុក្តៅហើយសើម, ហើយនៅជុំវិញវាមិនសូវមានរុក្ខជាតិតូចៗដុះទេ។

+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ។

+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល

+ **ការប្រើប្រាស់** ៖ - បញ្ចុះកំដៅ, ព្យាបាលស្បូន, ធ្លាក់ស, កូនខ្ចី

+ **កំរិតប្រើប្រាស់** ៖ ប្រើប្រាស់ពី១០g ទៅ ២០g ដាំទឹកផឹក

+ **ឯកសារយោង** ៖ តាមគ្រូបុរាណក្នុងការចុះអង្កេតស្រាវជ្រាវរុក្ខជាតិឱសថខេត្តរតនៈគិរី

**រៀបរៀងដោយនិស្សិត ៖ ឃួន កញ្ញា**








# វល្លិ៍សំបុកស្រមោច ឬ វល្លិ៍បន្តុងភ្លោក

Nom Scientifique : ***Dischidia rafflesiana wall***

Famille : **ASCLEPIACLACEAE**

# វល្លិ៍សំបុកស្រមោច ឬ វល្លិ៍បន្តុំភ្នែក

Nom Scientifique : ***Dischidia rafflesiana wall***

Famille : **ASCLEPIACLACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទវល្លិ៍ធំៗ ។
  - **ស្លឹក** ៖ ស្លឹកពណ៌បៃតង មានរាងមូលក្រាស់ ។
  - **ផ្កាផ្លែ** ៖ មានរាងមូលទ្រវែង
+ **កន្លែងដាំដុះ** ៖ រស់ផ្ញើខ្លួននឹងគេ រុំព័ទ្ធជុំវិញដើម និងមែក ចូលចិត្តរស់នៅដើមឈើពុករលួយ ។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ។
+ **ផ្នែកប្រើប្រាស់** ៖ ជ័រ និង ផ្លែ ។
+ **ការប្រើប្រាស់** ៖ ប្រើប្រាស់សំរាប់ព្យាបាលរលាក, និងជំងឺរលាកជើងធ្មេញ ។
+ **ផលរំខានប្រើប្រាស់** ៖ មិនទាន់មានការស្រាវជ្រាវ។
+ **ឯកសារយោង** ៖ - http://m.aob.oxfordjournals.org/content/os-7/243.extract

**រៀបរៀងដោយនិស្សិត ៖ កែវ ដាវី**





# វល្លិ៍ធោមស្អឹកធំ

Nom Scientifique : ***Paederia foetida L.***

Famille : **RUBIACEAE**

# វល្លិ៍ធោមស្លឹកធំ

Nom Scientifique : *Paederia foetida L.*

Famille : **RUBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិប្រភេទវល្លិ៍ វារលើដីឬតោងឡើង។ ដើម និងស្លឹក កាលណាគេឈ្លី ភាក្លិនដូចធោម។
  - **ស្លឹក** ៖ ស្លឹករាងសំប៉ែតលំនាំផ្លែលំពែងស្រួចចុង មានទងខ្លី។
  - **ផ្កា** ៖ ផ្កាពណ៌ស្វាយ ស្រទាប់ផ្កាជាបំពង់ ឬក៏ផែកជាប្រាំខាងចុង ផ្កាជាកញ្ចុំ ទងខ្លី សមាសចេញពីប្រគាបស្លឹកឬចុងមែក។
  - **ផ្លែ** ៖ ផ្លែ រាងសំប៉ែតរុំម្ខាងដោយត្របកដែលមិនជ្រុះ មានសំបកក្រៅស្តើងក្រមៅរលោង មាន គ្រាប់ពីរសំប៉ែតក្រមៅមានស្លាបព័ទ្ធខាង។
+ **កន្លែងដាំដុះ** ៖ ជារុក្ខជាតិដុះដោយខ្លួនឯងលើដីទំនាប។ ផ្កាផ្លែនៅខែ៧-៩។
+ **សមាសធាតុគីមី** ៖ នៅក្នុងស្លឹកមានសារធាតុប្រេងហួត Volatil oil and Alkalide : $\alpha$-paederine and $\beta$-paederine ។
+ **ផ្នែកប្រើប្រាស់** ៖ គេប្រើរុក្ខជាតិទាំងមូល ប្រើនៅស្រស់ ប្រមូលផលបានគ្រប់រដូវ។
+ **ការប្រើប្រាស់** ៖
  - រុក្ខជាតិនេះគេនិយមប្រើព្យាបាលរាគមូល, គេយកស្លឹកវាស្រស់៣០-៥០ក្រ. ចិញ្ច្រាំឱ្យម៉ត់ កូរលាយពងមាន់ រួចចំអិនលើខ្ទះ(កុំដាក់ប្រេងខ្លាញ់) ឬមួយខ្ចប់ស្លឹកចេកដាក់អាំង, ប្រើ២-៣ដងក្នុងមួយថ្ងៃ, បន្តប្រើ៣-៤ថ្ងៃថែមទៀត។
  - ស្លឹកប្រើដាំផឹក សម្រាប់ព្យាបាលជម្ងឺមានគ្រាប់គ្រួសក្នុងតំរងនោម (Kidney Stone), នោមតឹង, ឈឺសន្លាក់ឆ្អឹង, ពិបាករំលាយអាហារ, រលាកក្រពះ និងរលាកពោះវៀន។
  - ប្រើស្លឹកបុកលាយបំពោកគួបផ្សំបន្ថែម :
    - ឈឺសន្លាក់ឆ្អឹង : លាបរុំ ឬត្រាំកន្លែងឈឺ
    - នោមតឹង, គ្រាប់គ្រួសក្នុងថ្លោកនោម : លាបបំពោកពោះម៉ុំក្រោមផ្ចិត។
+ **កំរិតប្រើប្រាស់** ៖ ប្រើក្នុងមួយថ្ងៃកម្រិត ១០-២០ក្រ.។
+ **ឯកសារយោង** ៖ សៀវភៅ ឱសថកម្ពុជា ភាគ៤ បោះពុម្ពឆ្នាំ២០១០។

**រៀបរៀងដោយនិស្សិត ៖ ផាង សុផារ័ដ្ឋ**





# វល្លិ៍ព្រះក្រុខស្លឹករលីខ

Nom Scientifique : ***Cyclea Barbat Mier***

Famille : **SYN. SYCLEAR PETATA AUCT NON (Lamk) Mook.f. & Thomson**

# វល្លិ៍ព្រះគ្រុឌស្លឹករលីង

Nom Scientifique : ***Cyclea Barbat Mier***

Famille : **SYN. SYCLEAR PETATA AUCT NON (Lamk) Mook.f. & Thomson**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាវល្លិ៍ដើមតូចឆ្មារ មានរោមតូចឆ្មារៗ (ពេលដើមនៅខ្ចី) តែពេលវាចាស់វាជ្រុះរោមអស់ វាតោងឡើងមានប្រវែងអាចដល់ ៨ម៉ែត្រ។
  - **ស្លឹក** ៖ នៅដុះឆ្លាស់ស្ទើរតែមូល ឬ សុតរីកខាងគល់ ទងស្លឹកចេញក្បែរគល់ស្លឹក ផ្ទៃកខាងលើរលីង ផ្ទៃកខាងក្រោមមានរោមតូចៗ ទ្រនុងស្លឹកដុះចេញពីពុនទងទៅកែមស្លឹក កាលណាច្របាច់ដាក់ទឹកទុកមួយសន្ទុះរឹងចាហួយ។
  - **ផ្កា** ៖ កញ្ចុងផ្កាចេញពីក្រោមស្លឹកមាន ២ ផ្សេងគ្នា ពណ៌បៃតង និង ពណ៌លឿង។
  - **ផ្លែ** ៖ ជាសាច់រាងមូលទុំពណ៌ទឹកក្រូច ឬ ពណ៌ក្រហម។
+ **កន្លែងដាំដុះ** ៖ ដុះតាមទីវាលទំនេរ ទីទួលព្រៃល្បាស់ នៃតំបន់ព្រៃភ្នំ
+ **ផ្នែកប្រើប្រាស់** ៖ ដើម ឫស មើម។
+ **សារធាតុគីមី** ៖ មាន Bisbenzylisoquinoline altraloid ដែលមាន Tetrandione Isotetrandrine , Limachine , Fangchinoline , Berbmine , Homoaromaline et cocclaurine.
+ **ការព្យាបាល** ៖ - ដើម ស្លឹក : ព្យាបាលពិស បញ្ចុះកំដៅ ជំនួយឈាមស្ត្រី។
  - ឫស រឺ មើម : បញ្ចុះនោម កាត់ស្លេស បាយបាន គ្រុនចាញ់ ក្អក ហើមទឹកឈឺពោះ រំលូតកូន អ៊ុតស្វាយ គ្រុន ឫសដូងបាត។
+ **កំរិតប្រើប្រាស់** ៖ ស្រស់ ៥០-១០០ក្រាម ដាំផឹក ក្នុង ១ថ្ងៃ

**រៀបរៀងដោយនិស្សិត ៖ ឈួន ឆាមសុវណ្ណារ៉ា**







# គ្រុំខរោម

Nom Scientifique : *Aporusa villosa*

Famille : **EUPHORBIACEAE**

# គ្រុខរោម

Nom Scientifique : *Aporusa villosa*

Famille : **EUPHORBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាឈើតូច មានកំពស់ ពី ៨- ១០ម ។មែកខ្ចីមានពណ៌លឿងត្នោតមានរោមខ្លីៗ ។
- **ស្លឹក** ៖ ស្លឹក ទោលដុះឆ្លាស់ទង រាងស៊ុតទូលាយ មានប្រវែង ១០ទៅ ១៦ ម ។ គែមស្លឹករាងជាទឹករលកតិចៗទ្រនុងស្លឹកមានរោម ផ្ទៃស្លឹកមានរោមពណ៌ត្នោតលឿង
- **ផ្កាផ្លែ** ៖ - ផ្កាខ្លីៗជាចង្កោមចេញពីប្រគាបស្លឹក ។
  - ផ្លែរាងស៊ុតទ្រវែង ស្រួយសងខាង ពណ៌ទឹកក្រូចមានរោមពណ៌ត្នោតលឿង ប្រវែង ២ស.ម ។
+ **កន្លែងដាំដុះ** ៖ មានឃើញដុះនៅលើដីសើមស្ទើរគ្រប់តំបន់ ដុះតាមព្រៃរបោះបន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ ។
+ **ផ្នែកប្រើប្រាស់** ៖ ស្លឹក សំបកដើម ឫស។
+ **ការប្រើប្រាស់** ៖ - ស្លឹកព្យាបាលជម្ងឺឃ្លង់។
  - សំបកដើមទំលាក់ឈាមរដូវបណ្តេញខ្យល់ក្នុងពោះវៀន ព្យាបាលចុកសៀត ព្យាបាលក្រពះ ចុកឆ្អល់ ។
  - ដើមព្យាបាលឈឺឆ្អឹងឆ្អែង ថ្នាំសសៃកូនខ្ចី។
  - ឫស ឬដើម ដុសជាមួយទឹក ផឹកដើម្បីបញ្ចុះកំដៅ។
+ **កំរិតប្រើប្រាស់** ៖ ស្ងួត ១៥ ទៅ ២០ក្រាម ដាំផឹក។
+ **ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជាភាគ៣ បោះពុម្ពឆ្នាំ ២០០៩។

**រៀបរៀងដោយនិស្សិត ៖ ហាក់ សុខធីតា**







## វល្លិ៍យាវ

Nom Scientifique : *Tiliacora triandra Diels*
*Cocculus thumbergii DC.*
*Limacia triandra Miers*

Famille : **MENISPERMACEAE**

# វល្លិយាវ

Nom Scientifique : ***Tiliacora triandra Diels***
***Cocculus thumbergii DC.***
***Limacia triandra Miers***

Famille : **MENISPERMACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាវល្លិឈើថាលូនតោងឡើងតាមដើមឈើផ្សេងៗ។
- **ស្លឹក** ៖ ស្លឹកទោលដុះឆ្លាស់ទង រាងជាផ្លែលំពែង ឬរាងជាពងក្រពើ ស្រួចចុងទទឹង ៣-៦ បណ្ដោយ ៥-១២ សម គែមស្លឹករាងជាទឹករលក។
- **ផ្កា** ៖ កញ្ចុំផ្កាចេញតាមប្រគាបស្លឹក ។ផ្កាតូចៗពណ៌បៃតងលាយលឿង។
- **ផ្លែ** ៖ មូលរាងពងក្រពើបន្តិច (ទំហំប៉ុនគ្រាប់សណ្ដែកដី) ជាចង្កោមពណ៌បៃតង ពេលទុំពណ៌ ក្រហម ឬពណ៌ទឹកក្រូច។

+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯង តាមព្រៃរបោះទូទៅ ។ នៅតំបន់វាលថ្មរំប្លង់ ហើយបន្តពូជដោយ គ្រាប់។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ។
+ **ផ្នែកប្រើប្រាស់** ៖ ស្លឹក វល្លិ ឬស។
+ **ការប្រើប្រាស់** ៖ - ស្លឹក : (រស សាបល្វីង): គ្រុនពោះវៀន, ពិស, ឈឺក្បាល, អុតស្វាយ
- វល្លិ : គ្រុនក្ដៅ, គ្រុនចាញ់
- ឬស: គ្រុនចាញ់, បន្សាបស្រវឹងស្រា, គ្រុនពោះវៀន, ឈឺក្បាល, គ្រុនសន្និ ជំនួយបេះដូង
+ **កំរិតប្រើប្រាស់** ៖ ថ្នាំដែលសំងួតប្រើពី ១០ក្រាម – ២០ក្រាម ក្នុងមួយថ្ងៃ។
+ **ឯកសារយោង** ៖ www.sciencedirect.com/science/article/pii/ *Thalictrum thunbergii DC. .... (Menispe rmaceae) Limacia oblonga Miers ... Diels (Menispermaceae) Cocculus trilobus DC. .... dinklagei Engl. (Menispermaceae)Tiliacora triandra Diels ...*

**រៀបរៀងដោយនិស្សិត ៖ រឹម សាទី**







# វល្លិ៍ឪឡ

Nom Scientifique : *Lygodium flexuosum (L.)S*

Famille : **EUPHORBIACEAE**

# វល្លិ៍ឱឡ

Nom Scientifique *: Lygodium flexuosum (L.)S*

Famille : **EUPHORBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិប្រភេទវល្លិ៍វាតោងឡើងវែង។
  - **ស្លឹក** ៖ ស្លឹកដុះចន្លោះពីគ្នា ១០សម គែមស្លឹកមានធ្មេញជ្រៅដូចគេជៀក មួយធាងមានស្លឹកតូច៣ ៤គូ ស្លឹកមានសភាពរឹងមិនលាតត្រង់។
  - **ផ្កាផ្លែ** ៖ ផ្កាស្ទើរគ្មានទងជាកញ្ចុំប្រវែង ២-១០មម នៅតាមធាងស្លឹក។
+ **កន្លែងដាំដុះ** ៖ ជារុក្ខជាតិដុះខ្លួនឯងតាមគុម្ពោត ក្រោមដើមឈើធំៗ។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ។
+ **ផ្នែកប្រើប្រាស់** ៖ គេប្រើរុក្ខជាតិទាំងមូល លាងអោយស្អាត ។ ពេលខ្លះគេប្រើស្រស់។
+ **ការប្រើប្រាស់** ៖ បុកស្លឹកស្រស់ជាមួយបាយកកបន្តិចដាក់ទឹកខ្មេះបន្តិច បិទព្យាបាលពិសចុងម្រាមដៃ ជើង មួយថ្ងៃប្តូរថ្នាំម្តង។
  គេប្រើរុក្ខជាតិនេះ ដាំផឹកព្យាបាលរលាកផ្លូវនោម និង ផ្លូវភេទបុរស ស្ត្រី ជំនួយអោយស្ត្រីបំបៅកូនមានទឹកដោះច្រើន។ រុក្ខជាតិស្រស់បុកលាបលើរមាសឡើងកណ្តាប់វាល herpes circine, មុករបូស, រលាត់ និង រលាកស្បែក។
+ **កំរិតប្រើប្រាស់** ៖ ដាំផឹកមួយថ្ងៃប្រើ ២- ១២ក្រាម។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជា ភាគ៤

**រៀបរៀងដោយនិស្សិត ៖ យ៉ូ ស័ង**






# វល្លិឪជុំតូច

Nom Scientifique : *Scindapsus officinails schott*

Famille : **ARACEA**

# វល្លិ៍ឪជុំតូច

Nom Scientifique : ***Scindapsus officinalis schott***

Famille : **ARACEA**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រប្រភេទវល្លិ ដែលមានថ្នាំងខ្លីៗមានទទឹងដើមពី១-១,៥ស.ម ។
  - **ស្លឹក** ៖ ស្លឹកស្តើងប្រវែងដល់ ២០ស.ម ទ្រនុងទទឹងមាន ២-៨គូ ទងស្លឹកសំប៉ែតរាងជាស្រទបប្រវែង១០-១៥ស.ម ហើយឆាប់រលេះ ។
  - **ផ្កា** ៖ ផ្ការាងមូលទ្រវែងស្រោបដោយគ្របកផ្កា (ខ្ចុរ) ពណ៌ស។
  - **ផ្លែ** ៖ ផ្លែរួមទងជាប់ៗគ្នាជុំវិញស្នូលមួយប្រវែងពី ៣-៥ ស.ម ។
+ **កន្លែងដាំដុះ** ៖ មានដុះដោយខ្លួនឯង ហើយវាតោងឡើងដើមឈើ ឬដើមត្នោតជួនកាលគេដាំសំរាប់លំអរ ។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ។
+ **ផ្នែកប្រើប្រាស់** ៖ ស្លឹក និង វល្លិ។
+ **ការប្រើប្រាស់** ៖ ស្លឹកបុកយកទឹកផឹក កាកបិទសំរាប់ព្យាបាលពស់ចឹក វល្លិដាំទឹកផឹកព្យាបាលហើមខ្លួន ។
+ **កំរិតប្រើប្រាស់** ៖ ២០-៣០ ក្រាមស្ងួតដាំទឹកផឹក ។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជា ភាគ៣ ឆ្នាំ២០០៩។

**រៀបរៀងដោយនិស្សិត ៖ រី សុវត្ថា**







# ខល្លីទាស់

**Nom Scientifique :** ***Dalbergia hancei Benth.***

**Famille :** **FABACEAE**

# ខល្លីធាស់

Nom Scientifique : ***Dalbergia hancei Benth.***

Famille : **FABACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទវល្លិ៍ឈើដែលមានប្រវែងរហូតដល់ ៣០ម៉ែត្រ ហើយមានមែក។

**-ស្លឹក** ៖ ជាស្លឹករួមស្លាបមាន៩-១៣កូនស្លឹក ហើយមានរាងដូចស៊ុតផតចុង មានប្រវែងពី ១០-១២មម គ្មានរោម មានខ្នាយស្នបឆាប់ជ្រុះ។

**-ផ្កា** ៖ ជាគួរចេញតាមប្រគាបស្លឹកប្រវែងពី២- ៥សម មានទងគ្របដណ្តប់ដោយរោមក្រាស់ពណ៌លឿងភ្លាវ ចេញផ្កានៅខែ១១។

**-ផ្លែ** ៖ មានប្រវែងពី៣- ៧សម និង ទទឹង១.២សម គ្មានរោម មានគ្រាប់ពី១- ៤។

+ **កន្លែងដាំដុះ** ៖ ដុះនៅតាមតំបន់ភ្នំ ជាយព្រៃ និងព្រៃរបោះ។

+ **សមាសធាតុគីមី** ៖ មានជាតិ**Tannins**ច្រើន

+ **ផ្នែកប្រើប្រាស់** ៖ ដើម ឫស ជ័រ។

+ **ការប្រើប្រាស់** ៖ - ដើម : ព្យាបាលឈឺក្រពះ ឈឺឆ្អឹងឆ្អែង រោគទាស់ស្ត្រីក្រោយឆ្លងទន្លេ

- ឫស : ព្យាបាលឆ្អឹងបាក់
- ជ័រ : ព្យាបាលឈឺពោះ

+**កំរិតប្រើប្រាស់** ៖ ស្ងួត១០- ១៥ក្រាមដាំទឹកផឹក។

+**ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ៣/រៀបរៀងដោយមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ បោះពុម្ពដោយថវិការជាតិ ឆ្នាំ២០០៩

**រៀបរៀងដោយនិស្សិត ៖ ម៉ៅ ស៊ីវលីញ**







## វល្លិ៍វាយ

Nom Scientifique : ***Salacis chinensis Linn.***

Famille : **CELASTRACEAE**

# វល្លិ៍វាយ

Nom Scientifique : ***Salacis chinensis Linn.***

Famille : **CELASTRACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទរុក្ខជាតិវល្លិ៍រស់បានយូរឆ្នាំ ខ្នាតធំ មែកតូច និងមានជ្រុងពណ៌ក្រហមព្រឿងៗរួចក្លាយជាក្រមៅ។ សាច់ឈើជាស្រទាប់ៗពណ៌ក្រហមត្នោត ផ្ទៃស្រគាំមានពី ៧ទៅ៩ ស្រទាប។

- **ស្លឹក** ៖ ដុះទល់ទងរាងពងក្រពើ ឬរាងពងក្រពើទ្រវែង គែមស្លឹកខ្លះមានធ្មេញរណា រាងទឹករលកផ្ទៃក្រោម រាងស្រអាប់ ទទឹង២ទៅ៤ស.ម បណ្ដោយ៤ទៅ៨ស.ម។
- **ផ្កា** ៖ កញ្ចុំផ្កាចេញតាមប្រគាបស្លឹក ឬចេញតាមបែកផ្កាតូចៗ ពណ៌លឿងភាវ ឬដូចពណ៌ពងមាន់ មាន៥ត្របក។
- **ផ្លែ** ៖ មូលមានសាច់ អន្ទិលៗ ពណ៌ក្រហមពេលទុំ។

+ **កន្លែងដាំដុះ** ៖ វាដុំនៅតាមព្រៃស្បាត ព្រៃល្បោះ ដីទួល និងព្រៃជំរាលជើងភ្នំ។
+ **ផ្នែកប្រើប្រាស់** ៖ វល្លិ៍ និងឫស។
+ **សមាសធាតុគីមី** ៖ ស្លឹក: triterpene(foliasalacins A(1)-A(4),B(1)-B(3),C)

  សំបកឫស: effet hépato-protectif

  ដើម: anti-hyperglycémie,វាជាinhibiteurs2-glucosidase et salacinol
+ **ការប្រើប្រាស់** ៖ - វល្លិ៍: ដាំផឹក ឬត្រាំស្រាបំប៉នឈាម ព្យាបាលតាមសន្លាក់ឆ្អឹង ឈឺសាច់ដុះ លាងទំលាក់រដូវ បន្ទន់លាមក ដើរខ្យល់។

  ឫស: ដាំ ឬ ត្រាំស្រាសំរាប់ទំលាក់រដូវ បំប៉នឈាម បំបាត់ពិសក្ដៅក្នុងឈាម។
+ **កំរិតប្រើប្រាស់** ៖ ១៥ទៅ៣០ក្រាម ក្នុង១ថ្ងៃ។
+ **ឯកសារយោង** ៖ - សៀវភៅរុក្ខជាតិឱសថកម្ពុជា ភាគ២ នៃមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណឆ្នាំ ១៩៩៧

  http://www.jpronline.inf
  http://commons.wikimedia.org/wiki/category:salacia-chinensis

**រៀបរៀងដោយនិស្សិត៖ ត្រាយ សុថានិត**







# វល្លិ៍សៅម៉ៅព្រៃ

Nom Scientifique : ***Aporusa villosa***

Famille : **EUPHORBIACEAE**

# ទល្លីសៅម៉ៅព្រៃ

Nom Scientifique : ***Passiflora foetida linn.***

Famille : **PASSIFLORACEAE**

**+ លក្ខណៈរុក្ខជាតិ** ៖ វាជាវល្លិ៍វារឡើងដើមឈើមានប្រវែងពី២ទៅ១០ម៉ែត្រ។

**- ស្លឹក** ៖ -ស្លឹកឆ្លាសឆកសន្លឹកជាបី មានរោមទន់ ដៃវាដុះចេញទន្ទឹមពេលចេញផ្កា ។
-ក្នុងពេលទុរ្ភិក្សស្លឹកនិងមែកខ្ចីៗស្ងោរលាយអង្ករធ្វើជាបបរ។

**- ផ្កាផ្លែ** ៖ វាមានផ្កាមិនធម្មតា ពណ៌ស លាយស្វាយ ជាផ្កាទោលចេញពីប្រគាបស្លឹក។
-ផ្លែរាងមូលពេលទុំមានពណ៌លឿងទុំស្រោបដោយផ្កាំងគ្របកបី ជាសរសៃឆ្មារៗ។
-គ្រាប់ខ្មៅមានច្រើនពេលទុំ រសជាតិជូរផ្អែមអាចបរិភោគបាន ជាពិសេសក្មេងៗ។

**+ កន្លែងដាំដុះ** ៖ -មានដុះនៅប្រទេសកម្ពុជា ជាវល្លិ៍ដុះដោយធម្មជាតិនៅតាមព្រៃគុម្ពោត ដីទំនេរមានពន្លឺគ្រប់គ្រាន់។

**+ សមាសធាតុគីមី** ៖ -ផ្លែនិងគ្រាប់មានជាតិម្យ៉ាងដែលងាយប្រែជា acide cyahydrique នឹងacétone។
-Flavonoids មានដូចជា Vitexin, Saponarin, Orientien, Homo-orientin, Sachaflosid និង Apigenin ។
-Akaloids មានដូចជា Harmane, Harmin, Harmaline, Harmol និង Harmalol ។

**+ ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល ស្លឹក និង ផ្លែ។

**+ ការប្រើប្រាស់** ៖ -ស្លឹកបុកម៉ត់ព្យាបាលរមាស់ស្អៀប។ជាថ្នាំបញ្ចុះ សម្អាតឈាម។
-ទឹកដែលពូតចេញពីស្លឹក និងវល្លិ៍ជំនួយស្ត្រីមានគភ៌បាន។
-សំរួលសរសៃប្រសាទ សណ្តំប្រឆាំងការចុកចាប់សាច់ដុំ។
- ផ្កាវាបានបង្ហាញឲ្យ ដឹងថាមានសកម្មភាពទៅលើប្រព័ន្ធសរសៃប្រសាទកណ្តាល (CNS) ដែលចុះខ្សោយផងដែរ ។

**+ កំរិតប្រើប្រាស់** ៖ ប្រចាំថ្ងៃ ១៥ ទៅ ២០ ក្រាម។

**+ ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជា ២០០៦។

**រៀបរៀងដោយនិស្សិត ៖ អឿ ស្រីលិះ**









# វល្លិ៍អាណោ,វល្លិ៍ខ្ទិណោ

Nom Scientifique : *Adenia parviflora (Blanco) Cusset*

Famille : **PASSIFLORACEAE**

# វល្លិ៍អាណោ,វល្លិ៍ខ្ញីណោ

Nom Scientifique : ***Adenia parviflora (Blanco) Cusset***

Famille : **PASSIFLORACEAE**

**+ លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទវល្លិ៍វែងរាប់សិបម៉ែត្រ មានវិជ្ឈមាត្រ១០ម.ម មានដៃតោង។

**- ស្លឹក** ៖ រាងពងក្រពើ ឬ ពងក្រពើភ្នែកចាប រាងបេះដូងខាងគល់ ចុងស្រួច ស្លឹកខ្លះឆែកជាបី ផ្នែកខាងចុងមានប្រវែង១២ស.ម មានទ្រនុងដូចជើងទា។

**- ផ្កាផ្លែ** ៖ -ផ្កាជាចង្កោម រាងដូចស៊ុតត្រឡប់។
-ផ្លែរាងដូចស៊ុត ប៉ុនស៊ុតមាន់ពណ៌លឿង ពេលទុំពណ៌ក្រហម។

**+ កន្លែងដាំដុះ** ៖ ដុះនៅតាមព្រៃរបោះ ដំបូក និង កម្ពូតព្រៃតូចៗ។

**+ សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ។

**+ ផ្នែកប្រើប្រាស់** ៖ ផ្នែកខាងគលរុក្ខជាតិ។

**+ ការប្រើប្រាស់** ៖ -រុក្ខជាតិនេះមានជាតិក្តៅតិចៗ គេយកមកប្រើក្នុងការព្យាបាលសួតដែលខ្សោយ ឈឺខ្នងផ្នែកបោះដៃជុត។
-គេយកបំពុលសត្វចាប់ ដោយគ្រាន់តែ យកស្រូវត្រាំជាមួយវល្លិ៍អាណោ ស្រូវនេះអាចបំពុលចាបអោយងាប់បានប៉ុន្តែសត្វចាបបរិភោគបានដោយគ្មានពុល។

**+ កំរិតប្រើប្រាស់** ៖ ប្រើពី១៥-២០ក្រាមស្លឹកស្រស់។

**+ ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថបុរាណ នៃមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ បោះពុម្ពឆ្នាំ២០១០។

**រៀបរៀងដោយនិស្សិត ៖ ម៉ៅ វីណា**







## ដើម សម៉ ឬ ស្រម៉

Nom Scientifique : ***Terminalia chebula Rezt***

Famille : **COMBRETACEAE**

# ដើម សម៉ ឬ ស្រម៉

Nom Scientifique : *Terminalia chebula Retz*

Famille : **COMBRETACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាដើមឈើមានកំពស់ពី ១០-២០m សំបកប្រផេះ ប្រេះក្រហែងបណ្តោយ។
 - **ស្លឹក** ៖ ស្លឹកទោលដុះទល់ទង មានទងខ្លី ស្លឹករាងពងក្រពើ ស្រួចចុងបណ្តោយពី ១៥-២០cm ទទឹងពី ៩-១៥cm ស្លឹកស្ងិតមានរោមទន់។
 - **ផ្កា** ៖ តូចៗជាចង្កោមពណ៌លឿងខ្ចី ចេញនៅប្រគាបស្លឹក ខាងចុងមែក។
 - **ផ្លែ** ៖ ផ្លែមូលរាងពងក្រពើ មានទ្រនុង៥ជាចង្កោមពណ៌បៃតង-លឿងមានគ្រាប់១។
+ **កន្លែងដាំដុះ** ៖ ដុះតាមតំបន់ភ្នំ ខ្ពង់រាប ព្រៃរបោះ។ បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ ក្នុងផ្លែមាន triterpenoid glycosides ដូចជា chebulosides I និង II, argunin, arjungluoside, tannins chebulic acide, ellagie និង gallic acide។ Punicalinde, terflavin A, B, C, D, maslinic acide, anthraquinones និង ជាតិប្រេង។
+ **ផ្នែកប្រើប្រាស់** ៖ ផ្កា ផ្លែ សំបក ដើម។
+ **ការប្រើប្រាស់** ៖ - ផ្លែ: បន្ទន់លាមក, រំលាយអាហារ, ជំងឺថង់ប្រមាត់, រាគរាំរ៉ៃ, រាគមានឈាម, មូល, ឬសដូងបាត, ព្រូនក្នុងពោះវៀន, ក្អករាំរ៉ៃ, ឈឺបំពង់ក, ធ្លាក់ឈាមតាមស្បូន, រលាកស្បូន, ហូរទឹកកាមដោយខ្លួនឯង, ដំបៅមាត់, ស្ងោរលាងរបួសដំបៅ។
 - ផ្កា: ដាំផឹកព្យាបាលរាគមូល។
 - សំបកដើម: ដាំផឹកជំនួយបេះដូង, បញ្ចុះទឹកនោម។
+ **កំរិតប្រើប្រាស់** ៖ ៤-៦ក្រាម ដាំទឹកផឹកក្នុង១ថ្ងៃ, ប្រើកំរិតខ្ពស់ជាថ្នាំបញ្ចុះ។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជា ក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ បោះពុម្ពដោយថវិកាជាតិ ឆ្នាំ២០០៨ ភាគ២

**រៀបរៀងដោយនិស្សិត ៖ ហួរ ណារី**







# សន្ទូចតូច, ជូរព្រឹក

Nom Scientifique : ***Embelia ribes burm. f.***

Famille : **MYRSINACEAE**

# ដើមសន្ទចតូច, ជូរព្រឹក

Nom Scientifique : *Embelia ribes Burm. f.*
Famille : **MYRSINACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទចុល្លព្រឹក្សស្ទើរវល្លិ៍ កំពស់៣-៥ម មានដើមពណ៌ស្វាយឬក្រហម មែកសាខាឬវារលើរុក្ខជាតិជិតខាងក្នុងព្រៃនៃទ្វីបអាស៊ីក្តៅ
- **ស្លឹក** ៖ ស្លឹកពណ៌បៃតងរាងស្រួចចុង ទងពី ១០-១៥មម ស្លឹកនិងត្រួយមានរស់ជូរ
- **ផ្កាផ្លែ** ៖ ផ្កាជាកញ្ចុំមានច្រើនត្របក ត្របកផ្កាខាងក្នុង និងខាងក្រៅមានរោមពណ៌សរ ផ្លែទុំមានរសផ្អែម ជូរហើយអាចញ៉ាំបាន
+ **កន្លែងដាំដុះ** ៖ ដុះតាមភ្នំ ជុំវាលភ្នំ កំពោតព្រៃ ព្រៃរបោះ តាមជាយព្រៃ រឺតាមដំបូកជាដើម
+ **សមាសធាតុគីមី** ៖ 2,5-dihydroxy-3-udecyl, 1,4-benzoquinone
+ **ផ្នែកប្រើប្រាស់** ៖ ផ្លែ គ្រាប់ ស្លឹក សំបកដើម ឬស
+ **ការប្រើប្រាស់** ៖ ប្រើជាថ្នាំទំលាក់ព្រូន រាក រាកមូល ជំនួយកំលាំង ជួយអោយសុខភាពមានលំនឹង
ប្រឆាំងនឹងការករកើតនៃបាក់តេរី ប្រឆាំងនឹងការមានកូន ពន្យារកំណើត គ្រុនក្តៅ
ប្រឆាំងនឹងការរលាកខាងក្នុង បំបាត់ការឈឺចាប់ និងចេញកន្ទួលលើស្បែក
+ **កំរិតប្រើប្រាស់** ៖ ប្រើឬស ១៥-៣០g, ផ្លែ ១០-១៥g
+ **ឯកសារយោង** ៖ ដកចេញពីសៀវភៅ: PROSEA, CHINESE MEDICINAL HERBS OF HONG KONG, DY PHON PAULINE -2000

**រៀបរៀងដោយនិស្សិត ៖ ឧុយ រដ្ឋា**







# សខ្យ៉ រ

Nom Scientifique : ***Zizyphus oenoplia Mill***

Famille : **RHAMNCEAE**

# សង្ស័រ

Nom Scientifique : *Zizyphus oenoplia Mill*

Famille : **RHAMNCEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើដែលសំបូរដោយបន្លាស្រួចតូចៗ កោងខុបតាមដើម និងមែក មានកំពស់ពី ២-៦ម៉ែត្រ។ ផ្លែអាចបរិភោគបាន។
  - **ស្លឹក** ៖ រាងពងក្រពើស្រួចចុងបន្តិច មានទ្រនុង៣ ស្របតាមបណ្ដោយស្លឹក តែមស្លឹកពេញ មានរោមខ្លីទន់ល្មើយ ពណ៌បៃតងរលោង ខាងក្រោមស្លឹកមានពណ៌ស្លេកជាងខាងលើ ដុះឆ្លាស់ទងគ្នាជា២ជួររៀបរយ។
  - **ផ្កាផ្លែ** ៖ ផ្កា:ពណ៌បៃតងភាររាងមូលល្អិតៗ ទំហំ២-៤មម ជាចង្កោមចេញតាមប្រគាបស្លឹក។
    ផ្លែ:ផ្លែរាមូល មានសាច់ច្រើនទំហំវិជ្ជមាត្រ ១សម ពេលខ្ចីពណ៌បៃតង ពេលទុំពណ៌ខ្មៅរលោង។
+ **កន្លែងដាំដុះ** ៖ ដុះនៅក្នុងព្រៃរបោះ វាលទំនាប និងតំបន់ភ្នំទាបៗ ពាសពេញកម្ពុជា។
+ **សមាសធាតុគីមី** ៖ គ្មាន។
+ **ផ្នែកប្រើប្រាស់** ៖ ឫស សំបក ផ្លែ ស្លឹក គ្រាប់ ។
+ **ការប្រើប្រាស់** ៖ - ឫស សំបក: សំរាប់ព្យាបាល ដាំផឹក បញ្ចុះទឹកនោម ប្ញសក្នុងស្បូន និងទឹកនោមផ្អែម ធ្លាក់ស។
  - ផ្លែ: ព្យាបាលស្លេស្ម៍ ក្អក ធ្វើអោយសើមបំពង់ក។
  - គ្រាប់: ធ្វើជាថ្នាំបំបាត់ក្អួត ដេកលក់ រាកមូល រាលអាចម៍។
  - ស្លឹក: ដាំផឹក ធ្វើអោយផ្សះ។
  - សំបកឫស: ធ្វើអោយផ្សះរបួស និងក្រពះ។
+ **កំរិតប្រើប្រាស់** ៖ ៣ទៅ៥០ក្រាមក្នុងមួយថ្ងៃ។
+ **ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជាភាគ២។

**រៀបរៀងដោយនិស្សិត ៖ សៅ សុឃានីត**







# ដើមសម្លុងតូច

Nom Scientifique : ***Embelia ribes (Burm.f)***

Famille : **MYRSINACEAE**

# ដើមសម្លុងតូច

Nom Scientifique : ***Embelia ribes (Burm.f)***

Famille : **MYRSINACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាចុល្លព្រឹក្ស ស្ទើរវល្លិ បើដុះតែឯងមានកំពស់ ២-៣ម បើដុះតោងជាមួយគេ មានប្រវែងរហូតដល់ទៅ ២០ម។
- **ស្លឹក** ៖ ស្លឹកទោលដុះឆ្លាស់ទង រាងជាផ្លែលំពែង ផ្ទៃរលោងក្រាស់ស្រួយ។
- **ផ្កាផ្លែ** ៖ - កញ្ចុំផ្កាជាចង្កោមកួរ ចេញនៅចុងមែក ផ្កាតូចៗ ពណ៌លឿង ស។
  - ផ្លែសាច់រាងមូល ចេញជាចង្កោម ពេលទុំពណ៌រាងក្រហម-ក្រម៉ៅ។
+ **កន្លែងដាំដុះ** ៖ មានដុះដោយខ្លួនឯងតាមព្រៃ ព្រៃល្បោះ ជើងភ្នំ បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ នៅក្នុងផ្លែមាន Tannin, Anthiaquinon, ប្រេង និង Embelic acid 2-3% និងមាន Alkaloid ឈ្មោះ christembin, Resinoid ក្នុងស្លឹកមាន Caroten nig vitamin C។
+ **ផ្នែកប្រើប្រាស់** ៖ ស្លឹក ផ្លែ ឫស ដើម។
+ **ការប្រើប្រាស់** ៖ - ស្លឹក : រសជូរ ស្លឹកខ្ចីព្យាបាលពស់ចឹក។
  - ផ្លែ : ទំលាក់ព្រូន ព្យាបាលផ្សិតសើស្បែក។
  - ដើម: បំបាត់ការឈឺចាប់ស្បូនក្រោយឆ្លងទន្លេ ទំលាក់ឈាម។
  - ឫស: ព្យាបាល ក្អក រាក ផ្សះដំបៅ។
+ **គំរិតប្រើប្រាស់** ៖ ដើម ឫសស្ងួត ១០-២០ក្រាមដាំទឹកផឹក។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជា មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្រ្តបូរាណ បោះពុម្ពដោយថវិការជាតិឆ្នាំ ២០០៩។

**រៀបរៀងដោយនិស្សិត ៖ សៀង ចាន់ណា**








# ស្ដៅ

Nom Scientifique : *Azadirachta Indica A. Juss*

Famille : **MELIACEAE**

# ស្ដៅ

Nom Scientifique : ***Azadirachta Indica A. Juss***

Famille : **MELIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាដើមឈើដែលមានកំពស់ 10 – 15 m
  - **ស្លឹក** ៖ ស្លឹករួមស្លាបសេស ដុះឆ្លាស់រាងលំពែងទ្រវែងមានពី 6 – 15 គូ គែមមានធ្មេញរណារ ។
  - **ផ្កា** ៖ ក្រអូបពណ៌ស ប្រវែងពី 5 – 6 mm ចេញពីប្រគាបស្លឹកនៅចុងមែកផ្កាខ្លីជាងធាងស្លែក ។
  - **ផ្លែ** ៖ មូលទ្រវែង ២ cm មានសំបករឹង និងគ្រាប់មួយ សាច់ផ្លែពេលទុំពណ៌ខ្មៅ ។
+ **កន្លែងដាំដុះ** ៖ គេដាំតាមភូមិ និងដុះដោយខ្លួនឯងតាមទំនាប, ខ្ពង់រាប, ដីទំនេរ ។ បន្តពូជដោយគ្រាប់ ។
+ **សមាសធាតុគីមី** ៖ ជាតិប្រេងល្វីង និង acid margosic ។គ្រាប់មាន 4,5% ប្រេងល្វីង ឈ្មោះ Nimbin, Nimbinin, Nimbidin ។
+ **ផ្នែកប្រើប្រាស់** ៖ សំបកដើម, សំបកឫស, ផ្លែ, ផ្កា, គ្រាប់, ជរ័, ស្លឹក ។
+ **ការប្រើប្រាស់** ៖ សំបកដើម: ព្យាបាលគ្រុនចាញ់ ស្បែកលឿង, គ្រុន, ថ្លើម, លាងរបួស សំបកឫស: ព្យាបាលគ្រុនចាញ់ (តែសំបកដើមមានប្រសិទ្ធភាពជាងសំបកឫស) សំបកឫស និង ផ្លែខ្ចី ជាថ្នាំប៉ូវបញ្ចុះកំដៅ ។ ស្លឹក: បុកបំពោក សម្រកហើម, កើតពិស, បូសតាអក យកស្លឹកដាំទឹកលាងអោយសះ ។ ផ្លែ: ជាថ្នាំបញ្ចុះ និង ទំលាក់ព្រូន ។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជា ភាគ១

**រៀបរៀងដោយនិស្សិត ៖ សោ ដាលីន**





# ដើមស្នាយ

Nom Scientifique : ***Streblus asper Lour,***

Famille : **MORACEAE**

# ដើមស្នាយ

Nom Scientifique : ***Streblus asper Lour,***

Famille : **MORACEAE**

+**លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើតូច មានកំពស់ ២ ទៅ ៨ ម៉ែត្រ ។សំបកដើមពណ៌ប្រផេះភ្លឺ ឬ ត្នោតប្រផេះ មានជ័រពណ៌ស ។

- **ស្លឹក** ៖ មានរាងស៊ុតទ្រវែង គគ្រើម គេចូលចិត្តយកទៅ ដុះធ្មេញ ឬ ខាត់ សំភារៈតុ ទូ ។

- **ផ្កាផ្លែ** ៖ -ផ្ការាងល្អិតតូច ពណ៌សរាងលឿងតិចៗ ផែកស្រួចទៅខាង(២ទៅ៤) -ផ្លែរាងស៊ុតប៉ុនចង្កឹះ មានគ្រាប់តែមួយពេលទុំមានពណ៌ទឹកក្រូច មានរសផ្អែម អាចហូបបាន ។

+ **កន្លែងដាំដុះ** ៖ ដុះនៅតាមភ្លឺស្រែ ព្រៃរបោះ ទីទួលនានា(តំបន់ត្រូពិច) ។

+ **សមាសធាតុគីមី** ៖ Phenolic glycosides

+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល (សំបក និង ឬស) ។

+ **ការប្រើប្រាស់** ៖ - **រុក្ខជាតិទាំងមូល:** ស្ងោរ ផឹក សំរាប់ព្យាបាលជំងឺរាគ និង រាគមូល ។

-**ឬស:** ឆុង ឬ យកទៅស្ងោរផឹក សំរាប់ព្យាបាលក្អក របេង ដំបៅ បូស ពិស និង ហើម ។

-**ស្លឹក និងផ្លែ:** មានប្រសិទ្ធភាពទៅលើជំងឺភ្នែក ។

-**មែកនិងស្លឹក:** យកឆ្អើរភ្លើង ស្ងោរ ឬ ឆុងផឹក អោយចេញទឹកដោះ (កូនខ្ចី) ព្យាបាលរោគទាជទឹក និង ធ្វើជាថ្នាំបៀម ខ្ពុលមាត់ ព្យាបាលរោគបំពង់ក ហើយអាចប្រើជាថ្នាំព្យាបាលជំងឺគ្រុនចាញ់ ប្រឆាំង វីរុស និងប្រឆាំងមហារីកផងដែរ ។

-**សំបកដើម:** យកទៅដាំរងាស់ឲ្យខាប់យកទៅបៀមព្យាបាលធ្មេញរង្គើ។

+ **កំរិតប្រើប្រាស់** ៖ 15-30g

+ **ឯកសារយោង** ៖ -Http: //www.fruitipedia.com/siamese_rough_brus%20. streblus%20 asper.htm
-en witipedia.org/wiki/streblus_asper.

**រៀបរៀងដោយនិស្សិត ៖ នាង ស្រីណែត**







# ដើមស្លាយដែល,ក្រាយដែល,ស្មេហ៍ដែល,ដំរីឆ្នើល

Nom Scientifique : ***Polyalthia cerasoides (Roxb.) Benth.***

Famille : **ANNONACEAE**

# ដើមស្លាយដែល,ក្រាយដែល,ស្មេហ៍ដែល,ដំរីឆ្អើល

Nom Scientifique : ***Polyalthia cerasoides (Roxb.) Benth.***

Famille : **ANNONACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិដែលមានកំពស់ពី ៦ ដល់ ១០ម ឬ អាចដល់ ២៥ម ដុះត្រង់ខ្ពស់។
- **ស្លឹក** ៖ មានរាងជាផ្លែលំពែង ទ្រវែង ខាលលើរលីង ខាងក្រោមមានរោមគែមស្លឹករលោង ដុះឆ្លាស់ទងគ្នាជាពីរជួរ សងខាងបែកមែកតូច ៗ ។
- **ផ្លែ** ៖ រាងមូលមានទងជាចង្កោម ក្នុងមួយផ្លែមានគ្រាប់មួយរលោង ។

+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯង នៅតាមតំបន់ភ្នំទាបៗ និងព្រៃរបោះ ។

+ **សមាសធាតុគីមី** ៖ គ្រាប់មាន Phytostetrols និង Clerodanedi-terpenoid. ឬសមាន Dimeric aporphine alkaloid , Sesquiterpenes និង Isoquinoline alkaloids ។

+ **ផ្នែកប្រើប្រាស់** ៖ ឬស ដើម និង ស្លឹក ។

+ **ការប្រើប្រាស់** ៖ -ឬសដាំផឹក ជាភេសជ្ជៈនិងផ្សំជាមួយថ្នាំផ្សេងទៀតព្យាបាលជំងឺចាំងថ្ងៃ។
-ដើមដាំផឹកព្យាបាលរបេងសួត ចុករោយតាមរាងកាយ ឈឺខ្នងចង្កេះ សំរួលផ្លូវនោម ជំនួយសុខភាព បាយបានដុះជាមួយទឹកកំបោរលាបរបួស។
-ស្លឹក បុកពពោក បូស រលាក ។

+ **កំរិតប្រើប្រាស់** ៖ ស្ងួតដាំផឹកពី ២០ ទៅ ៣០ ក្រាមក្នុងមួយថ្ងៃ ។

+ **ឯកសារយោង** ៖ -រុក្ខជាតិឱសថកម្ពុជាភាគ២ រៀបរាង និង ចងក្រងដោយគណកម្មការស្រាវជ្រាវនៃមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណនៅឆ្នាំ ២០០៨ ។ ក
-http://www.thefreelibrary.com/Antiproliferative%2c+apoptotic

**រៀបរៀងដោយនិស្សិត ៖ អោក មួយឡេង**







# ស្លាយបន្លាត្រូច

Nom Scientifique : ***Streblus ilicifolius(Vidol) Corner***

***Syn: Taxotrophis ilicifolius Vidol***

Famille : **MORACEAE**

# ស្វាយបន្លាក្រូច

Nom Scientifique : ***Streblus ilicifolius(Vidol) Corner***

***Syn: Taxotrophis ilicifolius Vidol***

Famille : **MORACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិឈើតូចដុះជាគុម្ព មានបន្លារលោងវែង រហូតដល់ ២៤ មម ។
  - **ស្លឹក** ៖ ស្លឹកទោលរាងលំពែង ប្រវែង ៣-១០ សម ទទឹង ២-៤ សម ស្រួចចុងស្និត ផ្ទៃខាងលើរលោង គែមស្លឹកមានធ្មេញរណា មុតស្រួចដូចបន្លា ។
  - **ផ្កា** ៖ ផ្កាចេញពីប្រគាបស្លឹក មានចំនួនច្រើន ផ្កាញីមាន ១-៣ ផ្កាឈ្មោលមានច្រើន ផ្កាពណ៌លឿងមានឆ្នូតពណ៌កាហ្វេ។
  - **ផ្លែ** ៖ ផ្លែតូចៗរាងមូល។
+ **កន្លែងដាំដុះ** ៖ ច្រើនមានដុះនៅតំបន់ភ្នំ ពិសេសខេត្តរតនគិរី និងមណ្ឌលគីរី។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយ។
+ **ផ្នែកប្រើប្រាស់** ៖ គេប្រើសំបកដើម។
+ **ការប្រើប្រាស់** ៖ សំបកដើមគេស្ងោរហូបព្យាបាលរមាស់។
+ **កំរិតប្រើប្រាស់** ៖ សំបកដើម ១០-២០ ក្រាម។
+ **ឯកសារយោង** ៖

http://www.wikipedia.org/wiki/streblusilicifolius(Vidol)Corner
http://www.efloras.org
http://www.eol.org
http://theplantlist.org
http://tropicos.org/streblusilicifolius(vidol)corner
http://ipni.org

រៀបរៀងដោយនិស្សិត ៖ យក់ សម្ផាសន៍






## ស្វាយញ្ញាត

Nom Scientifique : ***Streblus ilicifolius***

Famille : **MORACEAE**

# ស្លាយញាត

Nom Scientifique : *Streblus ilicifolius*

Famille : **MORACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិតូចដុះជាគុម្ព មានបន្លារលោងវែងរហូតដល់ ២៤ ម.ម ។

- **ស្លឹក** ៖ ស្លឹកទោល រាងសំពែង ប្រវែង ៣-១០ ស.ម ។

- **ផ្កាផ្លែ** ៖ ផ្កាចេញពីប្រគាបស្លឹក មានចំនួនច្រើន ផ្កាញីមាន ១-៣ ផ្កាឈ្មោល មានច្រើន ផ្កាពណ៌លឿងមានឆ្នូតពណ៌កាហ្វេ ។ ផ្លែតូចៗរាងមូល ។

+ **កន្លែងដាំដុះ** ៖ ច្រើនមានដុះនៅតាមតំបន់ភ្នំ ពិសេសខេត្តរតនគីរី និងមណ្ឌលគីរី ។

+ **សមាសធាតុគីមី** ៖ មិនមានការស្រាវជ្រាវឡើយ ។

+ **ផ្នែកប្រើប្រាស់** ៖ គេប្រើសំបក ។

+ **ការប្រើប្រាស់** ៖
- សំបកដើមស្ងោរហូបព្យាបាលរមាស់ ។
- គេអាចដាំទឹកប្រើជាថ្នាំលាងពីលើកមរមាស់ធនាប់ជា ។
- ម្សៅសំបកដើមលាប ឬជូតជើងធ្មេញ ព្យាបាលឈឺធ្មេញ ។

+ **កំរិតប្រើប្រាស់** ៖ សំបកដើម ១០-២០ ក្រ ។

+ **ឯកសារយោង** ៖ សៀវភៅគណកម្មការស្រាវជ្រាវ នៃមជ្ឈមណ្ឌលជាតិស្រាវជ្រាវ វេជ្ជសាស្ត្របុរាណឆ្នាំ២០០៤ ។

**រៀបរៀងដោយនិស្សិត ៖ ទ៉ាន់ សុលីណា**









# ដើមស្នាក្របី

Nom Scientifique : ***Knema Globularia Warb,***

Famille : **MYRISTICACEAE**

# ដើមស្នាក្របី

Nom Scientifique : ***Knema Globularia Warb***

Famille : **MYRISTICACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាឈើតូចមានកំពស់ពី១០-១២ម។ មែកខ្ចីគ្របដណ្តប់ដោយរោមពណ៌ក្រហមត្នោត មែកចាស់រលីង។
  - **ស្លឹក** ៖ ស្លឹកទោលដុះឆ្លាស់ទង បន្ទះស្លឹករាងជាផ្លែលំពែងមានប្រវែង១០-១៧ស.ម ទទឹង៣-៥ស.ម ទ្រនុងច្បាស់ៗ។
  - **ផ្កា** ៖ ផ្កាកញ្ចុំចេញតាមប្រគាបស្លឹក ផ្កាតូចៗមានរោមពណ៌លឿងត្នោត។
  - **ផ្លែ** ៖ ផ្លែជាចង្កោមៗផ្លែនីមួយៗរាងដូចស៊ុត ពេលទុំរលោងប្រះបែកជាពីរ សាច់ពណ៌ក្រហមរុំគ្រាប់។
+ **កន្លែងដាំដុះ** ៖ ដុះតាមព្រៃភ្នំ ព្រៃរបោះ ជាយព្រៃ បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ ក្នុងគ្រាប់មានជាតិប្រេងដែលក្នុងនោះមានសមាសធាតុ invectaga , amylaza និងphotphataza។មានជាតិ Kneglomeratanol និង Kneglomeratanones(A,B)។
+ **ផ្នែកប្រើប្រាស់** ៖ គ្រាប់
+ **ការប្រើប្រាស់** ៖ ជំងឺសើស្បែកដូចជា; តាអក ,ស្រែង, កមរមាស់ យកគ្រាប់ស្នាក្របីលីងរួចបុកពូតយកប្រេងលាបឬផ្សំលាយជាមួយថ្នាំផ្សេងទៀត លាយប្រេងដូងលាប។
+ **កំរិតប្រើប្រាស់** ៖ ប្រើខាងក្រៅតាមចំនួនសមល្មម។
+ **ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជាភាគ៣ បោះពុម្ពដោយក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ ២០០៩. Medicinals Plants of Cambodia.

**រៀបរៀងដោយនិស្សិត ៖ ឃៀង គីមហុង**







# ស្វាយព្រៃ

Nom Scientifique*:* ***Mangifera du perreana Pierre***

*Famille :* ***Anacardiaceae***

# ស្វាយព្រៃ

Nom Scientifique : ***Mangifera du perreana Pierre***

*Famille :* ***Anacardiaceae***

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិដើមធំដែលមានកំពស់ពី ១០ទៅ២០ម៉ែត្រ

- **ស្លឹក** ៖ មែកតូចៗរបស់វាមានប្រវែងវែងហើយផ្លែដុះជាចង្កោមដែលមានផ្លែមួយមានគ្រាប់មួយនិងស្លឹកខ្ចីត្រួយពណ៌ស្វាយគេអាចបរិភោគបានជាពិសេសគេសំរាប់ស្ងោរជ្រក់ និងជាអន្លក់។
- **ផ្កាផ្លែ** ៖ ផ្លែទុំពណ៌ក្រហមស្វាយតូចៗ គេចូលចិត្តបរិភោគដោយវាមានរសជាតិជូរអែមចំនែកផ្លែខ្ចីមានរសជាតិជូរខ្លាំង។

+ **កន្លែងដាំដុះ** ៖ ជារុក្ខជាតិដែលមានដុះច្រើនក្នុងភូមិនិងព្រៃពាសពេញប្រទេសខ្មែរ។
+ **សមាសធាតុគីមី** ៖ សំបកដើមមានជាតិ phenolic compounds, tannis,និង phenolic acide មានក្នុងសាច់គ្រាប់
+ **ផ្នែកប្រើប្រាស់** ៖ សំបកដើម
+ **ការប្រើប្រាស់** ៖ សំរាប់ព្យាបាលជំងឺរលាកបំពង់កជំងឺស្វាយនិងរលាកផ្លូវនោម
+ **កំរិតប្រើប្រាស់** ៖ ពុំទាន់បានស្រាវជ្រាវ
+ **ឯកសារយោង** ៖ ដកស្រង់ចេញពីសៀវភៅរុក្ខជាតិឱសថកម្ពុជាឆ្នាំ ២០០៤
http://wildlifeofhawaii.com/flowers/1199/mangifera-indica-mango/

**រៀបរៀងដោយនិស្សិត ៖ សេង ដារីការ**







# ដើមស្វាយចន្ទី

Nom Scientifique : *Anacardium Occidental Linn,*

Famille : **ANACARDLACEA**

# ដើមស្វាយចន្ទី

Nom Scientifique *: Anacardium Occidental Linn,*

Famille : **ANACARDLACEA**

+ **លក្ខណៈរុក្ខជាតិ** ៖ ចុល្លព្រឹកបែកមែកមកច្រើន សំបកពណ៌ប្រផេះមានកំពស់ពី ៥ – ១០ ម។
  - **ស្លឹក** ៖ ស្លឹកទោលធំ រាងស៊ុតត្រឡប់ពណ៌បៃតងចាស់មានទទឹង ៨ – ១០ សម បណ្តោយ ១៦ – ២០ សម។ ផ្តុំនៅចុងមែក។
  - **ផ្កា** ៖ ផ្កានៅចុងមែកជាកួរវែងមានផ្កាតូចពណ៌ស មានក្លិនក្រអូប។
  - **ផ្លែ** ៖ ផ្លែរាងដូចជូង ឬ ដូចផ្លែជម្ពូ ផ្លែសាច់សំបូរទឹក ។ មានគ្រាប់រាងដូចគ្រាប់សណ្តែកធំមួយដុះជាប់នៅខាងចុងផ្លែ ។ ក្នុងគ្រាប់មានជាតិប្រេង ។
+ **កន្លែងដាំដុះ** ៖ គេអាចដាំដុះបានស្ទើរគ្រប់ទីកន្លែង ។ បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ +ស្លឹកមាន flavonoides ដែលសំខាន់ជាងគេក្នុងនោះមាន Glycosides of quercetin, Kaempferal, and hydroxybezoie acid.
  + សំបកមានanacardic acid, anacardol cadol and ginkol.
  + សំបក គ្រាប់មាន ៣៩% anacardic acid លាយជាមួយ Alhyl Salicylic acid.
+ **ផ្នែកប្រើប្រាស់** ៖ គ្រាប់, ជ័រ, សំបក, ដើម, ស្លឹក ។
+ **ការព្យាបាល** ៖ +គ្រាប់កំឡោចលាយប្រេង ជាថ្នាំព្យាបាល ស្រែង ភ្លី រោគសើរស្បែក
  + សំបក , ស្លឹក ឆុង ឬ ស្ងោរបៀប ព្យាបាល ឈឺធ្មេញ ហើមអញ្ចាញធ្មេញ ។
  + ស្លឹកចាស់ ស្ងួតឆុង ឬ ដាំទឹកព្យាបាល ជំងឺលើសឈាមនិងជំងឺទឹកនោមផ្អែម
+ **ឯកសារយោង** ៖ ដកស្រង់ពីសៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ៤ដោយមជ្ឈមណ្ឌលស្រាវជ្រាវវេជ្ជសាស្ត្របូរាណ ២០១០។

**រៀបរៀងដោយនិស្សិត ៖ តុល សុគន្ធូខ**



# ស្លែងប្រទៀក–ពោខាក់–ប្រខែក

Nom Scientifique : *Strychnosnux-blandaA.W.Hill.*

Famille : **STRYCHNACEAE (LOGANIACEAE)**

# ស្លែងប្រទៀក–ពោធាក់–ប្រវែក

Nom Scientifique : ***Strychnosnux-blandaA.W.Hill.***

Famille : **STRYCHNACEAE (LOGANIACEAE)**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាព្រឹក្សមានកំពស់រហូតដល់ ២៥ ម៉ែត្រ ។
  - **ស្លឹក** ៖ ស្លឹកទោល ទល់ទង រាងពងក្រពើធំ ទំហំ ១០–១៤ សម ទទឹង ៨–១០ សម ។
  - **ផ្កាផ្លែ** ៖ កញ្ចុំផ្កាចេញនៅចុងមែក ជាចង្កោម ផ្កាជាបំពង់រីកចុង ពណ៌បៃតងលឿង ។ ផ្លែមូល មានសាច់ច្រើន ពេលទុំពណ៌លឿង គ្រាប់សំប៉ែតមានច្រើន
+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯងនៅតំបន់ភ្នំ ។
+ **សមាសធាតុគីមី** ៖ សមាសធាតុគីមីបានមកពីអាល់កាលូអ៊ីតដែលមាននៅក្នុង ស្លឹក និងគ្រាប់ ។

  -គ្រាប់ ៖strychnine, brucine, strychnine N-oxide, brucine N-oxide

  ស្លឹក ៖ icajine, vomicine, novacine
+ **ផ្នែកប្រើប្រាស់** ៖ ស្លឹក សំបក ដើម ខ្លឹម និងឬស ។
+ **ការប្រើប្រាស់** ៖ - ស្លឹកបុកបិតព្យាបាលកន្លែងរបួស ហើមដោយប៉ះទង្គិច ។

  -សំបកដើម ដុសជាមួយ ស្រាលាបដំបៅ និងព្យាបាលពស់ចឹក ។

  -ដើម បំបាត់គ្រិច និង ប្រឆាំងនិងពស់ចឹក ។

  -ខ្លឹម បន្ធូរការឈឺសាច់ដុំ និង គ្រុនក្តៅ ។

  -ឬស ព្យាបាលគ្រុនចាញ់ ដុសជាមួយស្រា ព្យាបាលពស់ចឹក និងប្រើជាថ្នាំព្យាបាល ហើម រលាក បន្ទន់លាមក
+ **កំរិតប្រើប្រាស់** ៖ មិនទាន់មានការស្រាវជ្រាវ។
+ **ឯកសារយោង** ៖ **Madicinal** Plants of Cambodia, P257

  http://www.lookfordiagnosis.com/images.ph

  Chiang Mai University 1964

**រៀបរៀងដោយនិស្សិត ៖ គាន់ ចាន់ណា**





## ដើមសិរសាច់

Nom Scientifique : ***Glochidion obscurum (Roxb.ex Willd.)Blume***

Famille : **EUPHORBIACEAE**

# ដើមសិរសាច់

Nom Scientifique : *Glochidion obscurum (Roxb.ex Willd.)Blume*

Famille : **EUPHORBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិដើមតូច មានកំពស់ពី ១ទៅ៣ ម៉ែត្រ។
  - **ស្លឹក** ៖ ទោល ដុះឆ្លាស់ទង រាងស៊ុត បណ្តោយ ៤ទៅ៦ សង់ទីម៉ែត្រ។
  - **ផ្កា** ៖ កញ្ចុំចេញពីប្រគាបស្លឹកជាចង្កោមពណ៌បៃតងភ្លាវ ផ្កាឈ្មោលជាចង្កោម។
  - **ផ្លែ** ៖ ជាប្រភេទមូលទ្រមាច មានរាងចង្អូរខ្លែប៦ទៅ៨ចង្អូរ។
+ **កន្លែងដាំដុះ** ៖ ឃើញភាគច្រើនដុះនៅតំបន់មាត់សមុទ្រ។ បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ។
+ **ផ្នែកប្រើប្រាស់** ៖ ស្លឹក និង ឬស។
+ **ការប្រើប្រាស់** ៖ ស្លឹកវាព្យាបាលរាគ។
  ឬស ព្យាបាលអាហារមិនរលាយ ឈឺពោះ រាគមូល ក្អក ផ្តាសាយ និង ឈឺចង្កេះ។
+ **កំរិតប្រើប្រាស់** ៖ ប្រើ ១៥ ទៅ ៣០ ក្រាមដាំផឹកក្នុង១ថ្ងៃ។
+ **ឯកសារយោង** ៖ -សៀវភៅរុក្ខជាតិឱសថកម្ពុជា បោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្រ្តបុរាណ ឆ្នាំ២០០៩។
  -www.tropicos.org
  -www.herbstohealth.blogspot.com
  -www.theplantlist.com

**រៀបរៀងដោយនិស្សិត ៖ ជី សុជីវីន**







# ដើម ស្វក្រំ

Nom Scientifique : *Xylia xylocarpa(Roxp).Tanb.Var.Kerrii (Craib et Hutch)*

Famille : **LEGUMINOSAE-MINOSOIDEAE**

# ដើម ស្វាក្រាំ

Nom Scientifique : ***Xylia xylocarpa(Roxp).Tanb.Var.Kerrii (Craib et Hutch)***

Famille : **LEGUMINOSAE-MINOSOIDEAE**

**+ លក្ខណៈរុក្ខជាតិ** ៖ ជាដើមឈើធំមានកំពស់ពី២៥-៣០m។ សាច់ឈើរឹងមានពណ៌ក្រហមតិចៗ។

**- ស្លឹក** ៖ ស្លឹកជាស្លឹកសមាស មានទងរួមគ្នានិងស្លាប១ មានកូនស្លឹក៣-៥គូរ មានរាងពងក្រពើទ្រវែង ស្រួចចុងទទឹង៣-៧cm បណ្តោយ៧-២០cm។

**- ផ្កា** ៖ ផ្កាដុះចេញមកនូវចុងមែកឬ ពីប្រគាបស្លឹកផ្កាមានតែមួយដែលមានកេសរច្រើន មានពណ៌ស ឬ ពណ៌សលាយលឿង។

**- ផ្លែ** ៖ ផ្លែរាងសំប៉ែតផ្លែខ្ចីមានពណ៌ខៀវខ្ចីពេលទុំមានពណ៌ត្នោតសំបកផ្លែរឹងដូចឈើ រាងផ្លែកាំបិតរាវម្ខាង ផ្លែនៅខែមិនាឬមេសា។

**+ កន្លែងដាំដុះ** ៖ មានដុះនៅតាមតំបន់ភ្នំ, ខ្ពង់រាប, ព្រៃក្រាស់, និងព្រៃរបោះភាគច្រើននៅតំបន់ភាគពាយព្យនៃប្រទេសកម្ពុជា។

**+ សមាសធាតុគីមី** ៖ សំបកដើមនិងផ្លែមានជាតិ acide organique និង Tanin.

**+ ផ្នែកប្រើប្រាស់** ៖ សំបកដើម, ខ្លឹម, ផ្កា, ផ្លែ ប្រើបានគ្រប់រដូវ។

**+ ការប្រើប្រាស់** ៖ - សំបកដើម: ព្យាបាលបំបាត់គ្រុនក្តៅ, ទល់លាមក មហារីក កន្សែងមស្បូន និងមហារីកសួត, របួសគ្រាំក្នុង, បញ្ចុះកំដៅ, ជំនួយបេះដូង, ក្អួតធ្លាក់ឈាម, ជំងឺសសៃ, ព្យាបាលរីសដូងបាត និងឈឺតាមសន្លាក់ឆ្អឹង។

**+ កំរិតប្រើប្រាស់** ៖ ១៥-៣០ក្រាមក្នុង១ថ្ងៃ។

**+ ឯកសារយោង** ៖ មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ។ កំរងរុក្ខជាតិឱសថក្នុងការចុះអង្កេតស្រាវជ្រាវនៅខេត្តព្រះសីហនុ២០១០។ http://www.absoluteastromomy.com/topics/xylia-xylocarpa

**រៀបរៀងដោយនិស្សិត ៖ សៀក ផាន់ណាត**







# ដើមស្ទូរតី ,រឺ ស្ទុរតី

Nom Scientifique : ***Mammea siamensis Kosterm***

Famille : **CLUSIACEAE**

# ដើមស្វរគី ,រី ស្វរគី

Nom Scientifique : ***Mammea siamensis Kosterm***

Famille : **CLUSIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទរុក្ខជាតិមានកំពស់ ១០-១៥ ម៉ែត ។

- **ស្លឹក** ៖ ស្លឹកទោលទល់ទងគ្នា រាងពងក្រពើទ្រវែង ខ្លះស្រួចគល់ ស្រួចចុង ខ្លះទាលចុង ប្រវែង ១០-១៥សម ទទឹង៤-៥ម៉ែត្រ ផ្ទៃសន្លឹករលោងក្រាស់ស្វិត ពណ៌បៃតងចាស់ '

- **ផ្កាផ្លែ** ៖ ផ្កា : មូលតូចៗដុះត្រង់ ពណ៌ស កេសរឈ្មោល ពណ៌លឿង ក្រអូបងាយរង្គោះជ្រុះ ទងផ្កាវែង ផ្កាចេញតែមួយ ឬច្រើនៗ តាមមែក និងដើម ។
ផ្លែ : រាងស៊ុត ពណ៌លឿង ទឹកក្រូច ពេលទុំ ទំហំប៉ុនមេដៃសាច់មានរសផ្អែម ហូបបាន បើបកអោយត្រូវខ្យល់យូរទៅជាល្វីង គ្រាប់ធំមូលមានតែមួយ ។

+ **កន្លែងដាំដុះ** ៖ គេដាំសំរាប់លំអ ឬច្រើនឃើញដុះដោយខ្លួនឯងតាមតំបន់ភ្នំទាបៗ ឬតាមជើងភ្នំ ព្រៃរបោះ ។ បន្តពូជដោយគ្រាប់ ។

+ **សមាសធាតុគីមី** ៖ Coumarines: suragine C; therapine B; 1,7-hydroxyxanthone; 1- hydroxyl-5-methoxyxanthone;et xanthones suragine B; delta-tocotrienol (នៅក្នុងគ្រាប់); ពពួកstéroide: β-sitostérol; Stigmasterol; terpenoide: friedelin (នៅក្នុងផ្កា); xanthone (នៅក្នុងមែកខ្ចី); 4-alkylcoumarine et 4-phenylcoumarine ។

+ **ផ្នែកប្រើប្រាស់** ៖ សំបកដើម និង ផ្កា ។

+ **ការប្រើប្រាស់** ៖ - សំបកដើម ស្ងោរអោយខាប់ បៀមព្យាបាលធ្មេញរង្គើរ រាក់ស៊ីធ្មេញ ឈឺធ្មេញ ។
- ផ្កាស្ងួត ព្យាបាលគ្រុនក្ដៅ ខ្សោយបេះដូង ខ្សោយកំលាំង ។
- កេសរ រក្សាគភ៌ និង គ្រុន ។

+ **កំរិតប្រើប្រាស់** ៖ ១០-២០ក្រាមក្នុង១ថ្ងៃ ។

+ **ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជាភាគ២ក្រសួងសុខាភិបាលមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណបោះពុម្ពផ្សាយឆ្នាំ ២០០៨កំរងរុក្ខជាតិឱសថចុះស្រាវជ្រាវនៅខេត្តមណ្ឌលគីរី និស្សិតជំនាន់ទី៣១(២០១០-២០១១)
http;//herbstohealth,blogspot.com/2008/10/clusiaceaesaarphee,html

**រៀបរៀងដោយនិស្សិត ៖ គីម ចរិយា**







# ចន្ទ័រាប, ឆាយនីគាង

Nom Scientifique : ***Homalomena aromatica***

Famille : **ARACEAE**

# ចន្ទ័រាប, ឆាយនីគាខ

Nom Scientifique : ***Homalomena aromatica***

Famille : **ARACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិដែលរស់បានយូរឆ្នាំមានកំពស់ ២៥ស.ម ដើមរាងជាបំពង់មានលក្ខណៈ ហឹរ ក្តៅ មានរសជាតិល្វីង និង ក្លិនក្រអូបប្រហើរ។
  - **ស្លឹក** ៖ ដុះចេញពីដើមរឺមើម និងមានរាងបេះដូងស្លាបព្រួញមានប្រវែងបណ្តោយ ១៥-២០ស.ម និងទទឹង ៨.១២ស.ម មានស្រទបគល់រាងទ្រវែង។
  - **ផ្កាផ្លែ** ៖ ខួរផ្ការាងស្វើរស៊ីឡាំងមានពណ៌បៃតងលឿង ផ្លែមានសាច់ ទឹកច្រើនគ្រាប់ច្រើនរាងទ្រវែង។
+ **កន្លែងដាំដុះ** ៖ ដុះនៅតំបន់ត្រូពិចដែលមានអាកាសធាតុក្តៅហើយសើមជាពិសេស នៅតំបន់ភ្នំខ្ពង់រាប និងកន្លែងសើម ក្បែរមាត់ទឹក។
+ **សមាសធាតុគីមី** ៖ Two new sesquiterpene alcohols, homalomenol C and homalomenol D, besides (−)-α-cadinol and (−)-T-muurolol, have been isolated from the roots of *Homalomena aromatica*.
+ **ផ្នែកប្រើប្រាស់** ៖ ដើម និង ឫស ចិតជាចំនិតហាលថ្ងៃអោយស្ងួត។
+ **ការប្រើប្រាស់** ៖ ប្រើក្នុងការព្យាបាលថ្លើម ក្រលៀន បំបាត់ការឈឺចាប់ រោគសើរស្បែក ឈឺសន្លាក់ ខ្សោយចង្កេះ ជង្គង់ ស្ពឹកស្រពន់ចុងជើង កំចាត់ពួកផ្សិត ប្រើជាប្រេងក្រអូប និង ប្រើជាថ្នាំសុខភាពពាន់ឆ្នាំ។
+ **កំរិតប្រើប្រាស់** ៖ ៥-១០ក្រាម នៃដើម រឺ ឫស ដាំផឹក រឺ ត្រាំស្រាផឹក។
+ **ឯកសារយោង** ៖ -លោកគ្រូឱសថបុរាណៈ ថៃ តេកស៊្រុន
  - Medicinal Plants of Vietnam, Cambodia and Laos
  - http://acupuncturetoday.com/herbcentral/homalomena.php

រៀបរៀងដោយនិស្សិត ៖ ខាន់ សុម៉ានីតា









## ស្មៅស្លែព្រៃ

Nom Scientifique : *Erechites Hieracisolia*

Famille : **ASTERACEAE**

# ស្មៅស្លែព្រៃ

Nom Scientifique : ***Erechites Hieracisolia***

Famille : **ASTERACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទស្មៅដែលដុះជាប្រចាំឆ្នាំដែលមានកំពស់ ២ ម ,មានរសជាតិល្វីង
  - **ស្លឹក** ៖ វាមានរាងទ្រវែងឆែកពណ៌បៃតង ដុះចេញទៅក្រៅ
  - **ផ្កា** ៖ ផ្កាមានពណ៌លឿងខ្ចីដែលមានវិជ្ជមាត្រ ១២- ១៥ mm x ៦- ៨ mm ដែលបន្ទាត់ផ្ចិតរបស់វាគឺពាក់កណ្ដាលនៃប្រវែងរបស់វា។
  - **ផ្លែ** ៖ គ្រាប់របស់វាមានទំហំ ២ - ៥ mm ផ្នែកខាងក្រៅពណ៌ត្នោត ផ្នែកខាងក្នុងពណ៌ស។
+ **កន្លែងដាំដុះ** ៖ វាលូតលាស់នៅកន្លែងក្ដៅច្រើនជាងកន្លែងសើម នៅតាមបណ្ដោយផ្លូវ
+ **សមាសធាតុគីមី** ៖ Pyrrolizidine alcaloide ដែលមានលក្ខណៈពុលប៉ះពាល់ដល់ថ្លើម។
+ **ផ្នែកប្រើប្រាស់** ៖ ប្រេងដែលចំរាញចេញពីគ្រាប់ និងស្លឹក។
+ **ការប្រើប្រាស់** ៖ ពៅកំលាំង, ថ្នាំបណ្ដុះលាមក, ក្អួត, ត្រអក, ហូរឈាម, បំបាត់ឈឺបំពង់ក បើលាបខាងក្រៅបំបាត់ការឈឺចាប់ចំពោះអ្នកមានរោគសន្លាក់ឆ្អឹង និងការឈឺចាប់សសៃប្រសាទតាមបណ្ដោយគ្រលៀនរហូតដល់ចុងជើង។
+ **ឯកសារយោង** ៖ http://www.oswaldasia.org/Erechiteshieracifolia

**រៀបរៀងដោយនិស្សិត ៖ ឈុន សុម៉ាលីន**







# សម្បូរកក់

Nom Scientifique : ***Acacia con cinna* (Willd) DC.**

Famille : **FABACEAE**

# សម្បុរកក់

Nom Scientifique : *Acacia concinna* **(Willd) DC.**

Famille : **FABACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាចុល្លព្រឹក្សស្ទើរជាវល្លិ តាមដើម មែក ស្លឹកមានបន្លាកោងខុប មានកំពស់ពី ២-៥ម

- **ស្លឹក** ៖ រួមស្លាប២ជាន់ ដុះឆ្លាស់ទងស្លាបតូចមាន៨-១២គូ ស្លាបតូចនិមួយៗមានកូនស្លឹកពី៩-២៥គូ។

- **ផ្កា** ៖ កញ្ចុំផ្កាចេញនៅចុងមែក និងប្រគាបស្លឹក ផ្កាជាកញ្ចុំមូល មិនទាន់រីក ពណ៌ក្រហមក្រមៅ ពេលរីកជាកញ្ចុំពណ៌ លឿងភាវ។

- **ផ្លែ** ៖ ជាកួរវែង ក្រាស់ ប្រវែងពី ១០-១៥ស.ម ទទឹងពី ១,៥០-២,៥០ ស.ម ។

+ **កន្លែងដាំដុះ** ៖ ដុះតាមមាត់ផ្លូវ តាមភ្លឺស្រែ ។ បន្តពូជដោយគ្រាប់ ។

+ **សមាសធាតុគីមី** ៖ ក្នុងផ្លែស្ងួតមាន Alkaloid និង Saponin រហូតដល់ ២៨.៨ ភាគរយ ក្នុងនោះមាន Acacinin A,B,C,D,E. ។

+ **ផ្នែកប្រើប្រាស់** ៖ ផ្លែ ស្លឹក ផ្កា សំបក (រុក្ខជាតិទាំងមូល)។

+ **ការប្រើប្រាស់** ៖ ស្លឹក: រសជូរដាំផឹកសម្រាប់ទំលាក់ស្លេស្ម លាងរំអិលនៅក្នុងពោះវៀន រាគមូល លាងទំលាក់ឈាមរដូវ រោគភ្នែក កក់សក់។

ផ្កា: ឈឺចង្កេះ។

ផ្លែ: ដាំ ឬបុកទទួលទានសម្រាប់ព្យាបាលក្អក គ្រុនញាក់ធ្វើឲ្យក្អួត ឬព្យាបាលអង្គែ ឬយកសំឡីលាបលើស្បែក ព្យាបាល រោគសើរស្បែក និងរបួស។

ដើម: ព្យាបាលរោគភ្នែក។

ឬស: ព្យាបាលគ្រុន។

+ **កំរិតប្រើប្រាស់** ៖ ដើម និងឬសស្ងួត ប្រើពី ១៥-២០ ក្រាម។

ស្លឹកស្រស់ប្រើពី ៥០-៧៥ ក្រាម ដាំទឹកផឹក។

+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជាភាគ៣ ពីអក្សរ ក ដល់ ឪ ឆ្នាំ២០០៩

http://dokmaidogma.wordpress.com/2011/11/24/we-love-fruits/

http://www.theherbdepot.com/standard/acacia_acacia_1773.html

**រៀបរៀងដោយនិស្សិត ៖ មឿង សុធារ៉ា**







## ព័ន្ធតាឡី -ព័ន្ធលី -ប្រាំដំឡើង

Nom Scientifique : *Terminalia corticosa Pierre ex lanessan*

Famille : **TERMINALIA MUCRONATA CRAIB ET HUTCH**

# ព័ន្ធតាឡី -ព័ន្ធលី -ប្រាំជំឡើង

Nom Scientifique : *Terminalia corticosa Pierre ex lanessan*

Famille : **TERMINALIA MUCRONATA CRAIB ET HUTCH**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទរុក្ខជាតិដើមត្រង់មានពណ៌អុជៗច្រើន ហើយសំបកវាមានឆ្នូតបញ្ឈរនៅគល់។ វាមានកំពស់ទៅដល់៥០ ម៉ែត្រ។ចំនែកជាប្រភេទរុក្ខជាតិដើមត្រង់មានពណ៌អុជៗ ច្រើនហើយសំបកវាមានឆ្នូតបញ្ឈរនៅគល់។ វាមានកំពស់ទៅដល់៥០ ម៉ែត្រ។ចំនែកត្រួយ និងមែកខ្ចីរបស់គ្របដណ្តប់ដោយខ្លីៗពណ៌ត្នោតជាច្រើន និងមានរន្ធសំរាប់ ខ្យល់ចេញចូល។
- **ស្លឹក** ៖ ដុះទល់ទងគ្នា រាងវែងស្រួចខាងចុង។ ស្លឹករបស់វាស្តើង រលោងមានទ្រនុងនៅកណ្តាលយ៉ាងរឹងមាំ គ្របដណ្តប់រោមឆ្មារពណ៌ត្នោតជាច្រើន និងមានក្រពេញនៅទងស្លឹកខាងលើ។
- **ផ្កាផ្លែ** ៖ ផ្កាមានពណសចេញជាបញ្ចុំចេញពីប្រគាបស្លឹក គូរផ្កាធ្លាក់ ត្រយោងចុះក្រោម ទងផ្កាមានប្រវែង០.៥ ម៉ែត្រ។ ចំនែកផ្លែមានលក្ខណៈស្ងួតមិនជាប់សំបក មានពណ៌ត្នោតលឿងទុំ។

+ **កន្លែងដាំដុះ** ៖ វាដុះនៅតំបន់ក្តៅហើយសើម៕

+ **សមាសធាតុគីមី** ៖ មិនទាន់មានឯកសារស្រាវជ្រាវនៅឡើយ។

+ **ផ្នែកប្រើប្រាស់** ៖ សំបក

+ **ការប្រើប្រាស់** ៖ សំបកសំរាប់ព្យាបាលរលាកបំពងក ជំនួយអោយចេញទឹកដោះសំរាប់ស្ត្រីក្រោយពេលសម្រាលកូន និងជំងឺ Ascite

+ **កំរិតប្រើប្រាស់** ៖ សំបកស្ងួតអាចដាំទឹកផឹកបានចាប់ពី១០-១៥ក្រាម ក្នុងមួយថ្ងៃ។

+ **ឯកសារយោង** ៖ -បញ្ជីរុក្ខជាតិឱសថកម្ពុជា List of medicinal plant in Cambodia 2009 Pr. CHENG SUN KAING
- http: //www.biotik.org/laos/species/ t / terco / terco_en.html

រៀបរៀងដោយនិស្សិត ៖ ទាវ សុភារី







# ស្មៅក្បាលពស់វែក-ស្មៅពញ្លាក់

Nom Scientifique : ***Barleria siamensis Craib***,

Famille : **ACANTHACEAE**

# ស្មៅក្បាលពស់ថែក-ស្មៅពញ្លាក់

Nom Scientifique : ***Barleria siamensis Craib,***

Famille : **ACANTHACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទតិណជាតិ មានកំពស់ ៣០-៦០សម។ ដើមមានថ្នាំង ឫសជាឫសមើម
  - **ស្លឹក** ៖ ទោល ដុះទល់ទង មានរាងទ្រវែងស្រួច
  - **ផ្កា** ៖ កញ្ចុំផ្កាចេញពីប្រគាបស្លឹក រាងជាស្នបស្រទាប់ៗ មានពិណសលាយស្វាយ រីកម្តងមួយ
  - **ផ្លែ** នៅក្នុងស្នបស្រទាប់ផ្កា
+ **កន្លែងដាំដុះ** ៖ ដុះនៅតាមតំបន់ភ្នំ តំបន់ខ្ពង់រាប តំបន់មានដីសើម ព្រៃល្បោះ បន្តពូជដោយគ្រាប់
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ នៅឡើយ
+ **ផ្នែកប្រើប្រាស់** ៖ ឫស រឺ មើម
+ **ការប្រើប្រាស់** ៖ ឫស រឺ មើម បន្សាបពិសពស់ ពស់វែកស្ត ឈឺតាមសន្លាក់
+ **គំរិតប្រើប្រាស់** ៖ ឫសស្ងួត ១០-១៥ ក្រាម ដាំទឹកផឹកក្នុង ១ថ្ងៃ
+ **ឯកសារយោង** ៖ www.doa.go.th./pvp/research/Acanthaceae/acanthaceae1.html
  www.555aha.com/home01/feature/plant/20-barleria-siamensis-craib
  en.hortipedia/wiki/Barleria_siamensis
  រុក្ខជាតិឱសថជាតិភាគ៣ឆ្នាំ២០០៩

**រៀបរៀងដោយនិស្សិត ៖ ឆៀក ធីណា**







# ស្មៅកន្ទុយឆ្កែ

Nom Scientifique : *Pennisetum alopecuroides (L) Spreng,*

Famille : **POACEAE**

# ស្មៅកន្ទុយឆ្កែ

Nom Scientifique : ***Pennisetum alopecuroides (L) Spreng,***
Famille : **POACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាស្មៅដែលរស់បានយូរឆ្នាំ មានដើមឈរត្រង់ រឹងមាំ, កំពស់ដើម ៣០-១០០Cm, ដើមរាងសំប៉ែត
  - **ស្លឹក** ៖ ស្លឹកស្ដួបមានរាងទ្រវែងហើយស្រួច, ស្លឹកមានប្រវែង១០-៨០Cm ទទឹងស្លឹក២-៨mm
  - **ផ្កាផ្លែ** ៖ ផ្ការាងកញ្ចុំរាងជាងបំពង់មូលវែងហើយរាងដូចលំពែង,កញ្ចុំមានផ្កាតូចៗជាច្រើន មើលទៅដូចកន្ទុយឆ្កែ,ភាគច្រើនផ្ការីកនៅខែ៦និងខែ៧
+ **កន្លែងដាំដុះ** ៖ ដុះតាមវាល, តាមផ្លូវ, តាមជំរាលភ្នំ, តាមដីវាលស្មៅ, និងដុះដោយឯកឯង
+ **សមាសធាតុគីមី** ៖ គ្មានការស្រាវជ្រាវ
+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល, និងមើម គេប្រមូលផលនៅរដូវភ្លៀង គេកាត់ដើមខ្លីៗហាលថ្ងៃ ដើម្បីសំងួតធ្វើជាថ្នាំ
+ **ការប្រើប្រាស់** ៖ ប្រឆាំងនឹងការរលាក, បំបាត់ក្អក, ជំនួយភ្នែក, ក្អកធ្លាក់ឈាម, ឈឺភ្នែកក្រហម, កើតបុស
+ **គំរិតប្រើប្រាស់** ៖ មើម៣០-៦០g បុកជាមួយឫសស្បូវ១៥-៣០g ដាំទឹកផឹកព្យាបាលក្អកធ្លាក់ឈាម រុក្ខជាតិទាំងមូល១០-១៥gដាំទឹកផឹកព្យាបាលជំងឺភ្នែកក្រហម

+ **ឯកសារយោង** ៖ - Chinese Medicinal Herbs of Hong Kong
- http://www.perennials.com/plants/pennisetum-alopecuroides (L) Spreng.html

**រៀបរៀងដោយនិស្សិត ៖ ផល គឹមហ័ង**



# ស្មៅជើងតុកកែ

Nom Scientifique : ***Coldeniaprocumbens L.***

Famille : **BORAGINACEAE**

# ស្មៅជើងតុកកែ

Nom Scientifique : ***Coldeniaprocumbens L.***

Famille : **BORAGINACEAE**

**+ លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិដុះនៅលើដីដែលមានអាយុកាលតិចជាងមួយឆ្នាំដើមមានលក្ខណៈដុះក្រាបទៅនឹងដីមានប្រវែងរហូតដល់ ៤0Cm។ជាប្រភេទឫសស្ទឹងមានពណ៌ស ឬពណ៌ត្នោត ។ដើមនៅលើដីអត់មានដុះឫសដើមសំប៉ែតតាន់មានរោមពុំមានខ្នាយស្វប ។ចេញផ្កាពេញមួយឆ្នាំ។

**- ស្លឹក** ៖ ជាស្លឹកទោលមិនមែនជាប្រភេទស្លឹកដែលមានកំពក ឬផ្នែកមានរោមទ្រនុងស្លឹកមានរាងស្និត។

**- ផ្កា** ៖ ផ្កាទ្វេរភេទជាផ្កាទោលស្ថិតនៅចន្លោះស្លឹកមានស្រទាប់ផ្កាចំនួន៤មានពណ៌ស។ជាទូទៅចេញផ្កាក្នុងអំឡុងពីខែតុលា ដល់ខែមេសា។

**- ផ្លែ** ៖ ផ្លែមានរាងជាណាត់។

**+ កន្លែងដាំដុះ** ៖ រីករាលដាលនៅតំបន់ត្រូពិច និង តំបន់ស៊ុបត្រូពិច អាហ្វ្រិកអាស៊ី និង អូស្រ្តាលី។ វាអាចដុះនៅលើវាលស្រែស្ងួត ព្រោះអាចទ្រទ្រង់នៅពេលរាំងស្ងួតបាន។

**+ ផ្នែកប្រើប្រាស់** ៖ ស្លឹក និងជាតិប្រេងដែលមាននៅក្នុងស្លឹក ។

**+ ការប្រើប្រាស់** ៖ ស្លឹកត្រូវបានគេប្រើប្រាស់សំរាប់ស្អំឫសដែលរៀបនឹងធ្លាយ និងប្រើសំរាប់ហើមសន្លាក់ឆ្អឹង ។ស្លឹកអាចផលិតទៅជាប្រេងផ្សំសំខាន់ប្រើប្រាស់ជាថ្នាំរីតសំរាប់រីតនៅលើហើមក្បាលជង្គង់និងសន្លាក់។អាចប្រើប្រាស់ជាថ្នាំដើម្បីកាត់បន្ថយជាតិស្ករនៅក្នុងខ្លួនបាន។

**+ ឯកសារយោង** ៖
-Lavit Kham. 2004. Medicinal plants of Cambodia.
-Soerjani M., Kostermans A. J. G. H., Tjitrosoepomo G. 1987. Weeds of rice in Indonesia. Balai Pustaka. Jakarta.
-TavatchaiRadanachaless, J.F.Maxwell. 1994. Weeds of soybean fields in Thailand. Multiple Cropping, Center Publications. Thailand.

**រៀបរៀងដោយនិស្សិត៖ យ៉ន់ សុផល្គុណា**





# ដើមអង្កត់ខ្មៅធំ

Nom Scientifique : ***Diospyros venosa***

Famille : **EBENACEAE**

# ដើមអង្កត់ខ្មៅធំ

Nom Scientifique : *Diospyros venosa*

Synonyme : ***Maba merguensis***

***Maba teysmannii***

***Diospyros hermaphroditica***

Famille : **EBENACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិដើមធំ មានប្រវែង ៥-១០ ម។
  - **ស្លឹក** ៖ ដុះឆ្លាស់គ្នា។
  - **ផ្កា** ៖ មិនមានឯកសារបញ្ជាក់។
  - **ផ្លែ** ៖ មិនមានឯកសារបញ្ជាក់។
+ **កន្លែងដាំដុះ** ៖ ដុះនៅប្រទេសភូមា កម្ពុជា ថៃ វៀតណាម ម៉ាឡេស៊ី ។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ។
+ **ផ្នែកប្រើប្រាស់** ៖ រឹស និង ដើម។
+ **ការប្រើប្រាស់** ៖ ជំនួយសរសៃប្រសាទ ឯងុយគេង បំបាត់ការឈឺចុកចាប់។
+ **គំរិតប្រើប្រាស់** ៖ គ្មានការបញ្ជាក់ច្បាស់លាស់។
+ **ឯកសារយោង** ៖ http:/Zipcodezoo.com/plants

http:/WWW.Uniprot.org/uniprot
www.google.com

**រៀបរៀងដោយនិស្សិត ៖ 　ណុប ទិដ្ឋិនី**







# អំព្រាំប្រែក្រោយ

Nom Scientifique : ***Phyllodium pulchellum(L)Desv.***

Famille : **FABACEAE(Palpilionodeae)**

# អំព្រាំប្រែក្រោយ

Nom Scientifique : ***Phyllodium pulchellum(L)Desv***
Famille : **FABACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទរុក្ខជាតិដើមតូចមានមែកខ្លីមានរោមតិចៗ
- **ស្លឹក** ៖ ១ទងមាន៣ស្លឹក រាងពងក្រពើមូលចុងមានរោមតិចៗ គែមស្លឹកមានរាងទឹករលក។
- **ផ្កា** ៖ ផ្កាពណ៌ស នៅចុងមែក ឬ ប្រគាបស្លឹក។
- **ផ្លែ** ៖ ផ្លែតូចៗរាងសំប៉ែត មានស្នាមគន្លាក់គ្រាប់មានរោមពណ៌បៃតង។

+ **កន្លែងដាំដុះ** ៖ ច្រើនដុះជើងភ្នំ ខ្ពង់រាប ព្រៃរបោះ បន្តពូជដោយគ្រាប់។
+ **សមាសធាតុគីមី** ៖ Cinnamylphenols, pulchelstyrenes A(1),B(2),C(3),D(4),citrusinol,yukovanol,methyl piperitol,4-hudroxy-2.3-dimethoxybenzaldehyde
+ **ផ្នែកប្រើប្រាស់** ៖ ឬសស្លឹក។
+ **ការប្រើប្រាស់** ៖ រលាកថ្លើម ស្បូនស្រុត ព្រូនសីឈាម ធ្លាក់អណ្ដើក ក្ដៅខ្លួន ផ្កាសាយ គ្រុនញាក់ឈឺឆ្អឹងឆ្អែង គ្រាំគ្រា បញ្ចុះទឹកនោម។
+ **កំរិតប្រើប្រាស់** ៖ ១០ទៅ២០ក្រាម។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថបុរាណភាគ៣នៃមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ២០០៨
-http// :www.nebi.nlm.gov/pubmed/15921433

**រៀបរៀងដោយនិស្សិត ៖ មុយ ចណ្ណាថេន**








# ដើមអង្ក្រខ

Nom Scientifique : ***Zizyphus cambodiana Pierre***

Famille : **RHAMNACEAE**

# ដើមអន្ទ្រខ

Nom Scientifique : *Zizyphus cambodiana Pierre*

Famille : **RHAMNACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាចុល្លព្រឹក្សមានបន្លា ជួនកាលវារឡើងរុក្ខជាតិដែលដុះនៅជិតវា ហើយអាចមានប្រវែង៨ម៉ែត្រ រឺលើស។
  - **ស្លឹក** ៖ ទោល ដុះឆ្លាស់ទង រាងជាស៊ុត មានទ្រនុងស្របព មានប្រវែង៧ស.ម ទទឹង៣.៥ស.ម។
  - **ផ្កា** ៖ ផ្កាពណ៌លឿងភាវ ចេញនៅប្រគាបស្លឹកជាចង្កោម។
  - **ផ្លែ** ៖ ផ្លែនៅខ្ចីអាចខាំបែក ពេលទុំសំបកស្ងួត សាច់ក្នុងផ្លែសាញ រឹង ខាំមិនបែក មានគ្រាប់ធំ។
+ **កន្លែងដាំដុះ** ៖ មានដុះស្ទើរគ្រប់ទីកន្លែង។
+ **សមាសធាតុគីមី** ៖ សំបក ឫស មាន ceanothane និង lupine-type triterpenes, 3-0-(4- hydroxyl-3-methoxybenzoyl) ceanothic acid (3-0-vanillylceanothic acid) (1), identified as lupeol (2), betulinaldehyde (3), betulini acid (4), 2-0-E-p-coumaroyl alphitolic acid (5), alphitolic acid (6), zizyberanalic acid (7), zizyberenalic acid (8) និង ceanothic acid (9).

  Activity : -(1),(5) និង (8): antiplasmadial activity ប្រឆាំងនឹង Plasmodium falciparum.

  - (1) និង (3-8): antimycobacterial activity ប្រឆាំងនឹង Mycobacterium tuberculosis.
+ **ផ្នែកប្រើប្រាស់** ៖ រឹស សំបក ដើម ផ្លែ។
+ **ការប្រើប្រាស់** ៖ -រឹស ព្យាបាលឫសដូងបាត ធ្លាក់ស ទប់ឈាម និងជួយធ្វើឲ្យស្បែកស្វិត ផ្សះស្បូនក្រោយឆ្លងទន្លេ។
  - សំបក និងដើម ជួយបំបាត់ឈឺឆ្អឹងឆ្អែង ឈឺក្រពះ ព្យាបាលជម្ងឺផ្សិត។
  - ផ្លែ បញ្ចុះនោម ស្ត្រីធ្លាក់ស ជួយធ្វើឲ្យស្បែកស្វិត ឈឺចង្កេះ ឈឺខ្នង។
+ **កំរិតប្រើប្រាស់** ៖ - ផ្លែ ពី៣-១០ក្រាម។
  - សំបក រឹស១០-១៥ក្រាម ដាំទឹក។
+ **ឯកសារយោង** ៖ រុក្ខជាតិឱសថកម្ពុជា នៅមជ្ឈមណ្ឌលស្រាវជ្រាវវេជ្ជសាស្ត្របូរាណ ភាគ៣ ឆ្នាំ២០០៩

**រៀបរៀងដោយនិស្សិត ៖ ឈិន ស៊ីណាន**





# អង្រែងដែក

Nom Scientifique : *Dracaena angustifolia Jack*

*Famille :* **DRACAENACEAE**

# អង្រែងដែក

Nom Scientifique : *Dracaena angustifolia Jack*

*Famille :* **DRACAENACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទស្មៅ អាចរស់បានយូរឆ្នាំ ដើមមានស្នាមស្លឹកជ្រុះ។

- **ស្លឹក** ៖ប្រវែងពី ២០ - ៣៥សម ទទឹងពី ១,២ - ៤សម វែងស្រួចចុងមានចង្អូរបណ្តោយស្លឹក។
- **ផ្កាផ្លែ** ៖ ផ្កាចេញពីចុង កំពូលដើម ជា ចង្កោមក្ញរ ពណ៌ លឿងភ្លាវ ខាងក្នុង ពណ៌ស ជាចង្កោមក្ញរ, មូលៗ ពី ៨ - ១០ សម ផ្លែនីមួយៗមានគ្រាប់១ - ២ គ្រាប់។

+ **កន្លែងដាំដុះ** ៖ ដុះខ្លួនឯងនៅតាមតំបន់ភ្នំ និង វាលរាប និង គេច្រើនដាំដើម្បីលំអសួន។

+ **សមាសធាតុគីមី** ៖ មិនទាន់ស្រាវជ្រាវ។

+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល។

+ **ការប្រើប្រាស់** ៖ ដាំទឹកផឹក ព្យាបាលរាគមូល, ឬស និងផ្កា: ព្យាបាលរាគមូលឈាម ផ្កា យកមក លីងអោយស្ងួត ព្យាបាលជម្ងឺ ហឺត ម៉េម ប្រើជាថ្នាំ ប៉ូវ , បង្កើនកំលាំង, បំប៉នសុខភាព។

+ **កំរិតប្រើប្រាស់** ៖ ៦ - ១៥ក្រាម ដាំផឹកក្នុងមួយថ្ងៃ។

+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជា (មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្រ្តបូរាណ) បោះពុម្ពឆ្នាំ២០០៨

**រៀបរៀងដោយនិស្សិត ៖ ឆេង ជ័រ**









# ដើមផ្កាអង្គាសីល ( ផ្កាអង្គា ផ្កាអង្គាលឿង )

Nom Scientifique : *Ochna integerrima (Lour) Merr.*
*Syn: Ochna harmandii lecomte*
Famille : **OCHNACEAE**

# ដើមផ្កាអន្ធាសីល ( ផ្កាអន្ធា ផ្កាអន្ធាលឿង )

Nom Scientifique : ***Ochna integerrima (Lour) Merr.***
***Syn: Ochna harmandii lecomte***

Famille : **OCHNACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជាប្រភេទឈើតូចមានកំពស់ពី ២ ទៅ ៦ម ។

- **ស្លឹក** ៖ ស្លឹករលោង រាងពងក្រពើ មានធ្មេញរណារញឹក ដុះឆ្លាស់គ្នាបែកចេញជាទងតូចៗមានស្លឹកពី ៣ ទៅ ៥ សន្លឹក។
- **ផ្កា** ៖ ផ្កាមានទងវែងបែកជា៥ត្របក ពណ៌លឿង ផ្នែកកណ្តាលមានកេសរ
- **ផ្លែ** ៖ ច្រើន ផ្កាវាចេញពីខែ ១ ដល់ ខែ ៤ ។
ផ្លែ ផ្កានីមួយៗ មានផ្លែពី ១ទៅ៥ ផ្លែ។

+ **កន្លែងដាំដុះ** ៖ ច្រើនដុះដោយខ្លួនឯង នៅតាមព្រៃតូចៗ តាមជើងភ្នំ មាត់ស្ទឹង។ មានគេយកគ្រាប់ ឬ គាស់កូនមកដាំលំអផ្ទះផងដែរ។

+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវនៅឡើយទេ។

+ **ផ្នែកប្រើប្រាស់** ៖ ប្រើសំបកដើម។

+ **ការប្រើប្រាស់** ៖ អាហារមិនរលាយ មិនឃ្លានអាហារ។

+ **កំរិតប្រើប្រាស់** ៖ ១០ ទៅ ១៥ g ដាំទឹកផឹក។

+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថបុរាណភាគ២ មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ ឆ្នាំ២០០៨

**រៀបរៀងដោយនិស្សិត ៖ ជា ដាវី**





# ដើមអំបែងចាន រឺ ឥន្ទជា

Nom Scientifique : *Mallotus philippinensis,*

Famille : **EUPHORBIACEAE**

# ដើមអំបែងចានរី ឥន្ទជា

Nom Scientifique : ***Mallotus philippinensis,***

Famille : **EUPHORBIACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ គុម្ពព្រឹក្សមានកំពស់ ៥ម-១០ម
- **ស្លឹក** ៖ ស្លឹកទោលដុះឆ្លាក់ទង រាងផ្លែលំពែង ទទឹង ៤-៦សមបណ្ដោយពី៨-១០សមផ្ទៃស្លឹកពណ៌បៃតងរោមពណ៌សទន់នៅផ្នែកខាងក្រោមទងស្លឹកវែងប្រហែល៣-៥សម។ ស្លឹករឹង។
- **ផ្កា** ៖ កញ្ចុំផ្កានៅចុងមែកឬប្រគាបស្លឹកជាចង្កោមកួរ ផ្កាតូចពណ៌ក្រហម។
- **ផ្លែ** ៖ ជាផ្លែស្ងួត មូលត្រមៀចមានបីក្លែប ពណ៌បៃតងចាស់ ពណ៌លឿងទំគ្របដណ្ដប់ដោយរោម។

+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯង នៅក្នុងព្រៃភ្នំ ។
+ **សមាសធាតុគីមី** ៖ ក្នុងម្សៅជុំវិញគ្រាប់មានជាតិជ័រក្នុងនោះមានPolyphenolic, rottlecin, isorottlerin និងជាតិប្រេង។
+ **ផ្នែកប្រើប្រាស់** ៖ - រឹស សំបក រោមរបស់ផ្លែ
+ **ការប្រើប្រាស់** ៖ - ព្យាបាលរោគមួល ហើមបំពង់ក
- ព្យាបាលរាករូស
- ទំលាក់ព្រូនអៀន កាមរោគ និង រោគសើរស្បែក ដូចជាកើតអាត់ រមាស់។
+ **កំរិតប្រើប្រាស់** ៖ - ព្យាបាលរាក សម្បកដើម ៦-១២ក្រាម ដាំទឹកផឹក។
- ទំលាក់ព្រូនអៀន ម្សៅរោមរបស់ផ្លែ ២-៦ក្រាម ក្នុងមួយថ្ងៃ ដោយលាយជាមួយអង្ករលីង លើកទី២ ឃ្លាតពីគ្នាកន្លះម៉ោង។
ចំណាំ: កូនក្មេងប្រើកំរិតទាបជាង លៃតាមអាយុ។
+ **ឯកសារយោង** ៖ សៀវភៅរុក្ខជាតិឱសថកម្ពុជា២០១០ ភាគ៤មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ។

**រៀបរៀងដោយនិស្សិត៖ ឃូ សុខជា**







# ដើមអញ្ចាញ

Nom Scientifique : *Gmelina asiatica L.*

Famille : **VERBENACEAE**

# ដើមអញ្ចាញ

Nom Scientifique : *Gmelina asiatica L.*

Famille : **VERBENACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ជារុក្ខជាតិតូចបែកមែកសាញញាញមានកំពស់ពី៣ទៅ៦ម មានបន្លាខ្លីដុះចេញតាមប្រគាបស្លឹក។
  - **ស្លឹក** ៖ ដុះទល់ទងគ្នា រាងពងក្រពើ គែមស្លឹករលោង និងស្លឹក១ប្រភេទទៀតមានផែករាក់នៅចុង។
  - **ផ្កា** ៖ ធំពណ៌លឿងដុះជាកញ្ចុំ ចេញនៅចុងមែក មានត្របកស្រោមផ្កាជាច្រើនរាងពណ៌ស្វាយតិចៗ ផ្ការាងជាបំពង់កោង នោចុងផ្កាផែកជា៤ចំរៀកចេញផ្កាខែ ១២-០៤។
  - **ផ្លែ** ៖ ខ្ចីពណ៌បៃតងខ្ចី ពេលទុំពណ៌លឿង រាងពងក្រពើផ្លែនៅខែ០៤។
+ **កន្លែងដាំដុះ** ៖ ដុះតាមមាត់បឹង ទំនាប ព្រៃរនាម ខ្ពង់រាប បន្តពូជដោយគ្រាប់។
+ **ផ្នែកប្រើប្រាស់** ៖ ប្រើឫសនឹងស្លឹក ប្រមូលផលរាល់រដូវ ប្រើស្រស់ឬហាលស្ងួតទុកប្រើ។
+ **សមាសធាតុគីមី** ៖ Acide 1,2-benzenedicarboxylic;Diisooctyl ester(3.22%) Monolinoleoylglycerol trimethylsilyl ether(38,51%)
+ ការ**ប្រើប្រាស់** ៖ - ឫស: ដាំទឹកផឹក ព្យាបាលឈឺឆ្អឹង ឈឺខ្នង ឈឺប្រសៃប្រសាទ។
  - ស្លឹក: ក្តៅក្នុង បូស បិតកន្លែងក្បាលឆ្អឹងហើមឈឺ គេក៏ប្រើជាថ្នាំត្រជាក់នឹងគ្រុន។
  - ស្លឹកព្យាបាលបូសទំលាក់ព្រូន ដាំយកទឹកបៀមឈឺធ្មេញ អញ្ចាញធ្មេញឈឺរាប់ ប្រើស្លឹកស្រស់បុកបិត ព្យាបាលសក់រង្គោះឈឺក្បាល។
  - ដើម: ព្យាបាលពិស ថ្លើមកើតលឿង។
+ **កំរិតប្រើប្រាស់** ៖ ដើមពី ២០ទៅ៣០ក្រាម ស្លឹកពី ១៥ទៅ២០ក្រាម ក្នុង១ថ្ងៃដាំទឹកហូប។
+ **ឯកសារយោង** ៖ - សៀវភៅ: រុក្ខជាតិឱសថកម្ពុជាភាគ២នៃមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណឆ្នាំ ២០០៨

http://opendata-keystone-foundation.org/wp-content/gmelina-asiatica
http://www.phcogres.com/crtole.asp

**រៀបរៀងដោយនិស្សិត ៖ ឡោ គីមឆេង**








## កញ្ជាន់អាចម៍ជ្រូក-ជញ្ជាន់អាចម៍ជ្រូក

Nom Scientifique : *Urena lobata L,*

Famille : **MALVACEAE**

# កញ្ជាន់អាចម៏ជ្រូក-ជញ្ជាន់អាចម៏ជ្រូក

Nom Scientifique : ***Urena lobata L,***

Famille : **MALVACEAE**

+ **លក្ខណៈរុក្ខជាតិ** ៖ ចុល្លព្រឹក្សខ្នាតតូចកំពស់ពី ៥០-១២០សម មានរោម ឬសពណ៌លឿងខ្ចី។

- **ស្លឹក** ៖ ដុះឆ្លាស់គ្នារាងមូលផែករាក់ៗស្រួចចុងដើមខ្លះផែកធំៗ មានចង្អូរស្តើងៗ ខាងលើពណ៌បៃតង ខាងក្រោមពណ៌ប្រផេះមានរោម។
- **ផ្កា** ៖ ពណ៌ផ្កាឈូកមាន៥ត្របក ដុះមួយទង ឬពីរទង ចេញពីប្រគាបស្លឹក។
- **ផ្លែ** ៖ ផ្លែមូលទ្រុតខាងចុង មានរោមទំពក់ជុំវិញផ្លែ ផ្លែមួយមាន៥ក្លែបក្នុង១ក្លែប មាន១គ្រាប់។

+ **កន្លែងដាំដុះ** ៖ ដុះដោយខ្លួនឯង តាមចិញ្ចើមផ្លូវ ឬកន្លែងវាល។
+ **សមាសធាតុគីមី** ៖ មិនទាន់មានការស្រាវជ្រាវ
+ **ផ្នែកប្រើប្រាស់** ៖ រុក្ខជាតិទាំងមូល។
+ **ការប្រើប្រាស់** ៖ គ្រុនផ្តាសាយ ចុកស្រពន់ រាគមួល អាហារមិនរលាយ ហើមទឹក ឈឺឆ្អឹងឆ្អែង រលាកបំពង់ក ឈឺបំពង់ក គ្រុនពោះវៀន គ្រុនចាញ់ ធ្លាក់ស ពស់ចឹក រលាក ដោះ កើតពិស។
ពស់ចឹក និង រលាកដោះ បុកស្រស់បំពោក។
+ **កំរិតប្រើប្រាស់** ៖ រុក្ខជាតិស្ងួតៈ ប្រើពី១៥-៣០ក្រាម ក្នុង១ថ្ងៃ។
រុក្ខជាតិស្រស់ៈ ប្រើពី ៥០-១០០ក្រាម ក្នុង១ថ្ងៃ។
+ **ឯកសារយោង** ៖ កំរងរុក្ខជាតិឱសថស្តីពីការស្រាវជ្រាវក្នុងខេត្តព្រះសីហនុ។
http://www.suansavarose.com/index.php?mo=3&art=169147

**រៀបរៀងដោយនិស្សិត ៖ ស៊ូ បុទុម**

# សកម្មភាពចុះកម្មសិក្សានៅខេត្តរតនគីរី របស់និស្សិតឱសថសាស្ត្រឆ្នាំទី ៥ ជំនាន់ ៣២

# ពីថ្ងៃទី ០១ ដល់ទី ០៤ ខែមិនា ឆ្នាំ ២០១២
























# និស្សិតឱសថសាស្ត្រជំនាន់ ៣២

## + សាស្ត្រាចារ្យ លោកគ្រូ ណែនាំ និង ត្រួតពិនិត្យរុក្ខជាតិ៖

- លោកសាស្ត្រាចារ្យ ចេង ស៊ុនកាំង
- លោកគ្រូឱសថបុរាណ ហួន ធំ
- លោកគ្រូឱសថបុរាណ គី ប៊ូហាំង
- លោកគ្រូឱសថបុរាណ ថៃ សារី

## + គណៈកម្មការត្រួតពិនិត្យរួម ៖

- លោក មឿង សុធារ៉ា
- កញ្ញា អៀ សុមន្ទី
- លោក ហេង បុរី
- លោក ឈឿង ថាសុមិនា
- លោក សួន សំអែល
- កញ្ញា ឈិន ស៊ីណាន
- លោក ហ៊ុយ បារាំង

## + ក្រុមត្រួតពិនិត្យអក្ខរាវិរុទ្ធ

- លោក ហេង បុរី
- កញ្ញា ផៃ ប៊ុណ្ណា
- កញ្ញា ទី រិទ្ធិកា
- កញ្ញា យឹម សុភាមី
- កញ្ញា អៀ សុមន្ទី
- កញ្ញា សេង ស៊ីវនី
- កញ្ញា អឿ ស្រីលិះ
- លោក មឿង សុធារ៉ា
- កញ្ញា គីម ចរិយា
- លោក សួន សំអែល
- លោក ឈឿង ថាសុមិនា
- លោក ឡោ គីមឆេង
- កញ្ញា លឹម ហិរម៉ី

## + ក្រុមប្រមូលឯកសារ និង កែតំរូវ

- កញ្ញា គីម ចរិយា
- កញ្ញា ផៃ ប៊ុណ្ណា
- កញ្ញា ថា ផានី
- កញ្ញា យឹម សុភាមី
- កញ្ញា អឿ ស្រីលិះ
- កញ្ញា សេង ស៊ីវនី
- លោក សួន សំអែល
- លោក មឿង សុធារ៉ា
- លោក ឈឿង ថាសុមិនា
- លោក ហ៊ុយ បារាំង

## + ក្រុមចងក្រង និង បោះពុម្ពសៀវភៅ

- លោក មឿង សុធារ៉ា
- លោក ហេងបុរី
- លោក ឈឿង ថាសុមិនា
- លោក សួន សំអែល

បោះពុម្ពដោយថវិកានិស្សិតឱសថសាស្ត្រជំនាន់ ៣២